# របាយការណ៍ពិនិត្យឡើងវិញ
# លើ
# គោលនយោបាយស្ដីពីសុខុមាលភាពយុវជនកម្ពុជា



OECD dev
DEVELOPMENT CENTRE

# របាយការណ៍ពិនិត្យឡើងវិញ

លើ

# គោលនយោបាយស្ដីពីសុខុមាលភាពយុវជនកម្ពុជា

OECD dev

DEVELOPMENT CENTRE

មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD ត្រូវបានបង្កើតឡើងនៅឆ្នាំ 1962 ជាវេទិកាឯករាជ្យមួយសម្រាប់ការចែករំលែកចំណេះដឹង និងការសន្ទនាគោលនយោបាយរវាងបណ្តាប្រទេសជាសមាជិករបស់ OECD និងប្រទេសកំពុងអភិវឌ្ឍន៍ដែលអាចឱ្យប្រទេសទាំងនេះ សហការធ្វើសកម្មភាពឈានទៅមុខស្មើគ្នា។ សព្វថ្ងៃនេះ សមាជិករបស់មជ្ឈមណ្ឌលនេះ មានប្រទេសសមាជិក OECD ចំនួន 27 និងប្រទេសមិនមែនសមាជិកOECD ចំនួន 25 ។ មជ្ឈមណ្ឌលនេះយកចិត្តទុកដាក់លើបញ្ហាប្រព័ន្ធដែលកំពុងកើតឡើងនិងដែលទំនងជាមានផលប៉ះពាល់ដល់ការអភិវឌ្ឍជាសកល និងបញ្ហាប្រឈមផ្សេងទៀត ដែលបណ្តាលមកពីកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍថ្មីៗ ។ ការវិភាគនេះផ្អែកលើភស្តុតាង និងយុទ្ធសាស្ត្រភាពជាដៃគូដើម្បីជួយដល់ប្រទេសនានា បង្កើតគោលនយោបាយ និងរកដំណោះស្រាយបញ្ហាប្រឈម នៃការអភិវឌ្ឍជាសកលប្រកបដោយច្នៃប្រឌិត។

សំរាប់ព័ត៌មានបន្ថែមអំពីមជ្ឈមណ្ឌល និងសមាជិក សូមមើល www.oecd.org/dev ។

សូមដកស្រង់ការបោះពុម្ពនេះជា៖

OECD Development Centre (2017), “Youth Well-being Policy Review of Cambodia”, EU-OECD Youth Inclusion Project, Paris.

មតិ និងទឡ្ហីករណ៍ ដែលបានលើកឡើងនៅក្នុងអត្ថបទនេះនេះមិនឆ្លុះបញ្ចាំងពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD ឬរដ្ឋាភិបាលនៃបណ្តាប្រទេសជាសមាជិកឡើយ។

បកប្រែក្រៅផ្លូវការ

This translation has been undertaken by Lion TranServe.

This translation is published by arrangement with the OECD. It is not an official OECD translation. The quality of the translation and its coherence with the original language text of the work are the sole responsibility of the author(s) of the translation. In the event of any discrepancy between the original work and the translation, only the text of original work shall be considered valid.

## បុព្វកថា

នៅទូទាំងពិភពលោកនាពេលបច្ចុប្បន្ន យុវជនមានអាយុចាប់ពី 10 ឆ្នាំទៅ 24 ឆ្នាំ មានប្រហែល 1,8 ពាន់លាននាក់ ។ យុវជនទាំងនេះគឺជាក្រុមធំបំផុតដែលនឹងក្លាយជាមនុស្សពេញវ័យនាពេលអនាគត។ ជាង 85 ភាគរយ នៃពួកគេរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយប្រទេសជាច្រើនក៏មានយុវជនស្មើនឹង 30 ភាគរយ នៃចំនួនប្រជាជនសរុបដែរ ដែលចំនួននេះកើនឡើងជាលំដាប់។ ប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះនឹងមានសក្តានុពលទទួលបានផលប្រយោជន៍ពីយុវជនទាំងនេះ ប្រសិនបើប្រទេសទាំងនោះមានគោលនយោបាយសង្គម សេដ្ឋកិច្ច និងវិនិយោគត្រឹមត្រូវ។ ត្បិតថា យុវជនគឺជាតួអង្គសំខាន់ក្នុងឆាកពិភាក្សាស្តីពីគោលនយោបាយ និងជាកម្លាំងចលករនៃការអភិវឌ្ឍ។ ទោះយ៉ាងណា ការកំណត់ទិសដៅលើយុវជនវ័យក្មេងតម្រូវឱ្យមានដំណោះស្រាយបញ្ហាប្រឈមជាច្រើន ដោយរាប់ចាប់តាំងពី ឱកាសដែលយុវជនទទួលបានការងារសមរម្យ ការអប់រំប្រកបដោយគុណភាព រហូតដល់ ការទទួលបានសេវាសុខភាពងាយស្រួល និងការក្លាយជាពលរដ្ឋសកម្ម។

ការធ្វើអន្តរាគមន៍ទាន់ពេលអាចទទួលបានផលត្រឡប់មកវិញនូវការអភិវឌ្ឍប្រកបដោយចីរភាពច្រើនជាងការព្យាយាមស្រាយបញ្ហាក្នុងជីវិតរបស់យុវជនតាមក្រោយ។ គម្លាតក្នុងការអប់រំនិងជំនាញបឋមជាឧទាហរណ៍បានបង្ខំឱ្យយុវជនជាច្រើនបោះបង់ការសិក្សាទាំងនៅក្មេងវ័យដោយមិនបានត្រៀមខ្លួនសម្រាប់ការងារ និងជីវិត។ សព្វថ្ងៃនេះ ក្នុងចំណោមកុមារបួននាក់នៅក្នុងពិភពលោកមានម្នាក់បាត់ទៅហើយដែលបានបោះបង់ការសិក្សាតាំងពីនៅសាលាបឋមសិក្សា។ ប៉ុន្តែល្អដែរ ដែលចំនួននេះមិនបានកើនឡើងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ យុវជនគ្មានការងារធ្វើ និងប្រភេទការងារងាយរងគ្រោះបានរីករាលដាល។ យុវជនដែលគ្មានការងារធ្វើប្រហែលជាមានចំនួនបីដងច្រើនជាងមនុស្សចាស់ ។ តម្រូវការផ្នែកបន្តពូជ និងសុខភាពផ្លូវភេទរបស់យុវជនដោះស្រាយមិនទាន់បានទូលំទូលាយ ដែលនាំឱ្យហានិភ័យថ្មីៗពាក់ព័ន្ធនឹងសុខភាពរបស់ពួកគេកើតឡើងផងដែរ។ យុវជនមិនមានឱកាសស្មើគ្នាសម្រាប់វឌ្ឍនភាព ហើយយុវជនមួយចំនួនត្រូវបានទាត់ចេញពីដំណើរការ នៃសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។

ឱកាសសម្រាប់ការលុបបំបាត់គម្លាតសុខុមាលភាពរបស់យុវជននៅមានដំណោះស្រាយយ៉ាងពិតប្រាកដ។ លក្ខ័ណចាំបាច់គឺត្រូវវាស់ស្ទង់ និងវិភាគបញ្ហារបស់យុវជនដែលជួបការលំបាក រួចបង្កើតគោលនយោបាយសម្រាប់ពួកគេដោយផ្អែកលើភស្តុតាងដែលរកឃើញ។ ការចែករំលែកនូវបទពិសោធន៍ល្អៗ និងការផ្លាស់ប្តូរព័ត៌មានអំពីអ្វីដែលធ្វើបាន និងអ្វីដែលមិនអាចធ្វើបានមានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតគោលនយោបាយសម្រាប់យុវជនទាំងនៅក្នុងប្រទេសក្រីក្រ និងប្រទេសរីកចម្រើន។ គោលនយោបាយដែលធ្វើអន្តរាគមន៍នៅដំណាក់កាលសំខាន់ពិតជាអាចបញ្ចៀសហានិភ័យរបស់យុវជនមិនឱ្យធ្លាក់ទៅក្នុងការលំបាកជាងមុន។ ឧទាហរណ៍៖ ការសម្របសម្រួលយុវជនឱ្យបានចូលរួមនៅក្នុងពិភពការងារតាមរយៈការប្រឹក្សាទីផ្សារការងារនិងផ្តល់សេវាបណ្តុះបណ្តាលការងារទូលំទូលាយ គឺជាការចូលរួមជួយដល់សេដ្ឋកិច្ចរបស់យុវជន។ ភស្តុតាងជាច្រើនបានបង្ហាញថា វប្បធម៌និងសកម្មភាពច្នៃប្រឌិត កម្មវិធីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា និងសេវាកម្មគាំទ្រយុត្តិអនីតិជនអាចគាំទ្រយុវជនឱ្យក្លាយជាពលរដ្ឋសកម្ម។

គម្រោងបរិយាប័ន្នយុវជនដែលសហហិរញ្ញប្បទានដោយសហភាពអឺរ៉ុប និងដែលអនុវត្តដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD នឹងវិភាគអំពីទិដ្ឋភាពទាំងនេះនៅក្នុងប្រទេសកំពុងអភិវឌ្ឍទាំង១០ រួមមាន (កម្ពុជា កូតឌីវ័រ អែលសាល់វ៉ាឌ័រ អេត្យូពី ហ្ស៊កដានី ម៉ាឡាវី សាធារណរដ្ឋម៉ុលដាវី ប៉េរូ តូហ្គោ និងវៀតណាម) តាមរយៈការពិនិត្យឡើងវិញលើគោលនយោបាយស្តីពីសុខភាពរបស់យុវជន។ ការពិនិត្យនេះមានគោលបំណងគាំទ្ររដ្ឋាភិបាលដោយផ្តល់ភស្តុតាង និងដំបូន្មានជាក់លាក់អំពីរបៀបដោះស្រាយបញ្ហាប្រឈមរបស់យុវជនពីទស្សនវិស័យពហុវិស័យ និងរបៀបដឹកនាំយុវជនឱ្យចូលរួមយុវជនក្នុងដំណើរការអភិវឌ្ឍន៍ជាតិ។ ការពិនិត្យឡើងវិញនេះនឹងកំណត់កត្តាងាយរងគ្រោះរបស់យុវជន និងកត្តាដែលអាចរួមចំណែកជួយយុវជន នៃប្រទេសទាំងនោះមានការផ្លាស់ប្តូរ។ ការប្រើភស្តុតាងដើម្បីបង្កើតគោលនយោបាយល្អប្រសើរគឺជាវិធីមួយដ៏ល្អបំផុតដើម្បីកាត់បន្ថយបញ្ហាប្រឈម និងបង្កើនសក្តានុពលដែលអាចធ្វើឱ្យយុវជនក្លាយទៅជាភាគលាភរបស់សង្គមជាតិ។ គម្រោងបរិយាប័ន្នយុវជនគឺជាផ្នែកមួយនៃការងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្តីពីសង្គមរួមគ្នាហើយមានគោលបំណងគាំទ្របណ្តាប្រទេសនានាក្នុងការស្វែងរកដំណោះស្រាយបញ្ហាប្រឈមសង្គមប្រកបដោយភាពច្នៃប្រឌិត និងដើម្បីកសាងសង្គមកាន់តែស្អិតរមួត។

ម៉ារីយ៉ូ ផិនហ្ស៊ីនី (Mario Pezzini)

ប្រធាន

មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD

ទីប្រឹក្សាពិសេស នៃអគ្គលេខាធិការ OECD ស្តីពីការអភិវឌ្ឍ

# **អារម្ភកថា**

របាយការណ៍ពិនិត្យឡើងវិញលើគោលនយោបាយសុខមាលភាពរបស់យុវជននៅកម្ពុជាត្រូវបានរៀបចំដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍OECD ក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា (អយក.) នៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍ពិនិត្យឡើងវិញនេះដឹកនាំ និងរៀបចំដោយលោកស្រី **ជីយ៉ឹន រីម** (Ji-Yeun Rim) អ្នកសម្របសម្រួលគម្រោងបរិយាប័ន្នយុវជន ក្រោមការណែនាំរបស់លោក **អាឡិកសាន់ឌ្រី កូលឡេវ** (Alexandre Kolev) ប្រធានអង្គភាពស្វូលសង្គម (Social Cohesion Unit) និង លោកស្រី **ម៉ារីយ៉ូ ផេនហ្ស៊ី** (Mario Pezzini) ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍ និងជាទីប្រឹក្សាពិសេស នៃអគ្គលេខាធិការស្តីពីការអភិវឌ្ឍ OECD ។

អត្ថបទពាក់ព័ន្ធនឹងប្រវត្តិយុវជន និងកត្តាកំណត់ នៃការបោះបង់ការសិក្សានៅកម្រិតបឋមត្រូវបាន រៀបចំដោយលោកស្រី **ផាន់ ដាលីស** (Dalis Phann) និងលោក **ហ៊ីង វុត្ថា** (Vutha Hing) មកពីវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ។ ការស្ទង់មតិបែបគុណភាពស្តីពីការផ្តល់សិទ្ធិអំណាចដល់ស្ត្រីត្រូវបានធ្វើឡើងដោយលោក **ហេន ក្រេង** (Kreng Hen) លោក **ពៅ ជីវ័ន្ត** (Chivoin Peou) លោក **ហ្វាតា ណូ** (Fata No) លោកស្រី **យី រ៉ូហ្សា** (Rosa Yi) និងលោក **ជា សត្យា** (Sathya Chea) ហើយរបាយការណ៍ស្ទង់មតិនេះត្រូវបានកែសម្រួលដោយ លោក **សំ មាលី** (Sam Mealy) មកពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD) ។ លោក **បាក់ គីមជឿន** (Kimchoeun Pak) ជាអ្នកវិភាគលើស្ថាប័ន និងការធ្វើផែនការគោលនយោបាយ។ លោក **ចូណាថន ប្រូឃីហ្សុិន** (Jonathan Broekhuizen) លោក **ម៉ាណាស ប៉ាថាក** (Manas Pathak) និង លោក **ម៉ាធីល តារីហ្វ** (Mathilde Tarif) (មកពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD) ជាជំនួយការផ្នែកស្ថិតិ និងការស្រាវជ្រាវ។

របាយការណ៍នេះកើតចេញពីការពិគ្រោះយោបល់ជាមួយអ្នកជំនាញការជាតិ និងអន្តរជាតិនៅដំណាក់កាលផ្សេងៗគ្នា នៃគម្រោងនេះ។ កិច្ចពិភាក្សាលើគោលនយោបាយចំនួនពីរត្រូវបានរៀបចំនៅខែមិថុនា ឆ្នាំ 2015 និងខែឧសភា ឆ្នាំ 2016 ដើម្បីកំណត់វិសាលភាព នៃការស្រាវជ្រាវ និងពិភាក្សាអំពីការរកឃើញនៅពាក់កណ្តាលឆមាស។ ទិន្នន័យនេះបានមកពីប្រភពពាក់ព័ន្ធ រួមមាន៖ លោក **សីចា អែនតូនិន** (Seija Anttonen) (មកពីអង្គការអ្នកស្ម័គ្រចិត្តសហប្រជាជាតិUNV) លោក **នឿន បូ** Noeun Bou មកពីគណៈប្រតិភូ នៃសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា លោក **មុំ ប៊ុនថន** (Mom Bunthan) មកពីក្រសួងសង្គមកិច្ចកម្ពុជាកិច្ចការ អតីតយុទ្ធជន និងយុវនីតិសម្បទា លោក **ម៉ាធាវ កូញាក់** (Matthieu Cognac) មកពីអង្គការពលកម្មអន្តរជាតិILO លោក **ម៉ាក ឌឺវ៉ី** (Marc Derveeuw) មកពីមូលនិធិប្រជាជនអង្គការសហប្រជាជាតិ UNFPA លោក **អូឡេ ដូទិនជែម** (Ole Doetinchem) មកពីអង្គការ Deutsche Gesellschaft für Internationale Zusammenarbeit, GIZ លោក **ឈុន ហាក់** (Chhun Hak) មកពីក្រសួងកិច្ចការនារី លោក **លេញ ហ៊ាង** (Lenh Heang) មកពីក្រសួងផែនការ លោក **ឡាំ ខាន់ណារិទ្ធិ** (Lam Khannarith) មកពីមហាវិទ្យាល័យកសិកម្មព្រែកលៀប លោក **ហង្ស លីណា** (Hang Lina) មកពីវិទ្យាស្ថានជាតិស្ថិតិ លោក **សេង ម៉ុម** (Seng Mom) មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម លោក **តាន់ សម្បត្តិ** (Tann Sambath) មកពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក **ជុំ សេនាវាសនា** (Chum Senveasna) និង លោក **យ៉ាន់ សោភ័ណ** (Yann Sophorn) មកពីសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា និងលោក **សាណេត វឌ្ឍនា** (Saneth Vathna) មកពីវិទ្យាស្ថានជាតិសង្គមកិច្ច ។ ក្រុមការងារសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការយល់ដឹងដែលផ្តល់ដោយតំណាងអង្គការយុវជន ដូចជា លោកស្រី **ប៉ែន បុប្ផា** (Pen Bopha) លោក **សិទ្ធិ ហុងអៀង** (Sith Hong Eang) និងលោកស្រី **ហ៊ាង កញ្ញារី** (Heang Kanhary) មកពីសមាគមយុវជនខ្មែរ លោក **ឡុង គិមហ៊ន** (KimKhorn Long) មកពីសភាយុវជនខ្មែរ លោក **រ៉ុង រតនា** (Rong Rattana) មកពីក្រុមប្រឹក្សាក្សាយុវជនកម្ពុជា និងលោក **នាគ ស៊ីគីរិន** (Neak Seakirin) មកពីសហភាពសហព័ន្ធយុវជនកម្ពុជា ។

របាយការណ៍ចុងក្រោយនេះ រួមចំណែកផ្តល់យោបល់បច្ចេកទេសដោយ លោក **អៀនប៊្រេន វ៉េន័រ** (Ian Brand-Weiner) លោក **អែដ្រៀន ឡូរិនកូ** (Adrien Lorenceau) និងលោក **ប៉ាប្លូ សួរ៉េហ្សរ៉ូប** (Pablo Suarez Robles) មកពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD), **ឯកឧត្តម តូច ជឿន** (H.E. Tauch Choeun) អគ្គនាយកយុវជន នៃក្រសួង អយក.និងជាអគ្គលេខាធិការ.កជយ. លោក **ជុង វាន់ដារា** (Vandara Chong) មកពីUNFPA លោក **ឈុន ហាក់** (Chhun Hak) មកពីក្រសួងកិច្ចការនារី លោក **ក្រេង ហេង** (Kreng Heng) អ្នកជំនាញថ្នាក់ជាតិ លោក **ហម សុផាណ្ណា** (Hom Sophanna) មន្ត្រីនាយកយុវជន លោក **ឡុង គីមហ៊ន** (KimKhorn Long) មកពីសភាយុវជនខ្មែរ និងលោក **ប៉ាក់ គីមជឿន** (Kimchoeun Pak) អ្នកជំនាញថ្នាក់ជាតិ ។

ការអនុវត្តគម្រោងទាំងមូលនៅក្នុងប្រទេសកម្ពុជាអាចប្រព្រឹត្តទៅបានអាស្រ័យដោយមានការគាំទ្រពីអគ្គនាយកដ្ឋានយុវជន នៃក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសតាមរយៈការចូលរួមរបស់ **ឯកឧត្តម តូច ជឿន** (Tauch Choeun) អគ្គនាយកយុវជននៃក្រសួង អយក. និងជាអគ្គលេខាធិការ.កជយ. **ឯកឧត្តម ចឹក លឹម** (H.E. Chek Lim) អគ្គរងយុវជន និងជាអគ្គលេខាធិការរង.ក.ជ.យ. លោក **រស់ ភារៈ** (Ros Phearak) លោកស្រី **ទេព ស៊ីណាត** (Tep Sinath) ប្រធាននាយកដ្ឋានយុវជន និងជាប្រធានផ្នែកអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍយុវជន លោក **ហម សុផាណ្ណា** (Hom Sophanna) មន្ត្រីនាយកដ្ឋានយុវជន។ ក្រុមការងារសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន **(H.E. Dr. Hang Chuon Naron)** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ចំពោះការអនុម័ត និងគាំទ្រគម្រោងនេះ។

សូមថ្លែងអំណរគុណដល់សហភាពអឺរ៉ុបចំពោះការផ្តល់ហិរញ្ញប្រទានឱ្យមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD បានអនុវត្ត និងរៀបចំរបាយការណ៍ការពិនិត្យឡើងវិញដែលជាផ្នែកមួយនៃគម្រោងបរិយាប័ន្នយុវជន។

**មាតិកា**


បុព្វកថា ........ I

អារម្ភកថា ........ III

មាតិកា ........ V

បញ្ជីតារាង ........ VIII

បញ្ជីរូបភាព ........ XI

បញ្ជីប្រអប់ ........ XI

អក្សរកាត់ ........ XIII

ព័ត៌មានទូទៅ ........ XIV

សេចក្តីសង្ខេប ........ 1-S

**ជំពូកទី ១: របាយការណ៍យុវជនកម្ពុជា** ........ 1

១.១ ទិដ្ឋភាពទូទៅ ........ 2

១.២ សុខភាព ........ 3

១.២.១ អត្រាមរណភាពយុវជន ........ 3

១.២.២សុខភាពផ្លូវភេទ និងបន្តពូជ (SRH) ........ 4

១.២.៣ ការរំលោភបំពានដោយសារគ្រឿងញៀន ........ 5

១.២.៤ ការប្រើប្រាស់ថ្នាំជក់ និងគ្រឿងស្រវឹង ........ 6

១.៣ ការអប់រំ និងជំនាញ ........ 8

១.៣.១ ការចូលរួមក្នុងវិស័យអប់រំ ........ 8

១.៣.៣ អត្រាឡើងថ្នាក់ និងត្រួតថ្នាក់ ........ 11

១.៣.៤ អត្រាទទួលបានការអប់រំ ........ 12

១.៣.៥ លទ្ធផលសិក្សា ........ 12

១.៣.៦ អត្រាការងារ ........ 13

១.៣.៧ ការចូលរួមកម្លាំងពលកម្ម និងគុណភាពការងារ ........ 13

១.៣.៨ ស្ថានភាពការងារយុវជន ........ 14

១.៣.៩ NEET និងយុវជនអសកម្ម ........ 15

១.៣.១០ ម៉ោងធ្វើការ ........ 16

១.៣.១១ ភាពមិនស៊ីគ្នារវាងគុណវុឌ្ឍិនឹងមុខរបរ ........ 16

១.៤ ការផ្តល់សិទ្ធិអំណាច និងការចូលរួម ........ 18

១.៤.១ ធនធានសង្គម ........ 18

១.៤.២ ការចូលរួមក្នុងសកម្មភាពសង្គម និងនយោបាយ ........ 18

១.៤.៣ តុលាការអនីតិជន ........ 19

១.៤.៤ យុវជនរងគ្រោះដោយការវាយប្រហារ និងអំពើហិង្សា ជាពិសេសការវាយប្រហារ និងអំពើហិង្សាប្រឆាំងនឹងស្ត្រីវ័យក្មេង ........ 20

១.៥ សុខុមាលភាពរបស់យុវជន ........ 21

១.៦ សេចក្តីសន្និដ្ឋាន ........ 21

ឯកសារយោង ........ 33

**ជំពូកទី ២៖ គោលនយោបាយ និងបរិបទស្ថាប័នសម្រាប់យុវជន** ........ 36

២.១ បរិបទសេដ្ឋកិច្ចសង្គម .......... 37

២.២ ផែនការគោលនយោបាយស្តីពីយុវជន .......... 37

២.២.១ ក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍជាតិ .......... 38

២.២.២ សារពើភ័ណ្ឌនៃគោលនយោបាយពាក់ព័ន្ធនឹងយុវជន .......... 39

២.២.៣ ថវិកាកម្មវិធីយុវជន (Youth programme budget) .......... 40

២.៣ កំណែទម្រង់ស្ថាប័នយុវជន .......... 41

២.៣.១ ថ្នាក់ក្រោមជាតិ .......... 41

២.៣.២ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ) .......... 42

២.៣.៣ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន .......... 43

២.៤ ការចូលរួមរបស់យុវជនក្នុងដំណើរការបង្កើតគោលនយោបាយ .......... 44

២.៤.១ ការចូលរួមតាមរយៈអង្គការ និងវេទិកាយុវជន .......... 45

២.៤.២ ការចូលរួម តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងគណបក្សនយោបាយ .......... 45

២.៤.៣ ការចូលរួមក្នុងស្ថាប័នរាជរដ្ឋាភិបាល និងការអភិវឌ្ឍមូលដ្ឋាន .......... 45

២.៤.៤ ការចូលរួមតាមរយៈការងារស្ម័គ្រចិត្ត .......... 46

២.៥ សន្និដ្ឋាន និងអនុសាសន៍ .......... 46

ឯកសារយោង .......... **47**

**ជំពូកទី ៣៖ ចរិតលក្ខណៈ និងផ្លូវជីវិត នៃអ្នកការបោះបង់ការសិក្សា** .......... 59

៣.១ និន្នាការ នៃបោះបង់ការសិក្សា .......... 60

៣.២ មូលហេតុ នៃការបោះបង់ការសិក្សា .......... 61

៣.២.១ លក្ខខណ្ឌបុគ្គល .......... 61

៣.២.២ ស្ថានភាពសេដ្ឋកិច្ចគ្រួសារ .......... 63

៣.២.៣ បរិស្ថានសាលារៀន .......... 65

៣.៣ ក្តីរំពឹងរបស់និស្សិតដែលបានបបញ្ចប់ និងអ្នកបោះបង់ការសិក្សា .......... 66

៣.៣.១ ស្ថានភាពការងារ .......... 66

៣.៣.២ ប្រាក់ខែឈ្នួលប្រាក់/ .......... 70

៣.៣.៣ ការពេញចិត្តនឹងការងារ .......... 71

៣.៣.៤ ការងារសមរម្យ .......... 72

៣.៤ ការអប់រំក្រៅប្រព័ន្ធ .......... 73

៣.៤.១ ថ្នាក់អក្ខរកម្ម .......... 73

៣.៤.២ ការបន្តការអប់រំ .......... 73

៣.៤.៣ ការអប់រំសហគមន៍មជ្ឈមណ្ឌលសិក្សាសហគមន៍/ .......... 73

៣.៤.៤ ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ .......... 74

៣.៤.៥ បទពិសោធន៍ពីបរទេស .......... 75

៣.៥ សន្និដ្ឋាន និងអនុសាសន៍ .......... 76

ឯកសារយោង .......... **77**

**ជំពូកទី ៤: បញ្ហាប្រឈមក្នុងការងារដែលស្ត្រីកម្ពុជាជួបប្រទះ** .......... 91

៤.១ ស្ថានភាពទីផ្សារការងារ .......... 92

៤.១.១ កម្លាំងពលកម្ម .......... 92

៤.២ ទីផ្សារការងារសម្រាប់ស្ត្រី .......... 94

៤.២.១ ភាពមិនផ្លូវការ (Informality)........ 94

៤.២.២បទដ្ឋានសង្គម (Social norms) ........ 96

៤.២.៣ គម្លាតព័ត៌មាន និងបណ្ដាញសង្គម........ 97

៤.២.៤ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងសេវាកម្មការងារ ........ 98

៤.២.៥ ការបោះបង់កាសិក្សា ........ 98

៤.៣ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់កំណើនការងារនិងការចូលរួម ........ 100

៤.៤ សន្និដ្ឋាន ........ 101

**ឯកសារយោង ........ 102**

**ឧបសម្ព័ន្ធ ........ 116**

4A1 .វិធីសាស្ត្រ នៃការពិភាក្សាក្រុមគោលដៅ ........ 117

ការប្រមូលទិន្នន័យ និងការវិភាគ........ 118

សីលធម៍ស្រាវជ្រាវ ........ 118

បញ្ជីឈ្មោះអ្នកផ្ដល់ចម្លើយសម្ភាស ........ 118

## បញ្ជីតារាង


តារាង 1 (1-1) ការពិពណ៌នាពីយុវជនកម្ពុជាដែលមានអាយុពី 15 ទៅ 30 ឆ្នាំ ..... 2

តារាង 2 (1-2) អត្រាមរណភាពយុវជន (អាយុពី 15 ទៅ 29 ឆ្នាំ ក្នុងឆ្នាំ 2005 និង 2015 ..... 3

តារាង 3 (1-3) បំណែងចែកមូលហេតុនៃការស្លាប់ក្នុងចំណោមយុវជនដែលមានអាយុពី 15 ទៅ 29 ក្នុងឆ្នាំ 2005 និង 2015 ..... 4

តារាង 4 (1-4) អត្រាបន្តពូជសរុប ក្នុងចំណោមស្ត្រី)1 000 នាក់តាមលំនៅដ្ឋាន និងក្រុមអាយុ ឆ្នាំ (2014 ..... 5

តារាង 5 (1-5) យុវជនមានជំងឺសង្គមតាមតំបន់ និងទ្រព្យធន (ភាគរយ នៃយុវជនសរុបអាយុពី 15 ទៅ 29 ឆ្នាំ) ក្នុងឆ្នាំ 2005 និងឆ្នាំ 2014 ..... 5

តារាង 6(1-6) អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សាសម្រាប់ឆ្នាំសិក្សា 16/2015 និង 11/2010 ..... 8

តារាង 7 (1-7) អត្រាចុះឈ្មោះចូលរៀនសុទ្ធតាមតំបន់សម្រាប់ឆ្នាំសិក្សា 2010 /11 និង 2015 /16 ..... 9

តារាង 8 (1-8) ការចុះឈ្មោះចូលរៀនសរុបនៅកម្រិតឧត្តមសិក្សាឆ្នាំ 2004 និង 2014 ..... 10

តារាង 9 (1-9) អត្រាបោះបង់ការសិក្សាក្នុងឆ្នាំសិក្សា 2010/11 និង 2014/15 ..... 10

តារាង 10 (1-10) អត្រាឡើងថ្នាក់ និងអត្រាត្រួតថ្នាក់ក្នុងឆ្នាំសិក្សា 2009 /10 និង2014 /15 ..... 11

តារាង 11 (1-11) អត្រាយុវជនចេះអក្សរសរុប និងស្ថានភាពទ្រព្យធន ក្នុងឆ្នាំ 2004 និងឆ្នាំ 2014 ..... 12

តារាង 12 (1-12) ភាគរយនៃយុវជនដែលមានអាយុពី 15ទៅ29 ឆ្នាំដែលរកប្រាក់ចំណូលបានក្រោមប្រាក់ខែឬប្រាក់ចំណូលមធ្យម ឆ្នាំ (ភាគរយនៃការងារតាមប្រភេទ)2014 ..... 14

តារាង 13 (1-13) អត្រា NEET ក្នុងចំណោមយុវជនអាយុពី 15 ទៅ 29 ឆ្នាំ គិតជាភាគរយ តាមភេទ និងតំបន់ ឆ្នាំ 2004 និងឆ្នាំ 2014 ..... 16

តារាង 14 (1-14) ក្រុមមុខរបរនៅក្នុងចំណាត់ថ្នាក់របស់ ISCO និងកម្រិតអប់រំ ..... 17

តារាង 15 (1-15) ភាពមិនស៊ីគ្នារវាងគុណវុឌ្ឍិនឹងមុខរបររបស់យុវជន ក្នុងឆ្នាំ 2014 (គិតជា ភាគរយ) ..... 17

តារាង 16(1-16) អត្រានៃអំពើហិង្សាលើស្ត្រីវ័យក្មេងដែលមានអាយុចន្លោះពី 2014 ឆ្នាំ ក្នុងឆ្នាំ 29 ទៅ 15 ..... 20

តារាង 17 (2-1) សារពើភ័ណ្ឌនៃគោលនយោបាយស្តីពីយុវជន តាមក្រសួងពាក់ព័ន្ធ ..... 39

តារាង 18 (2-3) ការប្រតិបត្តិនិងការបែងចែកថវិកាជាតិ (គិតជា លានដុល្លារអាមេរិក) ..... 41

តារាង 19 (3-1) អត្រាបោះបង់ការសិក្សា តាមតំបន់ ក្នុងឆ្នាំសិក្សា (គិតជាភាគរយ)2009 / 10-2014 / 15 ..... 61

តារាង 20 (3-2) ស្ថានភាពគ្រួសាររបស់ប្រជាជនមានអាយុពី 15 ទៅ 24 ឆ្នាំ ពីឆ្នាំ 2004-2014 (គិតជា ភាគរយ តាមប្រភេទ) ..... 62

តារាង 21 (3-3)ការបែងចែកចំនួនប្រជាជនដែលមានអាយុពី 10 ទៅ 24 ឆ្នាំ តាមវិស័យការងារ ស្ថានភាពភេទ និងការចូលសាលារៀន ឆ្នាំ 2004 ឆ្នាំ 2009 ឆ្នាំ 2014 (គិតជា ភាគរយ) ..... 62

តារាង 22 (3-4)ការបែងចែកអត្រាបោះបង់ការសិក្សា និងសិស្សដែលមានអាយុពី 10 ទៅ 24 ឆ្នាំ តាមវិស័យ ការងារ តាមតំបន់ ឆ្នាំ 2004 និងឆ្នាំ 2014 (ភាគរយនៃចំនួនអ្នកធ្វើការសរុបដែលមានអាយុ 10 ទៅ 24ឆ្នាំ) ..... 62

តារាង 23 (3-5)ការចែកស្ថានភាពការងាររបស់ប្រជាជនចាប់ពីអាយុ 10 ទៅ 24 ឆ្នាំ 2004 និងឆ្នាំ 2014 (គិតជា %) ..... 63

តារាង 24 (3-6) អត្រាបោះបង់ការសិក្សាតាមស្ថានភាពទ្រព្យធន ឆ្នាំ 2004-14 ..... 63

តារាង 25 (3-7) លក្ខខណ្ឌគ្រួសារ នៃយុវជនដែលមានអាយុចន្លោះពី 6 ឆ្នាំ ទៅ 24 ឆ្នាំ នៅក្នុងឆ្នាំ 2004, 2009 និង 2014 ..... 65

តារាង 26 (3-8) សាលារៀន ថ្នាក់រៀន និងគ្រូបង្រៀន តាមកម្រិត និងតាមឆ្នាំសិក្សា 2010/11-2015/16 ..... 65

តារាង 27 (3-9) សមាមាត្រសិស្សនិងគ្រូ និងសមាមាត្រសិស្ស និងថ្នាក់រៀនតាមកម្រិត ក្នុងឆ្នាំសិក្សា 2010 /11-2015 /16 ..... 66

តារាង 28 (3-10) ភាគរយនៃស្ថានភាពការងាររបស់យុវជនក្នុងក្រុមអាយុពី 15 ទៅ 29 ឆ្នាំ ដែលបានបញ្ចប់ការសិក្សានិងបោះបង់ការសិក្សានៅឆ្នាំ 2014 ..... 67

តារាង 29 (3-11)ស្ថានភាពការងារនៃនិស្សិតបានបញ្ចប់ការសិក្សា និងបោះបង់ការសិក្សាដែលមានអាយុពី 15 ទៅ 29 ឆ្នាំ តាមកម្រិតការអប់រំ (ឆ្នាំ 2014) ..... 67

តារាង 30 (3-12) មុខរបរ និងកម្រិតអប់រំរបស់យុវជនដែលមានអាយុពី 15 ទៅ 29 ឆ្នាំ ក្នុង ឆ្នាំ 2014 ..... 67

តារាង 31 (3-13) មុខរបររបស់សិស្សបានបញ្ចប់ និងបោះបង់បឋមសិក្សា ដែលមានអាយុពី 15 ទៅ 19 ឆ្នាំ ក្នុងឆ្នាំ 2014 ..... 68

តារាង 32 (3-14) កម្រិតជំនាញ នៃសិស្សបានបញ្ចប់ និងបោះបង់បឋមសិក្សា ដែលមានអាយុពី 15 ទៅ 19 ក្នុងឆ្នាំ 2014 ..... 68

តារាង 33 (3-15) ស្ថានភាពការងាររបស់សិស្សដែលបានបញ្ចប់ និងបោះបង់បឋមសិក្សា ដែលមានអាយុពី 15 ទៅ 19 ឆ្នាំ ក្នុងឆ្នាំ 2014 ..... 68

តារាង 34 (3-16) កម្រិតជំនាញសិស្សដែលបានបញ្ចប់និងបោះបង់មធ្យមសិក្សា ដែលមានអាយុពី 20 ទៅ 24 ឆ្នាំ ក្នុងឆ្នាំ 2014 ..... 68

តារាង 35 (3-17) ស្ថានភាពការងារសិស្សដែលបានបញ្ចប់និងបោះបង់មធ្យមសិក្សា ដែលមានអាយុពី 20 ទៅ 24 ឆ្នាំ ក្នុងឆ្នាំ 2014 ..... 69

តារាង 36 (3-18) មុខរបររបស់និស្សិតដែលបានបញ្ចប់និងបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សា ដែលមានអាយុពីឆ្នាំ 25ទៅ29ឆ្នាំ ក្នុងឆ្នាំ 2012-14 ..... 69

តារាង 37 (3-19) កម្រិតជំនាញរបស់និស្សិតដែលបានបញ្ចប់ និងបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សាដែលមានអាយុពី 25ទៅ29 ឆ្នាំ ក្នុងឆ្នាំ2014 ..... 69

តារាង 38 (3-2) ស្ថានភាពការងាររបស់និស្សិតដែលបានបញ្ចប់និងបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សាដែលមានអាយុពី 25ទៅ29 ឆ្នាំក្នុងឆ្នាំ 2014 ..... 69

តារាង 39 (3-21) ប្រាក់ខែតាមកម្រិតសាលា និងជំនាញរបស់យុវជនដែលមានអាយុពី 15 ទៅ 29 ឆ្នាំ 2014 (រៀល (ម៉ោង / ..... 70

តារាង 40 (3-22) ប្រាក់ខែរបស់សិស្សដែលបានបញ្ចប់ និងបោះបង់ការសិក្សានៅកម្រិតបឋម ដែលមានអាយុពី 15 ទៅ 19 ឆ្នាំ តាមភេទ ក្នុងឆ្នាំ 2014 ............................ 70

តារាង 41 (3-23) ប្រាក់ខែរបស់សិស្សដែលបានបញ្ចប់ និងបោះបង់ការសិក្សានៅកម្រិតបឋម ដែលមានអាយុពី 15 ទៅ 19 ឆ្នាំ តាមតំបន់ ក្នុងឆ្នាំ 2014 (រៀល/ម៉ោង) ................ 70

តារាង 42 (3-24)ប្រាក់ខែរបស់សិស្សដែលបានបញ្ចប់និងបោះបង់ការសិក្សានៅមធ្យមសិក្សា ដែលមានអាយុពី 20 ទៅ 24 ឆ្នាំ ក្នុងឆ្នាំ 2014 (រៀល / ម៉ោង)........................ 70

តារាង 43 (3-25) ប្រាក់ខែរបស់និស្សិតដែលបានបញ្ចប់និងបោះបង់ការសិក្សានៅឧត្តមសិក្សា ដែលមានអាយុពី 20 ទៅ 24 ឆ្នាំ តាមភេទនិងតំបន់ ក្នុងឆ្នាំ 2014 (រៀល(ម៉ោង/........... 71

តារាង 44 (3-26) កម្រិតពេញចិត្តនឹងការងាររបស់និស្សិតបានបញ្ចប់ និងបោះបង់ការសិក្សាតាមកម្រិតអប់រំ ក្នុងឆ្នាំ 2014 ................................................................ 71

តារាង 45 (3-27) ភាគរយនៃយុវជនដែលទទួលបានការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារដែលខ្លួនកំពុងធ្វើ ក្នុងរយៈពេល 12 ខែចុងក្រោយ ក្នុងឆ្នាំ 2014 .............................. 72

តារាង 46 (-28) ថ្នាក់អក្ខរកម្ម ឆ្នាំ 2000-14..................................................................................... 73

តារាង 47 (3-29) CLC និងសិស្ស ឆ្នាំ 2006 ឆ្នាំ 2010 និងឆ្នាំ 2014................................................................ 73

តារាង 48 (3-30) ការចុះឈ្មោះចូលរៀនតាមកម្រិតបណ្តុះបណ្តាល ស្ថាប័នចុះបញ្ជីជាមួយ)TVET និង MoLVT)......................................... 74

តារាង 49 (3-31) TVET ផ្លូវការ និងប្រព័ន្ធអប់រំចំណេះទូទៅ ................................................................ 74

តារាង 50 (4-1) ប្រជាជននិងកម្លាំងពលកម្ម អាយុពី 15 ទៅ 64 ឆ្នាំ តាមភេទ និងភូមិសាស្រ្ត ឆ្នាំ 2014 (គិតជាភាគរយ).................................... 92

តារាង 51 (4-2) អត្រាចូលរួមកម្លាំងពលកម្ម តាមក្រុមអាយុ និងភេទ ឆ្នាំ 2014 គិតជាភាគរយ ............................................ 92

តារាង 52 (4-3) អត្រាចូលរួមកម្លាំងពលកម្ម តាមឆ្នាំ (2004, 2009 និងឆ្នាំ 2014) តាមភេទ និងតំបន់ គិតជាភាគរយ ........................... 93

តារាង 53 (4-4) បំណែងចែកកម្លាំងពលកម្ម តាមវិស័យ (2004, 2009 និងឆ្នាំ 2014) គិតជាភាគរយ ..................................... 93

តារាង 54 (4-5) បំណែងចែកកម្លាំងពលកម្មតាមមុខរបរសំខាន់ ឆ្នាំ 2004 - 2014 (គិតជា ភាគរយ)........................................ 94

តារាង 55 (4-6) យុវជនកំពុងធ្វើការ ដែលមានអាយុ 15 ឆ្នាំឡើង តាមកម្រិតអប់រំ ឆ្នាំ 2012 (គិតជា ភាគរយ)....................................... 94

តារាង 56 (4A-1-1) ខេត្តគោលដៅ និងលក្ខណៈជ្រើសរើស ........................................................ 117

តារាង 57 (4A-1-2) ចំនួននៃ FGDs តាមខេត្ត .................................................................. 118

តារាង 58 (4A-1-3) បញ្ជីឈ្មោះអ្នកផ្តល់ចម្លើយសម្ភាស ........................................................... 118

## បញ្ជីរូបភាព


រូបភាព 1(1-1) មូលហេតុឈានមុខគេក្នុងចំណោមមូលហេតុនៃការស្លាប់យុវជនសរុបអាយុពី 15 ទៅ 29 ឆ្នាំ នៅក្នុងឆ្នាំ 2005 និង 2015 ........ 3

រូបភាព 2 (1-2)បំណែងចែកអ្នកប្រើគ្រឿងញៀនតាមក្រុមអាយុក្នុងឆ្នាំ 2010 (គិតជា ភាគរយ)........ 6

រូបភាព 3 (1-3) អ្នកញៀនថ្នាំអាយុពី 18ទៅ35 ឆ្នាំស្វែងរកការផ្តល់សេវាស្តារនីតិសម្បទា (គិតជា ភាគរយ នៃអ្នកស្វែងរកការព្យាបាលសរុប) ........ 6

រូបភាព 4 (1-4) យុវជនអាយុពី 15 ទៅ 24 ឆ្នាំ ប្រើប្រាស់ផលិតផលថ្នាំជក់........ 6

រូបភាព 5 (1-5) ភាគរយនៃអាយុផ្តើមជក់បារីក្នុងចំណោមអ្នកជក់បារីទៀងទាត់អាយុពី 15 ទៅ 19 ឆ្នាំ ........ 7

រូបភាព 6 (1-6)អ្នកប្រើប្រាស់គ្រឿងស្រវឹងអាយុពី 15 ទៅ 19 ឆ្នាំក្នុងចំណោមបណ្តាប្រទេសអាស៊ានឆ្នាំ 2010 (គ្រឿងស្រវឹងសុទ្ធគិតជាលីត្រ)........ 7

រូបភាព 7 (1-7) អ្នកសេបគ្រឿងស្រវឹងធ្ងន់ធ្ងរដែលមានអាយុពី 15ទៅ19 ឆ្នាំ (ភាគរយ នៃប្រជាជន), ឆ្នាំ 2010........ 8

រូបភាព 8 (1-8)អត្រាចុះឈ្មោះចូលរៀនសរុប និងបញ្ចប់ការសិក្សាតាមកម្រិត 2010/11 និង 2015/16 ........ 10

រូបភាព 9 (1-9)អត្រាយុវជនទទួលបានការអប់រំ ក្នុងឆ្នាំសិក្សា 2004 និង 2014 (យុវជនអាយុ 25 ទៅ 29ឆ្នាំ គិតជាភាគរយ)........ 12

រូបភាព 10 (1-10)អត្រាយុវជនចេះអក្សរតាមតំបន់ក្នុងឆ្នាំ 2004 និងឆ្នាំ 2014 (គិតជា ភាគរយ) ........ 13

រូបភាព 11 (1-11) បំណែងចែកយុវជនដែលធ្វើការងារងាយរងគ្រោះតាមវិស័យ ឆ្នាំ2014........ 13

រូបភាព 12 (1-12) បំណែងចែកការងារយុវជនតាមស្ថានភាពការងារគិតជា ភាគរយ ក្នុងឆ្នាំ 2004 និងឆ្នាំ 2014 ........ 15

រូបភាព 13 (1-13) បំណែងចែកការងារយុវជនតាមស្ថានភាពការងារ ឆ្នាំ 2012 ........ 15

រូបភាព 14 (1-14) បណ្តាញគាំទ្រពីសង្គម តាមក្រុមអាយុ និងភេទ ឆ្នាំ 2006 និងឆ្នាំ 2015 ........ 18

រូបភាព 15 (1-15) ការចូលរួមរបស់យុវជនក្នុងសកម្មភាពសង្គម ........ 19

រូបភាព 16 (1-16) ចំនួនអ្នកជាប់ពន្ធនាគារពីឆ្នាំ 1999-2008 (ក្នុងចំណោមមនុស្ស 100 000 នាក់)........ 20

រូបភាព 17 (1-17) ការពេញចិត្តនឹងជីវិតរបស់យុវជនលើមាត្រដ្ឋាន 1/10 នាក់ ........ 21

រូបភាព 18 (2-1) រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិនៅកម្ពុជា........ 41

រូបភាព 19 (2-2)រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ហៅកាត់ថា ក.ជ.យ) ........ 42

រូបភាព 20 (3-1) អត្រាសិស្សបោះបង់សាលាតាមកម្រិតសិក្សា និងភេទ (ឆ្នាំសិក្សា 2009/10 និង 2014/15) ........ 60

រូបភាព 21 (3-2) អត្រាសរុបនៃចុះឈ្មោះចូលរៀននិងបញ្ចប់ ឆ្នាំសិក្សា (ភាគរយ)2010 / 11-2015 / 16........ 60

រូបភាព 22 (3-3) មូលហេតុនៃការបោះបង់ការសិក្សា ក្នុងឆ្នាំ 2014........ 64

រូបភាព 23 (3-4) គម្លាតនៃសេចក្តីប្រាថ្នារបស់យុវជន ........ 71


## បញ្ជីប្រអប់


ប្រអប់ 1 (2-1) ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈអាចជួយទប់ស្កាត់ការធ្វើចំណាកស្រុក........ 38

ប្រអប់ 2 (2-1) ការរកឃើញសំខាន់ៗពីការសិក្សាពាក់ព័ន្ធនឹងការចូលរួមរបស់យុវតីក្នុងវិស័យនយោបាយ........ 46

## អក្សរកាត់

| | |
|---|---|
| ASEAN | Association of Southeast Asian Nations |
| CDHS | Cambodia Demographic and Health Survey |
| CDRI | Cambodia Development Resource Institute |
| CS | Commune/Sangkat |
| CSES | Cambodia Socio-Economic Survey |
| DM | District/Municipality |
| EU | European Union |
| GDP | Gross domestic product |
| ILO | International Labour Organization |
| M&E | Monitoring and evaluation |
| MoLVT | Ministry of Labour and Vocational Training |
| MoEYS | Ministry of Education, Youth and Sport |
| MoH | Ministry of Health |
| MoSAVY | Ministry of Social Affairs, Veterans and Youth Rehabilitation |
| MoWA | Ministry of Women's Affairs |
| NCDD | National Committee for Sub-National Democratic Development |
| NEET | Not in Employment, Education or Training |
| NGO | Non-governmental organisation |
| NP-SNDD | National Program for Sub-National Democratic Development |
| NYAP | National Youth Action Plan |
| NYDC | National Youth Development Council |
| NYDP | National Youth Development Policy |
| OECD | Organisation for Economic Co-operation and Development |
| PBB | Programme-based budgeting |
| SME | Small and medium-sized enterprise |
| SNA | Sub-national administration |
| SRH | Sexual and reproductive health |
| STI | Sexually transmitted infection |
| SWTS-Cambodia | School-to-work transition survey of Cambodia |
| TIC | Transparency International Cambodia |
| TVET | Technical Vocational Education and Training |
| UN | United Nations |
| UNDP | United Nations Development Programme |
| UYFC | Union of Youth Federations of Cambodia |
| WDI | World Development Indicators |
| Y-MDI | Youth Multi-dimensional Deprivation Indicator |

## ព័ត៌មានទូទៅ

| | |
|---|---|
| ចំនួនប្រជាជន | 15.2 លាន (ឆ្នាំ 2013 ដោយប៉ាន់ស្មានពីជំរឿនឆ្នាំ 2008) |
| អត្រាកំណើនប្រជាជន | 1.56 ភាគរយ |
| រចនាសម្ព័ន្ធអាយុ | 0 ទៅ 14 ឆ្នាំ : 30.11 ភាគរយ<br>15 ទៅ 19 ឆ្នាំ : 11.43 ភាគរយ<br>15 ទៅ 24 ឆ្នាំ : 22.46 ភាគរយ<br>**15** ទៅ **29** ឆ្នាំ **: 31.76** ភាគរយ<br>25 ទៅ 54 ឆ្នាំ : 37.33 ភាគរយ<br>55 ទៅ 64 ឆ្នាំ : 5.69 ភាគរយ<br>65+ ឆ្នាំ : 4.42 ភាគរយ |
| សមាមាត្រភេទ | ពេលកើត: 1.05 ប/ស<br>0 ទៅ 14 ឆ្នាំ : 1.02 ប/ស<br>15 ទៅ 24 ឆ្នាំ : 0.98 ប/ស<br>25 ទៅ 54 ឆ្នាំ : 0.95 ប/ស<br>55 ទៅ 64 ឆ្នាំ : 0.65 ប/ស<br>65 ឆ្នាំឡើង: 0.6 ប/ស<br>ចំនួនប្រជាជនសរុប: 0.94 ប/ស |
| ក្រុមជនជាតិ | ខ្មែរ 97.6 ភាគរយ, អ៊ីស្លាម 1.2 ភាគរយ, វៀតណាម 0.1 ភាគរយ, ចិន 0.1 ភាគរយ, ផ្សេងៗ 0.9 ភាគរយ |
| សាសនា | ពុទ្ធសាសនិក (ផ្លូវការ) 96.9ភាគរយ, មូស្លីម 1.9ភាគរយ, គ្រិស្តសាសនិក 0.4ភាគរយ, ផ្សេងៗ 0.8 ភាគរយ |
| ភាសា | ភាសាខ្មែរ (ផ្លូវការ) 96.3 ភាគរយ, ផ្សេងៗ 3.7 ភាគរយ |
| នគរូបនីយកម្ម | ប្រជាជននៅទីក្រុង: 20 ភាគរយ នៃប្រជាជនសរុប<br>ប្រជាជននៅជនបទ: 80 ភាគរយ នៃប្រជាជនសរុប<br>អត្រានៃនគរូបនីយកម្ម: 2.7 ភាគរយ អត្រាផ្លាស់ប្តូរប្រចាំឆ្នាំ (2010-15 មធ្យម) |
| អត្រាធ្វើចំណាកស្រុកសុទ្ធ | -0.3 ចំណាកស្រុក ក្នុងចំណោមប្រជាជន 1,000 នាក់ |
| ប្រជាជនក្នុងអាយុធ្វើការសរុប | 10 000 000<br>**15** ទៅ **29** ឆ្នាំ**: 43** ភាគរយ |
| ចំនួនកម្លាំងពលកម្ម | 8 260 000 |
| អត្រាចូលរួមកម្លាំងពលកម្ម | 82.6 ភាគរយ (87.9 ភាគរយ ប្រុស/ 77.5 ភាគរយ ស្រី)<br>15 ទៅ 24 years: 71.6 ភាគរយ (73.8 ភាគរយ ប្រុស/69.1 ភាគរយ ស្រី)<br>**15** ទៅ **29** ឆ្នាំ**: 75.7** ភាគរយ |
| សមាមាត្រការងារនិងប្រជាពលរដ្ឋ | 77.8 ភាគរយ (81.4 ភាគរយ ប្រុស/74.7 ភាគរយ ស្រី)<br>**15**ទៅ**29** ឆ្នាំ**: 74.1** ភាគរយ<br>ទីក្រុង : 67.7 ភាគរយ |

| | |
|---|---|
| | ជនបទ : 80.8 ភាគរយ |
| កម្លាំងពលកម្មតាមផ្នែក | កសិកម្ម: 48.7 ភាគរយ<br>ឧស្សាហកម្ម : 19.9 ភាគរយ<br>សេវាកម្ម: 31.5 ភាគរយ (2013) |
| អាត្រាកំណើត | 23.4 ផ្តល់កំណើត ក្នុងចំណោមប្រជាជន 1,000 នាក់ |
| អត្រាមរណភាព | 7.6 ស្លាប់ ក្នុងចំណោមប្រជាជន 1,000 នាក់ |
| អាយុជាមធ្យមរបស់ម្តាយពេលមានកូនដំបូង | 23 ឆ្នាំ |
| អត្រាមរណភាពរបស់ទារក | សរុប : 48.7 ស្លាប់/1,000 រស់<br>ប្រុស : 55.2 ស្លាប់/1,000 រស់<br>ស្រី : 41.9 ស្លាប់/1,000 រស់ |
| អាយុកាលកំណើត | សរុប: 64.5 ឆ្នាំ<br>ប្រុស: 62 ឆ្នាំ<br>ស្រី: 67.1 ឆ្នាំ |
| អត្រាបន្តពូជសរុប | 2.56 កុមារកើត / ស្ត្រី |
| អត្រាពន្យារកំណើត | 50.5 ភាគរយ (2011) |
| មេរោគអេដស៍ / ជំងឺអេដស៍ | អត្រារាតត្បាតលើមនុស្សពេញវ័យ: 0.63 ភាគរយ<br>អ្នករស់មានមេរោគអេដស៍ / ជំងឺអេដស៍: 74 100<br>អ្នកស្លាប់: 2 000 |
| ផលិតផលក្នុងស្រុកសរុប | USD 19.37 ពាន់លាន (អត្រាប្តូរប្រាក់ផ្លូវការឆ្នាំ 2015) |
| ផលិតផលក្នុងស្រុកសរុបក្នុងម្នាក់ | USD 1 218 |
| អត្រាកំណើនផលិតផលក្នុងស្រុកសរុបពិតប្រាកដ | 7 ភាគរយ<br>7.3 ភាគរយ (2016-20 ការព្យាករជាមធ្យម) |
| សមាសភាពផលិតផលក្នុងស្រុកសរុបតាមវិស័យ | កសិកម្ម: 26.7 ភាគរយ<br>ឧស្សាហកម្ម : 29.8 ភាគរយ<br>សេវាកម្ម: 43.5 ភាគរយ |
| សមាសភាពនៃការនាំចេញ | វាយនភណ្ឌ: 71 ភាគរយ<br>ការដឹកជញ្ជូន: 4 ភាគរយ<br>គ្រឿងម៉ាស៊ីន / អគ្គិសនី: 4 ភាគរយ<br>ផលិតផលបន្លែ: 4 ភាគរយ<br>ផលិតផលរ៉ែ: 1 ភាគរយ<br>ផ្សេងៗ 16 ភាគរយ |
| សមាសភាពនៃការនាំចូល | វាយនភណ្ឌ: 27 ភាគរយ<br>គ្រឿងម៉ាស៊ីន / អគ្គិសនី: 14 ភាគរយ |

| | |
|---|---|
| | ផលិតផលរ៉ែ: 14 ភាគរយ<br>ការដឹកជញ្ជូន: 8 ភាគរយ<br>សារធាតុគីមីនិងសម្ព័ន្ធឧស្សាហកម្ម: 5 ភាគរយ<br>ផ្សេងៗ: 32 ភាគរយ |
| សន្ទស្សន៍ការអភិវឌ្ឍមនុស្ស | 143 ក្នុងចំណោម 188<br>លើសមីយ៉ាន់ម៉ា (148), ក្រោមវៀតណាម (116) និងឡាវ (141) |

***ប្រភព៖*** *CIA ឆ្នាំ 2015 និងការប៉ាន់ស្មានឆ្នាំ 2016; ស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជា (CSES) ឆ្នាំ 2014; ស្ទង់មតិលើការផ្លាស់ប្តូរពីសាលាទៅការងារ (SWTS) នៅកម្ពុជាឆ្នាំ 2014; OECD ឆ្នាំ 2016; UNDP ឆ្នាំ 2015 ។*

***ចំណាំ៖*** *តួលេខទាំងអស់គឺសម្រាប់ឆ្នាំ 2014 ឆ្នាំ 2015 ឬឆ្នាំ 2016, លើកលែងតែពេលបញ្ជាក់។*

**សេចក្តីសង្ខេប**

# សេចក្ដីសង្ខេប

នៅក្នុងព្រះរាជាណាចក្រកម្ពុជា យុវជនមានចំនួនប្រហែលមួយភាគបីនៃប្រជាជនសរុប។ ចំនួនយុវជនដ៏ច្រើនបែបនេះគឺជាតំណាងឱ្យភាគលាភដែលបានមកពីប្រជាសាស្ត្រ និងអាចនាំឱ្យមានកំណើនសេដ្ឋកិច្ចនិងកំណែទម្រង់នានា ប្រសិនបើគោលនយោបាយត្រឹមត្រូវ ។ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាកំពុងតែរីកចម្រើន ហើយឱកាសសម្រាប់ផ្ដល់សិទ្ធិអំណាចដល់យុវជនគឺមានយ៉ាងពិតប្រាកដ។ ទោះជាយ៉ាងណា យុវជនបានប្រឈមមុខនឹងបញ្ហាជាច្រើន។ យោងតាម សូចនាករនៃការបាត់បង់ពហុវិមាត្រ (Youth Multi-dimensional Deprivation Indicator ហៅកាត់ថា Y-MDI) បានឱ្យដឹងថា នៅក្នុងពេលតែមួយ យុវជនម្នាក់ក្នុងចំណោម 5 នាក់ បានបាត់បង់ធាតុសំខាន់ពីរ ឬច្រើន ដែលធាតុទាំងនោះគឺជាពហុវិមាត្រនៃសុខុមាលភាព រួមមាន សុខភាព ការងារ ការអប់រំ និងការចូលរួមក្នុងសកម្មភាពសង្គម ខណៈដែលយុវជន 40 ភាគរយ ផ្សេងទៀតមានធាតុមួយខ្សោយ យ៉ាងហោចណាស់។ ការពិនិត្យមើលគោលនយោបាយសុខមាលភាពរបស់យុវជនកម្ពុជាផ្ដោតលើស្ថានភាពយុវជនក្នុងវិស័យទាំង4នេះ ក្នុងគោលបំណងផ្ដល់អនុសាសន៍គោលនយោបាយដែលនឹងជួយលើកកម្ពស់ជីវភាពរបស់យុវជន។

ជាទូទៅ ស្ថានភាពសុខភាពរបស់យុវជនបានប្រសើរឡើងចាប់តាំងពីឆ្នាំ 2015 ។ អត្រាមរណភាពរបស់យុវជនបានថយចុះចំនួន 40 ភាគរយ ហើយអត្រាមរណភាពរបស់មាតាវ័យក្មេងបានថយចុះចំនួន 53 ភាគរយ ក្នុងចន្លោះឆ្នាំ2005 និង2015 ។ ចំនួនអ្នកស្លាប់បណ្ដាលមកពីការឆ្លងមេរោគអេដស៍ ឬជំងឺអេដស៍បានថយចុះចំនួន 86 ភាគរយ ក្នុងរយៈពេលដូចគ្នា។ ផ្ទុយទៅវិញ មូលហេតុឈានមុខដែលបណ្ដាលឱ្យយុវជនទទួលមរណភាព គឺគ្រោះថ្នាក់ចរាចរណ៍ដែលមានចំនួនជិតមួយភាគបួន នៃយុវជនដែលបានស្លាប់ គឺកើនឡើង 10 ភាគរយ ចាប់តាំងពីឆ្នាំ 2005 មក។ ការប្រើប្រាស់គ្រឿងស្រវឹងក្នុងចំណោមយុវជន ជាពិសេសក្មេងប្រុសកំពុងកើនឡើងផងដែរ ដែលកត្តានេះជំរុញឱ្យមានគ្រោះថ្នាក់ចរាចរណ៍។ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជគឺជាក្ដីបារម្ភ ពិសេសសម្រាប់កុមារីវ័យជំទង់ និងស្ត្រីវ័យក្មេង។ ការមានគភ៌ក្នុងវ័យជំទង់ (អាយុពី 15 ទៅ19 ឆ្នាំ) ប៉ះពាល់ស្ត្រីជាម្ដាយចំនួន 12 ភាគរយ បើទោះបីជាភាគច្រើននៃករណីទាំងនេះ ស្ត្រីជាម្ដាយមានអាយុចន្លោះពី 18 និង 19 ឆ្នាំ ក៏ដោយ។ អត្រាមានកូនរបស់ស្ត្រីវ័យជំទង់នៅក្នុងតំបន់ជនបទខ្ពស់ជាងទីក្រុងបីដង និងយ៉ាងហោចណាស់ក៏ខ្ពស់ជាងមួយដងកន្លះដែរចំពោះស្ត្រីមានអាយុពី 20 ទៅ 24 ឆ្នាំ ដែលរស់នៅតាមតំបន់ជនបទ។ ជាទូទៅ ជំងឺកាមរោគក្នុងចំណោមស្ត្រីវ័យក្មេង(អាយុពី 15 ទៅ 24ឆ្នាំ) មានច្រើនជាងបុរសវ័យក្មេង និងកំពុងមាននិន្នាការកើនឡើងផងដែរសម្រាប់ក្រុមនេះ។ ការបោះបង់ការសិក្សានៅបឋមសិក្សាគឺប្រហែលជាបញ្ហាធំបំផុតមួយដែលកម្ពុជាកំពុងប្រឈម នៅឆ្នាំ 2016 សិស្សដែលមានអាយុរៀនមធ្យមសិក្សា និងឧត្តមសិក្សាចំនួន 63 ភាគរយ (អាយុពី 12 ដល់ 22 ឆ្នាំ) បានបោះបង់ចោលការសិក្សា។ ផលលំបាកនៅដំណាក់កាលនេះមានជាច្រើនរាប់ចាប់តាំងពី គុណភាពនៃការអប់រំ តម្លៃឱកាសនៃការអប់រំផ្ដល់ដោយគ្រួសារក្រីក្រ កម្រិតនៃក្ដីរំពឹងចំពោះការងារល្អក្រោយពីរៀនចប់មធ្យមសិក្សា ឬឧត្តមសិក្សា និងការខ្វះខាតនៃឱកាសចូលរៀនជាលើកទីពីរ ឬកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈប្រកបដោយគុណភាព។ ទោះបីវាជាកាតព្វកិច្ចក៏ដោយ ក៏អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅបឋមភូមិមានត្រឹមតែ 39 ភាគរយ និង 19 ភាគរយ ប៉ុណ្ណោះនៅវិទ្យាល័យ។ អត្រាបោះបង់ការសិក្សានៅបឋមភូមិគឺជិត 20 ភាគរយ ហើយនៅតែមិនផ្លាស់ប្ដូរតាំងពីឆ្នាំ2010 មក។ យុវជននៅក្រៅសាលាដ៏ច្រើននេះត្រូវការអប់រំ ឬបណ្ដុះបណ្ដាលដើម្បីស្វែងរកការងារសមរម្យ និងដែលមានផលិតភាព ។ កត្តាជំរុញឱ្យមានការបោះបង់ការសិក្សានេះមានភាពស្មុគស្មាញ និងមានច្រើន រាប់ចាប់តាំងពីតម្លៃទាបដែលឪពុកម្ដាយមើលឃើញក្នុងការវិនិយោគនៅក្នុងវិស័យអប់រំ ដោយសារតែគុណភាពអប់រំនៅខ្សោយ។ យុវជនកម្ពុជាខ្លួនឯងមានគំនិតទុទ្ទិដ្ឋិនិយមអំពីផលដែលបានមកពី ការវិនិយោគក្នុងវិស័យអប់រំសារជាថ្មី។ ជាការពិតណាស់ សម្រាប់ការងារជំនាញទាបមួយចំនួន អ្នកបោះបង់ការសិក្សានៅបឋមសិក្សាអាចរកប្រាក់ចំណូលបានច្រើនជាងនិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់ខ្ពស់ទៅទៀត។ សម្រាប់គ្រួសារក្រីក្រផលដែលបានមកពីការងារមានប្រាក់ខែភ្លាមៗគឺមានតម្លៃច្រើនជាងការវិនិយោគនៅក្នុងវិស័យអប់រំ។ សញ្ញាបត្រដែលអាចទទួលបានប្រាក់ខែសមរម្យគឺចាប់ពីកម្រិតឧត្តមសិក្សានិងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈឡើងទៅ ប៉ុន្តែយុវជនភាគច្រើនបានចាកចេញពីសាលាមុនពេលពួកគេបានបញ្ចប់កម្រិតមធ្យមសិក្សាបាត់ទៅហើយ។ គុណភាពសិក្សានៅតាមសាលារៀនមិនអាចជួយបានដោយ សារតែការពិតថា គ្រូបង្រៀននាពេលបច្ចុប្បន្ននៅមានចំណេះដឹងមិនទាន់ទូលំទូលាយ និងមានប្រាក់ខែនៅទាប។ មានការលើកទឹកចិត្ត និងពេលវេលាតិចតួចសម្រាប់គ្រូបង្រៀនបន្តវិនិយោគក្នុងការបណ្ដុះបណ្ដាល និងបង្កើនជំនាញរបស់ខ្លួន ដោយសារពួកគេភាគច្រើនជាប់រវល់ជាមួយការងារទីពីរ និងបង្រៀនឯកជន។

ការទទួលបានការអប់រំទាបក្នុងចំណោមយុវវ័យធ្វើឱ្យភាពខ្វះជំនាញក្លាយជាបញ្ហាប្រឈមដ៏គួរឱ្យខ្លាចសម្រាប់ទីផ្សារការងារ។ និយោជកមិនអាចស្វែងរកកម្មករដែលមានសមត្ថភាពដើម្បីបំពេញតំណែងប្រកាស។ នៅក្នុងប្រទេសកម្ពុជា មានយុវជនតែ 31 ភាគរយ ប៉ុណ្ណោះ ដែលមានការងារដែលសមស្របនឹងគុណវុឌ្ឍិរបស់ពួកគេ ខណៈដែល 23 ភាគរយ មានការងារខ្ពស់ជាងគុណវុឌ្ឍិ និង 46 ភាគរយ មានការងារទាបជាងគុណវុឌ្ឍិ។ ការងារទាបជាងគុណវុឌ្ឍិគឺជាបញ្ហាធ្ងន់ធ្ងរនៅក្នុង
វិស័យឧស្សាហកម្មពោលគឺ 64 ភាគរយ នៃយុវជនមានការងារទាបជាងគុណវុឌ្ឍិ។ សក្ដានុពលនៃការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការអប់រំក្រៅប្រព័ន្ធគេត្រូវគេឱ្យតម្លៃមិនដល់។ ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សាមធ្យមសិក្សាចំនួន 250.000 នាក់ក្នុងឆ្នាំ 2014 មានតែ 3ភាគរយ ប៉ុណ្ណោះ ដែលសិក្សាវិស័យបច្ចេកទេស និងវិជ្ជាជីវៈ ដូចជា កសិកម្ម វិទ្យាសាស្ត្រ និងវិស្វកម្ម។ គុណវុឌ្ឍិខាងទាបក៏ប៉ះពាល់ដល់ស្ត្រីច្រើនជាងបុរសដែរ។ ស្ត្រីអាចចូលរួមការបណ្ដុះបណ្ដាលវិជ្ជាជីវៈមួយចំនួនដូចជាកាត់ដេរ ចម្អិនអាហារ និងមេកានិច ប៉ុន្តែវាមានឥទ្ធិពលតិចតួចទៅលើការផ្ដល់សិទ្ធិអំណាចដល់ស្ត្រី។

ទោះបីជាអត្រាយុវជនគ្មានការងារធ្វើទាបស្មើនឹង 0.7 ភាគរយ និងមានកំណើនយុវជនមាន ការងារធ្វើមានប្រាក់ខែក៏ដោយ ក៏គុណភាពការងារនៅក្នុងប្រទេសនេះនៅមានកម្រិតទាបនៅឡើយ។ យុវជនភាគច្រើន (73 ភាគរយ) ដែលមានការងារធ្វើរកប្រាក់ចំណូលបានតិចជាងប្រាក់ឈ្នួលមធ្យមប្រចាំសប្ដាហ៍។ ចំនួននៃយុវជនដែលស្ថិតក្នុងប្រភេទការងារងាយរងគ្រោះ (កម្មករគ្រួសារគ្មានប្រាក់ខែ និងកម្មករគណនីផ្ទាល់ខ្លួន) បានថយចុះចំនួន 40 ភាគរយ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប៉ុន្តែអត្រា 40 ភាគរយនេះ នៅតែជាទូរលេខដែលមិនគួរធ្វេសប្រហែស។ យុវជនអាយុពី 15 ទៅ 29 ឆ្នាំ ដែលមិនមានការងារធ្វើ មិនបានទទួលការអប់រំ ឬការបណ្ដុះបណ្ដាល (Neither in Employment nor in Education or Training ដែលហៅកាត់ថា NEET) គឺមានចំនួនទាបរៀងគ្នា។ NEET ដែលអសកម្មមានប្រហែល 6,4 ភាគរយ ។ ភាគច្រើននៃ NEETs គឺអសកម្ម ឧទាហរណ៍៖ មិនកំពុងស្វែងរកការងារធ្វើ និងមិនកំពុងរៀន ភាគច្រើនគឺជាស្ត្រី។ ស្ត្រីវ័យក្មេងច្រើនជួបការលំបាកក្នុងទីផ្សារការងារ បើធៀបទៅនឹងបុរសវ័យក្មេង។

បទដ្ឋានសង្គមប្រពៃណីទាក់ទងនឹងតួនាទីស្ត្រីនៅក្នុងគ្រួសារ និងសង្គមនៅតែមិនទាន់បានផ្លាស់ប្ដូរនៅឡើយ ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល។ គេនៅតែរំពឹងថា ស្ត្រីត្រូវទទួលខុសត្រូវជាច្រើនលើអម្រែកគ្រួសារ និងការថែទាំកូនចៅ ដោយមិនគិតពីស្ថានភាពការងាររបស់ពួកគេបែបណានោះទេ។ ការងារក្នុងផ្ទះនៅតែមិនទាន់បានបែងចែកឱ្យស្មើគ្នារវាងបុរសនិងស្ត្រី ដែលធ្វើឱ្យស្ត្រីជួបការលំបាកយ៉ាងខ្លាំង។ បទដ្ឋានសង្គមទាក់ទងតួនាទីស្ត្រីជា "***ប្រពន្ធល្អ***" ក៏ជាឧបសគ្គរាំងស្ត្រីមិនឱ្យចេញឆ្ងាយពីផ្ទះដើម្បីទទួលបានការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឬបន្តការអប់រំ និងទៅធ្វើការនៅក្រៅសហគមន៍របស់ពួកគេដែរ។ ជំនឿនេះមានជាក់ស្ដែង ជាពិសេសនៅក្នុងចំណោមស្ត្រីវ័យក្មេងដែលគ្មានការងារធ្វើ និងស្ត្រីវ័យចំណាស់នៅសហគមន៍ជនបទ។

យុវជនគឺជាកម្លាំងជំរុញយ៉ាងសំខាន់ក្នុងការអភិវឌ្ឍកម្ពុជា ហើយការចូលរួមរបស់ពួកគេនៅក្នុងដំណើរការបង្កើតគោលនយោបាយរឹតតែសំខាន់ទៅទៀត។ ការចូលរួមរបស់គេក្នុងនយោបាយ ឬការបង្កើតគោលនយោបាយនៅមានកម្រិតនៅឡើយ។ ការរួមសហការជាមួយរាជរដ្ឋាភិបាលមានតែនៅក្នុងអង្គការធំពីរ ឬបី ដែលមានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាល ដូចជា សហភាពសហព័ន្ធយុវជនកម្ពុជា (Union of Youth Federations of Cambodia ហៅកាត់ថា ស.ស.យ.ក. )។ ប៉ុន្តែទោះជាយ៉ាងណា ការរីករាលដាលយ៉ាងឆាប់រហ័សនៃការប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមនៅក្នុងចំណោមយុវជនកម្ពុជាបានធ្វើឱ្យឆាកនយោបាយមានការផ្លាស់ប្ដូរ។ យុវជនទទួលបានព័ត៌មានប្រសើរជាងមុន និងមានសិទ្ធិបញ្ចេញមតិច្រើនជាងមុន។ ការងារស្ម័គ្រចិត្តក៏កំពុងបានក្លាយជានិន្នាការពេញនិយម ព្រោះត្រូវបានគេចាត់ទុកថា ផ្ដល់អត្ថប្រយោជន៍ទាំងសហគមន៍ និងទាំងអ្នកស្ម័គ្រចិត្តដែលទទួលបានជំនាញទន់ដែលដែលចាំបាច់សម្រាប់កន្លែងធ្វើការងារ។

ការធ្វើកំណែទម្រង់គោលនយោបាយសម្រាប់សុខុមាលភាពយុវជននឹងត្រូវធ្វើឡើងជាច្រើនផ្នែកដូចជា៖

- **ផ្នែកសុខភាព**៖ គួរតែផ្ដល់អាទិភាពលើការកែលម្អសេវាសុខភាពផ្លូវភេទ និងបន្តពូជ (Sexual and Reproductive Health ហៅកាត់ថា SRH) សម្រាប់

យុវជន ជាពិសេសនៅតាមតំបន់ជនបទ។ គួរមានសេវាសុខភាពយុវជនងាយស្រួល និងគ្លីនិកយេនឌ័រ។ ការអប់រំ SRH គួរត្រូវបានអនុវត្តនៅតាមសាលារៀន និងសហគមន៍ដើម្បីយកឈ្នះបទដ្ឋានសង្គមរើសអើងយេនឌ័រដែលរារាំងយុវជនក្នុងការស្វែងរកការព្យាបាលជំងឺកាមរោគ (Sexually Transmitted Infection ហៅកាត់ថា STI) ។

- **ផ្នែកអប់រំ៖** គុណភាពនៃការអប់រំ និងអត្រាបញ្ចប់ការសិក្សាចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងជាងនេះ។ ការលុបបំបាត់ឧបសគ្គខាងសេដ្ឋកិច្ចដែលប៉ះពាល់ដល់ការចូលរៀនត្រូវតែកំណត់ជាអាទិភាពតាមរយៈកម្មវិធីដូចជាការផ្ទេរសាច់ប្រាក់តាមលក្ខខណ្ឌ។ គុណភាព នៃការអប់រំ ត្រូវធ្វើឱ្យប្រសើរឡើងតាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀនបច្ចុប្បន្ន និងផ្តល់ប្រាក់ខែប្រសើរជាងមុនជាការលើកទឹកចិត្ត ជាពិសេសសម្រាប់អ្នកដែលបង្រៀននៅតំបន់ដាច់ស្រយាល។ មធ្យោបាយទៅសាលារៀនក៏ជាឧបសគ្គមួយដល់កុមារដែលរស់នៅក្នុងតំបន់ជនបទដាច់ស្រយាលដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រសើរជាងមុន។ សម្រាប់តំបន់កសិកម្ម កូនៗជាអ្នកជួយកំឡុងរដូវច្រូតកាត់។ ដូចនេះកម្មវិធីសិក្សាគួរពិចារណាអំពីរដូវកាលនៃសកម្មភាពកសិកម្មផងដែរ។ ផ្នែកការងារ បញ្ហាមិនស្របនៃជំនាញត្រូវដោះស្រាយតាមរយៈការបណ្តុះបណ្តាលនៅកន្លែងការងារឬតាមរយៈកម្មវិធីអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (Technical Vocational Education and Training ហៅកាត់ថា TVET) ដែលអាចបត់បែន ដែលអាចអនុញ្ញាតឱ្យសិស្សសិក្សាផងធ្វើការផង។ គួរផ្តល់កម្មវិធីឱកាសទីពីរ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានច្រើនដល់យុវជននៅក្រៅសាលា និងយុវជនមិនសូវមានជំនាញ ដែលគេឃើញមានច្រើននៅកម្ពុជា។ ក្រុមយុវជននេះត្រូវការជំនាញគ្រប់គ្រាន់ដើម្បីអាចស្វែងរកការងារសមរម្យ។
- **ផ្នែកការងារ៖** បញ្ហាពាក់ព័ន្ធនឹងភាពមិនស្របគ្នានឹងជំនាញត្រូវដោះស្រាយតាមរយៈការបណ្តុះបណ្តាលនៅកន្លែងការងារ ឬតាមរយៈកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (Technical Vocational Education and Training ហៅកាត់ថា TVET) ដែលអាចបត់បែនបាន និងអាចអនុញ្ញាតឱ្យសិស្សសិក្សាផងធ្វើការផង។ ដោយសារយុវជនភាគច្រើនធ្វើការងារនៅក្នុងវិស័យក្រៅផ្លូវការ ដូច្នេះ គួរតែមានទម្រង់បែបបទមួយដែលបញ្ជាក់ពីបទពិសោធន៍កន្លងមក ព្រោះទម្រង់នេះអាចជួយយុវជនឱ្យមានសុពលភាពនៅក្នុងកែវភ្នែកនិយោជក។ ការពិនិត្យឡើងវិញកាន់តែស៊ីជម្រៅអំពីប្រព័ន្ធ TVET និងប្រសិទ្ធភាពនៃកម្មវិធីបច្ចុប្បន្នត្រូវការជាបន្ទាន់ដើម្បីសម្របសម្រួលជាមួយនឹងការបណ្តុះបណ្តាលវិស័យថ្មីៗ ដូចជាឧស្សាហកម្មកសិផល សេវាកម្ម និងទេសចរណ៍ និងតម្រូវការសហគ្រាសខ្នាតតូច និងមធ្យម។ គួរកំណត់ការបណ្តុះបណ្តាលណាដែលវិស័យឯកជនត្រូវការ និងវិធីសាស្ត្រដែលយុវជនអាចចូលរួមក្នុងអាជីវកម្មក្នុងតំបន់។
- ជាចុងក្រោយ សកម្មភាពសង្គមក៏គួរតែបញ្ចូលជាផ្នែកមួយនៃកម្មវិធីសិក្សាទៀងទាត់ និងរៀបចំយុទ្ធនាការដើម្បីបង្កើនការយល់ដឹងអំពីរបៀបដែលយុវជនអាចទទួលបានព័ត៌មាន និងចូលរួមក្នុងសកម្មភាពសង្គមកាន់តែច្រើន។ ការពិភាក្សាដេញដោលបើកទូលាយ និងបរិយាប័ន្នយុវជនជាផ្លូវការគួរបង្កើតឱ្យបានច្រើនឡើងដើម្បីឱ្យយុវជនបានចូលរួមនៅក្នុងការធ្វើការសម្រេចចិត្តនានា ដូចជាមានតំណាងយុវជននៅក្នុងសភាជាតិ ឬក្រុមប្រឹក្សាអភិវឌ្ឍន៍មូលដ្ឋាន ។ តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម យុវជនអាចមានឱកាសចូលរួមក្នុងកិច្ចពិភាក្សានយោបាយដោយចំហ។ សេរីភាពនៃការបញ្ចេញមតិគួរតែត្រូវបានគោរពដើម្បីឱ្យយុវជនអាចបញ្ចេញមតិរបស់ពួកគេដោយគ្មានការភ័យខ្លាចចំពោះការដាក់ទណ្ឌកម្ម។ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងក្រមសីលធម៌នៃការប្រើប្រាស់អ៊ីនធើណិតគួរតែត្រូវបានកំណត់តាមរយៈច្បាប់ច្បាស់លាស់ និងបទបញ្ញាដើម្បីឱ្យយុវជនអាចចូលរួមដោយសេរី និងគោរព។
- គោលនយោបាយត្រូវតែធ្វើការពិចារណាពិសេសសម្រាប់យុវជននៅតាមជនបទ និងស្ត្រីវ័យក្មេង ព្រោះ យុវជនជាង 80 ភាគរយ រស់នៅក្នុងតំបន់ជនបទនិងភាគច្រើនធ្វើការងារក្នុងវិស័យកសិកម្ម។ សក្តានុពលក្នុងការអភិវឌ្ឍវិស័យកសិកម្មតាមបណ្តោយខ្សែសង្វាក់កសិកម្មនេះគឺមានតម្លៃខ្ពស់។ ជាដំបូង គួរតែកែលម្អផលិតភាពកសិកម្មឱ្យប្រសើរឡើងដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករ។ តំបន់ជនបទត្រូវការហេដ្ឋារចនាសម្ព័ន្ធប្រសើរជាងមុន ដូចជា ធារាសាស្ត្រ និងបច្ចេកទេសផលិតកម្ម ហើយកសិករវ័យក្មេងគួរតែត្រូវបានបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍជំនាញអាជីវកម្ម និងទីផ្សារ។ សេវាការងារគួរគាំទ្រដល់សហគ្រិនវ័យក្មេងក្នុងតំបន់ជនបទដើម្បីលើកទឹកចិត្តក្នុងការបង្កើតផលិតផល និងសេវាកម្មតម្លៃបន្ថែមថ្មីៗតាមខ្សែសង្វាក់តម្លៃកសិ-អាហារ។ លទ្ធភាពទទួលបាននូវការគាំពារផ្នែកហិរញ្ញវត្ថុ និងសង្គមគឺពិតជាមានសំខាន់ខ្លាំងណាស់ក្នុងការជំរុញឱ្យយុវជននៅតាមជនបទបានក្លាយជាសហគ្រិន។ ការងារខ្នាតតូចនិងមធ្យម (SME) ក្នុងតំបន់មានសក្តានុពលបំផុតក្នុងការបង្កើតការងារសម្រាប់យុវជន។ ការអភិវឌ្ឍរបស់ពួកគេនៅក្នុងវិស័យកសិកម្ម និងសេវាកម្មគួរតែត្រូវបានលើកកម្ពស់។
- ម្យ៉ាងទៀតស្ត្រីវ័យក្មេងគួរតែទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់បន្ថែមទៀតទាក់ទិននឹងខ្ចីមសារ និងការចូលក្នុងសហគ្រិនភាព ការគ្រប់គ្រងអាជីវកម្ម ឬជំនាញកសិកម្មចម្រុះបន្ថែមទៀតដើម្បីបង្កើនផលិតភាព។ ទាំងនេះគួរតែអមដោយយន្តការគាំទ្រដូចជា ការថែទាំកូនប្រចាំថ្ងៃ និងការគាំពារសង្គមជាមូលដ្ឋាន ដើម្បីឱ្យស្ត្រីអាចបែងចែកពេលវេលារបស់ខ្លួនរវាងការងារនិងគ្រួសារ។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (National Youth Development Policy ហៅកាត់ថា NYDP) ដែលមានផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (National Youth Action Plan ហៅកាត់ថា NYAP) ផងនោះគឺអាចឆ្លុះបញ្ចាំងនូវការចូលរួមក្នុងនយោបាយថ្មី ដើម្បីបញ្ចូល និងជំរុញយុវជនឱ្យចូលរួមក្នុងវិស័យអាទិភាពផ្សេងៗ ។

ទាក់ទងនឹងការពង្រឹងស្ថាប័ន:

- NYDP ចាំបាច់ត្រូវមានថវិកាគ្រប់គ្រាន់ ហើយស្ថាប័នត្រូវមានសមត្ថភាពអនុវត្តផែនការសកម្មភាពនេះ។ ថវិកាជាតិប្រចាំឆ្នាំគួរបញ្ចូលថវិកាសម្រាប់ការអនុវត្តកម្មវិធី NYAP ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (National Youth Development Council ហៅកាត់ថា ក.ជ.យ.) និងអគ្គលេខាធិការដ្ឋានដែលទើបបង្កើតថ្មីគួរតែកៀរគរជំនួយបច្ចេកទេសពីគួរដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីជួយជំរុញឱ្យមានការកែលម្អ និងអនុវត្តឯកសារច្បាប់ និងគោលនយោបាយមូលដ្ឋានផ្សេងៗ ដូចជា ផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) តាមក្រសួងខ្សែបណ្តោយ ។ ការធ្វើស្ថាប័នភាវូបនីយកម្ម និងប្រតិបត្តិកម្មនៃ ក.ជ.យ. អាចទទួលបានជោគជ័យទៅបាន វាអាស្រ័យលើការចូលរួមចំណែកពីក្រសួងខ្សែបណ្តោយ និងអង្គការយុវជនធំៗ។ តំណាងយុវជននៅក្នុង ក.ជ.យ. មកពីសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) សម្រាប់ពេលបច្ចុប្បន្ន។ ចំណុចនេះនៅក្នុងភ្នែករបស់យុវជនគឺជាបញ្ហាស្របច្បាប់របស់ ក.ជ.យ.។
- ក.ជ.យ. បច្ចុប្បន្នស្ថិតនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា (អយក.) ។ ក.ជ.យ. គួរតែស្វែងរកឋានៈឯករាជ្យមួយ ដើម្បីធានាតួនាទីសម្របសម្រួលដោយមិនលម្អៀងក្នុងចំណោមអ្នកពាក់ព័ន្ធផ្សេងៗ។ គួរមាននីតិវិធីទំនាក់ទំនងរដ្ឋបាលផ្ទៃក្នុង និងខាងក្រៅយ៉ាងច្បាស់លាស់រវាងរាជរដ្ឋាភិបាល ថ្នាក់ក្រសួង និងថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- គួរពង្រឹងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន ក.ជ.យ.។ លេខាធិការដ្ឋានគួរមានលទ្ធភាពត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត NYAP ។ គួររៀបចំប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ (M & E system) ដែលមានសូចនាករជាក់លាក់របស់យុវជនសម្រាប់ NYAP ។
- គួររៀបចំឱ្យមានការពិគ្រោះជាទៀងទាត់ជាមួយយុវជន។ ការចូលរួមរបស់យុវជនកើតមានជាសំខាន់នៅថ្នាក់មូលដ្ឋាន។ ក.ជ.យ. គួរតែបង្កើតយន្តការពិគ្រោះយោបល់មួយជាមួយយុវជនដូចជាកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្តប្រចាំត្រីមាស ការពិគ្រោះពិភាក្សាប្រចាំតំបន់រយៈពេល 6 ខែម្តង និងសន្និបាតយុវជនជាតិប្រចាំឆ្នាំដូចមាននៅក្នុង NYDP។

# ជំពូកទី ១៖ របាយការណ៍យុវជនកម្ពុជា

## ជំពូកទី ១:

## របាយការណ៍យុវជនកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសមួយដែលសម្បូរទៅដោយធនធានយុវជន។ ពីរភាគបីនៃប្រជាជន ចំនួន 15 លាននាក់ នៃប្រទេសនេះ គឺជាយុវជនដែលមានអាយុក្រោម 30 ឆ្នាំ (យោងតាមការប៉ាន់ប្រមាណរបស់អង្គការសហប្រជាជាតិ ឆ្នាំ2013) ។ នេះតំណាងឱ្យភាគលាភប្រជាសាស្រ្តដែលអាចនាំឱ្យមានកំណើនសេដ្ឋកិច្ចសង្គម និងកំណែទម្រង់។ ភាគលាភប្រជាសាស្រ្តកើតឡើងនៅពេលដែលចំនួនសរុប នៃអត្រាកំណើតទាប និងអត្រាមរណភាពទាប ដែលនាំឱ្យមានកំណើនប្រជាជន និងយុវជនពេញអាយុធ្វើការ។ ដើម្បីទាញយកផលប្រយោជន៍ពីឱកាសនេះ ចាំបាច់ត្រូវមានគោលនយោបាយទូលំទូលាយនិងយុទ្ធសាស្រ្ត ដើម្បីផ្តល់លទ្ធភាពឱ្យយុវជនទទួលការអប់រំប្រកបដោយគុណភាព និងការងារល្អ ត្រូវបង្កើនជំនាញរបស់ពួកគេ និងត្រូវផ្តល់សេវាថែទាំសុខភាពងាយស្រួលដល់ពួកគេ។ ការខកខានមិនបានធ្វើដូច្នេះនឹងធ្វើឱ្យភាគលាភនេះក្លាយទៅជាចំណាយសេដ្ឋកិច្ចសង្គមដែលមិនអាចរ៉ែកពុនបាន និងអូសបន្លាយពេលយូរអង្វែង។ ដោយសារតែកម្ពុជាឈានចូលក្នុងសង្គមមួយដែលមានវ័យចំណាស់ មនុស្សដែលកំពុងកើនឡើងនេះនឹងពឹងផ្អែកទាំងស្រុងលើសមាជិកគ្រួសារ និងធនធានសាធារណៈដែលកំពុងខ្វះខាតស្រាប់។ ស្ថានភាពនេះទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ថាតើយុវជនកម្ពុជាកំពុងតែរីកចម្រើនប៉ុណ្ណា ផ្អែកលើទំហំខុសគ្នានៃសុខមាលភាព ដូចជា វិស័យអប់រំ ការងារ សុខភាព និងការចូលក្នុងសង្គម និងដើម្បីកំណត់នូវគម្លាតក្នុងគោលនយោបាយសម្រាប់យុវជន។

ទម្រង់នៃការវិភាគលើជំពូកនេះផ្អែកលើឧបករណ៍ដែលប្រើសម្រាប់បង្កើតគោលនយោបាយសុខុមាលភាពយុវជនរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD (the *Evidence-based Policy Making for Youth Well-being: A Toolkit* (យោងតាម OECD, 2017b)។ ឧបករណ៍នេះប្រើប្រាស់វិធីសាស្រ្តវដ្តជីវិត និងដាក់ចេញនូវទម្រង់នៃការវិភាគពហុវិមាត្រ (Multi-dimension) ដើម្បីពិនិត្យលើស្ថានភាពរបស់យុវជនតាមរយៈ ការអប់រំ សុខភាព ការងារ ការចូលរួមក្នុងសង្គម និងសុខុមាលភាព ដែលធាតុទាំង 5 នេះ ត្រូវបានចាត់ទុកថាជាគន្លឹះនៃសុខុមាលភាពរបស់យុវជន។ ការវិភាគនេះអាចរកឃើញទម្រង់នៃយុវជនដែលជួបការលំបាក និងដើម្បីបានយល់កាន់តែប្រសើរជាងមុននូវបុព្វហេតុនៃភាពងាយរងគ្រោះនិងលទ្ធផលអវិជ្ជមានដែលយុវជនកំពុងប្រឈម។ ដើម្បីធ្វើការប្រៀបធៀបឱ្យមានលក្ខណៈជាអន្តរជាតិ (គម្រោងពាក់ព័ន្ធនឹងយុវជនរបស់សហភាពអឺរ៉ុបនិងមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD បានអនុវត្តនៅក្នុងប្រទេសចំនួន១០) របាយការណ៍នេះនឹងពិនិត្យមើលទិន្នន័យនៃក្រុមយុវជនដែលមានអាយុពី 15ទៅ 29 ឆ្នាំ បើសិនជាអាច។ បើទោះបីជានិយមន័យរបស់អង្គការសហប្រជាជាតិគឺសំដៅលើក្រុមយុវជនដែលមានអាយុពី 15 ទៅ 24 ឆ្នាំក៏ដោយ ហើយព្រោះតែការវិភាគនេះប្រើវិធីសាស្រ្តវដ្តជីវិត ដូច្នេះក្រុមយុវជនដែលអាយុចន្លោះពី 15 ទៅ 29 ឆ្នាំ គឺជាក្រុមដែលអាចប្រមូលយកកត្តាដែលរាំងស្ទះ ឬកត្តាដែលអាចជួយឱ្យដំណើរផ្លាស់ប្តូរទៅវ័យចាស់របស់ពួកគេទទួលជោគជ័យ។ ផ្នែកតទៅនេះនឹងបង្ហាញពីទិដ្ឋភាព នៃស្ថានភាពយុវជនកម្ពុជាក្នុងវិស័យសុខាភិបាល ការងារ ការអប់រំ និងការចូលរួមក្នុងសកម្មភាពសង្គម (យោងតាម OECD, 2011) ។

### ១.១ ទិដ្ឋភាពទូទៅ

ពុំមាននិយមន័យនៃពាក្យ«**យុវជន**»ណាមួយដែលត្រូវបានគេកំណត់ជាសកលនោះទេ។ អង្គការសហប្រជាជាតិ (UN) កំណត់ថា យុវជនត្រូវមានអាយុពី 15ទៅ24 ឆ្នាំ ខណៈដែលសហភាពអាហ្វ្រិកកំណត់ថា ជាយុវជនត្រូវមានអាយុពី 15ទៅ35 ឆ្នាំ។ នៅក្នុងប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា (ហៅកាត់ថា អយក.) កំណត់ថា យុវជនត្រូវមានអាយុពី 15 ទៅ 30 ឆ្នាំ ទោះអ្នកនោះរៀបការរួចក៏ដោយ។ យុវជនគឺជារយៈពេលនៃការផ្លាស់ប្តូរទាំងរាងកាយ និងសង្គម ព្រោះថា មនុស្សម្នាក់ត្រូវតែឆ្លងពីកុមារភាពទៅវ័យចំណាស់។ រយៈពេលនេះគឺជារយៈពេលដែលងាយរងគ្រោះបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ ព្រោះថា នេះជាដំណាក់កាលនៃការរួមបញ្ចូលគ្នារវាងទំនួលខុសត្រូវដែលការកើនឡើងជាលំដាប់ ការសម្រេចចិត្តផ្លាស់ប្តូរជីវិត និងការកើនឡើងនូវ សម្ពាធសង្គម និងដៃគូដ៏លើសលុប។

នៅក្នុងប្រទេសកម្ពុជាយុវជន (15 ទៅ 30 ឆ្នាំ) មានចំនួនប្រហែល 33 ភាគរយ នៃចំនួនប្រជាជនសរុប (សូមមើល តារាង 1) ។ ភាគច្រើននៃយុវជនគឺ ជាជនជាតិខ្មែរ (96 ភាគរយ) និង 83 ភាគរយរស់នៅក្នុងតំបន់ជនបទ ដែលក្នុងនោះភាគច្រើនរស់នៅក្នុងតំបន់ជុំវិញបឹងទន្លេសាបនិងតំបន់វាលទំនាប។ ប្រជាជនសរុបនៅក្នុងទីក្រុងរាជធានីភ្នំពេញក្នុងឆ្នាំ 2004 និងឆ្នាំ 2014 បានការកើនឡើងចំនួន 19 ភាគរយដោយសារការវិវត្តប្រជាសាស្រ្ត និងនគរូបនីយកម្មផងដែរ។ យុវជននៅរាជធានីភ្នំពេញបានកើនឡើងចំនួន 57 ភាគរយ ។ ពួកគេភាគច្រើន (91 ភាគរយ) ចេះអក្សរ (យោងតាម CSES ឆ្នាំ2014) ប៉ុន្តែក្នុងចំណោមនេះមានតែ 28 ភាគរយ ប៉ុណ្ណោះដែលបានចុះឈ្មោះចូលរៀននៅកម្រិតមធ្យម (យោងតាម អយក. ឆ្នាំ 2016) ។ ពីរភាគបីនៃយុវជនបានបញ្ចប់ការសិក្សា ហើយមួយភាគបីកំពុងសិក្សា ប៉ុន្តែពាក់កណ្តាលនៃពួកគេធ្វើការងារផងរៀនផង (យោងតាម SWTS, ILO 2013)។

**តារាង 1 (1-1) ការពិពណ៌នាពីយុវជនកម្ពុជាដែលមានអាយុពី 15 ទៅ 30 ឆ្នាំ**

| **អាយុពី 15 ទៅ 30 ឆ្នាំ** | | **2004** | **2014** | **2004** | **2014** |
|---|---|---|---|---|---|
| | | **ចំនួន** | | **ភាគរយ** | |
| **ចំនួនប្រជាជន** | សរុប | 4 139 253 | 5 071 495 | 100.00 | 100.00 |
| | ប្រុស | 2 062 098 | 2 565 481 | 49.82 | 50.59 |
| | ស្រី | 2 080 966 | 2 510 332 | 50.27 | 49.50 |
| **ជាតិសាសន៍** | ខ្មែរ | 3 980 606 | 4 886 572 | 96.17 | 96.35 |
| | ជនជាតិភាគតិចផ្សេងៗ | 36 432 | 72 976 | 0.88 | 1.44 |
| | ផ្សេងៗ | 127 272 | 117 998 | 3.07 | 2.33 |
| **ជនពិការភាព** | ពិការ | 79 733 | 52 634 | 1.93 | 1.04 |
| | មិនពិការ | 4 058 738 | 5 013 257 | 98.05 | 98.85 |
| **ទីក្រុង / ជនបទ** | ទីក្រុង | | 862 154 | | 17.00 |
| | ជនបទ | | 4 209 341 | | 83.00 |
| **តំបន់** | ភ្នំពេញ | 439 280 | 690 580 | 10.61 | 13.62 |
| | ទំនាប | 1 752 604 | 1 754 526 | 42.34 | 34.60 |

| | | | | | |
|---|---|---|---|---|---|
| | ទន្លេសាប | 1 225 546 | 1 660 570 | 29.61 | 32.74 |
| | ឆ្នេរ | 296 917 | 360 988 | 7.17 | 7.12 |
| | ខ្ពង់រាប និងភ្នំ | 428 586 | 600 288 | 10.35 | 11.84 |

***ប្រភព៖*** *ស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជា (CSES) ឆ្នាំ 2004 និង 2014*

## ១.២ សុខភាព

យុវជនគឺជាពេលវេលាងាយរងផលប៉ះពាល់លើអាកប្បកិរិយាប្រថុយប្រថានដំបូង ដូចជា ទំនាក់ទំនងផ្លូវភេទនិងសារធាតុញៀន។ ជាពិសេសមនុស្សវ័យជំទង់អាចប្រឈមមុខនឹងបញ្ហាជាច្រើនលើសពីនេះទៅទៀត។ នៅទូទាំងពិភពលោក មួយភាគបួននៃយុវតី (39 លាននាក់) និង 17 ភាគរយ នៃក្មេងប្រុសដែលមានអាយុរៀននៅមធ្យមសិក្សាចន្លោះពី 11ទៅ15 ឆ្នាំ មិនបានចុះឈ្មោះចូលរៀនទេ (យោងតាម អង្គការយូណេស្កូ ឆ្នាំ 2008) ។ ការស្ថិតនៅក្រៅសាលារៀនធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះខាងផ្លូវភេទ ការរៀបអាពាហ៍ពិពាហ៍ និងមានកូននៅវ័យក្មេងផងដែរ។ យុវតីរាប់លាននាក់ត្រូវបានបង្ខំឱ្យចូលទៅក្នុងការរួមភេទ អាពាហ៍ពិពាហ៍ដែលខ្លួនមិនចង់បាន ហើយនៅទីបំផុតមានគភ៌ទាំងខ្លួនមិនចង់បាន រំលូតកូនគ្មានសុវត្ថិភាព ការឆ្លងជំងឺផ្លូវភេទ (ជំងឺកាមរោគ) និងមេរោគអេដស៍។ នៅក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម (មិនរាប់រួមបញ្ចូលប្រទេសចិនទេ) 12 ភាគរយ នៃយុវតីត្រូវបានបង្ខំឱ្យរៀបការមុនពេលពួកគេមានអាយុ 15 ឆ្នាំ ខណៈពេលដែល 34 ភាគរយ ទៀតបានរៀបការ ឬមានសម្ព័ន្ធមេត្រីមុនអាយុ 18 ឆ្នាំ។ មូលហេតុចម្បងនៃការឆ្លងជំងឺ និងការស្លាប់ក្នុងចំណោមស្ត្រីវ័យក្មេងដែលមានអាយុចន្លោះពី 15 ទៅ 24 ឆ្នាំ ក្នុងប្រទេសទាំងនេះកើតចេញពីផលវិបាកនៃការមានគភ៌ ការរំលូតកូនគ្មានសុវត្ថិភាពនិងការសម្រាលកូនគ្មានសុវត្ថិភាព។ នៅក្នុងឆ្នាំ 2011 ក្នុងចំណោមអ្នកឆ្លងមេរោគអេដស៍ថ្មីៗមាន 41 ភាគរយ ជាក្មេងជំទង់ និងយុវជន (យោងតាមUNFPA 2013) ។ ជាធម្មតា សូចនាករសុខភាពយុវជនរាប់បញ្ចូលទាំងអត្រាមរណភាព ការឆ្លងជំងឺ ការឆ្លងជំងឺផ្លូវភេទ និងសារធាតុញៀន។

### ១.២.១ អត្រាមរណភាពយុវជន

ស្ថានភាពសុខភាពទូទៅរបស់យុវជនកម្ពុជាមានភាពប្រសើរឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។ អត្រាមរណភាពរបស់យុវជនបានថយចុះចំនួន 40 ភាគរយ គឺថយចុះពី 2,5 ក្នុងឆ្នាំ 2005 ដល់ 1,5 ក្នុងឆ្នាំ 2015 ។ ចំណែកអត្រាមរណភាពនៅឆ្នាំ 2015 គឺ 119 នាក់ ក្នុងចំណោមស្ត្រី 100 000 នាក់ និង 183 ក្នុងចំណោមបុរស 100 000 នាក់ (សូមមើល តារាង 1.2) ។ បុរសវ័យក្មេងគឺមានចំនួន 50ភាគរយ ដែលពួកគេរងផលប៉ះពាល់ច្រើនជាងស្ត្រីវ័យក្មេង។ អត្រាមរណភាពរបស់យុវជននេះគឺ គណនាចំនួននៃការស្លាប់ក្នុងចំណោមមនុស្សចំនួន 100 000 នាក់ ដែលមានអាយុចន្លោះពី 15 ទៅ 29 ឆ្នាំ។

អត្រាមរណភាពរបស់មាតា (Maternal Mortality Rate ហៅកាត់ថា MMR) ក៏មានភាពប្រសើរឡើងចំនួ 53 ភាគរយ ផងដែរ នៅចន្លោះឆ្នាំ 2005 និងឆ្នាំ 2014។ នៅក្នុងឆ្នាំ 2014 ស្ត្រីវ័យក្មេងចំនួន 13 នាក់ក្នុងចំណោមស្ត្រី 100 000 នាក់បានស្លាប់ពេលសំរាលកូន បើប្រៀបធៀបទៅឆ្នាំ 2005 ស្លាប់រហូតដល់ 28 នាក់ (សូមមើល តារាង 1.2) ។ ដូច្នេះ ឃើញថា ការធ្លាក់ចុះនៃអត្រាមរណភាពរបស់មាតា (MMR) មានការរីកចម្រើន។ MMR សំដៅលើចំនួនស្ត្រីដែលស្លាប់ប្រចាំឆ្នាំ (គឺស្រីវ័យក្មេងដែលអាយុចន្លោះពី15ទៅ29ឆ្នាំ) ក្នុងចំណោមស្ត្រីចំនួន 100 000 នាក់ ដោយសារបញ្ហាធ្ងន់ធ្ងរពេលមានគភ៌ ឬការគ្រប់គ្រងខ្លួនមិនបានល្អ (មិនរាប់បញ្ចូលគ្រោះថ្នាក់ ឬឧបទ្ទវហេតុចៃដន្យទេ)។

**តារាង 2 (1-2) អត្រាមរណភាពយុវជន (អាយុពី 15 ទៅ 29 ឆ្នាំ ក្នុងឆ្នាំ 2005 និង 2015**

| | 2005 | | | 2015 | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| អត្រាមរណភាពមាតា MMR (ក្នុង 1 000 នាក់) | 2.5 | 2.2 | 2.9 | 1.5 | 1.2 | 1.8 |
| អត្រាមរណភាពមាតា (ក្នុង 1 00 000 នាក់ ពេលសំរាល) | | 27.8 | NA | | 13 | NA |

***ប្រភព៖*** *អង្គការសុខភាពពិភពលោកឆ្នាំ2005 ឆ្នាំ2015; DHS ឆ្នាំ2014 សម្រាប់ទិន្នន័យ MMR ។*

***ចំណាំ៖*** *MMR នេះរួមបញ្ចូលទាំងការស្លាប់អំឡុងពេលមានគភ៌ ពេលសម្រាលកូន ឬក្នុងរយៈពេល 42 ថ្ងៃក្រោយការរំលូតកូន មិនគិតពីទីកន្លែងនិងរយៈពេលមានគភ៌ឆ្នាំឡើយ។ * ទិន្នន័យសម្រាប់ឆ្នាំ 2014 ។*

ភាគរយនៃការស្លាប់បណ្តាលមកពីការឆ្លងមេរោគអេដស៍ ឬជំងឺអេដស៍ក្នុងចំណោមយុវជនដែលមានអាយុចន្លោះពី 15 ទៅ 29 ឆ្នាំបានថយចុះចំនួន 87 ភាគរយ ចាប់តាំងពីឆ្នាំ 2005 មកម្ល៉េះ។ ប៉ុន្តែមូលហេតុឈានមុខគេ នៃការស្លាប់ក្នុងចំណោមយុវជននាពេលនេះគឺ គ្រោះថ្នាក់ចរាចរណ៍ បន្ទាប់មកទៀតគឺ ការបង្កគ្រោះថ្នាក់ខ្លួនឯង ដែលប្រការនេះកាន់តែធ្ងន់ធ្ងរឡើងៗតាំងពីឆ្នាំ 2005 ជាពិសេសសម្រាប់យុវជនវ័យក្មេងជាងគេ (សូមមើល តារាង 1.3) ។ មូលហេតុឈានមុខគេផ្សេងទៀតរួមមានជំងឺរបេង លក្ខខណ្ឌសុខភាពរបស់មាតា និងជំងឺសរសៃឈាមបេះដូង។

**រូបភាព 1(1-1) មូលហេតុឈានមុខគេក្នុងចំណោមមូលហេតុនៃការស្លាប់យុវជនសរុបអាយុពី 15 ទៅ 29 ឆ្នាំ នៅក្នុងឆ្នាំ 2005 និង 2015**




*ប្រភព៖ អង្គការសុខភាពពិភពលោកឆ្នាំ2015*

**តារាង 3 (1-3) បំណែងចែកមូលហេតុនៃការស្លាប់ក្នុងចំណោមយុវជនដែលមានអាយុពី 15 ទៅ 29 ក្នុងឆ្នាំ 2005 និង 2015**

| មូលហេតុនៃការស្លាប់ | 2005 | | | 2015 | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី វ័យក្មេង | បុរស វ័យក្មេង | សរុប | ស្ត្រី វ័យក្មេង | បុរស វ័យក្មេង |
| គ្រោះថ្នាក់ចរាចរណ៍ | 11.6 | 3.1 | 18.2 | 16.8 | 5.1 | 24.3 |
| បង្កគ្រោះថ្នាក់ខ្លួនឯង | 7.8 | 8.0 | 7.7 | 11.3 | 11.1 | 11.4 |
| លង់ទឹក | 4.9 | 2.7 | 6.6 | 5.9 | 3.2 | 7.6 |
| អំពើហឹង្សារវាងបុគ្គល | 3.3 | 0.8 | 5.3 | 2.6 | 0.8 | 3.8 |
| ការរងរបួសផ្សេងៗ | 6.1 | 5.1 | 6.8 | 7.7 | 6.5 | 8.4 |
| ជំងឺរបេង | 7.6 | 7.1 | 8.0 | 7.1 | 7.2 | 7.1 |
| មេរោគអេដស៍ / ជំងឺអេដស៍ | 23.4 | 27.0 | 20.7 | 3.3 | 4.6 | 2.4 |
| ការឆ្លងមេរោគផ្លូវដង្ហើម | 2.6 | 3.2 | 2.1 | 3.5 | 4.8 | 2.7 |
| ជំងឺមាតាភាព | 3.4 | 7.8 | NA | 3.4 | 8.6 | NA |
| ជំងឺឆ្លងផ្សេងៗ | 8.7 | 10.5 | 7.4 | 7.6 | 10.4 | 5.9 |
| ជំងឺសរសៃឈាមបេះដូង | 7.6 | 9.8 | 5.9 | 10.7 | 13.5 | 8.9 |
| ជំងឺមិនឆ្លងផ្សេងៗ | 12.9 | 14.9 | 11.4 | 20.1 | 24.3 | 17.5 |
| **សរុប** | 100 | 100 | 100 | 100 | 100 | 100 |

*ប្រភព៖ អង្គការសុខភាពពិភពលោក (WHO)ឆ្នាំ2005 និង 2015*

### ១.២.២ សុខភាពផ្លូវភេទ និងបន្តពូជ (SRH)

សុខភាពផ្លូវភេទនិងបន្តពូជ (SRH) គឺជាការព្រួយបារម្ភជាពិសេសសម្រាប់ស្ត្រីវ័យជំទង់ និងស្ត្រីវ័យក្មេងព្រោះថា ការមានគភ៌និងការមានកូនវ័យក្មេងអាចមានផលប៉ះពាល់អវិជ្ជមានរយៈពេលវែងក្នុងជីវិតរបស់ពួកគេ។ អង្គការសុខភាពពិភពលោក (WHO) បានប៉ាន់ប្រមាណថា នៅទូទាំងពិភពលោកស្ត្រីវ័យក្មេងប្រហែល 16 លាននាក់ដែលមានអាយុចន្លោះពី 15 ទៅ 19 ឆ្នាំ និងយុវតីចំនួន មួយលាននាក់ដែលមានអាយុក្រោម 15 ឆ្នាំផ្តល់កំណើតឱ្យកូនជារៀងរាល់ឆ្នាំ ដែលការផ្តល់កំណើតបែបនេះមានច្រើនបំផុតនៅក្នុងប្រទេសដែលមានចំណូលមធ្យម និងទាប។ ផលវិបាកក្នុងពេលមានគភ៌ និងបង្កើតកូនគឺជាបុព្វហេតុធំបំផុតទីពីរនៃការស្លាប់របស់យុវតីអាយុចន្លោះពី 15 ទៅ 19 ឆ្នាំនៅទូទាំងពិភពលោក។ ជារៀងរាល់ឆ្នាំ យុវតីដែលមានអាយុចន្លោះពី 15 ទៅ 19 ឆ្នាំ ប្រមាណជា 3 លាននាក់ទៅរកសេវារំលូតកូនគ្មានសុវត្ថិភាព។ ទារកដែលកើតលើម្តាយដែលមានវ័យជំទង់អាចប្រឈមមុខនឹងហានិភ័យនៃការស្លាប់ខ្ពស់ជាងទារកដែលកើតលើស្ត្រីដែលមានអាយុចន្លោះពី 20 ទៅ 24 ឆ្នាំ (យោងតាមអង្គការ WHO ឆ្នាំ 2014)។

នៅប្រទេសកម្ពុជា អត្រាបន្តពូជសរុប (Total Tertility Rate ហៅកាត់ថា TFR) ដែលកំណត់ថាជាចំនួនមធ្យមនៃកុមារដែលកើតលើស្ត្រីដែលមានអាយុចន្លោះពី 15 ទៅ 49 ឆ្នាំបានថយចុះពីចំនួន 3,4 ក្នុងឆ្នាំ 2005 ដល់ចំនួន 2,7 ក្នុងឆ្នាំ 2014។ ទោះយ៉ាងណា អត្រាបន្តពូជរបស់ក្មេងជំទង់ (អាយុពី 15ទៅ19 ឆ្នាំ) បានកើនឡើងនាពេលថ្មីៗនេះគឺ ពីចំនួន 47 នាក់ ទៅ 57 នាក់ ក្នុងចំណោមស្ត្រីចំនួន 1000 នាក់នៅឆ្នាំ 2005 ពោលគឺស្មើនឹង 12ភាគរយ នៃក្មេងស្រីជំទង់ដែលបានក្លាយជាម្តាយ ឬពរពោះកូនដំបូងរបស់ខ្លួន។ ករណីទាំងនេះភាគច្រើនម្តាយមានអាយុចន្លោះពី 18ទៅ19 ឆ្នាំ ដែលអាយុ 18 ឆ្នាំ ជាអាយុរៀបការស្របច្បាប់។ នៅឆ្នាំ 2014 យុវតីម្នាក់ក្នុងចំណោមក្មេងស្រីបីនាក់ដែលមានអាយុ 19 ឆ្នាំ បានផ្តល់កំណើតទារក ឬពរពោះកូនដំបូងរបស់ខ្លួន។ ចំណែកអត្រាបន្តពូជរបស់ក្មេងស្រីនៅតាមតំបន់ជនបទគឺ មានចំនួនបីដងខ្ពស់ជាងនៅក្នុងតំបន់ទីក្រុង និង ចំនួន 1,5 ដង ខ្ពស់ជាងស្ត្រីដែលមានអាយុចន្លោះពី 20ទៅ 24 ឆ្នាំ (សូមមើល តារាង 1.4)។

បុព្វហេតុ នៃការមានគភ៌របស់ក្មេងជំទង់ ឬភាពជាម្តាយវ័យក្មេងមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងកម្រិតនៃការអប់រំ។ ជាងមួយភាគបីនៃក្មេងជំទង់ (37 ភាគរយ) ដែលមិនបានចូលសាលាបានផ្តល់កំណើត ឬមានគភ៌ បើធៀបនឹងក្មេងស្រីបានទទួលការអប់រំត្រឹមថ្នាក់បឋមសិក្សា គឺមានចំនួន 18 ភាគរយ ហើយបើធៀបនឹងអ្នកទទួលបានការអប់រំមធ្យមសិក្សា ឬខ្ពស់ជាងនេះ គឺមានតែ 8 ភាគរយ ប៉ុណ្ណោះ (យោងតាម CDHS ឆ្នាំ2014)។ ការវិភាគលើការថយចុះ នៃអថេរចម្រុះដែលបានអនុវត្តសម្រាប់ការសិក្សានេះបានបង្ហាញថា គ្រប់យ៉ាងគឺស្មើគ្នាទាំងអស់គឺថា ស្ត្រីវ័យក្មេងដែលទទួលបានការអប់រំត្រឹម

កម្រិតមធ្យមសិក្សាមានហានិភ័យពេលសំរាលកូនទាបជាងស្ត្រីវ័យក្មេងដែលមិនបានទទួលការអប់រំនៅកម្រិតមធ្យមសិក្សា។ ហើយស្ត្រីវ័យក្មេងដែលកំពុងធ្វើការក៏ទំនងជាមានកូនតិច ជាងស្ត្រីវ័យក្មេងដែលមិនកំពុងធ្វើការដែរ (យោងតាម Meng, Po & Thiep ឆ្នាំ 2013)។

**តារាង 4 (1-4) អត្រាបន្តពូជសរុប (ក្នុងចំណោមស្ត្រី 1 000 នាក់) តាមលំនៅដ្ឋាន និងក្រុមអាយុ ឆ្នាំ2014**

| ក្រុមអាយុ | ទីក្រុង | ជនបទ | សរុប |
|---|---|---|---|
| **15-19** | 21 | 66 | 57 |
| **20-24** | 101 | 179 | 162 |
| **25-29** | 135 | 156 | 152 |
| **30-34** | 92 | 104 | 102 |
| **35-39** | 56 | 50 | 51 |
| **40-44** | 11 | 18 | 17 |
| **45-49** | 3 | 5 | 4 |
| **សរុប (អាយុពី 15-49 ឆ្នាំ)** | 2.1 | 2.9 | 2.7 |

*ប្រភព៖ ការស្ទង់មតិសុខភាពនិងប្រជាសាស្ត្រកម្ពុជា (CDHS) ឆ្នាំ 2014*

ស្ត្រីវ័យក្មេងជួបហានិភ័យនៃការឆ្លងជំងឺផ្លូវភេទ (ជំងឺកាមរោគ) ច្រើនជាងបុរសវ័យក្មេង។ យោងតាម CDHS ឆ្នាំ 2014 បានឱ្យដឹងថា អត្រានៃជំងឺកាមរោគជាស្ត្រីក្នុងអំឡុងពេល 12 ខែមុនពេលស្ទង់មតិមានចំនួន 5,6 ភាគរយ ក្នុងចំណោមស្ត្រីអ្នកផ្តល់ចម្លើយចំនួន 11 678 នាក់ ដែលមានអាយុចន្លោះពី 15ទៅ 49 ឆ្នាំ ដែលធ្លាប់រួមភេទ រាប់ទាំងការរួមភេទជាមួយប្តីរបស់ខ្លួនផង។ នៅក្នុងចំណោមស្ត្រីអាយុចន្លោះពី 15 ទៅ 29 ឆ្នាំអត្រាឆ្លងគឺ 5 ភាគរយ នៅក្នុងឆ្នាំ 2014 មានការកើនឡើងចំនួន 2,7 ភាគរយ ក្នុងឆ្នាំ 2005។ អត្រានៃការឆ្លងមេរោគគឺខ្ពស់បំផុតនៅក្នុងតំបន់រាជធានីភ្នំពេញនិងតំបន់ឆ្នេរ និងទាបបំផុតនៅតំបន់ទន្លេសាប។ ស្ត្រីវ័យក្មេងជាច្រើនដែលមានស្ថានភាពក្រីក្របំផុត និងមានបំផុតមានជំងឺកាមរោគ។ នេះអាចពន្យល់បានយ៉ាងច្បាស់ថា ស្ត្រីជាច្រើនមកពីគ្រួសារក្រីក្របំផុតរៀបការនៅវ័យក្មេងពេក ហើយចំណេះដឹងអំពីជំងឺកាមរោគនៅមានកម្រិតនៅឡើយ (យោងតាម Santhya & Jejeebhoy 2012) ។ ស្ត្រីវ័យក្មេងដែលមានស្ថានភាពទ្រព្យធនមានបំផុត ពួកគេទំនងជារងផលប៉ះពាល់ឥរិយាបថគ្រោះថ្នាក់ពីដៃគូរបស់ខ្លួន ព្រោះថា ទ្រព្យសម្បត្តិបានផ្សារភ្ជាប់យ៉ាងខ្លាំងជាមួយដៃគូរួមភេទច្រើន (យោងតាម Rutaremwa et al, n.d; Chimoyi & Musenge 2014; Kuhanen 2010)។ អត្រាឆ្លងជំងឺកាមរោគបុរសគឺមានតិចតួច ប្រហែល 0,5 ភាគរយ ក្នុងចំណោមបុរសដែលរួមភេទចំនួន 3506 នាក់។ យុវជនអាយុពី 15 ទៅ 29 ឆ្នាំប្រហែល 0,7 ភាគរយ អាចឆ្លងជំងឺកាមរោគតិចជាងស្ត្រីវ័យក្មេង។ ជំងឺកាមរោគលើយុវជនមិនសូវកើតមានញឹកញាប់ទេ នៅក្នុងតំបន់ឆ្នេរ និងទន្លេសាប (សូមមើល តារាង 1.5) ។

**តារាង 5 (1-5) យុវជនមានជំងឺសង្គមតាមតំបន់ និងទ្រព្យធន (ភាគរយ នៃយុវជនសរុបអាយុពី 15 ទៅ 29 ឆ្នាំ) ក្នុងឆ្នាំ 2005 និងឆ្នាំ 2014**

| | 2005 | | 2014 | |
|---|---|---|---|---|
| | ស្ត្រី វ័យក្មេង | បុរស វ័យក្មេង | ស្ត្រី វ័យក្មេង | បុរស វ័យក្មេង |
| **សរុប** | 2.7 | 0.9 | 5.0 | 0.7 |
| **តំបន់** | | | | |
| ភ្នំពេញ | 4.6 | 1.0 | 5.7 | 1.2 |
| វាលទំនាប | 1.8 | 0.6 | 4.7 | 0.8 |
| ទន្លេសាប | 4.1 | 1.2 | 3.8 | 0.5 |
| ឆ្នេរ | 1.3 | 0.7 | 7.9 | 0.0 |
| ខ្ពង់រាប និងភ្នំ | 1.8 | 0.6 | 5.6 | 0.8 |
| **ស្ថានភាពទ្រព្យធន** | | | | |
| ក្រីក្របំផុត | 2.9 | 0.3 | 4.5 | 0.5 |
| ក្រីក្រ | 2.5 | 0.7 | 4.1 | 0.5 |
| កណ្តាល | 2.8 | 1.6 | 5.6 | 0.6 |
| មាន | 2.1 | 0.9 | 5.4 | 0.0 |
| មានបំផុត | 3.2 | 0.9 | 5.4 | 1.5 |

*ប្រភព៖ CDHS ឆ្នាំ 2005 និងឆ្នាំ 2014* *ចំណាំ៖ អត្រាឆ្លងក្នុងរយៈពេល 12 ខែមុនពេលស្ទង់មតិ។*

### ១.២.៣ ការរំលោភបំពានដោយសារគ្រឿងញៀន

ការប្រើប្រាស់គ្រឿងញៀននិងការញៀនថ្នាំក្នុងចំណោមយុវវ័យកម្ពុជាកំពុងកើនឡើង។ ទិន្នន័យផ្លូវការស្តីពីអ្នកប្រើប្រាស់គ្រឿងញៀននិងអ្នកញៀនថ្នាំមានការលំបាកក្នុងការប្រមូលព្រោះអ្នករងផលប៉ះពាល់ទំនងជាមិនចង់រាយការណ៍អំពីខ្លួនឯង។ របាយការណ៍ប្រចាំឆ្នាំរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

(National Authority for Combatting Drugs ហៅកាត់ថា NACD) ដែលផ្តល់នូវការប៉ាន់ស្មាននៃចំនួនអ្នកញៀនថ្នាំ បានព្រមានថា ចំនួនសរុបគឺទំនងជាខ្ពស់ជាងនេះ។ ក្នុងឆ្នាំ 2010 NACD រកឃើញអ្នកញៀនថ្នាំពី 5 000 ទៅ 6 000 នាក់ គឺប្រមាណ 60 ភាគរយ ចន្លោះអាយុពី 18ទៅ25 ឆ្នាំ។ អ្នកដែលមានអាយុចន្លោះពី 26 និង 45 ឆ្នាំមានចំនួន 31 ភាគរយ នៃអ្នកប្រើប្រាស់ថ្នាំញៀនទាំងអស់គ្នា (សូមមើលរូបភាពទី 1.2) ។ ចំនួននៃអ្នកញៀនដែលបានស្វែងរកការព្យាបាលនៅមណ្ឌលស្តារនីតិសម្បទាគ្រឿងញៀនឯកជន និងសាធារណៈ កំពុងកើនឡើងដែលបង្ហាញថា ការប្រើប្រាស់គ្រឿងញៀននិងការញៀនគឺកើនឡើង។ ចំនួនសរុបនៃអ្នកស្វែងរកការព្យាបាលកើនឡើងពី 1 162 នាក់ ទៅ 1 286 នាក់ ក្នុងឆ្នាំ 2014។ សមាមាត្រនៃយុវជន(18ទៅ35ឆ្នាំ) ដែលកំពុងស្វែងរកសេវាស្តារនីតិសម្បទាតាមមណ្ឌលសាធារណៈនិងឯកជនបានកើនឡើងពី 86 ភាគរយ ទៅ 91 ភាគរយ ក្នុងអំឡុងពេលនោះ (សូមមើល រូបភាពទី 1.3) ។ ទោះជាយ៉ាងណា ចំនួននេះនៅមានការចម្រូងចម្រាសយ៉ាងខ្លាំងព្រោះថា ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្មបានអះអាងថា ចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅក្នុងប្រទេសកម្ពុជាមានរហូតដល់ 46 000 នាក់ (យោងតាម UNOCD ឆ្នាំ2013)។

**រូបភាព 2 (1-2) បំណែងចែកអ្នកប្រើគ្រឿងញៀនតាមក្រុមអាយុក្នុងឆ្នាំ 2010 (គិតជា ភាគរយ)**




*ប្រភព៖ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំ 2010*

**រូបភាព 3 (1-3) អ្នកញៀនថ្នាំអាយុពី 18ទៅ35 ឆ្នាំស្វែងរកការផ្តល់សេវាស្តារនីតិសម្បទា (គិតជា ភាគរយ នៃអ្នកស្វែងរកការព្យាបាលសរុប)**




*ប្រភព៖ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំ 2012, 2013 និង 2014*

### ១.២.៤ ការប្រើប្រាស់ថ្នាំជក់ និងគ្រឿងស្រវឹង

បារីជក់ការនៃនិន្នាការបានប្រសើរឡើងហើយក្នុងចំណោមយុវជនដែលមានអាយុចន្លោះពី 15 ទៅ 17 ឆ្នាំ ប៉ុន្តែមានកម្រិតខ្ពស់ក្នុងចំណោមយុវជនអាយុពី 18 ទៅ 24ឆ្នាំ។ យោងតាមការស្ទង់មតិថ្នាំជក់ជាតិមនុស្សពេញវ័យកម្ពុជាឆ្នាំ 2011 (National Adult Tobacco Survey of Cambodia ហៅកាត់ថា NATSC) ដែលធ្វើឡើងដោយក្រសួងផែនការនៃប្រទេសកម្ពុជាក្នុងឆ្នាំ 2011 បានឱ្យដឹងថា 2 ភាគរយ ក្នុងចំណោមក្មេងប្រុសជំទង់អាយុ 15 ទៅ 17 ឆ្នាំ បានប្រើប្រាស់ផលិតផលថ្នាំជក់ ទាំងទៀងទាត់ ឬម្តងម្កាល (រូបភាព 1.4)។ ភាគរយនៃអ្នកជក់បារីក្នុងចំណោមបុរសអាយុចន្លោះពី 18 ទៅ 24 ឆ្នាំមានរហូតដល់ 13.1 ភាគរយ។ គេប៉ាន់ប្រមាណថា ចំនួន 40 ភាគរយ នៃបុរសកម្ពុជាដែលមានអាយុ 15 ឆ្នាំឡើង គឺជាអ្នក

ជក់បារី។ អត្រានៃស្ត្រីវ័យក្មេងដែលជក់បារីគឺជិតដល់កម្រិតសូន្យ។

**រូបភាព 4 (1-4) យុវជនអាយុពី 15 ទៅ 24 ឆ្នាំ ប្រើប្រាស់ផលិតផលថ្នាំជក់**




*ប្រភព៖ ក្រសួងផែនការ )NATSC Cambodia ឆ្នាំ (2011*

បារីមានតម្លៃថោកនិងងាយស្រួលរកសម្រាប់មនុស្សវ័យក្មេងនិងវ័យជំទង់។ ការស្ទង់មតិរបស់ NATSC បានបង្ហាញថា ម្នាក់ក្នុងចំណោមអ្នកជក់បារីប្រាំនាក់ដែលមានអាយុពី 15 ទៅ 19 ឆ្នាំ បានចាប់ផ្តើមជក់បារីមុនអាយុ 15 ឆ្នាំ (សូមមើល រូបភាព 1.5) ។ អង្គការសុខភាពពិភពលោក WHO ក៏បានធ្វើការស្ទង់មតិថ្នាំជក់ចំនួនពីរជុំនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ 2003 និងឆ្នាំ 2010 លើអាយុពី 13ទៅ15 ឆ្នាំ រៀនថ្នាក់ទី 7 ដល់ ថ្នាក់ទី12។ ការស្ទង់មតិទាំងពីរបានបង្ហាញថា ភាគរយនៃក្មេងប្រុសជក់បារីគឺខ្ពស់ជាងយុវតី ដែលអត្រាសម្រាប់ក្មេងស្រីនេះស្ទើរតែមិនគួរកត់សម្គាល់ផង។ ចំនួនសរុបនៃក្មេងប្រុសជក់បារីបានធ្លាក់ចុះពី 4,6 ភាគរយ ក្នុងឆ្នាំ 2003 ដល់ 0,4 ភាគរយ នៅក្នុងឆ្នាំ 2010 ។ ម្យ៉ាងទៀត ផលិតផលថ្នាំជក់ក្រៅពីបារីកំពុងតែមានប្រជាប្រិយភាពក្នុងចំណោមមនុស្សវ័យជំទង់។ ការស្ទង់មតិនេះបានបង្ហាញថា ផលិតផលថ្នាំជក់ដូចជា (ខ្សៀ បារីស៊ីហ្គា បារីស៊ីហ្គារីឡូ បំពង់ទឹក ខ្សៀហ្វូកា ថ្នាំជក់សម្រាប់ហឺត ការចុកថ្នាំ ថ្នាំទឹកផ្សេងៗទៀត) ត្រូវបានប្រើដោយក្មេងប្រុសចំនួន 6ភាគរយ និងយុវតីចំនួន 3ភាគរយ ដែលមានអាយុពី 13 ទៅ 15 ឆ្នាំ នៅឆ្នាំ 2010 ពោលគឺ កើនឡើង 3,3 ភាគរយ និង 3 ភាគរយ ក្នុងឆ្នាំ 2003 (យោងតាមប្រព័ន្ធទិន្នន័យតាមដានថ្នាំជក់សកល GTSS DATA)។

**រូបភាព 5 (1-5) ភាគរយនៃអាយុផ្តើមជក់បារីក្នុងចំណោមអ្នកជក់បារីទៀងទាត់អាយុពី 15 ទៅ 19 ឆ្នាំ**




*ប្រភព៖ ស្ថិតិវិទ្យាស្ថានជាតិ (NIS) ឆ្នាំ **2011***

ប្រើប្រាស់គ្រឿងស្រវឹងក្នុងចំណោមយុវជនកំពុងកើនឡើងនៅក្នុងប្រទេសកម្ពុជា។ និន្នាការនេះគឺជាក្តីបារម្ភមួយ ពិសេសដោយសារតែវាបានបង្កគ្រោះថ្នាក់ចរាចរណ៍ក្នុងចំណោមយុវជន។ គ្រោះថ្នាក់ចរាចរណ៍គឺជាមូលហេតុទីមួយនៃការស្លាប់យុវជន ហើយការប្រើប្រាស់គ្រឿងស្រវឹងជាមូលហេតុឈានមុខទីពីរនៃគ្រោះថ្នាក់ចរាចរណ៍ (យោងតាម Mom and Khuon 2009។ បច្ចុប្បន្ននេះ នៅមិនទាន់មានការកំណត់អាយុសម្រាប់អ្នកសេពគ្រឿងស្រវឹងនៅក្នុងច្បាប់នៃប្រទេសកម្ពុជាទេ។ ជាលទ្ធផលក្មេងជំទង់ដែលមានអាយុចាប់ពី 14 ឆ្នាំឡើងបានប្រើប្រាស់គ្រឿងស្រវឹងជាទៀងទាត់ (យោងតាមមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងការស្រាវជ្រាវសន្តិភាព PCDPR ឆ្នាំ 2009) ។ ក្នុងចំណោមយុវជនអាយុពី 15 ទៅ 19 ឆ្នាំ គឺ 42 ភាគរយ នៃបុរស និង 27 ភាគរយនៃស្ត្រីជាអ្នកសេពគ្រឿងស្រវឹងនាពេលបច្ចុប្បន្ននេះ។ កម្រិតនៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងចំណោមប្រជាជនកម្ពុជាដែលមានអាយុចន្លោះពី 15 និង 19 ឆ្នាំស្ថិតក្នុងលំដាប់ខ្ពស់បំផុតនៃបណ្តាប្រទេសអាស៊ាន (យោងតាម WHO, n.d. ) (សូមមើលរូបភាពទី 1.6) ។ ការស្រាវជ្រាវជាក់ស្តែងអំពីទំនាក់ទំនងរវាងការប្រើប្រាស់ថ្នាំជក់ និងការរំលោភបំពានដោយការសេពគ្រឿងស្រវឹងនៅក្នុងប្រទេសកម្ពុជាបានបង្ហាញថាក្នុងសប្តាហ៍កន្លងទៅនេះបុរសដែលជក់បារីគឺទំនងជាសេពគ្រឿងស្រវឹងច្រើនជាងអ្នកមិនជក់បារី ដែលប្រការនេះអាចបង្ហាញថា ការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងអាចគ្រប់គ្រងការប្រើប្រាស់ថ្នាំជក់បាន (យោងតាម Banta etal, 2012)។

**រូបភាព 6 (1-6) អ្នកប្រើប្រាស់គ្រឿងស្រវឹងអាយុពី 15 ទៅ 19 ឆ្នាំក្នុងចំណោមបណ្តាប្រទេសអាស៊ានឆ្នាំ 2010 (គ្រឿងស្រវឹងសុទ្ធគិតជាលីត្រ)**




*ប្រភព៖ អង្គការសុខភាពពិភពលោក, n.d.*

ការបន្តសែបគ្រឿងស្រវឹងច្រើនគឺជាផ្នែកមួយនៃការសូចនាករសំខាន់បំផុត នៃការប្រើប្រាស់គ្រឿងស្រវឹងធ្ងន់ធ្ងរ។ ការបន្តសែបគ្រឿងស្រវឹងធ្ងន់ធ្ងរកំណត់ថា ជាការសែបជាតិអាល់កុលសុទ្ធចំនួន 60 ក្រាមឬច្រើនជាងនេះ។ ឱកាសសែបបែបនេះមានយ៉ាងហោចណាស់ម្តងដែរក្នុងរយៈ 30 ថ្ងៃមុននេះ និងត្រូវបានគណនាជាភាគរយនៃចំនួនប្រជាជនទាំងមូល។ នៅឆ្នាំ 2010 ក្នុងចំណោមប្រជាជនកម្ពុជាដែលមានអាយុចន្លោះពី 15 ទៅ 19 ឆ្នាំ ប្រមាណជា 10 ភាគរយ ជាអ្នកសែបគ្រឿងស្រវឹងធ្ងន់ធ្ងរ (សូមមើល រូបភាព 1,7) ។

**រូបភាព 7 (1-7) អ្នកសែបគ្រឿងស្រវឹងធ្ងន់ធ្ងរដែលមានអាយុពី 15ទៅ19 ឆ្នាំ (ភាគរយ នៃប្រជាជន), ឆ្នាំ 2010**




*ប្រភព៖ អង្គការសុខភាពពិភពលោក, n.d.*

១.៣ ការអប់រំ និងជំនាញ

បញ្ហាដែលយុវជនប្រឈមធំបំផុតគឺភាពក្រីក្រ និងការទាត់ចោលពីសកម្មភាពសង្គម ដោយសារតែឱកាសការងារតិចតួច ដោយសារតែគ្មានឬមានលទ្ធភាពតិចតួចក្នុងការទទួលបានការអប់រំ ឬបណ្តុះបណ្តាលវិជ្ជាជីវៈ។ យុវជនមួយចំនួនមានលទ្ធភាពជាមូលដ្ឋានតាំងពីកំណើតរួមទាំងលទ្ធភាពក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ការងារសមរម្យ ការថែទាំសុខភាពនិងការគាំពារសង្គមផ្សេងៗ។ អ្នកខ្លះទៀតរស់នៅក្នុងបរិស្ថានឬកន្លែងដែលពួកគេ និងក្រុមគ្រួសាររបស់ពួកគេងាយរងគ្រោះទៅនឹងហានិភ័យបរិស្ថាន សេដ្ឋកិច្ច សង្គម និងបុគ្គលមួយចំនួន។ តាមពិតភាគច្រើននៃយុវជននៅក្នុងប្រទេសកំពុងអភិវឌ្ឍនាពេលបច្ចុប្បន្ននេះបានធ្លាក់ចូលទៅក្នុងហានិភ័យបែបនេះ ជាពិសេសសម្រាប់យុវជនដែលរស់នៅក្នុងតំបន់ជនបទដាច់ស្រយាល ជនជាតិភាគតិច ជនពិការ និងបញ្ហាគ្រួសារ សុទ្ធតែកត្តារួមចំណែកដល់ភាពងាយរងគ្រោះ។ ស្ថានភាពនេះក៏មិនខុសពីប្រទេសកម្ពុជាដែរ ដែលភាពក្រីក្រ ការគ្មានលទ្ធភាពចូលរៀននៅសាលា និងគុណភាពទាបនៃការអប់រំបានជំរុញឱ្យកុមារនៅក្រៅសាលា។ ខាងក្រោមនេះជាលទ្ធផល នៃការអប់រំរបស់យុវជនកម្ពុជាដែលត្រូវបានវាស់ស្ទង់ រួមមាន អត្រាចុះឈ្មោះចូលរៀន និងឡើងថ្នាក់ អត្រានៃការបញ្ចប់កាសិក្សា និងការទទួលបានការអប់រំ និងលទ្ធផលសិក្សា។

**១.៣.១ ការចូលរួមក្នុងវិស័យអប់រំ**

អត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សាមានកម្រិតខ្ពស់ ប៉ុន្តែមានការធ្លាក់ចុះយ៉ាងខ្លាំងនៅមធ្យមសិក្សា បើទោះជាមានកាតព្វកិច្ចសិក្សានៅកម្រិតនេះក៏ដោយ។ នៅក្នុងប្រទេសកម្ពុជាកុមារចាប់ផ្តើមចូលរៀននៅបឋមសិក្សានៅអាយុ 6 ឆ្នាំ និងនៅមធ្យមសិក្សានៅអាយុ 12 ឆ្នាំ។ បន្ទាប់ពីការអប់រំចំនួន 12 ឆ្នាំនៅសាលាចំណេះទូទៅ សិស្សអាចបន្តការសិក្សាទៅឧត្តមសិក្សា ឬបណ្តុះបណ្តាលវិជ្ជាជីវៈ។ យោងតាមក្រសួងអប់រំយុវជននិងកីឡា (អយក.) ក្នុងឆ្នាំ 2015 បានឱ្យដឹងថា អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅកម្រិតបឋមសិក្សាមានចំនួន 94 ភាគរយ ប៉ុន្តែអត្រាសម្រាប់ការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យដែលនៅតែជាកាតព្វកិច្ចនៅឡើយនោះបានធ្លាក់ចុះដល់ 39 ភាគរយ (សូមមើល តារាង 1.6) (យោងតាម ក្រសួងអយក. ឆ្នាំ 2016)។ អត្រាចុះឈ្មោះចូលរៀនសុទ្ធសំដៅលើចំនួនសិស្សសរុបនៅក្នុងក្រុមអាយុមួយដែលបានចុះឈ្មោះនៅកំរិតមួយកណត់ដោយទ្រឹស្តីអប់រំ ដោយផ្តើមចេញពីភាគរយ នៃចំនួនប្រជាជនសរុបនៅក្នុងក្រុមអាយុនោះ។

**តារាង 6 (1-6) អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សាសម្រាប់ឆ្នាំសិក្សា 2010/11 និង 2015/16**

| | | 2010/11 | 2011/12 | 2012/13 | 2013/14 | 2014/15 | 2015/16 |
|---|---|---|---|---|---|---|---|
| **បឋមសិក្សា** | **សរុប** | 95.2 | 96.4 | 97.0 | 95.6 | 94.5 | 93.9 |
| | ស្រី | 94.6 | 96.1 | 97.0 | 95.8 | 94.9 | 94.6 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រុស | 95.8 | 96.7 | 96.9 | 95.4 | 94.1 | 93.4 |
| **អនុវិទ្យាល័យ** | **សរុប** | 35.0 | 35.1 | 37.8 | 38.5 | 39.1 | 38.9 |
| | ស្រី | 37.2 | 37.4 | 40.2 | 41.1 | 42.2 | 42.7 |
| | ប្រុស | 33.0 | 33.0 | 35.5 | 36.0 | 36.0 | 35.3 |
| **វិទ្យាល័យ** | **សរុប** | 20.6 | 19.6 | 18.1 | 17.1 | 17.3 | 18.6 |
| | ស្រី | 20.5 | 20.1 | 18.8 | 18.0 | 18.6 | 20.3 |
| | ប្រុស | 20.6 | 19.1 | 17.4 | 16.2 | 16.0 | 17.1 |

***ប្រភព***៖ *អយក.ឆ្នាំសិក្សា 2010 /11 និង 2015 /16*

អត្រាចុះឈ្មោះចូលរៀនសុទ្ធខុសគ្នាដោយតំបន់។ គួរឱ្យភ្ញាក់ផ្អើលដែលនៅក្នុងរាជធានីភ្នំពេញមិនមានអត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សាខ្ពស់បំផុតនោះទេ ហើយជាការពិតណាស់ អត្រានេះបានធ្លាក់ចុះចំនួន 10 ភាគរយ ចាប់តាំងពី 2012/13 ដែលពេលនោះរាជធានីភ្នំពេញមានអត្រាចុះឈ្មោះខ្ពស់បំផុត។ នៅតំបន់ឆ្នេរ និងនៅតំបន់ទន្លេសាប អត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សាបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ ប៉ុន្តែក្នុងរយៈពេលប្រាំឆ្នាំនេះ ការចុះឈ្មោះចូលរៀនអនុវិទ្យាល័យគ្រប់តំបន់ទាំងអស់ក៏មានភាពប្រសើរឡើងផងដែរ លើកលែងតែរាជធានីភ្នំពេញទេដែលមានការថយចុះពិតប្រាកដ (សូមមើល តារាង 1,7)។ ទោះបីជាមានបទប្បញ្ញត្តិផ្នែកច្បាប់ពលកម្មក៏ដោយ ក៏ពលកម្មកុមារនៅតែជាបញ្ហាមួយនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ និងស្បែកជើងផងដែរ (យោងតាមអង្គការរោងចក្រកាន់តែប្រសើរ BF ឆ្នាំ 2013) ។ ពោលគឺនៅក្នុងឆ្នាំ 2012 កុមារកម្ពុជាជិត 11 ភាគរយ ត្រូវបានគេរកឃើញកំពុងធ្វើការជាកម្មករ (យោងតាម ADB ឆ្នាំ2015) ។

**តារាង 7 (1-7) អត្រាចុះឈ្មោះចូលរៀនសុទ្ធតាមតំបន់សម្រាប់ឆ្នាំសិក្សា 2010 /11 និង 2015 /16**

| | 2010/11 | 2011/12 | 2012/13 | 2013/14 | 2014/15 | 2015/16 |
|---|---|---|---|---|---|---|
| | **បឋមសិក្សា** | | | | | |
| **ភ្នំពេញ** | 91.8 | 92.4 | 98.0 | 89.5 | 89.5 | 88.6 |
| **វាលទំនាប** | 96.0 | 97.6 | 97.6 | 98.0 | 99.0 | 97.9 |
| **បឹងទន្លេសាប** | 95.8 | 96.6 | 96.7 | 93.8 | 90.1 | 84.1 |
| **តំបន់ឆ្នេរ** | 95.0 | 91.9 | 93.6 | 84.9 | 78.2 | 76.2 |
| **ខ្ពង់រាប និងភ្នំ** | 91.4 | 94.0 | 96.8 | 96.2 | 93.5 | 94.8 |
| **សរុប** | 95.2 | 96.4 | 97.0 | 95.6 | 94.5 | 93.9 |
| | **អនុវិទ្យាល័យ** | | | | | |
| **ភ្នំពេញ** | 50.0 | 52.4 | 53.5 | 51.4 | 48.7 | 45.8 |
| **វាលទំនាប** | 39.5 | 40.4 | 44.3 | 44.9 | 44.2 | 44.5 |
| **បឹងទន្លេសាប** | 31.0 | 28.9 | 30.5 | 31.4 | 32.9 | 31.1 |
| **តំបន់ឆ្នេរ** | 30.6 | 31.9 | 34.2 | 34.5 | 35.3 | 33.8 |
| **ខ្ពង់រាប និងភ្នំ** | 24.1 | 21.8 | 23.9 | 26.3 | 26.6 | 26.8 |
| **សរុប** | 35.0 | 35.1 | 37.8 | 38.5 | 39.1 | 38.9 |
| | **វិទ្យាល័យ** | | | | | |
| **ភ្នំពេញ** | 46.8 | 39.2 | 34.3 | 30.0 | 28.5 | 29.3 |
| **វាលទំនាប** | 20.9 | 20.8 | 19.5 | 19.0 | 18.8 | 20.5 |
| **បឹងទន្លេសាប** | 16.5 | 14.8 | 13.6 | 12.7 | 13.2 | 13.5 |
| **តំបន់ឆ្នេរ** | 20.2 | 18.8 | 17.5 | 16.4 | 15.0 | 16.5 |
| **ខ្ពង់រាប និងភ្នំ** | 13.4 | 11.8 | 11.8 | 12.0 | 11.9 | 12.8 |
| **សរុប** | 20.6 | 19.6 | 18.1 | 17.1 | 17.3 | 18.6 |

***ប្រភព***៖ *អយក.ឆ្នាំសិក្សា 2010 /11 និង 2015 /16*

ការចុះឈ្មោះចូលរៀននៅឧត្តមសិក្សាមានភាពប្រសើរឡើងហើយ ប៉ុន្តែនៅតែមានកម្រិតទាបនៅឡើយ។ អត្រាចុះឈ្មោះចូលរៀននៅកម្រិតឧត្តមសិក្សាសរុបត្រូវបានកំណត់នៅក្នុងរបាយការណ៍នេះថា ជាចំនួនសិស្សឧត្តមសិក្សា (ដោយមិនគិតពីអាយុ) ក្នុងចំណោមប្រជាជនសរុបដែលមានអាយុពី 18 ទៅ 22 ឆ្នាំ។ ដោយផ្អែកលើនិយមន័យនេះ នៅក្នុងឆ្នាំ 2014 យុវជនកម្ពុជាចំនួនប្រហែល 20 ភាគរយ បានចុះឈ្មោះចូលរៀននៅឧត្តមសិក្សា។ នេះគឺតំណាងឱ្យប្រសើរឡើងយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ 2004 ដែលនៅនោះពេលអត្រាចុះឈ្មោះចូលរៀនមានត្រឹមតែ 5 ភាគរយ ប៉ុណ្ណោះ (សូមមើល តារាង 1.8) ។ ចំណែកឯការចុះការឈ្មោះចូលរៀនរបស់យុវជននៅតាមជនបទ ក៏បានកើនឡើងផងដែរក្នុងអំឡុងពេលនេះ ទោះបីជានៅតែទាបជាងទីក្រុងច្រើនក៏ដោយ។ ចំពោះអត្រាចុះឈ្មោះចូលរៀននៅកម្រិតឧត្តមសិក្សារបស់យុវជនមកពីគ្រួសារដែលមានទ្រព្យធនច្រើន (ស្ថានភាពទ្រព្យធនកំពូល) ច្រើនជាងប្រាំពីរដង នៃយុវជនមកពីគ្រួសារក្រីក្របំផុត ដែលប្រការនេះបង្ហាញពី វិសមភាពលទ្ធភាពប្រាក់ចំណូលសម្រាប់ការតស៊ូរៀនដល់កម្រិតឧត្តមសិក្សា។

ការបោះបង់ការសិក្សានៅកម្រិតដំបូងនៅតែបន្ត និងរីករាលដាល។ ក្នុងឆ្នាំសិក្សា 2014/15 ទោះបីមានការកាត់ពូកិច្ចអប់រំក៏ដោយ ក៏អត្រាសិស្សបោះបង់ការសិក្សានៅបឋមសិក្សា(ថ្នាក់ទី 1-6) មានចំនួនរហូតដល់ 6 ភាគរយ និង 19 ភាគរយ នៅអនុវិទ្យាល័យ (ថ្នាក់ទី 7-9) ។ អត្រាបោះបង់ការសិក្សាត្រូវបានគណនាជាភាគរយនៃសិស្សបឋមសិក្សាអាយុចន្លោះពី 6 ទៅ 11 ឆ្នាំ និងសិស្ស

អនុវិទ្យាល័យអាយុពី 12 ទៅ 14 ឆ្នាំ ដែលមិនបានបញ្ចប់ការសិក្សាវដ្តអប់រំ ហើយដែលបច្ចុប្បន្ននៅក្រៅសាលា ប៉ុន្តែមិនរាប់បញ្ចូលកុមារដែលមិនធ្លាប់បានចូលរៀននៅសាលានោះទេ។ នៅចន្លោះឆ្នាំ 2010/11 និងឆ្នាំ2014/15 អត្រាបោះបង់ការសិក្សានៅសាលាបឋមសិក្សាបានថយចុះតិចតួច ប៉ុន្តែនៅអនុវិទ្យាល័យគឺនៅដដែល។ នៅតំបន់ខ្ពង់រាបឬតំបន់ភ្នំនិងរាជធានីភ្នំពេញ អត្រាសិស្សបោះបង់ការសិក្សានៅអនុវិទ្យាល័យបានកើនឡើង (សូមមើល តារាង 1.9)។ ទិន្នន័យរដ្ឋបាលរបស់ក្រសួង អយក. ត្រូវបានប្រើប្រាស់ដើម្បីគណនាអត្រាបោះបង់ការសិក្សា ព្រោះទិន្នន័យនេះមានទំហំធំជាងទិន្នន័យពីការស្ទង់មតិសេដ្ឋកិច្ចសង្គមនៅកម្ពុជា (Cambodia Socio-Economic Survey ហៅកាត់ថា CSES)។

ការរួមបញ្ចូលគ្នានៃអត្រាសិស្សបោះបង់ការសិក្សាខ្ពស់ និងអត្រាចុះឈ្មោះចូលរៀនទាបនៅកម្រិតបន្ទាប់បានបន្សល់ទុកនូវមនុស្សវ័យក្មេងតិចតួចក្នុងសាលារៀនប៉ុណ្ណោះ។ របាយការណ៍នេះបានប៉ាន់ប្រមាណថា 63 ភាគរយ នៃយុវជនដែលមានអាយុរៀននៅមធ្យមសិក្សា និងឧត្តមសិក្សាបានចាកចេញពីប្រព័ន្ធអប់រំ។ នៅឆ្នាំ 2015/16 ទោះបីជាអត្រាចុះឈ្មោះចូលរៀនសរុបនៅសាលាបឋមសិក្សាមានចំនួន 110 ភាគរយក៏ដោយ ក៏មានតែ 80 ភាគរយ នៃចុះឈ្មោះចូលរៀនទាំងនោះប៉ុណ្ណោះ ដែលបានបញ្ចប់វដ្តសិក្សានៅបឋមសិក្សា។ អត្រាចុះឈ្មោះចូលរៀន និងអត្រាបញ្ចប់វដ្តសិក្សាបានបន្តធ្លាក់ចុះនៅកម្រិតមធ្យមសិក្សា (សូមមើល រូបភាពទី 1.8 )។

**តារាង 8 (1-8) ការចុះឈ្មោះចូលរៀនសរុបនៅកម្រិតឧត្តមសិក្សាឆ្នាំ 2004 និង 2014**

| | | 2004 | | | 2014 | | |
|---|---|---|---|---|---|---|---|
| | | អត្រាចុះឈ្មោះចូលរៀនសរុប | ចំនួននៃការចុះឈ្មោះចូលរៀនឧត្តមសិក្សាគ្រប់វ័យ | ចំនួនប្រជាជនដែលមានអាយុរៀននៅឧត្តមសិក្សា (18-22 ឆ្នាំ) | អត្រាចុះឈ្មោះចូលរៀនសរុប | ចំនួននៃការចុះឈ្មោះចូលរៀនឧត្តមសិក្សាគ្រប់វ័យ | ចំនួនប្រជាជនដែលមានអាយុរៀននៅឧត្តមសិក្សា (18-22 ឆ្នាំ) |
| សរុប | | 4.9 | 412 | 8,375 | 20.3 | 1,131 | 5,570 |
| ប្រុស | | 6.6 | 273 | 4,129 | 23.4 | 635 | 2,715 |
| ស្រី | | 3.3 | 139 | 4,246 | 17.4 | 496 | 2,855 |
| តំបន់ | ទីក្រុង | 16.5 | 321 | 1,941 | 36.5 | 641 | 1,754 |
| | ជនបទ | 1.4 | 91 | 6,434 | 12.8 | 490 | 3,816 |
| ស្ថានភាពទ្រព្យធន (ទី1= ក្រីក្របំផុត ទី5=មាន បំផុត) | 1 | 0.2 | 3 | 1,494 | 2.6 | 29 | 1,118 |
| | 2 | 0.1 | 2 | 1,540 | 6.6 | 72 | 1,091 |
| | 3 | 0.4 | 6 | 1,625 | 15.6 | 177 | 1,134 |
| | 4 | 2.1 | 36 | 1,736 | 26.3 | 295 | 1,121 |
| | 5 | 18.4 | 365 | 1,980 | 50.5 | 558 | 1,106 |

*ប្រភព៖ CSES ឆ្នាំ 2004 និងឆ្នាំ 2014*

*ចំណាំ៖ ទិន្នន័យ CSES ត្រូវបានគេប្រើប្រាស់ ព្រោះអយក.មិនមានទិន្នន័យសម្រាប់ការអប់រំឧត្តមសិក្សា។ ឧត្តមសិក្សារួមបញ្ចូលទាំងសិស្សនិស្សិតមហាវិទ្យាល័យនិងសាកលវិទ្យាល័យ*

**តារាង 9 (1-9) អត្រាបោះបង់ការសិក្សាក្នុងឆ្នាំសិក្សា 2010/11 និង 2014/15**

| | ការបោះបង់ការសិក្សា នៅបឋមសិក្សា | | ការបោះបង់ការសិក្សា នៅមធ្យមសិក្សា | |
|---|---|---|---|---|
| | 2010/11 | 2014/15 | 2010/11 | 2014/15 |
| សរុប | 9.3 | 6.2 | 20.7 | 19.2 |
| ប្រុស | 9.7 | 7.2 | 20.7 | 20.3 |
| ស្រី | 8.8 | 5.2 | 20.8 | 18.2 |
| ភ្នំពេញ | 5 | 4.1 | 11.3 | 12.4 |
| វាលទំនាប | 6.1 | 4.6 | 22.6 | 19.5 |
| បឹងទន្លេសាប | 10.1 | 7.3 | 22.8 | 19.9 |
| តំបន់ឆ្នេរ | 8.9 | 6.4 | 21 | 18.3 |
| ខ្ពង់រាប និងភ្នំ | 11.8 | 7.3 | 17.7 | 19 |

*ប្រភព៖ អយក.ឆ្នាំសិក្សា 2010 /11 និង 2015 /16*

**រូបភាព 8 (1-8)អត្រាចុះឈ្មោះចូលរៀនសរុប និងបញ្ចប់ការសិក្សាតាមកម្រិត 2010/11 និង 2015/16**




***ប្រភព:*** *ក្រសួង អយក. ឆ្នាំ 2010/11 និង 2015/16, សូចនាករអប់រំ និងស្ថិតិ*

### ១.៣.៣ អត្រាឡើងថ្នាក់ និងត្រួតថ្នាក់

អត្រាឡើងថ្នាក់គឺស្រដៀងគ្នាទាំងក្មេងប្រុស និងក្មេងស្រី ដែលក្នុងនោះក្មេងស្រីប្រសើរជាងក្មេងប្រុស ប៉ុន្តែអត្រាឡើងថ្នាក់ជាមធ្យមរបស់សិស្សទាំងពីរភេទនៅបឋមសិក្សាគឺនៅជុំវិញ 85 ភាគរយ ក្នុងឆ្នាំ 2014/15។ អង្គការយូណេស្កូបានកំណត់និយមន័យនៃអត្រាឡើងថ្នាក់ថា ជាសមាមាត្រនៃសិស្សមួយក្រុមដែលបានចុះឈ្មោះចូលរៀនក្នុងថ្នាក់ណាមួយនៃឆ្នាំសិក្សា ហើយក្រោយពីបញ្ចប់ឆ្នាំ សិស្សនោះអាចបន្តការសិក្សានៅថ្នាក់បន្ទាប់ក្នុងឆ្នាំសិក្សាក្រោយទៀត។ ចំណែកអត្រាត្រួតថ្នាក់របស់យុវតីជាមធ្យមនៅបឋមសិក្សាមានចំនួន 4.9 ភាគរយ នៅក្នុងអំឡុង 2009-2014 បើប្រៀបធៀបទៅក្មេងប្រុសមានតែ 6.7 ភាគរយ ប៉ុណ្ណោះក្នុងរយៈពេលដូចគ្នានេះ។ ចំពោះអត្រាត្រួតថ្នាក់របស់សិស្សស្រីជាមធ្យមនៅអនុវិទ្យាល័យគឺ 1.15 ភាគរយ និង 1.7 ភាគរយ នៅវិទ្យាល័យ ក្នុងរយៈពេលដូចគ្នានេះ។ ចំណែកអត្រាត្រួតថ្នាក់របស់សិស្សប្រុសជាមធ្យមគឺ 2.4 ភាគរយនៅអនុវិទ្យាល័យ និង 3.0 ភាគរយ នៅវិទ្យាល័យ (សូមមើល តារាង 1.10)។ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ ខណៈពេលដែលអត្រាឡើងថ្នាក់ និងអត្រាត្រួតថ្នាក់នៅបឋមសិក្សាមានស្ថេរភាពរៀងគ្នាក្នុងឆ្នាំ2009/10 និងឆ្នាំ 2014/15 អត្រាឡើងថ្នាក់នៅវិទ្យាល័យបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ចំណែកអត្រាត្រួតថ្នាក់នៅវិទ្យាល័យក៏កើនឡើងដែរ ចាប់តាំងពីឆ្នាំ 2013 មក។

**តារាង 10 (1-10) អត្រាឡើងថ្នាក់ និងអត្រាត្រួតថ្នាក់ក្នុងឆ្នាំសិក្សា 2009 /10 និង2014 /15**

| | | 2009/10 | 2010/11 | 2011/12 | 2012/13 | 2013/14 | 2014/15 |
|---|---|---|---|---|---|---|---|
| **បឋមសិក្សា** | | | | | | | |
| អត្រាឡើងថ្នាក់ | ស្រី | 85.1 | 87.2 | 90.7 | 87.6 | 88.5 | 89.4 |
| | ប្រុស | 83.4 | 84.8 | 91.2 | 82.1 | 84.7 | 84.7 |
| | សរុប | 84.2 | 85.9 | 91.0 | 84.7 | 86.5 | 87.0 |
| អត្រាត្រួតថ្នាក់ | ស្រី | 6.2 | 5.0 | 4.5 | 4.1 | 4.3 | 5.3 |
| | ប្រុស | 7.9 | 6.5 | 6.0 | 5.5 | 6.0 | 8.1 |
| | សរុប | 7.1 | 5.8 | 5.3 | 4.8 | 5.1 | 6.7 |
| **អនុវិទ្យាល័យ** | | | | | | | |
| អត្រាឡើងថ្នាក់ | ស្រី | 78.6 | 76.9 | 80.3 | 78.3 | 78.5 | 80.5 |
| | ប្រុស | 78.3 | 76.1 | 76.9 | 76.5 | 75.8 | 76.6 |
| | សរុប | 78.4 | 76.5 | 78.5 | 77.4 | 77.2 | 78.6 |
| អត្រាត្រួតថ្នាក់ | ស្រី | 1.3 | 1.2 | 1.0 | 0.9 | 1.2 | 1.3 |
| | ប្រុស | 2.6 | 2.3 | 1.9 | 2.0 | 2.5 | 3.2 |
| | សរុប | 2.0 | 1.8 | 1.5 | 1.4 | 1.8 | 2.2 |
| **វិទ្យាល័យ** | | | | | | | |
| អត្រាឡើងថ្នាក់ | ស្រី | 88.2 | 85.4 | 89.1 | 86.8 | 71.4 | 75.3 |
| | ប្រុស | 85.1 | 83.0 | 87.5 | 82.3 | 65.8 | 70.7 |
| | សរុប | 86.4 | 84.1 | 88.2 | 84.4 | 68.5 | 73.0 |
| អត្រាត្រួតថ្នាក់ | ស្រី | 1.1 | 1.5 | 1.1 | 1.0 | 3.2 | 2.5 |
| | ប្រុស | 2.4 | 2.8 | 2.3 | 2.1 | 4.7 | 3.9 |
| | សរុប | 1.8 | 2.2 | 1.7 | 1.6 | 4.0 | 3.2 |

**ប្រភព:** អយក. 2009/10-2015/16

### ១.៣.៤ អត្រាទទួលបានការអប់រំ

អត្រាយុវជនអាយុពី 25 ទៅ 29 ឆ្នាំ ដែលទទួលបានការអប់រំខ្ពស់បំផុតត្រឹមបឋមសិក្សាបានធ្លាក់ចុះចាប់តាំងពីឆ្នាំ2004 ពោលគឺ ក្នុងឆ្នាំ 2014 ចំនួនយុវជនដែលទទួលបានការអប់រំខ្ពស់បំផុតនៅបឋមសិក្សាមានប្រហែល 47 ភាគរយ ហើយចំនួនយុវជនដែលទទួលបានការអប់រំខ្ពស់បំផុតនៅអនុវិទ្យាល័យមានតែ 29 ភាគរយ ប៉ុណ្ណោះ (សូមមើល រូបទី 1.9)។ ចំនួនមធ្យម នៃឆ្នាំដែលសិស្សបានចំណាយពេលនៅក្នុងសាលាគឺ 8.6 ឆ្នាំ គឺតិចជាងចំនួនឆ្នាំដែលតម្រូវឱ្យបញ្ចប់អនុវិទ្យាល័យ។ ផ្ទុយទៅវិញ ចំនួនយុវជនដែលបានទទួលការអប់រំនៅឧត្តមសិក្សាបានកើនឡើងយ៉ាងឆាប់រហ័សគឺប្រហែល 2 ភាគរយ 2004។ ហើយពុំមានយុវជនណាម្នាក់មិនបានចូលរៀននោះទេ។ អត្រាក្មេងស្រីដែលទទួលបានការអប់រំខ្ពស់បំផុតត្រឹមបឋមសិក្សាមានច្រើនជាងក្មេងប្រុស។ ចាប់ពីកម្រិតវិទ្យាល័យឡើង អត្រានេះគឺផ្ទុយគ្នាវិញ។

**រូបភាព 9 (1-9) អត្រាយុវជនទទួលបានការអប់រំ ក្នុងឆ្នាំសិក្សា 2004 និង 2014 (យុវជនអាយុ 25 ទៅ 29ឆ្នាំ គិតជាភាគរយ)**




*ប្រភព NIS (2005b) NIS (2015b) CSES ឆ្នាំ 2004 និងឆ្នាំ 2014*

### ១.៣.៥ លទ្ធផលសិក្សា

ពលរដ្ឋដែលបានបញ្ចប់កាតព្វកិច្ចអប់រំ យ៉ាងហោចណាស់ក៏គួរតែអាចចេះអាន សរសេរ និងយល់ន័យសេចក្តីក្នុងការប្រាស្រ័យទាក់ទងគ្នាប្រចាំថ្ងៃដែរ។ នៅទូទាំងពិភពលោក 9 ភាគរយ នៃយុវជនគឺជាអនក្ខរកម្ម ( យោងតាម អង្គការយូណេស្កូ 2015)។ យោងតាមការស្ទង់មតិសេដ្ឋកិច្ចសង្គមនៅកម្ពុជា (យោងតាម CSES) ឆ្នាំ 2014 បានឱ្យដឹងថា ប្រហែល 29 ភាគរយនៃចំនួនប្រជាជនសរុបនៅមានការខ្វះខាតជំនាញមូលដ្ឋានក្នុងការអាននិងការសរសេរ។ ទោះបីជា កម្រិតជំនាញនេះបានប្រសើរឡើងចាប់តាំងពី 10 ឆ្នាំមុនមកដែលនៅពេលនោះកម្រិតជំនាញនេះមានអត្រា 41 ភាគរយ ក៏ដោយ ក៏បច្ចុប្បន្ននេះ កម្រិតជំនាញនេះនៅតែគួរឱ្យបារម្ភនិងជាបញ្ហាចោទលើគុណភាពនៃការអប់រំនៅបឋមសិក្សា។

ប្រទេសកម្ពុជាមានអត្រាអក្ខរកម្មទាបបំផុតទីពីរក្នុងចំណោមបណ្តាប្រទេសអាស៊ានបន្ទាប់ពីប្រទេសឡាវ។ អត្រាអក្ខរកម្មក្នុងចំណោមយុវជនដែលមានអាយុចន្លោះពី 15 ទៅ 24 ឆ្នាំ មានចំនួន 91 ភាគរយ ចំណែកមនុស្សពេញវ័យដែលមានអាយុចន្លោះពី 18 ទៅ 40 ឆ្នាំ មានចំនួន 85 ភាគរយ (សូមមើល តារាង 1.11) ដែលបានបង្ហាញថា អ្នកជំនាន់ថ្មីមានការអប់រំល្អប្រសើរជាងឪពុកម្តាយរបស់ពួកគេ។ ទ្រព្យសម្បត្តិរបស់គ្រួសារក៏ហាក់ដូចជាមានបញ្ហាផងដែរនៅពេលដែលនិយាយពីអក្ខរកម្ម ព្រោះថា យុវជនដែលមកពីគ្រួសារអ្នកមានទំនងជាមានអត្រាអក្ខរកម្មខ្ពស់ជាងអ្នកដែលមកពីគ្រួសារក្រីក្រ ដែលគម្លាតនេះខុសគ្នាដល់ទៅ 25 ភាគរយ។ អត្រាអក្ខរកម្មនៅតំបន់ទន្លេសាបហាក់នៅពីក្រោយគេបំផុតបើធៀបនឹងតំបន់ផ្សេងទៀត (សូមមើល រូបភាពទី 1.10)។ យ៉ាងហោចណាស់ 50 ភាគរយ នៃយុវជនពិការអាចចេះអាន និងចេះសរសេរ។

**តារាង 11 (1-11) អត្រាយុវជនចេះអក្សរសរុប និងស្ថានភាពទ្រព្យធន ក្នុងឆ្នាំ 2004 និងឆ្នាំ 2014**

| | | 2004 | | | 2014 | | |
|---|---|---|---|---|---|---|---|
| | | អត្រាអក្ខរកម្ម | ចំនួនអ្នកអក្ខរកម្ម | ចំនួនប្រជាជនសរុប | អត្រាអ្នកអក្ខរកម្ម | ចំនួនអ្នកអក្ខរកម្ម | ចំនួនប្រជាជនសរុប |
| ចំនួនប្រជាជនសរុប | សរុប | 59 | 43,788 | 74,719 | 71 | 36,522 | 51,212 |
| | ប្រុស | 64 | 23,151 | 35,942 | 76 | 18,562 | 24,476 |
| | ស្រី | 53 | 20,637 | 38,777 | 67 | 17,960 | 26,736 |
| ស្ថានភាពទ្រព្យធន | 1 (ក្រីក្របំផុត) | 42 | 6,322 | 14,947 | 56 | 5,738 | 10,245 |
| | 2 | 53 | 7,923 | 14,941 | 65 | 6,679 | 10,243 |
| | 3 | 58 | 8,659 | 14,945 | 73 | 7,427 | 10,241 |
| | 4 | 65 | 9,639 | 14,944 | 78 | 7,944 | 10,242 |
| | 5 | 75 | 11,245 | 14,942 | 85 | 8,734 | 10,241 |
| យុវជនអាយុពី 15-24 ឆ្នាំ | សរុប | 81 | 13,927 | 17,147 | 91 | 9,829 | 10,773 |
| | ប្រុស | 85 | 7,209 | 8,490 | 91 | 4,869 | 5,340 |
| | ស្រី | 78 | 6,718 | 8,657 | 91 | 4,960 | 5,433 |
| ស្ថានភាពទ្រព្យធនយុវជន | 1 (ក្រីក្របំផុត) | 67 | 2,072 | 3,095 | 82 | 1,757 | 2,144 |
| | 2 | 76 | 2,525 | 3,305 | 88 | 1,844 | 2,107 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | 3 | 81 | 2,717 | 3,364 | 94 | 2,072 | 2,204 |
| | 4 | 86 | 3,053 | 3,552 | 95 | 2,025 | 2,124 |
| | 5 | 93 | 3,560 | 3,831 | 97 | 2,131 | 2,194 |

*ប្រភព៖ CSES ឆ្នាំ2004-14*

**រូបភាព 10 (1-10) អត្រាយុវជនចេះអក្សរតាមតំបន់ក្នុងឆ្នាំ 2004 និងឆ្នាំ 2014 (គិតជា ភាគរយ)**




*ប្រភព៖ CSES ឆ្នាំ2004-14*

**១.៣.៦ អត្រាការងារ**

នៅទូទាំងពិភពលោក យុវជនចំនួន 13,1ភាគរយ នៃយុវជនទាំងអស់គ្មានការងារធ្វើ (យោងតាមអង្គការ ILO ឆ្នាំ 2016)។ ច្រើនជាងមួយភាគបី (37.7 ភាគរយ) នៃយុវជនដែលមានការងារធ្វើនៅអាយុចន្លោះពី 15 ទៅ 24 ឆ្នាំនៅក្នុងប្រទេសកំពុងអភិវឌ្ឍគឺជាជនក្រីក្រ ហើយយុវជនចំនួន 17.7 ភាគរយ រស់នៅក្នុងភាពក្រីក្រខ្លាំងដែលមានចំណូលតិចជាង 1.25 ដុល្លារអាមេរិកក្នុងមួយថ្ងៃ (យោងតាមអង្គការ ILO ឆ្នាំ2016)។ យុវជនមកពីគ្រួសារក្រីក្រមានទំនោរទៅរកការឆាប់ចាកចេញពីសាលានិងទទួលយកការងារណាមួយទោះបីជាប្រាក់ខែទាប និងលក្ខខណ្ឌការងារពុំមានសុវត្ថិភាពក៏ដោយ។ នេះធ្វើឱ្យគេជាប់អន្ទាក់ក្នុងការងារជំនាញទាប និងគុណភាពទាបដែលជាទូទៅជាការងារក្នុងវិស័យក្រៅផ្លូវការដែលងាយនឹងឱ្យពួកគេរងគ្រោះ តក់ស្លុត និងមានឱកាសតិចតួចប៉ុណ្ណោះក្នុងស្វែងរកការងារល្អប្រសើរ។ ការងារបែបនេះបានប៉ះពាល់ដល់យុវជនរហូតដល់ 14 ភាគរយ នៃយុវជនចំនួន(169 លាននាក់) នៅលើពិភពលោក ហើយចំនួននេះខិតជិតដល់ 25 ភាគរយ ប្រសិនបើរាប់បញ្ចូលទាំងអ្នកដែលមានជីវភាពលើកម្រិតក្រីក្របន្តិច គឺអ្នកដែលមានចំណូលក្រោម 4 ដុល្លា ក្នុងមួយថ្ងៃ (យោងតាមអង្គការ ILO ឆ្នាំ2015)។ សូចនាកររាស់ស្ទង់លទ្ធផលការងារនៅក្នុងប្រទេសកំពុងអភិវឌ្ឍជាធម្មតារាប់បញ្ចូលអត្រានៃយុវជនដែលមិនមានការងារធ្វើ មិនបានទទួលការអប់រំ ឬការបណ្តុះបណ្តាល (ហៅកាត់ថា NEET) អត្រាការងារក្រៅផ្លូវការ ភាគរយនៃយុវជនមានប្រាក់ខែតិច និងភាពមិនស្របនឹងជំនាញ។

**១.៣.៧ ការចូលរួមកម្លាំងពលកម្ម និងគុណភាពការងារ**

នៅប្រទេសកម្ពុជា ការចូលរួមកម្លាំងពលកម្មរបស់យុវជនដែលមានអាយុចន្លោះពី 15 ទៅ 29 ឆ្នាំមានអត្រាខ្ពស់រហូតដល់ 76 ភាគរយ ក្នុងឆ្នាំ 2014 ប៉ុន្តែអត្រាអ្នកគ្មានការងារធ្វើមានកម្រិតទាប គឺនៅជុំវិញ 0.7 ភាគរយ (យោងតាម CSES ឆ្នាំ 2014)។ អត្រាអ្នកគ្មានការងារធ្វើនៅក្នុងប្រទេសកំពុងអភិវឌ្ឍជាធម្មតាមានកម្រិតទាប ដោយសារតែយុវជនភាគច្រើនទទួលយកការងារដោយមិនគិតពីប្រាក់ខែ ឬលក្ខខណ្ឌការងារ។ ដូច្នេះ សូចនាករនេះមិនបានឆ្លុះបញ្ចាំងពីគុណភាពនៃការងារនោះទេ។ នៅក្នុងឆ្នាំ 2014 យុវជនចំនួន 40 ភាគរយ ធ្វើការឱ្យខ្លួនឯង (ឬកម្មករគណនីផ្ទាល់ខ្លួន) ឬធ្វើការឱ្យគ្រួសារដោយគ្មានប្រាក់ខែដែលត្រូវចាត់ទុកថាជាការងារដែលងាយរងគ្រោះ។ ទោះបីអត្រាអ្នកគ្មានការងារធ្វើប្រសើរឡើងពី 10 ឆ្នាំមុនដែលនៅនោះមានអត្រានេះមានចំនួន 73 ភាគរយ ក៏ដោយ ក៏ភាគរយនៃកម្មករយុវជនដែលងាយរងគ្រោះនេះនៅតែជាបញ្ហាសំខាន់។ ការងារទាំងនេះធម្មតាគឺជាការរៀបចំមិនផ្លូវការ គ្មានការការពារពីសង្គមនិងទទួលបានប្រាក់ខែតិចតួច។ យុវជនភាគច្រើន (69 ភាគរយ) បានទទួលយកការងារងាយរងគ្រោះ ដែលត្រូវបានគេរកឃើញនៅក្នុងវិស័យកសិកម្ម (សូមមើល រូបភាព 1.11.B) ។ តាមការប្រៀបធៀប ក្នុងចំណោមយុវជនសរុបដែលមានការងារធ្វើ និងមានអាយុពី 15 ទៅ 29 ឆ្នាំ ចំនួន 50 ភាគរយ បានធ្វើការក្នុងវិស័យកសិកម្ម 16 ភាគរយ ក្នុងវិស័យឧស្សាហកម្ម និង 34 ភាគរយ ក្នុងវិស័យសេវាកម្ម (យោងតាម ILO SWTS 2013) (សូមមើល រូបភាព 1.11.A)។ យុវជនយុវតីវ័យក្មេងមកពីគ្រួសារក្រីក្រក៏ទំនងជាស្ថិតក្នុងការងារងាយរងគ្រោះដែរ។ យោងតាមអង្គការ ILO បានឱ្យដឹងថា ការងារងាយរងគ្រោះត្រូវបានកំណត់តាមរយៈការរកប្រាក់ចំណូលមិនគ្រប់គ្រាន់ ផលិតភាពទាប និងលក្ខខណ្ឌការងារលំបាក ដែលប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់កម្មករ។

**រូបភាព 11 (1-11) បំណែងចែកយុវជនដែលធ្វើការងារងាយរងគ្រោះតាមវិស័យ ឆ្នាំ2014**




*__ប្រភព__: NIS (ឆ្នាំ 2015b) ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ 2014|*

73 ភាគរយ នៃយុជនដែលមានការងារមានប្រាក់ខែរកប្រាក់ចំណូលបានក្រោមមធ្យម។ នៅក្នុងឆ្នាំ 2014 ប្រាក់ខែជាមធ្យមរបស់យុវជនដែលមានអាយុពី 15 ដល់ 29 ឆ្នាំ មានចំនួន 4,6 ភាគរយ ទាបជាងមនុស្សពេញវ័យ និងទាបជាងចំនួនប្រជាជនសរុបដែលមានចំនួន 4,3 ភាគរយ ។ យុវនារីទទួលបានប្រាក់ខែទាបជាងយុវបុរសចំនួន 11ភាគរយ ។ ជាការពិត បុគ្គលិកទទួលបានប្រាក់ខែជាលុយខ្មែរចំនួន 86328 រៀល ក្នុងមួយសប្តាហ៍នៅក្នុងឆ្នាំ 2014 គឺច្រើនជាង10 ឆ្នាំមុនចំនួន 16 ភាគរយ ។ អត្រាប្រាក់ខែពិតប្រាកដរបស់យុវជនដែលធ្វើការនៅតំបន់វាលទំនាបមានកម្រិតទាបជាងគេបំផុតក្នុងចំណោមតំបន់ទាំងអស់ ខណៈដែលអត្រាប្រាក់ខែខ្ពស់បំផុតគឺ (105107៛ ក្នុងមួយសប្តាហ៍) នៅក្នុងរាជធានីភ្នំពេញ។ គម្លាតប្រាក់ខែរវាងតំបន់ទាំងពីរគឺ 27 ភាគរយ។ យុវជនដែលធ្វើការឱ្យខ្លួនឯង (ឬកម្មករគណនីផ្ទាល់ខ្លួន) ទទួលបានប្រាក់ចំណូលចំនួន 44 932៛ ក្នុងមួយសប្តាហ៍ ពោលគឺ 48 ភាគរយ ទាបជាងប្រាក់ខែមធ្យមរបស់និយោជិតយុវជន។ អង្គការពលកម្មអន្តរជាតិបានកំណត់និយមន័យនៃការងារសមរម្យ ថា៖ ជាការងារដែលមានផលិតភាព ផ្តល់ប្រាក់ចំណូលសមរម្យ សន្តិសុខនៅកន្លែងការងារ មានការការពារពីសង្គមដល់ក្រុមគ្រួសារ មានលទ្ធផលល្អសម្រាប់អភិវឌ្ឍខ្លួននិងសមាហរណកម្មសង្គម មានសេរីភាពក្នុងការបង្ហាញពីការព្រួយបារម្ភរបស់ខ្លួន អាចរៀបចំ និងចូលរួមនៅក្នុងការសម្រេចចិត្តណាដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ មានឱកាស និងការគោរពប្រតិបត្តិចំពោះបុរសនិងស្ត្រីទាំងអស់ស្មើគ្នា។ មិនថានិយោជិតឬអ្នកដែលធ្វើការឱ្យខ្លួនឯងទេ លក្ខខណ្ឌការងាររបស់យុវជននៅមានគុណភាពទាប និងមិនទៀងទាត់។

**តារាង 12 (1-12) ភាគរយនៃយុវជនដែលមានអាយុពី 15ទៅ29 ឆ្នាំដែលរកប្រាក់ចំណូលបានក្រោមប្រាក់ខែឬប្រាក់ចំណូលមធ្យម (ភាគរយនៃការងារតាមប្រភេទ) ឆ្នាំ 2014**

| % | | ការងារមានប្រាក់ខែ | | ការងារខ្លួនឯង | ការងារសរុប |
|---|---|---|---|---|---|
| | | **2004** | **2014** | **2014** | **2014** |
| | **សរុប** | 87.5 | 73.0 | 47.4 | 49.1 |
| | ស្ត្រី | 86.5 | 69.1 | 45.8 | 47.9 |
| | បុរស | 88.5 | 77.4 | 49.0 | 50.3 |
| តំបន់ | ភ្នំពេញ | 66.4 | 57.2 | 53.4 | 50.2 |
| | ទំនាប | 91.3 | 81.1 | 50.6 | 55.7 |
| | ទន្លេសាប | 92.1 | 72.2 | 42.5 | 41.1 |
| | ឆ្នេរ | 92.6 | 80.4 | 47.5 | 46.7 |
| | ភ្នំ/ខ្ពង់រាប | 93.5 | 79.7 | 51.0 | 50.7 |
| ស្ថានភាពទ្រព្យធន (1=ក្របំផុត, 5=មានបំផុត) | 1 | 94.7 | 82.1 | 62.1 | 60.0 |
| | 2 | 94.9 | 80.4 | 49.5 | 52.3 |
| | 3 | 91.7 | 77.6 | 41.9 | 50.7 |
| | 4 | 89.4 | 70.3 | 40.4 | 45.4 |
| | 5 | 70.6 | 51.1 | 44.1 | 34.2 |

*__ចំណាំ__: ទិន្នន័យ 2004 សម្រាប់ខ្លួនឯងមិនមាន*

*__ប្រភព:__ NIS (ឆ្នាំ 2015b) ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ 2014*

### ១.៣.៨ ស្ថានភាពការងារយុវជន

បន្ទាប់ពីការពង្រីកវិស័យរោងចក្រកាត់ដេរនិងវិស័យទេសចរណ៍ យុវជនបានផ្លាស់ប្តូរពីការងារកសិកម្មទៅរកការងារផ្នែកសេវាកម្ម និងឧស្សាហកម្មជាការងារមានប្រាក់ខែ ដែលធ្វើឱ្យចំនួនយុវជនមានការងារធ្វើកើនឡើង។ ភាគរយនៃការងារមានផលិតភាពនិងការងារសមរម្យគឺជាមធ្យោបាយសំខាន់ក្នុងការជួយយុវវ័យឱ្យមានឯករាជ្យផ្នែកហិរញ្ញវត្ថុ ទទួលបានការជឿជាក់លើខ្លួនឯងនិងស្ថានភាពសង្គម និងកសាងអនាគតមួយសម្រាប់ខ្លួន។ ដោយសារតែយុវជនដែលមានអាយុពី 15 ទៅ 29 ឆ្នាំបានកើនឡើងចំនួន 43 ភាគរយ នៃចំនួនប្រជាជនដែលមានអាយុធ្វើការសរុបនៅក្នុងប្រទេសកម្ពុជា ការធានាថា យុវជនសព្វថ្ងៃដែលមានលទ្ធភាពរកការងារមានគុណភាពគឺពិតមានសារៈសំខាន់ក្នុងការកសាងកម្លាំងពលកម្មប្រកបដោយគុណវុឌ្ឍិ និងផលិតភាព។ ពុំមានការប្រសើឡើងនៅក្នុងផលិតភាពនោះទេ ទាំងវិស័យសេវាកម្ម និងឧស្សាហកម្ម ហើយការងារភាគច្រើនទាមទារជំនាញកម្រិតទាបដូចជាមុខរបរដែលទាក់ទងនឹងសិប្បកម្ម ឬការងារបឋមនៅក្នុងរោងចក្រ (យោងតាម ADB ឆ្នាំ2015)។ អត្រាការងាររបស់យុវជននៅក្នុងឆ្នាំ 2014 មានចំនួន 76 ភាគរយ ចំណែកអត្រាការងារមនុស្សពេញវ័យ (18 ទៅ 40 ឆ្នាំ) មានចំនួន 86 ភាគរយ។ នៅឆ្នាំ 2014 ក្នុងចំណោមយុវជនដែលមានការងារមានប្រាក់ខែ មានយុវជនចំនួន 59 ភាគរយ ដែលនៅឆ្នាំ 2004 មានយុវជនតែ 26 ភាគរយប៉ុណ្ណោះ។ ចំណែកភាគរយនៃកម្មករធ្វការឱ្យគ្រួសារដោយគ្មានប្រាក់ខែបានថយចុះយ៉ាងខ្លាំងក្នុងរយៈពេលដូចគ្នា គឺពី 53 ភាគរយ ទៅ 9 ភាគរយ ។ យុវជនកំពុងតែផ្លាស់ប្តូរពីការងារកសិកម្មទៅរកការងារផ្នែកសេវាកម្ម និងការលក់ដូរ។ ប្រភាគនៃអ្នកគ្រប់គ្រងបានធ្លាក់ចុះគួរឱ្យកត់សម្គាល់នៅក្នុងចំណោមកម្លាំងការងារសរុបនៅក្នុងប្រទេសកម្ពុជា ដែលជាគម្លាតមួយ ដែលត្រូវបំពេញយ៉ាងពិតប្រាកដ (យោងតាម ADB ឆ្នាំ 2015) ។

**រូបភាព 12 (1-12) បំណែងចែកការងារយុវជនតាមស្ថានភាពការងារគិតជា ភាគរយ ក្នុងឆ្នាំ 2004 និងឆ្នាំ 2014**




Source: CSES 2004 and 2014

ក្នុងឆ្នាំ 2012 ក្នុងចំណោមយុវជនដែលមានការងារធ្វើមានអាយុចាប់ពី 15 ឆ្នាំដល់ 30 ឆ្នាំមាន 50 ភាគរយនៅក្នុងវិស័យកសិកម្ម 16 ភាគរយ នៅក្នុងវិស័យឧស្សាហកម្ម និង 34 ភាគរយ ជាអ្នកផ្តល់សេវាកម្ម (Kanol, Khemarin and Elder ឆ្នាំ 2013) (សូលមើល រូបភាព 1.13) ។

**រូបភាព 13 (1-13) បំណែងចែកការងារយុវជនតាមស្ថានភាពការងារ ឆ្នាំ 2012**




*ប្រភព :Kanol, Khemarin និង Elder ឆ្នាំ 2013) ការផ្លាស់ប្តូរទីផ្សារការងាររបស់ស្ត្រី និងបុរសវ័យក្មេងនៅកម្ពុជា*

### ១.៣.៩ NEET និងយុវជនអសកម្ម

NEET សំដៅលើចំនួនយុវជនដែលមិនមានការងារធ្វើ មិនបានទទួលការអប់រំ ឬការបណ្តុះបណ្តាល។ ចំនួននេះរាប់ទាំងយុវជនមិនមែនសិស្សមិនមានការងារនិងកំពុងស្វែងរកការងារធ្វើ និងយុវជនមិនមែនសិស្សដែលលមិនសកម្មក្នុងការស្វែងរកការងារ (ឬយើងហៅថា ជនអសកម្មដែលមិនមែនជាសិស្ស)។ នៅក្នុងប្រទេសកម្ពុជា អត្រាយុវជន NEET មានចំនួ 6,4 ភាគរយ នៅក្នុងឆ្នាំ 2014 ដែលនៅក្នុងនោះមានជនអសកម្មដែលមិនមែនសិស្សចំនួន 6,2 ភាគរយ និងយុវជនមិនមែនសិស្សដែលមិនមាន ការងារធ្វើចំនួន 0,2 ភាគរយ។ នេះគឺជាការធ្លាក់ចុះមួយ ព្រោះនៅក្នុងឆ្នាំ 2004 អត្រាយុវជន NEET មានចំនួន 8,7 ភាគរយ ។ នៅក្នុងឆ្នាំ 2014 ស្ត្រីវ័យក្មេងចំនួន 10,4 ភាគរយ គឺជា NEET ខណៈដែលបុរសវ័យក្មេងចំនួន 2,2 ភាគរយ គឺជា NEETs (យោងតាមតារាង 1.12) ។ អត្រាយុវជន NEET នៅតំបន់ទីក្រុងមានចំនួន 6,7 ភាគរយ និង 6,3 ភាគរយ នៅជនបទ។ ប្រវត្តិគ្រួសារក៏ធ្វើឱ្យមានភាពខុសគ្នាផងដែរ ព្រោះថា NEET មានចំនួន 7,9 ភាគរយ ក្នុងគ្រួសារស្ថានភាពក្រីក្របំផុត ប៉ុន្តែនៅក្នុងគ្រួសារស្ថានភាពទ្រព្យធនខ្ពស់ NEET មានចំនួន ត្រឹមតែ 5,2 ភាគរយ ប៉ុណ្ណោះ ចំណែក 38 ភាគរយ នៃ NEET ផ្សេងទៀតគឺចេញមកពីគ្រួសារកសិករ។ នៅតំបន់ទន្លេសាបមានចំនួន NEET ខ្ពស់បំផុតគឺ 6.8 ភាគរយ (យោងតាម CES 2014)។

**តារាង 13 (1-13) អត្រា NEET ក្នុងចំណោមយុវជនអាយុពី 15 ទៅ 29 ឆ្នាំ គិតជាភាគរយ តាមភេទ និងតំបន់ ឆ្នាំ 2004 និងឆ្នាំ 2014**

| | | 2004 | | | 2014 | | |
|---|---|---|---|---|---|---|---|
| | | NEET | អ្នកអត់ការងារធ្វើដែលមិនមែនសិស្ស | អ្នកអសកម្មដែលមិនមែនសិស្ស | NEET | អ្នកអត់ការងារធ្វើដែលមិនមែនសិស្ស | អ្នកអសកម្មដែលមិនមែនសិស្ស |
| **យុវជន** (ភាគរយ) | **សរុប** | 8.73 | 0.70 | 8.03 | 6.39 | 0.15 | 6.24 |
| | ប្រុស | 4.71 | 0.77 | 3.94 | 2.24 | 0.14 | 2.10 |
| | ស្រី | 12.64 | 0.63 | 12.01 | 10.41 | 0.16 | 10.25 |
| **តំបន់** (ភាគរយ) | ភ្នំពេញ | 12.18 | 2.36 | 9.82 | 5.08 | 0.11 | 4.97 |
| | តំបន់ទំនាប | 7.34 | 0.41 | 6.93 | 6.45 | 0.14 | 6.31 |
| | តំបន់ទន្លេ | 8.29 | 0.64 | 7.65 | 6.77 | 0.23 | 6.54 |
| | តំបន់ឆ្នេរ | 12.98 | 0.76 | 12.22 | 6.62 | 0.13 | 6.49 |
| | តំបន់ភ្នំនិងខ្ពង់រាប | 8.61 | 0.10 | 8.51 | 7.02 | 0.08 | 6.94 |
| **ពិការភាព (ភាគរយ ក្នុងចំណោមប្រជាជនអសមត្ថភាព)** | | 19.66 | 0.75 | 18.91 | 42.59 | 0.00 | 42.59 |

*__ប្រភព__៖ CSES ឆ្នាំ 2004 និងឆ្នាំ 2014*

*__ចំណាំ__៖ NEET = ចំនួនយុវជនអត់ការងារដែលមិនមែនជាសិស្ស + យុវជនអសកម្មដែលមិនមែនជាសិស្ស*

ភាគច្រើននៃ NEET (*ចំនួននៃយុវជនដែលមិនមានការងារធ្វើ មិនបានទទួលការអប់រំ ឬការបណ្តុះបណ្តាល*) គឺយុវជនអសកម្ម។ មានន័យថា យុវជនអសកម្មមានរហូតដល់ 97 ភាគរយ នៃយុវជន NEET សរុប។ ដូច្នេះហើយមានតែ 3,0 ភាគរយ នៃយុវជនមិនមែនសិស្សប៉ុណ្ណោះ ដែលកំពុងសកម្មរកការងារធ្វើ។ ទោះបីជាភាគច្រើននៃ NEET ជាស្ត្រី (83 ភាគរយ) ហើយចំនួននេះអាចបង្ហាញពីកម្រិតនៃភាពអសកម្មដែលស្ត្រីកម្ពុជាភាគច្រើនឈប់ធ្វើការក្រោយពេលរៀបការរួចក៏ដោយ ក៏អត្រា NEET បានបង្កប់នៅក្នុងចំណោមអ្នកដែលបាក់ទឹកចិត្ត ដែលបានបោះបង់ការស្វែងរកការងារ ដោយហេតុផលច្បាស់លាស់ច្រើនជាងជម្រើសផ្ទាល់ខ្លួនដែរ (សូមមើល ជំពូកទី 4) ។ ការធ្លាក់ទឹកចិត្តដោយសារខ្វះឱកាស និងធនធាន ជាពិសេសនៅតាមតំបន់ជនបទ គួបផ្សំនឹងគុណវុឌ្ឍិទាប និងភាពជឿជាក់លើខ្លួនឯងទាបផងនោះ ជំរុញឱ្យយុវជនរួមទាំងស្ត្រីផងដែរ ក្លាយទៅជាអសកម្ម និងបោះបង់ការស្វែងរកការងារធ្វើ។ ចំនួននៃអ្នកធ្លាក់ទឹកចិត្តនេះគឺពិបាកក្នុងការចាប់យកណាស់ និងបានបង្កប់នៅក្នុងចំណោមយុវជនអសកម្ម។

**១.៣.១០ ម៉ោងធ្វើការ**

ម៉ោងធ្វើការមធ្យមរបស់យុវវ័យគឺ 46 ម៉ោងមួយសប្តាហ៍ ស្រដៀងគ្នានឹងមនុស្សពេញវ័យដែរ ហើយធៀបនឹងអ្នកធ្វើការទូទៅគឺតិចជាងពីរម៉ោង។ ស្ត្រីវ័យក្មេង (អាយុចន្លោះពី 15 ទៅ 29 ឆ្នាំ) ធ្វើការតិចម៉ោងជាងបុរសវ័យក្មេង។ នៅឆ្នាំ 2014 យុវជនដែលធ្វើការក្នុងវិស័យកសិកម្ម ត្រូវធ្វើការចំនួន 36 ម៉ោង ក្នុងមួយសប្តាហ៍ ពោលគឺក្នុងមួយសប្តាហ៍ ពួកគេធ្វើការតិចជាងវិស័យផ្សេងទៀតចំនួន14 ម៉ោង។ អ្នកដែលធ្វើការនៅក្នុងវិស័យឧស្សាហកម្ម ពួកគេធ្វើការចំនួន 54 ម៉ោង និងអ្នកដែលធ្វើការនៅក្នុងវិស័យសេវាកម្ម ពួកគេធ្វើការចំនួន 50 ម៉ោង ក្នុងមួយសប្តាហ៍។ កម្មករគណនីផ្ទាល់ខ្លួនធ្វើការចំនួន 36 ម៉ោង ក្នុងមួយសប្តាហ៍ ហើយកម្មករធ្វើការឱ្យគ្រួសារគ្មានប្រាក់ខែ ពួកគេធ្វើការតិចជាងកម្មករកគណនីផ្ទាល់ខ្លួន (យោងតាម CSES ឆ្នាំ 2014)។

មាត្រា 137 នៃច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា ក្នុងគ្រឹះស្ថានបែបណាក៏ដោយ ទោះបីគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងវិជ្ជាជីវៈសេរី ក៏ដោយ ថេរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវឱ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងក្នុងមួយអាទិត្យឡើយ។ ភាគច្រើននៃយុវជន (86 ភាគរយ) ដែលមានការងារ ពួកគេធ្វើការយ៉ាងហោចណាស់ 40 ម៉ោងក្នុងមួយអាទិត្យ។ ពីរភាគបីនៃយុវជនដែលធ្វើការ ពួកគេធ្វើការលើសម៉ោង (50 ម៉ោងក្នុងមួយអាទិត្យ ឬច្រើនជាងនេះ ក្នុងមួយអាទិត្យ) (យោងតាម ILO SWTS ឆ្នាំ 2013)។

ភាពអត់ការងារពាក់ព័ន្ធនឹងម៉ោងធ្វើការ ប៉ះពាល់ដល់មួយចំនួនតូចនៃយុវជនដែលកំពុងធ្វើការ។ ភាពអត់ការងារពាក់ព័ន្ធនឹងម៉ោងធ្វើការ ធ្វើឱ្យយុវជនដែលកំពុងមានឆន្ទៈ និងអាចបង្កើនម៉ោងធ្វើការ មានការព្រួយបារម្ភនៅពេលដែលពួកគេធ្វើការបានតិចជាងចំនួនម៉ោងកំណត់ (40 ម៉ោងក្នុងមួយអាទិត្យ ជាអន្តរជាតិ)។ នៅឆ្នាំ 2014 យុវជនប្រហែល 0,2 ភាគរយ អត់ការងារធ្វើ ដែលជាការធ្លាក់ចុះមួយ ព្រោះនៅឆ្នាំ 2004 យុវជនប្រហែលអត់ការងារធ្វើមានចំនួន 7.2 ភាគរយ (យោងតាម CSES ឆ្នាំ 2014)។

**១.៣.១១ ភាពមិនស៊ីគ្នារវាងគុណវុឌ្ឍិនឹងមុខរបរ**

គេយល់ថា កម្លាំងពលកម្មនៅកម្ពុជាមានចំណេះដឹងតិចតួចនិងមានជំនាញទាប។ ភាពមិនស្របគ្នារវាងនឹងគុណវុឌ្ឍិនិងមុខរបរនេះគឺជាបញ្ហាធំបំផុតក្នុងទីផ្សារការងារនៃប្រទេសកម្ពុជា។ និយោជកមិនអាចរកបេក្ខជនដែលមានគុណវុឌ្ឍិមកបំពេញដំណែងប្រកាស រីឯយុវជនវិញកំពុងតស៊ូធ្វើការដែលមានគុណភាពខ្សោយ។ ភាពមិនស្របរវាងនឹងគុណវុឌ្ឍិនិងមុខរបររបស់យុវជនត្រូវបានគណនាតាមប្រភេទជំនាញវិជ្ជាជីវៈនៃចំណាត់ចាត់ថ្នាក់មុខរបរអន្តរជាតិ (International Standard Classification of Occupations ហៅកាត់ថា ISCO) និងចំណាត់ថ្នាក់សម្រាប់ស្តង់ដា នៃការអប់រំអន្តរជាតិ (International Standard Classification of Education ហៅកាត់ថា ISCED) ។ គេធ្វើការបានផ្គូផ្គងមុខរបរចំនួន១០ក្រុមទៅនឹងកម្រិត ISCED ចំនួន 6 កម្រិត (សូមមើល តារាង 1.13)។

**តារាង 14 (1-14) ក្រុមមុខរបរនៅក្នុងចំណាត់ថ្នាក់របស់ ISCO និងកម្រិតអប់រំ**

| ចំណាត់ចាត់ថ្នាក់មុខរបរអន្តរជាតិ (ISCO) | | កម្រិតជំនាញ | កម្រិតសិក្សា |
|---|---|---|---|
| 1 | អ្នកតាក់តែងច្បាប់ មន្ត្រីជាន់ខ្ពស់ និងអ្នកគ្រប់គ្រង | ជំនាញខ្ពស់ មិនដោយដៃ | ឧត្តមសិក្សា (ISCED 5-6) |
| 2 | អ្នកជំនាញ | | |
| 3 | អ្នកបច្ចេកទេសនិងអ្នកជំនាញសហការី | | |
| 0 | កងកម្លាំងប្រដាប់អាវុធ | ជំនាញទាប មិនដោយដៃ | មធ្យមសិក្សា (ISCED 3-4) |
| 4 | ជំនួយការស្មៀន | | |
| 5 | កម្មករសេវាកម្មនិងលក់ | | |
| 6 | កម្មករជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជំនាញដោយដៃ | |
| 7 | សិប្បករ និងអាជីវករសិប្បកម្ម | | |
| 8 | អ្នកដំឡើង និងប្រតិបត្តិការម៉ាស៊ីន និងរោងចក្រ | | |
| 9 | មុខរបរបន្ទាប់បន្សំ | គ្មានជំនាញ | បឋមសិក្សា (ISCED 1-2) |

*ប្រភព៖ អង្គការពលកម្មអន្តរជាតិឆ្នាំ 2013 លើកឡើងក្នុង Sparreboom និង Staneva (2014)*

*ចំណាំ៖ ISCO កម្រិត 6 រួមមានកម្មករតម្រង់ទិសទៅទីផ្សារដែលមានជំនាញកសិកម្មព្រមទាំងកសិករនិងអ្នកនេសាទ។*

ប្រមាណ 31 ភាគរយ នៃយុវជនដែលកំពុងធ្វើការមានគុណវុឌ្ឍិស្របនឹងមុខរបរ។ ក្នុងចំណោមយុវជនដែលកំពុងធ្វើការសរុប មានយុវជនចំនួន 23 ភាគរយ មានគុណវុឌ្ឍិខ្ពស់ជាងមុខរបរ រីឯយុវជនដែលមានគុណវុឌ្ឍិទាបជាងមុខរបរមានចំនួន 46 ភាគរយ ។ ពាក់កណ្តាលនៃកម្មករស្ត្រី និង 41 ភាគរយ នៃកម្មករបុរសមានគុណវុឌ្ឍិទាបជាងមុខរបរ។ មានតែ 27 ភាគរយ នៃកម្មករស្ត្រី និង 36 ភាគរយ នៃកម្មករបុរសប៉ុណ្ណោះ ដែលមានគុណវុឌ្ឍិស្របនឹងមុខរបរ។ នៅតំបន់ជនបទ យុវជនដែលមានគុណវុឌ្ឍិទាបជាងមុខរបរមានចំនួន 49 ភាគរយ ។ នៅទីក្រុង អត្រានៃការងារដែលស្របនឹងគុណវុឌ្ឍិ និងអត្រានៃការងារដែលមានគុណវុឌ្ឍិទាបជាងមុខរបរមានកម្រិតមធ្យមគឺ 37 ភាគរយ និង 38 ភាគរយ រៀងគ្នា។ នៅតំបន់វាលទំនាបអត្រានៃការងារដែលមានគុណវុឌ្ឍិទាបជាងមុខរបរមានកម្រិតខ្ពស់គឺ 51 ភាគរយ។ ចំណែកអត្រាការងារដែលមានគុណវុឌ្ឍិខ្ពស់ជាងមុខរបរនៅក្នុងតំបន់ទាំងអស់គឺ មានលក្ខណៈប្រហាក់ប្រហែលគ្នា (គឺប្រហែល 20 ភាគរយ) ។ នៅរាជធានីភ្នំពេញ អត្រានៃការងារដែលមានគុណវុឌ្ឍិស្របនឹងមុខរបរមានកម្រិតខ្ពស់ជាងគេ គឺ 40 ភាគរយ ។ ក្នុងវិស័យឧស្សាហកម្មគឺលើសលុបទៅដោយកម្មករដែលមានគុណវុឌ្ឍិទាបជាងមុខរបរ និងមានកម្មករដែលមានគុណវុឌ្ឍិខ្ពស់ជាងមុខរបរតិចបំផុត។ ក្នុងវិស័យសេវាកម្មវិញ ការងារស្របនឹងគុណវុឌ្ឍិបំផុត។ កម្មករដែលមានគុណវុឌ្ឍិទាបជាងមុខរបរមានចំនួនច្រើននៅក្នុងប្រភេទការងារងាយរងគ្រោះ ប៉ុន្តែមានតិចតួចនៅក្នុងប្រភេទការងារដែលមានប្រាក់សមរម្យ (សូមមើល តារាង 1.14) ។ រយៈជាង 10 ឆ្នាំ កន្លងមកនេះ អត្រានៃកម្មករដែលមានគុណវុឌ្ឍិខ្ពស់ជាងមុខរបរបានផ្លាស់ប្តូរយ៉ាងខ្លាំង ជាពិសេសក្នុងចំណោមប្រភេទការងារងាយរងគ្រោះ និងការងារកសិកម្ម។

**តារាង 15 (1-15) ភាពមិនស៊ីគ្នារវាងគុណវុឌ្ឍិនឹងមុខរបររបស់យុវជន ក្នុងឆ្នាំ 2014 (គិតជា ភាគរយ)**

| | | 2004 | | | 2014 | | |
|---|---|---|---|---|---|---|---|
| | | ផ្គូផ្គងល្អ | ក្រោមកម្រិតអប់រំ | លើ កម្រិតអប់រំ | ផ្គូផ្គងល្អ | ក្រោមកម្រិតអប់រំ | លើ កម្រិតអប់រំ |
| | **សរុប** | 38.3 | 55.7 | 6.1 | 31.4 | 45.6 | 23.0 |
| | ប្រុស | 41.6 | 50.9 | 7.5 | 35.7 | 41.1 | 23.2 |
| | ស្រី | 34.5 | 61.0 | 4.4 | 26.9 | 50.4 | 22.7 |
| **ស្ថានភាពការងារ** | ការងារងាយរងគ្រោះ | 35.7 | 60.3 | 4.1 | 31.4 | 38.2 | 30.4 |
| | ការងារមានប្រាក់ខែ | 45.1 | 44.1 | 10.8 | 31.5 | 50.7 | 17.8 |
| **ការងារ តាមវិស័យ** | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 30.0 | 69.4 | 0.6 | 29.2 | 43.1 | 27.7 |
| | ឧស្សាហកម្ម | 45.4 | 44.8 | 9.8 | 23.0 | 64.0 | 13.0 |
| | សេវាកម្ម | 51.1 | 33.6 | 15.3 | 43.4 | 28.0 | 28.6 |
| **តំបន់** | ភ្នំពេញ | 53.3 | 26.9 | 19.8 | 40.4 | 35.4 | 24.1 |
| | វាលទំនាប | 40.0 | 55.1 | 4.9 | 28.5 | 51.4 | 20.1 |
| | បឹងទន្លេសាប | 33.3 | 62.3 | 4.4 | 31.7 | 44.2 | 24.0 |
| | ឆ្នេរ | 39.4 | 55.4 | 5.2 | 34.6 | 42.1 | 23.4 |
| | ខ្ពង់រាប និងភ្នំ | 29.0 | 67.7 | 3.3 | 26.4 | 48.3 | 25.3 |
| **ស្ថានភាពប្រើប្រាស់** | 1 | 26.6 | 70.6 | 2.8 | 25.7 | 51.0 | 23.3 |
| | 2 | 31.3 | 65.6 | 3.1 | 26.9 | 53.3 | 19.8 |
| | 3 | 36.9 | 59.2 | 3.8 | 31.4 | 48.0 | 20.6 |
| | 4 | 42.3 | 50.9 | 6.9 | 34.9 | 42.3 | 22.8 |
| | 5 | 50.6 | 36.7 | 12.6 | 40.0 | 30.7 | 29.3 |

*ប្រភព៖ CSES ឆ្នាំ 2014*

១.៤ ការផ្តល់សិទ្ធិអំណាច និងការចូលរួម

ការចូលរួម និងការផ្តល់សិទ្ធិអំណាចគឺជាសិទ្ធិយ៉ាងសំខាន់បំផុតសម្រាប់សុខុមាលភាពរបស់យុវជន។ ការចូលរួមគឺ សំដៅលើកម្រិតនៃការចូលរួមរបស់យុវជនណាម្នាក់នៅក្នុងសកម្មភាពសង្គមនិងនយោបាយ។ ការផ្តល់សិទ្ធិអំណាចគឺ ជាទស្សនៈទូលំទូលាយលើវិស័យសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងសុខុមាលភាពនិងការចូលរួមរបស់យុវជន ដោយគិតទាំងការផ្តល់សិទ្ធិអំណាចបុគ្គលនិងសង្គម ការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងការផ្តល់សិទ្ធិអំណាចផ្នែកនយោបាយ (យោងតាម MSActionAid-Denmark ឆ្នាំ 2010) ។ ដូចដែលបានចែងនៅក្នុងយុទ្ធសាស្ត្រក្នុងកម្មវិធីអភិវឌ្ឍន៍យុវជនកម្ពុជារបស់សហប្រជាជាតិ (ហៅកាត់ថា UNDP) ឆ្នាំ 2014-2017 ការផ្តល់សិទ្ធិអំណាចដល់យុវជនតម្រូវឱ្យមានការធានាការដល់សិទ្ធិរបស់ពួកគេក្នុងការចូលរួមធ្វើការសម្រេចចិត្តក្នុងកិច្ចការរបស់រាជរដ្ឋាភិបាលនិងដំណើរការនានានៅកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន (យោងតាម UNDP ឆ្នាំ 2014) ។ ការចូលរួមនិងការផ្តល់សិទ្ធិអំណាច ទោះជាយ៉ាងណា ត្រូវបានធ្វើឡើងតាមរយៈវត្តមាន និងជាការពង្រឹងក្របខ័ណ្ឌច្បាប់ដែលការពារសិទ្ធិរបស់យុវជនក្នុងការចូលរួមក្នុងសកម្មភាពសង្គម និងនយោបាយនិងសេរីភាពនៃការបញ្ចេញមតិ។ ជាធម្មតា សូចនាករនៃការចូលរួម និងការផ្តល់សិទ្ធិអំណាចរួមមាន មូលធនសង្គម (បណ្តាញគាំទ្រសង្គម និងសេចក្តីទុកចិត្ត) ការចូលរួមក្នុងសកម្មភាព និងនយោបាយ រួមទាំងបទឧក្រិដ្ឋ និងអំពើហិង្សា។

**១.៤.១ ធនធានសង្គម**

កេរ្តិ៍ដំណែលនៃសង្គ្រាម និងរបបខ្មែរក្រហមបានដើរតួនាទីយ៉ាងសំខាន់ពាក់ព័ន្ធនឹងសេចក្តីទុកចិត្តរបស់ប្រជាជនកម្ពុជា។ អំឡុងសម័យខ្មែរក្រហមមនុស្សជាច្រើនបានស្លាប់ដោយសារតែការធ្វើការងារបាក់កម្លាំង ជំងឺ និងសេចក្តីស្រេកឃ្លាន។ លើសពីនោះ គោលនយោបាយរបបនេះគឺធ្វើយ៉ាងណាបង្កើតឱ្យមានការមិនទុកចិត្តគ្នារវាងអ្នកជិតខាងនិងអ្នកជិតខាង និងសូម្បីតែរវាងកូនៗនិងឪពុកម្តាយ។ មនុស្សមិនទុកចិត្តគ្នានិងរាយការណ៍ជូនថ្នាក់លើពីសកម្មភាពរបស់គ្នាទៅវិញទៅមក ដែលទង្វើទាំងនេះគឺជាបញ្ហាដល់ការរស់នៅនិងនាំឱ្យមានមនុស្សស្លាប់។ ការខ្វះខាតសេចក្តីទុកចិត្តនេះបានបន្តរហូតដល់ថ្ងៃបច្ចុប្បន្ន។ យោងតាមការសិក្សាមួយដោយ Inada ឆ្នាំ 2013 ទោះបីមិនបានផ្តោតលើយុវជនក៏ដោយ ក៏បានរកឃើញថា ប្រជាជនកម្ពុជាមានជំនឿទុកចិត្តទាបបំផុតលើមនុស្សដែលនៅខាងក្រៅក្រុមគ្រួសាររបស់ខ្លួន។ នៅពេលសាកសួរអំពីបញ្ហានេះ មនុស្សជាច្រើនបាននិយាយថា នៅក្នុងសហគមន៍របស់ពួកគេ មានមនុស្សតិចតួចណាស់ដែលពួកគេអាចជឿទុកចិត្តបាន ។ កម្រិតនៃសេចក្តីទុកចិត្តនៅតំបន់ជនបទមានខ្ពស់ជាងនៅក្នុងទីក្រុង ហើយមនុស្សជឿទុកចិត្តលើសមាជិកក្រុមគ្រួសារនិងសាច់ញាតិខ្លួនច្រើនបំផុត បន្ទាប់មកលើមិត្តភក្តិ បន្តទៀតលើមនុស្សដែលនៅក្នុងសង្កាត់ខ្លួននិងស្ថាប័នសាធារណៈដូចជា មន្ទីរពេទ្យ និងសាលារៀន រដ្ឋអំណាចមូលដ្ឋាននិងស្ថាប័នសាសនា។ ប្រជាជនមានទំនុកចិត្តតិចតួចលើគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នករួមការងារ និងនិយោជក។ ស្ថាប័នដែលប្រជាជនទុកចិត្តតិចបំផុតគឺស្ថាប័នយោធា។ ការខ្វះខាតនៃសេចក្តីទុកចិត្តកាត់បន្ថយកំណើននៃធនធានសង្គមដែលជាកាតាលីករនៃកំណើនសេដ្ឋកិច្ច។ ធនធានសង្គមបង្កើតបានជាទំនាក់ទំនងមួយប្រកបដោយទំនុកចិត្តដែលទំនុកចិត្តនេះបង្កើតបានជាធនធានសង្គមមកវិញ (យោងតាម Fu 2004) ។ ដូច្នេះ ការកសាងទំនុកចិត្តរបស់យុវជនកម្ពុជាគឺជាបុរេលក្ខខណ្ឌសំខាន់បំផុតក្នុងការកែលម្អសុខុមាលភាពរបស់ពួកគេ។

នៅកម្ពុជា សង្គមមានលក្ខណៈជាឋានានុក្រមដែលមានគ្រួសារជាចំណងរឹងមាំ ហើយជាធម្មតាសមាជិកគ្រួសារពឹងផ្អែកលើក្រុមគ្រួសារនិងសាច់ញាតិរបស់ខ្លួនជាងលើអ្នកដទៃនិងជាងស្ថាប័នដទៃ។ នេះជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលអាចនាំឱ្យមានវប្បធម៌នយោបាយបក្ខពួកនិយម (យោងតាម Inada 2013)។ យុវជនដែលមានសមាជិកគ្រួសារនិងសាច់ញាតិមានតំណែងសំខាន់នៅក្នុងជួររាជរដ្ឋាភិបាលរីករាយជាមួយនឹងភាពអនុគ្រោះដូចជា ការងារក្នុងស្ថាប័នសាធារណៈ និងឡើងឋានៈឆាប់រហ័ស។ យុវជនដែលរស់នៅក្នុងតំបន់ជនបទ ឬយុវជនដែលពុំមានសមាជិកគ្រួសារនិងសាច់ញាតិមានអំណាចគឺទំនងជាមានទំនាក់ទំនងនិងបណ្តាញសង្គមខ្សោយ។ យុវជនមានបណ្តាញគាំទ្រពីសង្គមតិចជាងមនុស្សចាស់ (សូមមើល រូបភាព 1.13)។

**រូបភាព 14 (1-14) បណ្តាញគាំទ្រពីសង្គម តាមក្រុមអាយុ និងភេទ ឆ្នាំ 2006 និងឆ្នាំ 2015**




*__ប្រភព__៖ ការបោះឆ្នោតពិភពលោកក្រុមហ៊ុន Gallup ឆ្នាំ 2006 និងឆ្នាំ 2015*

*__ចំណាំ__៖ សំណួរ: បើអ្នកមានបញ្ហា តើអ្នកមានសាច់ញាតិឬមិត្តភក្តិដែលអ្នកអាចពឹងពាក់រកជំនួយនៅពេលដែលអ្នកត្រូវការដែរឬទេ?*

**១.៤.២ ការចូលរួមក្នុងសកម្មភាពសង្គម និងនយោបាយ**

ដោយសារតែកេរ្តិ៍ដំណែលនៃសង្គ្រាមយុវជនមានការប្រុងប្រយ័ត្នខ្លាំងក្នុងការចូលរួមក្នុងសកម្មភាពសង្គមនិងនយោបាយ។ ការចូលរួមក្នុងសកម្មភាពនយោបាយត្រូវបានគេជឿថា អាចឱ្យពួកគេគ្រោះថ្នាក់ច្រើនជាងទទួលបានអត្ថប្រយោជន៍ ម្យ៉ាងទៀត ជាធម្មតា មាតាបិតាក៏មិនចង់ឱ្យកូនរបស់ខ្លួនចូលរួមក្នុងសកម្មភាពនយោបាយដែរ។ **យ៉ែម ចក់** ដែលជាឪពុកម្តាយម្នាក់មានអាយុ 59 ឆ្នាំត្រូវបានដកស្រង់សម្តីក្នុងកាសែតភ្នំពេញប៉ុស្តិ៍ក្នុងឆ្នាំ 2012 ថា៖ *"ខ្ញុំមិនចង់ឱ្យកូនរបស់ខ្ញុំពាក់ព័ន្ធនឹងនយោបាយទេ ព្រោះថា វាធ្វើឱ្យពួកគេខាតពេលវេលារៀនសូត្រនិងរកស៊ី។ លើសពីនេះ វាអាចប៉ះពាល់ដល់សុវត្ថិភាពរបស់ពួកគេ។ កាលពីជំនាន់ខ្ញុំ នយោបាយមិនស្ថិតស្ថេរទេនិងបណ្តាលឱ្យមនុស្សធម្មតា មនុស្សទន់ខ្សោយស្លាប់បាត់បង់ជីវិត»* ។ ទោះយ៉ាងណា ពេលនេះដោយមានការរីកសាយនៃប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា ហ្វេសប៊ុក ជាដើមនោះ ក៏មានការកើនឡើងនូវចំនួននៃយុវជនចូលរួមក្នុងសកម្មភាពសង្គមនិងនយោបាយ ជាពិសេសយុវជននៅទីក្រុងដែលមានអ៊ីនធើណិតប្រើប្រាស់។ ពួកគេត្រូវបានលើកទឹកចិត្តមួយកម្រិតឱ្យការចូលរួមក្នុងសកម្មភាពនយោបាយនិងពេលខ្លះទទួលបានការគាំទ្រពីក្រុមអ្នកនយោបាយរហូតក្លាយជាការប្រេះឆាក៏មាន។ ឥឡូវនេះ មានទាំងចលនាយុវជនគាំទ្ររាជរដ្ឋាភិបាល និងចលនាយុវជនប្រឆាំងរាជរដ្ឋាភិបាល។ សកម្មជនផ្សេងទៀតដូចជា សហជីពកម្មកររោងចក្រកាត់ដេរដែលភាគច្រើនជាយុវជនវ័យក្មេងនោះ កំពុងឥទ្ធិពលលើការចរចារនានា និងការបង្កើតគោលនយោបាយ។ ពួកគេធ្វើយុទ្ធនាការដើម្បីកែលម្អសុខុមាលភាពរបស់កម្មកររោងចក្រកាត់ដេរ។ ក្នុងឆ្នាំ 2014 សហជីពបានប្រមូលផ្តុំគ្នាទាមទារឱ្យមានការដំឡើងប្រាក់ខែ និងទទួលបានជោគជ័យមួយកម្រិតដែរ។ ការបោះឆ្នោត គឺជា

សកម្មភាពសំខាន់មួយទៀតដែលតាមរយៈនេះយុវជនអាចបញ្ចេញទស្សនៈនយោបាយរបស់ខ្លួន។ យោងតាមវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (National Democratic Institute ហៅកាត់ថា NDI) បានឱ្យដឹងថា សម្រាប់ការបោះឆ្នោតឆ្នាំ 2013 យុវជនចំនួន 65 ភាគរយ នៃយុវជនដែលមានអាយុចន្លោះពី 18 ទៅ 19 ឆ្នាំ បានចុះឈ្មោះបោះឆ្នោត។ អត្រាចុះឈ្មោះបោះឆ្នោតនៃយុវជនដែលអាយុចន្លោះពី 25 ទៅ 45 ឆ្នាំ មានចំនួន 84 ភាគរយ។ ទោះបីជាពុំឃើញមានទិន្នន័យនៃយុវជនដែលមានអាយុចន្លោះពី 18 ទៅ 30 ឆ្នាំ ក៏ដោយ ក៏គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ដូចដែលបានលើកឡើងដោយវិទ្យុសំឡេងសហរដ្ឋអាមេរិកនៅថ្ងៃទី 10 ខែកក្កដា ឆ្នាំ 2013) បានលើកឡើងថា មានយុវជនតែ 37 ភាគរយ ប៉ុណ្ណោះដែលបានបានចុះឈ្មោះបោះឆ្នោត។ ទោះយ៉ាងណា ដោយសារតែការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមកើនឡើង យុវជនអាចបញ្ចេញមតិរបស់ខ្លួនតាមរយៈវេទិកានេះ ចំណែកឯអ្នកនយោបាយវិញក៏បានសម្របខ្លួននឹងការប្រើប្រាស់មធ្យោបាយនេះ ដើម្បីឱ្យការសន្ទនារបស់ខ្លួនបានជ្រួតជ្រាបដល់ស្រទាប់ប្រជាជន និងយុវជនផងដែរ។ បច្ចុប្បន្ន វត្តមានរបស់យុវជនក្នុងមុខតំណែងគ្រប់គ្រងក្នុងជួររដ្ឋាភិបាលកំពុងកើនឡើង ហើយពួកគេជាប់ឆ្នោតជាមន្ត្រីក្នុងជួររដ្ឋអំណាចមូលដ្ឋានទៀតផង (យោងតាម Heng et al. ឆ្នាំ 2014)។

ការចូលរួមក្នុងសកម្មភាពសង្គមរបស់យុវជនអាចមានទ្រង់ទ្រាយជាការងារស្ម័គ្រចិត្តផងដែរ។ ស្ថាប័នរបស់រាជរដ្ឋាភិបាលជាច្រើនបានបង្កើតក្រុមយុវជនស្ម័គ្រចិត្តដូចជា យុវជនកាកបាទក្រហម (Red Cross Youth ហៅកាត់ថា RCY) ។ RCY គឺជាក្រុមមួយក្នុងចំណោមក្រុមយុវជនស្ម័គ្រចិត្តធំៗនៅកម្ពុជា ដែលបានរៀបចំសកម្មភាពជាច្រើនដូចជាបង្កើនការយល់ដឹងអំពីច្បាប់សុវត្ថិភាពចរាចរណ៍ដល់ប្រជាពលរដ្ឋជាដើម។ លើសពីនេះ រដ្ឋាភិបាលបានជ្រើសរើសនិស្សិតស្ម័គ្រចិត្តរាប់ពាន់នាក់ទៅចុះវាស់វែងដីធ្លីនិងផ្តល់ប្លង់កម្មសិទ្ធិជូនប្រជាពលរដ្ឋនៅតាមខេត្តមួយចំនួន ដែលការអនុវត្តបែបនេះបានបង្កឱ្យមានការចម្រូងចម្រាសផ្នែកច្បាប់មួយចំនួនផងដែរ។ ក្រៅពីក្រុមយុវជនដែលដឹកនាំដោយរដ្ឋាភិបាល ក៏មានក្រុមយុវជនដែលជានិស្សិតសាកលវិទ្យាល័យ ក្រុមយុវជនគណបក្សនយោបាយ និងក្រុមយុវជនអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងក្រុមយុវជនស្ម័គ្រចិត្តដទៃទៀត កំពុងចាប់ផ្តើមបង្កើតឱកាស កាន់តែច្រើនដើម្បីឱ្យយុវជនកម្ពុជាបានចូលរួមក្នុងសកម្មភាពនយោបាយ ក្នុងបណ្តាញសង្គម និងក្នុងការងារស្ម័គ្រចិត្ត។ នៅក្នុងឆ្នាំ 2015 មានយុវជនប្រហែលពាក់កណ្តាលនៃយុវជនសរុប បានចូលរួមនៅក្នុងសកម្មភាពសង្គមមួយចំនួន (ដូចជា ការបរិច្ចាកប្រាក់ ការស្ម័គ្រចិត្ត ឬជួយអ្នកដទៃ)។ ទោះជាយ៉ាងណា ការចូលរួមក្នុងសកម្មភាពសង្គមរបស់យុវជនមានការថយចុះតិចតួច ក្នុងរយៈពេល 10 ឆ្នាំ កន្លងមកនេះ។ យុវជនបានចូលរួមក្នុងសកម្មភាពសង្គមច្រើនជាងយុវតី ហើយយុវជននៅទីក្រុងចូលរួមបានចូលរួមក្នុងសកម្មភាពសង្គមច្រើនជាងយុវជននៅជនបទ។

**រូបភាព 15 (1-15) ការចូលរួមរបស់យុវជនក្នុងសកម្មភាពសង្គម**




*ប្រភព៖ ការបោះឆ្នោតពិភពលោកក្រុមហ៊ុន Gallup ឆ្នាំ 2006 និងឆ្នាំ 2015 ប្រភព៖ ការបោះឆ្នោតពិភពលោកក្រុមហ៊ុន Gallup ឆ្នាំ 2008 និងឆ្នាំ 2015*

*ចំណាំ៖ សំណួរសួរថា៖ នៅក្នុងខែកន្លងមកនេះ តើអ្នកមានបានបរិច្ចាគប្រាក់ទៅឱ្យសប្បុរសជន លះបង់ពេលវេលាស្ម័គ្រចិត្តដើម្បីអង្គការមួយ ឬជួយអ្នកដទៃ ឬនរណាម្នាក់ដែលគេក៏មិនដឹងថា ត្រូវត់រកនរណាឱ្យជួយ ដែរឬទេ?*

**១.៤.៣ តុលាការអនីតិជន**

នៅក្នុងតំបន់ដែលមានអត្រាឧក្រិដ្ឋកម្ម ឬបទដ្ឋានសង្គមខ្ពស់ដែលរុញច្រានយុវជនឱ្យធ្លាក់ក្នុងឥរិយាបថមួយដែលប្រឈមនឹងបទព្រហ្មទណ្ឌ និងគ្រោះថ្នាក់នោះ គេមិនអាចកសាងធនធានសង្គមបានទេ ហើយយុវជនក៏មិនអាចចូលរួមក្នុងសកម្មភាពសង្គម និងនយោបាយដោយសេរីដែរ។ កម្ពុជាបានប្រឈមនឹងបញ្ហាជាច្រើនក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដោយសារតែសង្គ្រាមស៊ីវិលគួរឱ្យតក់ស្លុតមានរយៈពេលវែង។ សង្គ្រាមបានបង្កអសន្តិសុខផ្ទាល់ខ្លួនដូចជា ការភ័យខ្លាចដល់ការធ្វើទារុណកម្ម ឬការដាក់ទណ្ឌកម្មឃោរឃៅខុសពីធម្មតា ដែលជាឧបសគ្គមិនអាចឱ្យសង្គមជឿនលឿនបាន ព្រោះកត្តាទាំងនេះបានធ្វើឱ្យបុគ្គលមួយចំនួនរារាំងក្នុងការចូលរួមក្នុងចលនា និងការអភិវឌ្ឍដោយខ្លួន។ ដូច្នេះហើយ មានតែការកាត់បន្ថយភាពអយុត្តិធម៌ ការកាត់បន្ថយឧក្រិដ្ឋកម្ម និងអំពើហិង្សាទេ ដែលអាចកាត់បន្ថយភាពងាយរងគ្រោះ ជាពិសេសសម្រាប់យុវជន។ នៅកម្ពុជា អាយុស្របច្បាប់ដែលអាចទទួលទោសព្រហ្មទណ្ឌគឺអាយុ 18 ឆ្នាំ។ ទោះយ៉ាងណា យោងតាមមាត្រា 39 នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទៅលើអនីតិជនអាយុចាប់ពី 14 (ដប់បួន) ឆ្នាំឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ កុមារដែលជាប់ឃុំជាមួយឧក្រិដ្ឋជនវ័យចំណាស់អាចជួបហានិភ័យដូចជា អំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន ប៉ុន្តែប្រព័ន្ធពន្ធនាគារដែលមានមនុស្សណែនណាន់តាន់តាប់មិនអាចញែកអនីតិជនចេញពីអ្នកទោសផ្សេងទៀតនោះទេ។ ទោះបីជាច្បាប់បានផ្តល់ការការពារដល់កុមារក៏ដោយ ក៏វាមិនមានប្រសិទ្ធិភាពដែរ គឺដោយសារតែប្រព័ន្ធតុលាការព្រហ្មទណ្ឌមិនដំណើរការធម្មតា ។ នេះជាឧបសគ្គដល់ការស្តារនីតិសម្បទាជាអនីតិជន។

យោងតាមទូរលេខកុមារក្នុងប្រព័ន្ធតុលាការព្រហ្មទណ្ឌកម្ពុជា (Cambodian Center for Human Rights ហៅកាត់ថា CCHR) ឆ្នាំ 2014 បានឱ្យដឹងថា នៅក្នុងឆ្នាំ 2012 មានអនីតិជនជាប់ចោទចំនួន 92 ភាគរយ ត្រូវបានឃុំខ្លួនមុនសវនាការ និងមនុស្សចាស់ជនជាប់ចោទមានចំនួន 71 ភាគរយ។ សមាមាត្រនៃការឃុំខ្លួនមុនសវនាការគឺ 63 ភាគរយ ។ អត្រាស្ត្រីជាប់ពន្ធនាគារមុនសវនាការគឺ 70 ភាគរយ និងអត្រាអនីតិជនជាប់ពន្ធនាគារមុនសវនាការគឺ 83 ភាគរយ ។ ប្រទេសនេះជាប់លំដាប់ទី 23 ក្នុងចំណោមប្រទេសចំនួន 211 ប្រទេសដែលមានការឃុំខ្លួនមុនសវនាការ (យោងតាមអង្គការ LICADHO ឆ្នាំ 2015)។ អត្រាខ្ពស់នេះគឺ ដោយសារតែភាគច្រើននៃអនីតិជនជាប់ចោទពុំមានអាសយដ្ឋានអចិន្ត្រៃយ៍ច្បាស់លាស់ និងដោយសារតែប្រព័ន្ធការពារតាមតុលាការស្មុគស្មាញពេក។ ឯកជនភាពរបស់អនីតិជនជាប់ចោទគួរតែត្រូវបានរក្សាការសម្ងាត់ ព្រោះថា បើលេចធ្លាយសាធារណៈអាចគ្រោះថ្នាក់ និងប៉ះពាល់ដល់អនីតិជនពេលពួកគេត្រឡប់ទៅវិញ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាបញ្ហាបែបនេះមិនត្រូវបានគេគិតដល់នោះទេ។

នៅក្នុងឆ្នាំ 2009 ក្នុងចំណោមមនុស្ស 100 000 នាក់ មានអនីតិជនមួយចំនួនធំបានជាប់ចោទពីបទចោរកម្ម និងការលួច (ព្រហ្មទណ្ឌកម្រិតស្រាល) ដែលជាបទឧក្រិដ្ឋសាមញ្ញ គឺមាន 8.07 ករណី ការបង្ករបួសស្នាម 7.2 ករណី និងមនុស្សឃាត 2.5 ករណី (យោងតាម Broadhurst et al 2013) ។ ចាប់ពីឆ្នាំ 1999 ដល់ឆ្នាំ 2008 អត្រាអ្នកជាប់ពន្ធនាគារបានកើនឡើងពី 24 នាក់ ទៅ 84 នាក់ ក្នុងចំណោមមនុស្សចាស់ចំនួន 100 000 នាក់។ ក្នុងចំណោមអ្នកទោសសរុបនៅឆ្នាំ 2008 មានអ្នកទោសស្ត្រីមានចំនួន 5.6 ភាគរយ និងអនីតិជនចំនួន 6.3 ភាគរយ (គិតពីឆ្នាំ 1999 កើនឡើងចំនួន 3.3 ភាគរយ) (សូមមើល រូបភាពទី 19) ។ គិតពីឆ្នាំ 2010 រហូតមកដល់ឆ្នាំ 2011 អ្នកទោសសរុបបានកើនឡើងចំនួន 13 ភាគរយ ស្មើនឹង 15001 នាក់ (អ្នកទោសចំនួន 98.1 នាក់ក្នុងចំណោមមនុស្ស 100000 នាក់) (យោងតាមអង្គការ LICADHO ឆ្នាំ 2011) ។

**រូបភាព 16 (1-16) ចំនួនអ្នកជាប់ពន្ធនាគារពីឆ្នាំ 1999-2008 (ក្នុងចំណោមមនុស្ស 100 000 នាក់)**




*ប្រភព៖ ដកស្រង់ពី Broadhurst (2013)*

### ១.៤.៤ យុវជនរងគ្រោះដោយការវាយប្រហារ និងអំពើហិង្សា ជាពិសេសការវាយប្រហារ និងអំពើហិង្សាប្រឆាំងនឹងស្ត្រីវ័យក្មេង

ការវាយប្រហារ និងអំពើហិង្សាផ្សេងៗមកលើយុវជនជះឥទ្ធិពលយ៉ាងខ្លាំងទៅលើឥរិយាបទរបស់ពួកគេនាពេលអនាគត ព្រោះយុវជនដែលជួបប្រទះការវាយប្រហារធ្ងន់ធ្ងរ ឬយូរអង្វែង អាចធ្វើសកម្មភាពដូចគ្នានេះនៅពេលក្រោយ។ វាអាចបណ្តាលឱ្យពួកគេប្រព្រឹត្តបទឧក្រិដ្ឋ បោះបង់សាលារៀន រត់ចេញពីផ្ទះ ឬក្លាយទៅជាពិការផ្លូវកាយឬផ្លូវចិត្ត។ យោងតាមទិន្នន័យពីការស្ទង់មតិសេដ្ឋកិច្ចសង្គមនៅកម្ពុជា (ហៅកាត់ថា CSES) ឆ្នាំ 2014 បានឱ្យដឹងថា ជនរងគ្រោះដោយអំពើហិង្សាមានចំនួន 0.3 ភាគរយ នៃប្រជាជនសរុប ដែលកាលពីឆ្នាំ 2004 មានត្រឹមតែ 1.2 ភាគរយ ប៉ុណ្ណោះ។ ភាគច្រើននៃអ្នកទាំងនោះ (96 ភាគរយ) រងគ្រោះដោយការវាយប្រហារលើរាងកាយ រួមមាន ការទះ ការរុញច្រាន ការដាល់ ឬការវាយដំ ការដុត និងអំពើហិង្សាផ្សេងទៀតដែលបង្កឱ្យមានរបួសស្នាមធ្ងន់ធ្ងរ។ ក្នុងចំណោមជនរងគ្រោះទាំងនោះមានយុវជនចំនួន 30 ភាគរយ និងស្ត្រីរងគ្រោះចំនួន 17ភាគរយ ។ ក្នុងចំណោមយុវជនរងគ្រោះទាំងនោះ មានយុវជនចំនួន 92 ភាគរយ រងគ្រោះដោយការវាយប្រហារលើរាងកាយ ដែលនៅក្នុងនោះក៏មានស្ត្រីរងគ្រោះចំនួន 61 ភាគរយ ផងដែរ។ ចំណែកអំពើហិង្សាក្នុងគ្រួសារលើស្ត្រីវ័យក្មេងមានចំនួន 29 ភាគរយ (យោងតាម CDHS ឆ្នាំ 2014) ។ ស្ត្រីដែលរស់នៅក្នុងគ្រួសារក្រីក្របំផុត និងនៅក្នុងគ្រួសារអ្នកមានបំផុត ជួបប្រទះនឹងអំពើហិង្សាច្រើនជាងស្ត្រីដទៃទៀត (សូមមើល តារាង 1.15)។ ការវិភាគពីមូលហេតុតាមរយៈការសិក្សាបានសន្និដ្ឋានថា អំពើហិង្សាក្នុងគ្រួសារផ្សារភ្ជាប់យ៉ាងរឹងមាំទៅនឹងកម្រិតនៃការអប់រំទាបរបស់ជនរងគ្រោះ និងឥរិយាបថរបស់ប្តីផងដែរ (កម្រិតគ្រឿងស្រវឹង ឬចិត្តប្រចណ្ឌ)។

**តារាង 16 (1-16) អត្រានៃអំពើហិង្សាលើស្ត្រីវ័យក្មេងដែលមានអាយុចន្លោះពី 15 ទៅ 29 ឆ្នាំ ក្នុងឆ្នាំ 2014**

| | | **អំពើហិង្សាលើរាងកាយឬផ្លូវភេទលើស្ត្រីវ័យក្មេង (ភាគរយ)** |
|---|---|---|
| យុវជនអាយុពី 15 ទៅ 29 ឆ្នាំ | | 29.0 |
| តំបន់ | វាលទំនាប | 43.8 |
| | បឹងទន្លេសាប | 24.2 |
| | ឆ្នេរ | 27.5 |
| | ខ្ពង់រាប និងភ្នំ | 38.5 |
| | ភ្នំពេញ | 28.5 |
| **ស្ថានភាពទ្រព្យធន )1= ក្របំផុត 5=មានបំផុត)** | 1 | 31.5 |
| | 2 | 24.7 |
| | 3 | 27.6 |
| | 4 | 30.5 |
| | 5 | 30.5 |

*ប្រភព៖ CDHS ឆ្នាំ 2014*

### ១.៥ សុខុមាលភាពរបស់យុវជន

ជាទូទៅយុវជនកម្ពុជាមានគំនិតវិជ្ជមានណាស់អំពីជីវិតរបស់ពួកគេ។ បើទោះបីជា ការវាស់ស្ទង់និងការប្រៀបធៀបសុខុមាលភាពនៅក្នុងបណ្តាប្រទេសមួយចំនួនមានភាពចម្រូងចម្រាស់ ក៏ដោយ ក៏បញ្ហាសុខុមាលភាពគឺជាកម្មវត្ថុដែលមនុស្សត្រូវយល់ដឹង។ អង្គការ Gallup បានធ្វើការស្ទង់មតិនៅក្នុងប្រទេសជាច្រើនស្តីពីការពេញចិត្តនឹងជីវិត។ យោងតាមការបោះឆ្នោតស្ទង់មតិជាសកលឆ្នាំ 2012 បានឱ្យដឹងថា 72 ភាគរយ នៃប្រជាជនកម្ពុជាបាននិយាយថា ជាទូទៅពួកគេពេញចិត្តនឹងជីវិតរបស់ខ្លួន។ ប៉ុន្តែជាទូទៅ ទោះបីជាពួកគេបានសម្តែងការពេញចិត្តក៏ដោយ ក៏យុវជនកម្ពុជាមួយចំនួនមានការព្រួយបារម្ភ និងភ័យខ្លាចផងដែរ។ ការការព្រួយបារម្ភធំរបស់ពួកគេគឺ ភាពគ្មានការងារធ្វើ។ យោងតាមការស្ទង់មតិមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលវិភាគបញ្ហាអភិវឌ្ឍន៍បានឱ្យដឹងថា នៅក្នុងចំណោមសិស្សវិទ្យាល័យចំនួន 630 នាក់ និងនិស្សិតសាកលវិទ្យាល័យដែលមានអាយុចន្លោះពី 15 ទៅ 35 ឆ្នាំ ទាំងនៅរាជធានីភ្នំពេញ ខេត្តមណ្ឌលគិរី រតនគិរី តំបន់ព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងកំពង់ធំ មានសិស្សនិស្សិតចំនួន 49 ភាគរយ បាននិយាយថា ពួកគេភ័យខ្លាចអត់ការងារធ្វើ (យោងតាមកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី 10 ខែសីហា ឆ្នាំ 2015)។ ការអប់រំនៅមានគុណភាពទាប និងការខ្វះខាតគ្រូមានសមត្ថភាព គឺជាហេតុផលចម្បងដែលនាំឱ្យសិស្សនិស្សិតភ័យខ្លាចអត់ការងារធ្វើ។ ដោយមានសហគមន៍សេដ្ឋកិច្ចអាស៊ានចូលកាន់តែជិត និស្សិតបារម្ភថា ពួកគេមិនអាចប្រកួតប្រជែងជាមួយនិស្សិតមកពីបណ្តាប្រទេសផ្សេងទៀត។ **សុខ ច័ន្ទបូណ៌មី** ជានិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទសេដ្ឋកិច្ច និងនីតិសាស្ត្របានឱ្យដឹងថា៖ *«យុវជនក្នុងបណ្តាប្រទេសអាស៊ានផ្សេងទៀតបានត្រៀមខ្លួនអស់រយៈពេលប្រាំឬដប់ឆ្នាំមកហើយ ប៉ុន្តែយើងទើបតែចាប់ផ្តើមឆ្នាំនេះទេ ដូច្នេះខ្ញុំព្រួយបារម្ភថា យើងមិនអាចតាមទាន់ពួកគេ»* (យោងតាម វិទ្យុសំឡេងសហរដ្ឋអាមេរិក កាលពីថ្ងៃទី 19 វិច្ឆិកា 2014)។

សូម្បីតែនិស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យក៏ពិបាកក្នុងការស្វែងរកការងារធ្វើដែរ។ អត្រាអ្នកអត់ការងារធ្វើក្នុងចំណោមយុវជនដែលបញ្ចប់ការសិក្សានៅមហាវិទ្យាល័យគឺ 3,8 ភាគរយ ខ្ពស់ជាងអ្នកដែលមានកម្រិតបឋម (1,6 ភាគរយ) ឬអនុវិទ្យាល័យ (1,5 ភាគរយ) (Kanol, Khemarin និង Elder, 2013) ។ ការដែលអត់ការងារធ្វើយូរពេកអាចនាំឱ្យយុវជនរងនូវការមាក់ងាយពីសង្គម ភាពឯកោ និងបញ្ហាផ្លូវចិត្ត ដូចជា ការធ្លាក់ទឹកចិត្តនិងការបាត់បង់សេចក្តីក្លាហាន ។ យុវជនដែលធ្លាប់ជួបបញ្ហាគ្មានការងារធ្វើងាយរងការប៉ះទង្គិចផ្លូវចិត្តជាងយុវជនដែលមិនធ្លាប់ជួប ។ ការអត់ការងារធ្វើនាំឱ្យមានបញ្ហាសេដ្ឋកិច្ច និងអារម្មណ៍ខ្មាស់អៀន ហើយការដែលមានការងារធ្វើនាំឱ្យសុខុមាលភាពប្រសើរឡើង (យោងតាម Reneflot និង Evensen 2014)។ ដោយសារតែការអត់ការងារធ្វើនៅតែជាបញ្ហាធំបំផុតក្នុងចំណោមយុវជនកម្ពុជា ហើយភាគច្រើននៃពួកគេគ្មានការងារធ្វើ (ឬកំពុងធ្វើការងារ) ឬមានការភ័យខ្លាចអំពីការអត់ការងារធ្វើផងនោះ ក្តីរំពឹង និងសុខុមាលភាពរបស់ពួកគេសម្រាប់អនាគតត្រូវបានបាត់បង់។ ការពេញចិត្តក្នុងជីវិតរបស់យុវវ័យកម្ពុជាមានកម្រិត 4,5 លើមាត្រដ្ឋាន 1/10 នាក់ ដែល 10នាក់នេះ គឺជាអ្នកដែលពេញចិត្តនឹងជីវិតបំផុត ហើយអ្នកដែលមិនពេញចិត្តនឹងជីវិតសោះនោះគឺគ្មានទេ។

**រូបភាព 17 (1-17) ការពេញចិត្តនឹងជីវិតរបស់យុវជនលើមាត្រដ្ឋាន 1/10 នាក់**




*ប្រភព៖ ក្រុមហ៊ុន Gallup 2015*

### ១.៦ សេចក្តីសន្និដ្ឋាន

ដោយសារតែមួយភាគបីនៃចំនួនប្រជាជនមានអាយុចន្លោះពី 15 និង 29 ឆ្នាំ កម្ពុជានឹងមានសក្តានុពលទទួលបានផលប្រយោជន៍ពីយុវជនទាំងនេះយ៉ាងពិតប្រាកដ។ ទោះជាយ៉ាងណាបង្អួចនៃឱកាសនេះគឺតូចចង្អៀត ហើយដោយសារតែជាយុវជនកម្ពុជាប្រឈមនឹងបញ្ហាច្រើនផងនោះ តម្រូវឱ្យមានឆ្លើយតបតាមរយៈកំណែទម្រង់គោលនយោបាយយុវជនទូលំទូលាយ។

ទាក់ទិននឹងបញ្ហាសុខភាព គួរតែផ្តល់អាទិភាពដល់ការកែលម្អសេវាសុខភាពផ្លូវភេទ និងបន្តពូជ (SRH) សម្រាប់យុវជន ជាពិសេសនៅតាមតំបន់ជនបទ។ សេវាកម្មសុខភាពនិងគ្លីនិកយេនឌ័រគួរតែបង្កលក្ខណៈងាយស្រួលសម្រាប់យុវជន។ ការអប់រំ SRH គួរតែត្រូវបានអនុវត្តនៅតាមសាលារៀននិងនៅក្នុងសហគមន៍ដើម្បីយកឈ្នះបទដ្ឋានសង្គមយេនឌ័ររើសអើងដែលរារាំងយុវជន មិនឱ្យស្វែងរកការព្យាបាលនៅពេលឆ្លងជំងឺផ្លូវភេទ (STI)។ មណ្ឌលស្តារនីតិសម្បទាសម្រាប់អ្នកប្រើគ្រឿងញៀនគួរតែបង្កលក្ខណៈងាយស្រួលដល់យុវជន គឺដើម្បីកុំឱ្យពួកគេនៅឡុកឡំជាមួយមនុស្សចាស់។ កម្មវិធីការពារនិងយុទ្ធនាការសាធារណៈស្តីពីការប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំជក់ដែលមានគោលដៅលើក្មេងជំទង់គួរបំពេញបន្ថែមគ្នាជាមួយនឹងវិធានការសុវត្ថិភាពចរាចរណ៍ផ្លូវគោក។ ការផ្សព្វផ្សាយពាណិជ្ជកម្មបារីគួរតែបានហាមឃាត់ និងកាត់បន្ថយឱ្យដល់កម្រិតអប្បបរមា និងគួរកំណត់នៅក្នុងច្បាប់នូវ អាយុដែលអាចសេពគ្រឿងស្រវឹង។

បញ្ហាបោះបង់ការសិក្សានៅវ័យដំបូង គឺជាបញ្ហាធំបំផុតសម្រាប់យុវជនដែលមានអាយុរៀននៅអនុវិទ្យាល័យឡើងទៅ។ កុមារមកពីគ្រួសារក្រីក្រមានអត្រាចុះឈ្មោះចូលរៀនទាបបំផុតនៅក្នុងវិស័យអប់រំកម្រិតមធ្យមសិក្សាដែលចង្អុលបង្ហាញថា បញ្ហាហិរញ្ញវត្ថុជាហេតុផលសំខាន់មួយនៃការបោះបង់សាលា។ កម្មវិធីផ្តល់ប្រាក់កម្ចីមានលក្ខខណ្ឌអាចជួយលុបបំបាត់ឧបសគ្គផ្នែកសេដ្ឋកិច្ចរបស់គ្រួសារក្រីក្រ។ ម្យ៉ាងមិញទៀត គុណភាពនៃការអប់រំនៅមានកម្រិតទាបដោយសារតែគ្រូមានសមត្ថភាពទាប គួបផ្សំនឹងប្រាក់ខែលើកទឹកចិត្តគ្រូនៅតិចតួចផងដែរ។ បើគ្មានការបណ្តុះបណ្តាល និងការលើកទឹកចិត្តដល់គ្រូបង្រៀនឱ្យបានសមល្មមទេ នឹងមិនអាចកែលម្អការអប់រំឱ្យមានគុណភាពបានឡើយ ហើយឪពុកម្តាយសិស្សក៏ពិបាកនឹងការវិនិយោគក្នុងវិស័យអប់រំដែរ ។ មធ្យោបាយទៅសាលារៀនក៏ជាឧបសគ្គមួយសម្រាប់កុមារដែលរស់នៅក្នុងតំបន់ជនបទដាច់ស្រយាល ដូចជា តំបន់ភ្នំ និងតំបន់ខ្ពង់រាប ។ ដូច្នេះ មធ្យោបាយធ្វើដំណើរទាំងផ្លូវគោក និងផ្លូវទឹកត្រូវតែធ្វើឱ្យប្រសើរឡើង។ កុមារទាំងនេះក៏ប្រហែលជាជាប់ពាក់ព័ន្ធនឹងការងារកសិកម្មផងដែរ។ នៅក្នុងតំបន់ណាក៏ដោយ ឱ្យតែវិស័យកសិកម្មលេចធ្លោ ត្រូវតែសម្រួលពេលវេលាសិក្សាទៅតាមរដូវកាល នៃសកម្មភាពកសិកម្ម។

អត្រាអ្នកអត់ការងារធ្វើ និងអត្រានៃចំនួនយុវជនដែលមិនមានការងារធ្វើ មិនបានទទួលការអប់រំ ឬការបណ្តុះបណ្តាល (NEET) នៅក្នុងប្រទេសកម្ពុជាមានកម្រិតទាបដូចគ្នា។ យុវជនដែលមានការងារមានប្រាក់ខែមានច្រើន ប៉ុន្តែចំនួនយុវជនដែលកំពុងធ្វើការងារងាយរងគ្រោះមានប្រហែល 40ភាគរយ ដែលជាអត្រាមិនអាចធ្វេសប្រហែសនោះទេ។ គុណភាពការងារនៅមានកម្រិតទាបនៅឡើយ ហើយយុវជនភាគច្រើនរកចំណូលបានទាបជាងប្រាក់ឈ្នួលមធ្យមប្រចាំសប្តាហ៍។ ត្រូវតែជួយឱ្យយុវជនសព្វថ្ងៃនេះបង្កើនជំនាញរបស់ខ្លួនប្រសើរឡើង តាមរយៈការបណ្តុះបណ្តាលនៅនឹងកន្លែងធ្វើការផ្ទាល់ ឬតាមរយៈកម្មវិធីអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (TVET) បត់បែនបាន ដែលអាចឱ្យយុវជនរៀនបណ្តើរ និងធ្វើការបណ្តើរ។ ដោយសារយុវជនភាគច្រើនធ្វើការងារក្នុងវិស័យក្រៅផ្លូវការ គួរតែមានទម្រង់បញ្ជាក់ពីបទពិសោធន៍កន្លងមកដែល

អាចជួយឱ្យយុវជនបញ្ជាក់សុពលភាពរបស់ខ្លួនឯងនៅចំពោះមុខនិយោជក។ ដោយសារភាគច្រើននៃ NEET គឺជាស្ត្រីអសកម្មដែលរងនូវគំនាបគ្រួសារផងនោះ មជ្ឈមណ្ឌលការងារគួរតែផ្តល់នូវព័ត៌មានល្អប្រសើរជាងមុនអំពីឱកាសការងារនៅជុំវិញតំបន់ដែលពួកគេរស់នៅ ហើយគួរបង្កើតឱ្យមានសេវាកម្មគាំទ្រលំនៅដ្ឋាន និងការថែទាំកូនរបស់ពួកគេ ។

ជាង 80 ភាគរយ នៃយុវជនរស់នៅតាមតំបន់ជនបទ ហើយភាគច្រើននៃពួកគេធ្វើការក្នុងវិស័យកសិកម្ម។ ទោះជាយ៉ាងណា ប្រសិនបើពួកគេមានឱកាសធ្វើចំណាកស្រុកទៅទីក្រុង ឬទៅប្រទេសក្រៅ ឬអាចរកការងារក្នុងវិស័យផ្សេងទៀតបាន ពួកគេនឹងធ្វើដូច្នេះ។ សក្តានុពលក្នុងការអភិវឌ្ឍវិស័យកសិកម្មរួមទាំងសង្វាក់តម្លៃកសិ–ស្បៀងអាហារ គឺមានកម្រិតខ្ពស់។ ជាដំបូង ត្រូវលើកកម្ពស់ផលិតភាពកសិកម្មឱ្យមានភាពប្រសើរឡើង ដើម្បីបង្កើនប្រាក់ចំណូលកសិករ។ តំបន់ជនបទត្រូវការហេដ្ឋារចនាសម្ព័ន្ធប្រសើរជាងមុន ដូចជា ធារាសាស្ត្រ និងបច្ចេកទេសផលិតកម្ម ហើយកសិករវ័យក្មេងគួរតែទទួល បានបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍជំនាញអាជីវកម្ម និងទីផ្សារ។ សហគ្រិនវ័យក្មេងនៅក្នុងតំបន់ជនបទគួរត្រូវបានលើកទឹកចិត្តឱ្យបង្កើតផលិតផលបន្ថែមតម្លៃថ្មី និងសេវាកម្មរួមទាំងសង្វាក់តម្លៃកសិ-ស្បៀងអាហារផងដែរ ។ ដើម្បីឱ្យយុវជននៅតាមតំបន់ជនបទក្លាយជាសហគ្រិនវ័យក្មេង សំខាន់ពួកគេត្រូវមានលទ្ធភាពផ្នែកហិរញ្ញវត្ថុ និងការការពារពីសង្គម ។ គួរតែមានការគាំទ្របន្ថែមទៀតលើការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យមក្នុងវិស័យកសិកម្ម ព្រោះថា វាមានសក្តានុពលធំបំផុតក្នុងការបង្កើតការងារសម្រាប់យុវជន។

កង្វះខាតជំនាញគឺជាបញ្ហាធំបំផុតនៅក្នុងទីផ្សារការងារ។ និយោជកមិនអាចស្វែងរកកម្មករដែលមានសមត្ថភាពដើម្បីបំពេញតំណែងប្រកាស។ មានយុវជនតែ 31 ភាគរយ ប៉ុណ្ណោះ ដែលមានមុខរបរ ស្របនឹងគុណវុឌ្ឍិរបស់ខ្លួន ខណៈពេលដែលយុវជនចំនួន 23 ភាគរយ មានគុណវុឌ្ឍិខ្ពស់មុខរបរ និង 46 ភាគរយ មានគុណវុឌ្ឍិទាបជាងមុខរបរ។ គុណវុឌ្ឍិមិនគ្រប់គ្រាន់គឺជាបញ្ហាធ្ងន់ធ្ងរបំផុតមួយនៅក្នុងវិស័យឧស្សាហកម្ម។ ដោយសារតែអត្រាសិស្សបោះបង់សាលាខ្ពស់ មានយុវជនចំនួន 63 ភាគរយ ដែលមានអាយុចន្លោះពី 12 ទៅ 22 ឆ្នាំ បានស្ថិតនៅក្រៅសាលារៀន។ ហើយជារឿយៗ យុវជនទាំងនេះក្លាយជាកម្លាំងពលកម្មដោយគ្មានទាំងជំនាញមូលដ្ឋានទៀតផង។ យុវជនវ័យក្មេងមួយចំនួនអាចវិលត្រឡប់ទៅរកការអប់រំចំណេះទូទៅវិញបាន ប៉ុន្តែមនុស្សចាស់ចាំបាច់ត្រូវគាំទ្រពួកគេ តាមរយៈការហ្វឹកហ្វឺន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ។ កម្មវិធីផ្តល់ឱកាសលើកទីពីរនេះត្រូវតែធ្វើដោយប្រុងប្រយ័ត្នស្របនឹងតម្រូវការទីផ្សារការងារ ហើយត្រូវបណ្តុះបណ្តាលយុវជនទាំងជំនាញរឹង និងជំនាញទន់ ដើម្បីឱ្យពួកគេអាចរកការងារមានប្រាក់ខែសមរម្យ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ កំណើនអត្រាអ្នកមានគុណវុឌ្ឍិខ្ពស់ មិនត្រឹមតែគូសបញ្ជាក់អំពីគុណភាពនៃការអប់រំប៉ុណ្ណោះទេ ប៉ុន្តែ ក៏បានបង្ហាញអំពីតម្រូវការក្នុងការធ្វើឱ្យសេដ្ឋកិច្ចសម្បូរបែបពីឧស្សាហកម្មដែលត្រូវការកម្មករជំនាញទាប ដើម្បីបង្កើតបានជាការងារដែលទាមទារជំនាញខ្ពស់។

ការចូលរួមក្នុងសកម្មភាពសង្គម ធម្មតាវាផ្សារភ្ជាប់នឹងសកម្មភាពនយោបាយ ដែលគេជឿថាមិនមានសុវត្ថិភាព។ ឪពុកម្តាយបង្អាក់ទឹកចិត្តកូនមិនឱ្យចូលរួមក្នុងក្រុមនយោបាយ ឬ មិនឱ្យចំណាយពេលស្ម័គ្រចិត្តក្នុងសកម្មភាពសង្គម។ យុវជនខ្លួនឯងក៏ស្ទាក់ស្ទើរក្នុងការចូលរួមក្នុងសកម្មភាពនយោបាយផងដែរ គឺដោយសារតែការភ័យខ្លាចនឹងការផ្តន្ទាទោស។ យុវជនភាគច្រើនមិនយល់ពីគោលគំនិត ដូចជា លទ្ធិប្រជាធិបតេយ្យ សភាជាតិ ឬក្រុមប្រឹក្សាឃុំ នោះទេ។ ការងារស្ម័គ្រចិត្តគឺសរសរស្តម្ភមួយ នៃចតុស្តម្ភដែលជំរុញដោយយុទ្ធសាស្ត្រជាតិដើម្បីអភិវឌ្ឍយុវជន។ ហេតុផលនៅពីក្រោយនោះគឺថា ការងារស្ម័គ្រចិត្តមិនត្រឹមតែជួយ សហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយយុវជនឱ្យមានជំនាញទន់ដែលកន្លែងធ្វើការមួយត្រូវការចាំបាច់បំផុត។ កន្លែងសម្រាប់អង្គការមិនមែនរដ្ឋាភិបាលកំពុងកើនឡើង ប៉ុន្តែនៅមានព្រំដែននៅឡើយ។ អង្គការយុវជនធំៗមួយចំនួននៅតែគ្រប់គ្រងលើការចូលរួមក្នុងសកម្មភាពសង្គមរបស់យុវជន និងនៅតែមានទំនាក់ទំនងជាមួយនឹងអ្នកនយោបាយជាន់ខ្ពស់។ សកម្មភាពសង្គមគួរតែត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃកម្មវិធីសិក្សានៅសាលារៀន និងគួរតែរៀបចំឱ្យមានយុទ្ធនាការបន្ថែមទៀត ដើម្បីបង្កើនការយល់ដឹងអំពីរបៀបដែលយុវជនអាចចូលរួមក្នុងសកម្មភាពសង្គម ។ គួរបង្កើតឱ្យមានកិច្ចពិភាក្សាបើកចំហបន្ថែមទៀត និងឱ្យយុវជនបានចូលរួមជាផ្លូវការក្នុងការសម្រេចចិត្ត ឧទាហរណ៍៖ មានតំណាងយុវជននៅក្នុងសភាជាតិ ឬក្នុងក្រុមប្រឹក្សាអភិវឌ្ឍមូលដ្ឋាន។ តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម យុវជនមានឱកាសក្នុងការបង្កើតបរិយាកាសអំណោយផលដល់ការពិភាក្សានយោបាយបើកចំហ។សេរីភាពនៃការបញ្ចេញមតិគួរតែត្រូវបានគោរពដើម្បីឱ្យយុវជនអាចបញ្ចេញមតិរបស់ពួកគេដោយគ្មានការភ័យខ្លាចចំពោះការដាក់ទណ្ឌកម្ម។ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងក្រមសីលធម៌តាមអ៊ីនធើណិតគួរតែត្រូវបានកំណត់តាមរយៈ ច្បាប់និងបទបញ្ញាច្បាស់លាស់ដើម្បីយុវជនអាចចូលរួមដោយសេរី និងគោរព។

# ឯកសារយោង

ឯកសារយោង


ADB (2015), *Cambodia: Addressing the Skills Gap – Employment Diagnostic Study*, Asian Development Bank and International Labour Organization, Manila, https://www.adb.org/sites/default/files/publication/176283/cambodia-addressing-skills-gap.pdf.

Banta, J.E. et al. (2012), "Patterns of Alcohol and Tobacco Use in Cambodia", Asia Pacific Journal of *Public Health*, Vol. 25, No. 5 (suppl.), pp. 33S-44S.

Better Factories Cambodia (2013), "Preventing child labour in the garment industry", Better Factories Cambodia website, 30 January, http://betterfactories.org/?p=397.

Broadhurst, R., T. Bouhours and C. Keo (2013), "Crime and Justice in Cambodia", in Liu, J., B. Hebenton and S. Jou (eds), *The Asian Handbook of Criminology*, pp. 167-81, Springer Publishing, New York.

CCHR (2014), "Children in the Cambodian criminal justice system", *Briefing Note*, Cambodian Center for Human Rights, Phnom Penh.

CDC (n.d.), Global Tobacco Surveillance System Data, Centers for Disease Control and Prevention, https://www.cdc.gov/tobacco/global/gtss/gtssdata/ (accessed 20 September 2016).

Chimoyi, L. and E. Musenge (2014) Spatial analysis of factors associated with HIV infection among young people in Uganda, 2011, BioMed Central Public Health.

David, S. and C. Rollet (2015), "Youth fear joblessness", *The Phnom Penh Post*, 10 August, http://www.phnompenhpost.com/national/youth-fear-joblessness.

Fu, Q. (2004), "Trust, Social Capital, and Organizational Effectiveness", Major paper submitted to the Faculty of the Virginia Polytechnic Institute and State University in partial fulfilment of the requirements for the degree of Master of Public and International Affairs, Blacksburg VA.

Heng S., V. Mun and C. Sreang (2014), "The Enduring Gap: Decentralisation Reform and Youth Participation in Local Rural Governance", *Cambodia Development Resource Institute Working Paper Series*, No. 94, Phnom Penh.

ILO (2016), *World Employment Outlook: Trends for Youth 2016*, International Labour Office, International Labour Organization, Geneva.

ILO (2015), *Global Employment Trends for Youth 2015: Scaling up investments in decent jobs for youth*, International Labour Office, International Labour Organization, Geneva.

Inada, J. (2013), "Analysis of the Survey on Social Capital in Cambodia", *The Senshu Social Capital Review*, No. 4, July, pp. 161-89.

Kanol, H., K. Khemarin and S. Elder (2013), *Labour market transitions of young women and men in Cambodia*, Work4Youth Publication Series, September, International Labour Office, International Labour Organization, Geneva.

Kuhanen, J. (2010), "Sexualised space, sexual networking and the emergence of AIDS in Rakai, Uganda", Health & Place.

LICADHO (2015), *Rights at a Price: Life Inside Cambodia's Prisons*, Cambodian League for the Promotion and Defense of Human Rights, Phnom Penh.

LICADHO (2011), *Beyond Capacity 2011: A Progress Report on Cambodia's Exploding Prison Population*, Cambodian League for the Promotion and Defense of Human Rights, Phnom Penh.

Meng, K., M. Po and C. Thiep (2013), *Teenage Fertility and its Socio-Demographic Characteristics and Risk Factors: Further Analysis of the Cambodia Demographic and Health Survey*, National Institute of Statistics, Ministry of Planning: Directorate General for Health, Ministry of Health, Phnom Penh.

Menghun, K. and P. Zsombor (2013), "UN Says Government Statistics on Drug Users Are Too Low", *The Cambodia Daily*, 20 March, https://www.cambodiadaily.com/archives/un%E2%80%88says-government-statistics-on-drug- users-are-too-low-15356/

MoEYS (2015/16), *Education Indicators and Statistics.* Ministry of Education, Youth and Sport, Phnom Penh.

MoEYS (2010/11), *Education Indicators and Statistics.* Ministry of Education, Youth and Sport, Phnom Penh.

MoEYS (2009/10), *National Policy on Youth Development.* Ministry of Education, Youth and Sport, Phnom Penh.

Mom, Kunthear and L. Khoun (2009), "Study shows rise in youth alcohol use", *The Phnom Penh Post*, 14 September. http://www.phnompenhpost.com/national/study-shows-rise-youth-alcohol- use.

Mony, S. (2014), "Youth Fear Impending Job Competition with ASEAN", *Voice of America Cambodia*, 19 November, https://www.voacambodia.com/a/youth-fear-impending-job-competition-with-asean/2526333.html.

NACD (2014), *Annual Report on the Control of Drugs.* National Authority for Combating Drugs, Phnom Penh.

NACD (2013), *Annual Report on the Control of Drugs.* National Authority for Combating Drugs, Phnom Penh.

NACD (2012), *Annual Report on the Control of Drugs.* National Authority for Combating Drugs, Phnom Penh.

NACD (2010), *Annual Report on the Control of Drugs.* National Authority for Combating Drugs, Phnom Penh.

NDI (2013), *Report on the Voter Registry Audi (VRA) in Cambodia 2013*, National Democratic Institute, Phnom Penh.

NIS (2015a), *Cambodia Demographic Health Survey 2014*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2015b), *Cambodia Socio-Economic Survey 2014*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2012), *Cambodia School-to-Work Transition Survey 2012*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2011), *National Adult Tobacco Survey of Cambodia 2011*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2005a), *Cambodia Demographic Health Survey 2004*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2005b), *Cambodia Socio-Economic Survey 2004*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS, DGH and ICF (2015), *Cambodia Demographic and Health Survey 2014*, National Institute of Statistics, Ministry of Planning, Directorate General for Health, Ministry of Health, and The DHS Program, ICF International, Phnom Penh and Rockville, MD.

OECD (2017a), *Economic Outlook for Southeast Asia, China and India: Addressing Energy Challenges*, OECD Publishing, Paris.

OECD (2017b), *Evidence-based Policy Making for Youth Well-being: A Toolkit*, OECD Publishing, Paris.

OECD (2011), *How's Life? Measuring Well-being*, OECD Publishing, Paris, http://dx.doi.org/10.1787/9789264121164-en.

Phearun, S. and O. Banung (2012), "The political pushback: What's stopping us?", *The Phnom Penh Post*, 16 May, http://www.phnompenhpost.com/lift/political-pushback-what%E2%80%99s-stopping-us.

Reneflot, A. and M. Evensen (2014), "Unemployment and psychological distress amongst young adults in the Nordic countries: A review of the literature", *International Journal of Social Welfare*, Vol. 23, No. 1, pp. 3-15.

Rutaremwa, G. et al (n.d.), "Association between Risky Sexual Behaviour and having STIs or HIV among young persons aged 15-24 years in Uganda", https://paa.confex.com/paa/2016/mediafile/ExtendedAbstract/Paper7149/gideon%20et%20al_R evised%20mauscript25-09-2015.pdf.

Theara, K. (2013), "Youth Showing More Political Engagement as Election Approaches", *Voice of America Cambodia*, 10 July, https://www.voacambodia.com/a/youth-showing-more-political-engagement-as-election-approaches/1698262.html.

UNDP (2015), *Human Development Report 2015: Work for Human Development*, United Nations Development Programme, New York.

UNDP (2014), *UNDP Youth Strategy 2014-2017: Empowered Youth, Sustainable Future*, United Nations Development Programme, New York.

UNESCO (2015), *Adult and Youth Literacy*, UIS Factsheet, United Nations Educational, Scientific and Cultural Organization, Paris.

UNFPA (2013), *UNFPA Strategy on Adolescents and Youth*, United Nations Population Fund, New York.

WHO (2014), Adolescent pregnancy: Fact sheet, http://www.who.int/mediacentre/factsheets/fs364/en/.

# ជំពូកទី ២៖ គោលនយោបាយ និងបរិបទស្ថាប័នសម្រាប់យុវជន

# ជំពូកទី ២៖

# គោលនយោបាយ និងបរិបទស្ថាប័នសម្រាប់យុវជន

រដ្ឋាភិបាលនៃប្រទេសជាច្រើនកំពុងដាក់ចេញនូវគោលនយោបាយកើនឡើងដើម្បីអភិវឌ្ឍគោលនយោបាយទូលំទូលាយក្នុងគោលបំណងឆ្លើយតបល្អប្រសើរជាងមុនទៅនឹងតម្រូវការ និងសេចក្តីប្រាថ្នារបស់យុវជន។ ស្ទើរតែពីរប្រទេសទៅហើយក្នុងចំណោមបីប្រទេសនៅលើពិភពលោក ដែលនាពេលបច្ចុប្បន្ននេះមានគោលនយោបាយជាតិជាសម្រាប់អភិវឌ្ឍយុវជន។ ប៉ុន្តែទោះជាយ៉ាងណា គោលនយោបាយជាតិសម្រាប់អភិវឌ្ឍយុវជន ជារឿយៗ មិនត្រូវបានដាក់បញ្ចូលរួមគ្នាជាមួយនឹងផែនការអភិវឌ្ឍន៍ជាតិ ឬគោលនយោបាយជាតិឱ្យបានគ្រប់វិស័យនោះទេ ហើយក៏គ្មានកញ្ចប់ថវិកាសម្រាប់អនុវត្តដែរ។ ការខ្វះខាតនៃកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលតាមខ្សែបណ្តោយ និងខ្សែទទឹងសម្រាប់អ្នកប្រត្តិបត្តិវិស័យនីមួយៗដែលធ្លាប់មានកន្លងមកអាចបោះពាល់ដល់លទ្ធផលនៃការអនុវត្តគោលនយោបាយ និងបង្កឱ្យមានអប្រសិទ្ធភាព ដូចជា គោលយោបាយដូចគ្នា ឬជំទាស់គ្នាទៅវិញ។ ដូច្នេះ ការធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់យុវជនតម្រូវឱ្យមានការវាយតម្លៃបរិយាកាសរបស់យុវជនឱ្យបានទូលំទូលាយ និងកំណត់ថា តើគោលនយោបាយ និងបទដ្ឋានសង្គម អាចរួមចំណែកក្នុងការបើក ឬបិទសក្តានុពល ដើម្បីអភិវឌ្ឍយុវជនដោយរបៀបណា និងថាតើយុវជនអាចចូលរួមក្នុងដំណើរការគោលនយោបាយដោយរបៀបណា។

ជំពូកនេះនឹងពិនិត្យនូវគម្លាតនៃគោលនយោបាយ ជាពិសេសសម្រាប់យុវជនដែលជួបការលំបាក ពិនិត្យនូវឯកភាពគោលនយោបាយ និងការសម្របសម្រួលរវាងស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធនឹងកម្មវិធីនិងគោលនយោបាយសម្រាប់យុវជន ពិនិត្យនូវសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា (អយក.) ជាពិសេស ក្រុមប្រឹក្សាយុវជនជាតិ (NYC) និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាយុវជនជាតិដែលទើបបង្កើតថ្មីក្នុងការអនុវត្តតួនាទីរបស់ខ្លួនដែលជាទីភ្នាក់ងារសម្របសម្រួលគោលនយោបាយស្តីពីយុវជន។ ជាចុងក្រោយ ជំពូកនេះនឹងពិនិត្យពីស្ថានភាពនៃការចូលរួមក្នុងសកម្មភាពសង្គម និងយន្តការច្បាប់ និងការអនុវត្តជាក់ស្តែងដែលត្រូវលើកកម្ពស់យុវជនឱ្យចូលរួមក្នុងដំណើរការបង្កើតគោលនយោបាយ។

## ២.១ បរិបទសេដ្ឋកិច្ចសង្គម

កម្ពុជាសម្រេចបាននូវអត្រាកំណើនផលិតផលសរុបក្នុងស្រុក (Gross Domestic Product ហៅកាត់ថា GDP) ជាមធ្យមចំនួន 7 ភាគរយ ក្នុងរយៈពេល 10 ឆ្នាំកន្លងមកនេះ និងបានកាត់បន្ថយភាពក្រីក្រ[9]ពីចំនួន 50 ភាគរយ ក្នុងឆ្នាំ 2003 ដល់ 17,7 ភាគរយ ក្នុងឆ្នាំ 2012 (យោងតាម WDI)។ បច្ចុប្បន្ននេះ យុវជនកម្ពុជាមានចលភាព ទំនាក់ទំនងកាន់តែច្រើន និងមានសេចក្តីប្រាថ្នាសម្រាប់អនាគតខ្ពស់ជាងមុន។ អត្រាយុវជននៅកម្ពុជាមានចំនួនច្រើនជាង 30 ភាគរយ នៃប្រជាជនសរុបដែលមានអាយុចន្លោះពី 15 ទៅ 30 ឆ្នាំ ហើយយុវជនទាំងនេះនឹងក្លាយជាធនធានដ៏រុងរឿងរបស់កម្ពុជានាពេលអនាគត។ ទោះជាយ៉ាងណា បើប្រៀបធៀបទៅនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ចដែលសម្រេចបាន សុខុមាលភាពរបស់យុវជននៅមិនប្រសើរនៅឡើយទេ។ កាលពីឆ្នាំ 2009 ការសិក្សាមួយដែលធ្វើឡើងដោយ UNDP លើកឡើងថារចនាសម្ព័ន្ធសេដ្ឋកិច្ចនាពេលបច្ចុប្បន្នមិនបានបំពេញតម្រូវការរបស់យុវជនទេ ជាពិសេសក្នុងវិស័យការងារ ការអប់រំនិងជំនាញ និងវិស័យសុខភាព។ ហើយក៏មានយុវជនដែលជួបការលំបាកមួយក្រុមដែលបានទទួលការគាំទ្រជាសាធារណៈតិចតួចបំផុត (យោងតាម UNDP ឆ្នាំ 2009)។ ទីផ្សារការងារមិនអាចស្រូបយកកម្លាំងពលកម្មថ្មីដែលក្នុងមួយឆ្នាំមានចំនួន 300 000 នាក់ឱ្យចូលក្នុងទីផ្សារការងារនោះទេ។

ទោះបីជាការពិតដែលថា មានយុវជនជាង 80 ភាគរយ រស់នៅក្នុងតំបន់ជនបទក៏ដោយ ក៏ពួកគេតិចតួចណាស់មានបំណងចង់ក្លាយជាកសិករដូចឪពុកម្តាយរបស់ខ្លួន និងសុខចិត្តធ្វើចំណាកស្រុកទៅទីក្រុងឬទៅប្រទេសជិតខាងដើម្បីស្វែងរកការងារបានប្រាក់ខែសមរម្យ។ យោងតាម MFI បានឱ្យដឹងថា ផ្លូវថ្នល់ល្អ ទូរគមនាគមន៍ល្អ និងលទ្ធភាពខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុងាយស្រួល ការរីកចម្រើនផ្នែកវិស័យទេសចរណ៍ និងវិស័យកាត់ដេរបានទាក់ទាញយុវជនជាច្រើនទៅកាន់ទីក្រុង ជាពិសេសទៅរាជធានីភ្នំពេញ និងទៅខេត្តសៀមរាប (យោងតាម Bylander, 2013). ។ នៅក្នុងឆ្នាំ2013-14 ឧស្សាហកម្មកាត់ដេរមួយចំណែកចំនួន 16 ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅកម្ពុជា (យោងតាម Kane, ឆ្នាំ 2015) ហើយនៅក្នុងឆ្នាំ វាបានបង្កើតឱកាសការងារសម្រប់កម្មករប្រហែល 630 000 នាក់ ភាគច្រើនជាស្ត្រី និងចំណាកស្រុក (យោងតាម Turton 2015 & UNDP ឆ្នាំ 2015)។ ភស្តុតាងមួយចំនួនបានបង្ហាញថា ការបោះបង់សាលានៅវ័យដំបូងបានផ្សារភ្ជាប់ទៅនឹងឱកាសការងារ ដែលនាំឱ្យមានអត្រាខ្ពស់នៃយុវជនកម្ពុជាចូលទៅក្នុងទីផ្សារការងារជាកម្មករគ្មានជំនាញ (យោងតាម CCASVA ឆ្នាំ2015) ។ ទោះបីជាប្រាក់ខែអប្បបរមារបស់កម្មករកាត់ដេរបានកើនឡើងពី 140 ដុល្លារអាមេរិក ទៅ 153 ដុល្លារអាមេរិក តាំងពីខែមករា ឆ្នាំ2017 មកក៏ដោយ ក៏វានៅតែទាបនៅឡើយ បើប្រៀបធៀបទៅនឹងតម្លៃ នៃការចំណាយនាពេលបច្ចុប្បន្ន។

សុខភាព និងអាហារូបត្ថម្ភគឺជាទិដ្ឋភាពសំខាន់ នៃសុខុមាលភាពរបស់យុវជន ជាពិសេសសុខភាពផ្លូវភេទនិងបន្តពូជ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីម្ចាស់ជំនួយធំៗបានខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការឆ្លងមេរោគអេដស៍គួរជាទីកត់សម្គាល់ និងក្នុងការលើកកម្ពស់ការអនុវត្តការធ្វើផែនការគ្រួសារដ៏មានប្រសិទ្ធិភាព។ លើសពីនេះ កម្ពុជាកំពុងយកចិត្តទុកដាក់ចំពោះបញ្ហាសុខភាពរបស់យុវជនពោលគឺ អាហាររូបត្ថម្ភ និងសុវត្ថិភាពចំណីអាហារ។ កម្រិតខ្ពស់នៃការខ្វះខាតអាហារូបត្ថម្ភរបស់កុមារកម្ពុជាទាក់ទងផ្ទាល់ជាមួយនឹងអាហារូបត្ថម្ភរបស់ម្តាយវ័យក្មេង (យោងតាម MoH ឆ្នាំ2008)។ សុវត្ថិភាពចំណីអាហារគឺជាក្តីបារម្ភមួយទៀតដែលកំពុងកើតឡើងក្នុងស្រទាប់ប្រជាជនទូទៅ និងកាន់តែបារម្ភថែមទៀតចំពោះកម្មករចំណាកស្រុក ជាពិសេសកម្មករកាត់ដេរ (យោងតាមអង្គការ Care ឆ្នាំ2015)។

ដោយមានការកើនឡើងនូវលទ្ធភាពប្រើប្រាស់អ៊ីនធើណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម យុវជនបានចូលរួមក្នុងនយោបាយច្រើនជាងមុន។ ការបោះឆ្នោតឆ្នាំ 2013 គឺជាការបោះឆ្នោតក្មេងខ្ចីនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដោយមានការចូលរួមក្នុងនយោបាយពីសំណាក់យុវជនអាយុក្រោម 25 ឆ្នាំ ដែលមិនធ្លាប់មានពីមុនមកនេះ អាចជាសារមួយថា រដ្ឋាភិបាលមិនបានធ្វើគ្រប់យ៉ាងសម្រាប់ពួកគេ។ ថ្មីៗនេះ ប្រព័ន្ធផ្សព្វផ្សាយសង្គមជួយបានយ៉ាងច្រើនពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសង្គម និងនយោបាយ។ គណបក្សកាន់អំណាចក៏បានប្រើប្រាស់វិធីសាស្ត្រនេះដើម្បីចូលទៅដល់ស្រទាប់យុវជន និងដើម្បីបើកទ្វារចំហឱ្យយុវជនទាំងនៅក្នុងគណបក្សនិងក្នុងជួររដ្ឋាភិបាលក្លាយជាអ្នកដឹកនាំជំនាន់ថ្មីផងដែរ ។ បច្ចុប្បន្ននេះ រដ្ឋាភិបាលកំពុងប្រើប្រាស់ប្រព័ន្ធអ៊ីនធើណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីចូលដល់ស្រទាប់យុវជន និងកំពុងព្យាយាមសាងរូបភាពថ្មីមួយងាយស្រួលសម្រាប់យុវជន។ អំឡុងពេលប៉ុន្មានឆ្នាំមកនេះ អ្នកនយោបាយជំនាន់ថ្មី មន្ត្រីរាជការ ពាណិជ្ជករ សាស្ត្រាចារ្យ មេដឹកនាំសហគមន៍ និងអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានផុសចេញជារូបរាងឡើង។

ការចូលរួមរបស់យុវជនក្នុងដំណើរការបង្កើតគោលនយោបាយទាមទារឱ្យមានការយល់ដឹងអំពីបរិបទប្រវត្តិសាស្ត្រកម្ពុជា។ យុវជនជំនាន់ក្រោយ ឬយុវជនបច្ចុប្បន្នបានកើតក្រោយសម័យសង្គ្រាម និងក្រោយរបបប្រល័យពូជសាសន៍ ហើយការគិតរបស់ពួកគេពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសង្គម និងតួនាទីរបស់រាជរដ្ឋាភិបាលគឺខុសគ្នាពីការគិតរបស់ឪពុកម្តាយពួកគេ។ បច្ចុប្បន្ននេះ វិធីដែលយុវជនអាចចូលរួមក្នុងសកម្មភាពសង្គមដែលភាគច្រើនក្នុងរូបភាពជាការងារស្ម័គ្រចិត្តគឺតាមរយៈអង្គការយុវជនធំៗដែលគ្រប់គ្រងដោយរដ្ឋាភិបាល ។ ទោះបីជាមានអង្គការក្រៅរដ្ឋាភិបាលដឹកនាំដោយយុវជនបានផុសឡើងយ៉ាងច្រើនក៏ដោយ ក៏ការចូលរួមក្នុងសកម្មភាពសង្គម និងនយោបាយមិនត្រូវបានយល់ពីសំណាក់មនុស្សចាស់ដែរ ។ របាយការណ៍មួយរបស់អង្គការសហប្រជាជាតិឆ្នាំ 2009 ស្តីពីការចូលរួមរបស់យុវជនបានផ្តល់អនុសាសន៍ថា ត្រូវជំរុញកិច្ចខិតខំប្រឹងប្រែងធ្វើវិមជ្ឈការ និងវិសហមជ្ឈការដើម្បីឱ្យយុវជនអាចមានឱកាសចូលរួមក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន (យោងតាម UN ឆ្នាំ2009)។

## ២.២ ផែនការគោលនយោបាយស្តីពីយុវជន

គោលនយោបាយ និងយន្តការជាច្រើនត្រូវអនុវត្តនៅនឹងកន្លែងដើម្បីកែលម្អស្ថានភាពរបស់យុវជនឱ្យបានប្រសើរឡើង។ គម្រោងថ្នាក់ជាតិដើម្បីអភិវឌ្ឍន៍ និងគោលនយោបាយគ្រប់វិស័យសុទ្ធតែផ្តោតលើការអភិវឌ្ឍយុវជន ជាពិសេសផ្តោតលើការងាររបស់យុវជន។ នៅតាមស្ថាប័ន យន្តការថ្មីៗត្រូវបានបង្កើតឡើងដើម្បីសម្រួលដល់ការចូលរួមរបស់យុវជន និងមានតំណាងយុវជននៅក្នុងដំណើរការបង្កើតគោលនយោបាយ។ ទោះយ៉ាងណា

ការអនុវត្តវិធានការទាំងនេះបានប្រឈមនឹងបញ្ហាខ្លះៗដែរ។ ក្នុងផ្នែកនេះនឹងពិនិត្យលើខ្លឹមសារសំខាន់ នៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ( National Youth Development Policy ហៅកាត់ថា NYDP) លើផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (National Youth Action Plan ហៅកាត់ថា NYAP ) លើគោលនយោបាយគ្រប់វិស័យពាក់ព័ន្ធនឹងដំណើរ និងកំណែទម្រង់ការផ្ទេរិកា និងពាក់ព័ន្ធនឹងយន្តការផ្តល់សេវានៅថ្នាក់ក្រោមជាតិ។

### ២.២.១ ក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍជាតិ

យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី III (Rectangular Strategy Phase III) និង ផែនការយុទ្ធសាស្រ្តជាតិដើម្បីអភិវឌ្ឍន៍ (National Strategic Development Plan ហៅកាត់ថា NSDP) បានដាក់ចេញដើម្បីធានាឱ្យបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំចំនួន 7 ភាគរយ បង្កើតការងារបន្ថែម សម្រាប់យុវជនតាមរយៈការជំរុញវិស័យឯកជន ការពារបរិស្ថាន និងពង្រឹងអភិបាលកិច្ចល្អទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ គោលនយោបាយម៉ាក្រូផ្សេងទៀតដូចជា គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម គោលនយោបាយជាតិមុខរបរ និងការងារ និងគោលនយោបាយទេសន្តប្រវេសន៍ការងារ ក៏បានរួមបញ្ចូលទាំងវិធានការកែលម្អការងាររបស់យុវជនផងដែរ។ គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មមានមុំបួនគឺ៖ ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម ការកែលម្អបរិយាកាសវិនិយោគ និងការអភិវឌ្ឍធនធានមនុស្សសម្រាប់កម្លាំងពលកម្ម ដែលការអភិវឌ្ឍធនធានមនុស្សសម្រាប់កម្លាំងពលកម្មមានផលប៉ះពាល់ដោយផ្ទាល់លើការអភិវឌ្ឍយុវជន។ គោលនយោបាយជាតិមុខរបរ និងការងាររួមចំណែកក្នុងការលើកកម្ពស់ការងារ និងជំនាញ ជាពិសេសសម្រាប់យុវជន ដោយប្រើសសរស្តម្ភបីគឺ៖ (១) ការបង្កើនឱកាសការងារសមរម្យ និងផលិតភាព (២) ការពង្រឹងជំនាញ និងការអភិវឌ្ឍធនធានមនុស្ស និង (៣) ការលើកកម្ពស់អភិបាលកិច្ចទីផ្សារការងារ។ គោលនយោបាយទេសន្តប្រវេសន៍ ការងារភាគច្រើនផ្តោតលើការធ្វើចំណាកស្រុកឆ្លងកាត់ព្រំដែន និងគ្រប់គ្រងពលករចំណាកស្រុកដើម្បីការអភិវឌ្ឍ។ (សូមមើលប្រអប់ 2.1 ស្តីពីផលប៉ះពាល់នៃសោភាកម្មការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈពាក់ព័ន្ធនឹងការធ្វើចំណាកស្រុក) ។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (NYDP) ដែលត្រូវបានអនុម័តនៅឆ្នាំ 2011 និងសេចក្តីព្រាង នៃផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP ) ដែលផ្តួចផ្តើមឡើងនៅឆ្នាំ 2015 ទាមទារឱ្យមានការយល់ដឹងនូវបរិបទ នៃការគោលនយោបាយម៉ាក្រូខាងលើឱ្យបានទូលំទូលាយ។ ទាំង NYDP និង NYAP មានវិសាលភាពទូលំទូលាយពិស្តារ ដោយតម្រូវឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមក្នុងកម្មវិធី និងសកម្មភាពអភិវឌ្ឍយុវជន។ NYDP កំណត់ចក្ខុវិស័យវែងឆ្ងាយ "ដើម្បីប្រមូលផ្តុំកិច្ចខិតខំប្រឹងប្រែងទាំងអស់ដែលមាននៅក្នុងប្រទេស ដើម្បីរួមចំណែកជាវិជ្ជមានដល់ការអភិវឌ្ឍយុវជន និងផ្តល់ឱកាសឱ្យពួកគេធ្វើការអភិវឌ្ឍសក្តានុពលខ្លួនទទួលបានការអប់រំ សេវាការងារនិងសុខភាព និងការចូលរួមនៅក្នុងការសម្រេចចិត្ត និងរួមចំណែកដល់គ្រួសារ សហគមន៍ ការអភិវឌ្ឍជាតិ និងសកលលោក ។ "ទោះយ៉ាងណាឯកសារទាំងពីរមិនបានបញ្ចូលយន្តការថវិកា និងហិរញ្ញប្បទានលម្អិតនោះទេ។ "

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (NYDP) បានដាក់ចេញយុទ្ធសាស្រ្តចំនួន 12 គឺ៖(1) អភិវឌ្ឍក្របខ័ណ្ឌច្បាប់និងយន្តការ (2) ការលើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព (3) បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព (4) បណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ (5) ការលើកកម្ពស់កិច្ចការពារសុវត្ថិភាព សន្តិសុខ និងយុត្តិធម៌ (6) បង្កើនការចូលរួមរបស់យុវជន (7) ការលើកកម្ពស់ការសំរាក ការកម្សាន្ត និងកីឡា (8) លើកកម្ពស់សិល្បៈនិងវប្បធម៌ (9) លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច (10) បង្កើនការងារស្ម័គ្រចិត្ត (11) ការលើកកម្ពស់សមភាពយេនឌ័រ (12) ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងការស្តារនីតិសម្បទាយុវជនដែលរងគ្រោះដោយគ្រឿងញៀន។ ដំណាក់បឋមនេះ ផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) ផ្តោតលើយុទ្ធសាស្រ្តចំនួន 6 ដំបូងគេ ក្នុងចំណោមយុទ្ធសាស្រ្តទាំង 12 ។

ផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) ដែលបានកំណត់គោលបំណងដើម្បីប្រតិបត្តិ NYDP ចែងថា គ្រប់ក្រសួង និងទីភ្នាក់ងាររបស់រាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នមិនមែនរដ្ឋ ត្រូវបានគេរំពឹងថានឹងរួមចំណែកក្នុងការអនុវត្តស្មារតីរបស់ខ្លួន។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ) ដែលបង្កើតឡើងនៅក្នុងឆ្នាំ 2014 គឺដើម្បីដើរតួនាទីសម្របសម្រួល នាំយកសកម្មភាពដែលបានអនុវត្តនៅទូទាំងប្រទេសមកបញ្ចូលគ្នា កំណត់អត្តសញ្ញាណការអនុវត្តល្អបំផុត អនុម័តនិងកែតម្រូវសម្រាប់បរិបទក្នុងតំបន់ និងបន្តធ្វើការត្រួតពិនិត្យ និងវាយតម្លៃដើម្បីធានាថា សកម្មភាពទាំងនោះធ្វើឡើងដើម្បីជាប្រយោជន៍ដល់យុវជនកម្ពុជា។ ទោះបីជាមានវិធីសាស្រ្តការធ្វើផែនការដែលទំនើបក៏ដោយ ក៏ NYAP មិនបានផ្តល់ព័ត៌មានស្តីពីយន្តការ និងការផ្តល់ថវិកានៅថ្នាក់ក្រោមជាតិនោះទេ។

**ប្រអប់ 1 (2-1) ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈអាចជួយទប់ស្កាត់ការធ្វើចំណាកស្រុក**

ការសិក្សាដែលមានមូលដ្ឋានលើការស្ទង់មតិថ្មីមួយដោយមជ្ឈមណ្ឌលអភិវឌ្ឍOECDបានរកឃើញថា កត្តាជំរុញចម្បងនៃការធ្វើចំណាកស្រុកគឺជាឱកាសការងារ។ ជិត 2 ភាគ 3 នៃជនអន្តោប្រវេសន៍បច្ចុប្បន្នត្រូវបានរាយការណ៍ថា បានចាកចេញពីប្រទេសដើម្បីស្វែងរកការងារនៅបរទេស។ គោលដៅដ៏ពេញនិយមរួមមានប្រទេសថៃ ម៉ាឡេស៊ី និងកូរ៉េខាងត្បូងដែលប្រាក់ខែខ្ពស់ជាងនៅនៅក្នុងស្រុក។ ក្នុងចំនោមអ្នកដែលធ្វើចំណាកស្រុកទាំងនោះ មាន 1 ភាគ 3 ផ្ញើរដូច្នេះដើម្បីជួយគ្រួសារ។ សេវាការងារដូចដែលផ្តល់ការផ្តល់ដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ (ហៅកាត់ថា NEA) បានផ្តល់ការណែនាំដល់អ្នកស្វែងរកការងារធ្វើ និងផ្តល់ព័ត៌មានទីផ្សារការងារ។ ទោះយ៉ាងណាក៏ដោយ មជ្ឈមណ្ឌលអភិវឌ្ឍOECD បានរកឃើញថា មានតែ 4 ភាគរយ នៃប្រជាជនកម្ពុជាដែលធ្វើការនៅក្នុងវិស័យសាធារណៈ ឬឯកជន បានរកការងារតាមរយៈភ្នាក់ងារការងាររបស់រាជរដ្ឋាភិបាល (បុរស 6 ភាគរយ និងស្ត្រី 2 ភាគរយ។ ( មនុស្សភាគច្រើនបានប្រើប្រាស់បណ្តាញផ្ទាល់ខ្លួនរបស់ពួកគេ ឬទាក់ទងទៅនិយោជកដោយផ្ទាល់។ ការរកឃើញគួរឱ្យចាប់អារម្មណ៍មួយគឺសម្រាប់អ្នកដែលរកការងារធ្វើតាមរយៈទីភ្នាក់ងារការងាររបស់រដ្ឋាភិបាលមានចំនួនតិចតួចប៉ុណ្ណោះ (6 ភាគរយ) មានបំណងធ្វើចំណាកស្រុក ខណៈដែលចំនួនច្រើនជាងនេះ (17 ភាគរយ) ដែលរកបានការងារដោយខ្លួនឯងបានគ្រោងនឹងធ្វើចំណាកស្រុក ។

ទោះបីជាការការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស (TVET) មានសក្តានុពលក្នុង ដើម្បីពង្រឹងកម្លាំងពលកម្ម និងកាត់បន្ថយគម្លាតជំនាញនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏បច្ចុប្បន្ននេះមានតែ 5% នៃកម្លាំងពលកម្មប៉ុណ្ណោះដែលចូលរួមក្នុង TVET ។ ការសិក្សានេះបានរកឃើញថា នៅប្រទេសកម្ពុជាអ្នកដែលបានទទួលការបណ្តុះបណ្តាលទំនងជាមិនសូវធ្វើចំណាកស្រុក និងទំនងជារកការងារធ្វើក្នុងទីផ្សារការងារក្នុងស្រុក គឺមិនដូចនៅប្រទេសដទៃដែលការបណ្តុះបណ្តាលវិជ្ជាជីវៈជាទូទៅជួយជនអន្តោប្រវេសន៍ឱ្យមានការងារធ្វើក្រៅប្រទេសហើយហេតុនេះជំរុញឱ្យមានការធ្វើអន្តោប្រវេសន៍ ។

ប្រភព: OECD / CDRI (ឆ្នាំ2017) ទំនាក់ទំនងរវាងគោលនយោបាយសាធារណៈ: ការធ្វើចំណាកស្រុក និងការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា, http://dx.doi.org/10.1787/9789264273634-en.

### ២.២.២ សារពើភ័ណ្ឌនៃគោលនយោបាយពាក់ព័ន្ធនឹងយុវជន

ផ្នែកនេះនឹងនិយាយអំពីគោលនយោបាយផ្សេងៗដែលមានប្រកាសចេញពី ក្រសួងអប់រំ យុវជន និងកីឡា (ហៅកាត់ថា អយក.) ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (ហៅកាត់ថា MOLVT) ក្រសួងសុខាភិបាល (ហៅកាត់ថា MoH) ក្រសួងកិច្ចការនារី (ហៅកាត់ថា MoWA) និង ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា (ហៅកាត់ថា MoSAVY) (សូមមើល តារាង 2.1)។

**តារាង 17 (2-1) សារពើភ័ណ្ឌនៃគោលនយោបាយស្តីពីយុវជន តាមក្រសួងពាក់ព័ន្ធ**

| វិស័យ | ក្របខ័ណ្ឌយុទ្ធសាស្ត្រ | កម្មវិធីគន្លឹះ និងបញ្ហាបានដោះស្រាយ |
|---|---|---|
| **អប់រំ** | **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ 2014-18** | **សសរស្តម្ភសំខាន់ទាំងបី៖**<br>១. សមភាពក្នុងសេវាអប់រំ<br>• **គោលនយោបាយសាលាកុមារមេត្រី** (Child friendly school **ហៅកាត់ថា CFS**)៖ ចូលជាធរមានតាំងពីឆ្នាំ 2001 គោលបំណងគឺដើម្បីរួមចំណែកដល់គោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នាតាមរយៈការបង្កើតបរិយាកាសសិក្សាឱ្យបានសមរម្យធ្វើឱ្យកុមារស្នាក់នៅក្នុងសាលារៀនយូរ ឬយ៉ាងហោចណាស់បញ្ចប់រយៈពេលប្រាំបួនឆ្នាំនៃការអប់រំកម្រិតមូលដ្ឋាន។ CFS ត្រូវបានគេអនុវត្តនៅក្នុង 70 ភាគរយ នៃសាលាបឋមសិក្សា ហើយនឹងត្រូវពង្រីកទៅគ្រប់ខេត្ត។<br>• **កម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូច (**Early childhood care and development **ហៅកាត់ថា ECCD)**៖ ECCD ចាប់ផ្តើមក្នុងឆ្នាំ 2010 មានគោលបំណងដើម្បីផ្តល់នូវសេវាអភិវឌ្ឍការថែទាំកុមារតូចអាយុ 5 ឆ្នាំ ជាពិសេសកុមារជួបការលំបាកនិងកុមារមានហានិភ័យខ្ពស់នៃជំងឺវិកលចរិតអភិវឌ្ឍ ការខ្វះខាតអាហារូបត្ថម្ភ និងពិការ។ នៅឆ្នាំ 2013 កម្មវិធីនេះសម្រេចបានអត្រា 53 ភាគរយ លើគោលដៅ 60 ភាគរយ នៃការចុះឈ្មោះចូលរៀនរបស់កុមារអាយុ 5 ឆ្នាំ។ គោលដៅបច្ចុប្បន្នគឺចុះឈ្មោះចូលរៀនឱ្យបាន 80 ភាគរយ នៃកុមារនៅឆ្នាំ 2018។<br>• **គម្រោងអប់រំកុមារពិការ** (Education for Children with Disabilities **ហៅកាត់ថា ECD)**៖ គម្រោងសាកល្បងមួយដែលបានចាប់ផ្តើមនៅឆ្នាំ 2000 ដោយសហការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការបានផ្តល់ថវិកាដោយអង្គការ UNICEF មានគោលបំណងធ្វើសមាហរណកម្មកុមារពិការទៅក្នុងសហគមន៍និងស្ថាប័នដែលពាក់ព័ន្ធផ្តល់សេវាព្យាបាលដោយចលនានិងសុខភាព ការអប់រំដែលមានគុណភាពនិងជំនាញជីវិត។ ឥឡូវ ECD បានពង្រីកទៅដល់សាលារៀនចំនួន 80 នៅក្នុងខេត្តចំនួន 15 និងបន្តបង្កើនការគ្របដណ្តប់របស់ខ្លួន។<br>• កម្មវិធីអក្ខរកម្មនិងសិក្សាពេញមួយជីវិត<br>• ឱកាសទទួលបានការអប់រំលើកទីពីរតាមរយៈកម្មវិធីអប់រំក្រៅប្រព័ន្ធដែលរួមមានកម្មវិធីអក្ខរកម្មសម្រាប់ការងារណាមួយ កម្មវិធីសមមូល មជ្ឈមណ្ឌលសិក្សាសហគមន៍ កម្មវិធីត្រួតថ្នាក់ កម្មវិធីបំប៉ន។<br>• ហារូបករណ៍ជាសាច់ប្រាក់និងម្ហូបអាហារសម្រាប់អ្នកសិក្សាអប់រំក្រៅប្រព័ន្ធ<br>២. ការផ្តល់សេវាអប់រំប្រកបដោយគុណភាពនិងប្រសិទ្ធភាព<br>• ប្រព័ន្ធគុណភាពសាលារៀននិងកម្មវិធីធានាគុណភាព<br>• មធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេសតាមរយៈការថវិកា GTHS សម្រាប់ប្រតិបត្តិការសាលារៀន ការអភិវឌ្ឍកម្មវិធីសិក្សា បំណិនជីវិត EVEP សេវាការតំរង់ទិសវិជ្ជាជីវៈ និងផ្តល់ប្រឹក្សាការងារ<br>• កម្មវិធីពង្រឹងប្រព័ន្ធវាយតម្លៃនិស្សិតជាតិនិងអន្តរជាតិ<br>• កម្មវិធីអភិវឌ្ឍន៍ថ្នាក់ឧត្តមសិក្សា<br>• កម្មវិធីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងលទ្ធផលជាមូលដ្ឋាន<br>• ការធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុនិងកម្មវិធីផ្តល់ហិរញ្ញប្បទានដល់ការអប់រំ<br>• សេវាអប់រំសុខភាព<br>• កម្មវិធីអាហារូបករណ៍សម្រាប់ការអប់រំមធ្យមសិក្សា ការអប់រំបច្ចេកទេស និងឧត្តមសិក្សា<br>• កម្មវិធីអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ<br>• កម្មវិធីអភិវឌ្ឍន៍ជំនាញទន់និងជំនាញបច្ចេកទេសសម្រាប់យុវជន<br>• ការងារក្រុមប្រឹក្សាយុវជននិងកុមារ កម្មវិធីមិត្តអប់រំមិត្ត កម្មវិធីយុវជនស្ម័គ្រចិត្ត និងសកម្មភាពសមាគមនិស្សិត<br>• អប់រំកាយនិងកម្មវិធីកែលម្អកីឡា<br>៣. ការអភិវឌ្ឍស្ថាប័ននិងសមត្ថភាពមន្ត្រីអប់រំសម្រាប់វិមជ្ឈការ<br>• ការគ្រប់គ្រងការងារគ្រូបង្រៀននិងកម្មវិធីវាយតម្លៃដើម្បីកែលម្អគុណភាពនៃការបង្រៀន |
| **សុខភាព** | **ផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ 2008-15** | • ការធ្វើផែនការគ្រួសារនិងការពន្យារកំណើត<br>• ការរំលូតកូនដោយសុវត្ថិភាព<br>• អាហារូបត្ថម្ភមាតានិងកូន (ស្ត្រីជាម្តាយមានអាយុជាយុវជន)<br>• សមាហរណកម្មថែរក្សាមាតានិងទារកក្រោយពេលសម្រាល<br>• សេវាសុខភាពយុវជន/មនុស្សវ័យជំទង់<br>• ការបង្ការនិងការថែទាំជំងឺអេដស៍/មេរោគអេដស៍/និងជំងឺកាមរោគ<br>• សុខភាពផ្លូវចិត្តរួមទាំងការប្រើប្រាស់គ្រឿងញៀន<br>• សុវត្ថិភាពអាហារ<br>• ថ្នាំជក់ |
| **ការងារ** | **ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ 2013**<br><br>**ផែនការយុទ្ធសាស្ត្រការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ 2014-18** | • **ហាងលក់ការងារ៖** គឺជាសេវាការងារនៅក្នុងមហាវិទ្យាល័យដើម្បីជួយដល់និស្សិតបញ្ចប់ការសិក្សាបច្ចេកទេសនិងសមាជិកសហគមន៍ស្វែងរកការងារ។<br>• **ជំនាញស្ពាន៖** កម្មវិធី 168 ម៉ោងផ្តល់ឱ្យយុវជនក្រៅសាលាដែលបានបញ្ចប់ថ្នាក់ទី 7 ប៉ុន្តែមិនបានបញ្ចប់ថ្នាក់ទី 9 និងបានចេញពីសាលារៀនយ៉ាងហោចណាស់ពីរឆ្នាំ។ កម្មវិធី TVET ទទួលយកតែសិស្សដែលយ៉ាងហោចណាស់មានសញ្ញាបត្រថ្នាក់ទី 9 ។ កម្មវិធីនេះគ្រប់គ្រងដោយសាលាបច្ចេកទេសក្នុងតំបន់ដែលស្គាល់ភូមិនៅក្នុងតំបន់របស់ពួកគេ (ថវិកា៖ ដុល្លារពី ADB និង AFD ចំនួន 2 លានដុល្លារអាមេរិក)<br>• **និតប័ណ្ណបណ្តុះបណ្តាលជំនាញ ៖** គឺជាកម្មវិធីបណ្តុះបណ្តាលខ្លីពី 2 សប្តាហ៍ទៅ 3 ខែរៀបចំដោយមហាវិទ្យាល័យបច្ចេកទេស តាមការស្នើរសុំពីភូមិដើម្បីបំពេញតម្រូវការការងាររបស់យុវជនក្រៅសាលានិងសមាជិកសហគមន៍។ ឧទាហរណ៍៖ កម្មវិធីហ្វឹកហ្វឺនកូនជាងជាមួយសិប្បករក្នុងតំបន់ដែលបានទទួលប្រាក់ឧបត្ថម្ភសម្រាប់បណ្តុះបណ្តាសិស្សថ្មី។ កម្មវិធីនេះណ្តុះបណ្តាលយុវជនពី 100.000 ដល់ |

| | | |
|---|---|---|
| | **ផែនការអភិវឌ្ឍការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (ហៅកាត់ថា TVET) ឆ្នាំ 2008** | 200.000 នាក់ ជារៀងរាល់ឆ្នាំ (ចាប់ផ្តើមជាមួយនឹងការផ្តល់មូលនិធិដំបូងពី ADB ហើយឥឡូវនេះជាផ្នែកមួយនៃថវិកាជាតិ)។<br>• **កម្មវិធីផ្តល់ប្រឹក្សាអាជីព៖** ផ្តល់ជូនតាមរយៈមហាវិទ្យាល័យបច្ចេកទេស។ បន្ថែមពីនោះ ទីភ្នាក់ងារជាតិមុខរបរនិងការងារក្នុងលើសពីនេះទៀតនាយកដ្ឋាននៃ MoLVT មានកម្មវិធីផ្តល់ប្រឹក្សាអាជីពសកម្មសម្រាប់សិស្សនិស្សិតទាំងអស់តាមរយៈមជ្ឈមណ្ឌលអាជីពរបស់ខ្លួននៅក្នុងខេត្តនីមួយ។<br>• **វិញ្ញាបនប័ត្របណ្តុះបណ្តាលវិជ្ជាជីវៈ 1, 2, 3៖** ប្រព័ន្ធ TVET នៃវិទ្យាស្ថានបច្ចេកទេសចំនួន 39 ផ្តល់កម្មវិធីវិញ្ញាបនបត្រក្រោយថ្នាក់ទី9 បន្ទាប់ពីការសិក្សារយៈពេលបីឆ្នាំដែលអាចឈានដល់ទទួលបានវិញ្ញាបនបត្រក្នុងក្របខ័ណ្ឌគុណៈសម្បត្តិគុណវុឌ្ឍិនៅកម្ពុជា។ គោលដៅគឺនិស្សិតបញ្ចប់ការសិក្សាចំនួន 22.000 នាក់ក្នុងមួយឆ្នាំ(ថវិកា៖ 5 លានដុល្លារពីថវិកាជាតិ) ។<br>• **កម្មវិធីនិស្សិតកម្មសិក្សាស្ម័គ្រចិត្ត៖** គោលនយោបាយ TVET ជាតិគាំទ្រកម្មវិធីនិសិត្សកម្មសិក្សាស្ម័គ្រចិត្តនិងទម្រង់សម្រាប់ផ្សារភ្ជាប់ការបណ្តុះបណ្តាលសិស្សថ្មីរវាងមហាវិទ្យាល័យបច្ចេកទេសនិងការងារ។ និសិត្សកម្មសិក្សាស្ម័គ្រចិត្តកំពុងបង្កើតឡើងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ADB ។<br>**កម្មវិធីផ្សេងទៀត:**<br>• យន្តការកំណត់ប្រាក់ខែ<br>• គម្រោងធានារ៉ាប់រងមូលនិធិសន្តិសុខសង្គម<br>• កម្មវិធីអាហារូបករណ៍<br>• សេវាការងារចល័ត<br>• ការងារនិងតម្លៃអាជីព |
| **កិច្ចការនារី** | **ផែនការយុទ្ធសាស្រ្តនារីរតនៈឆ្នាំ 2014-18 សម្រាប់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី** | • ការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី<br>• សេវាសង្គមនិងការគាំពារសង្គម<br>• ការអប់រំសម្រាប់ស្ត្រីនិងកុមារ និងការផ្លាស់ប្តូរឥរិយាបទ<br>• លើកកម្ពស់សុខភាពនិងអាហាររូបត្ថម្ភស្ត្រីនិងកុមារ និងការបង្ការជំងឺអេដស៍<br>• ការការពារផ្នែកច្បាប់ដល់ស្ត្រីនិងកុមារ<br>• ស្ត្រីក្នុងការសម្រេចចិត្តនិងការបញ្ជ្រាបយេនឌ័រក្នុងវិមជ្ឈការនិងការបង្កើតគោលនយោបាយ<br>• ការគ្រប់គ្រងយេនឌ័រ ផ្លាស់ប្តូរអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយ<br>• ពង្រឹងស្ថាប័ននិងអភិវឌ្ឍសមត្ថភាពឆ្ពោះទៅរកសមភាពយេនឌ័រ<br>• ផ្តល់ការបណ្តុះបណ្តាលជំនាញ ការងារ ធនធានផលិតភាព និងការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច<br>• កែលម្អលទ្ធភាពទទួលបានការអប់រំសម្រាប់កុមារីនិងស្ត្រី<br>• កែលម្អការផ្តល់សេវាសុខភាពស្ត្រី<br>• ធានាឱ្យបាននូវសុវត្ថិភាពនិងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ<br>• កែលម្អការសម្របសម្រួលជំនួយនិងសមត្ថភាពស្ថាប័នដើម្បីដោះស្រាយបញ្ហាស្ត្រី |
| **សង្គមកិច្ច** | **ផែនការយុទ្ធសាស្រ្ត ឆ្នាំ 2014-18** | • សុខុមាលភាពនៃក្រុមដែលងាយរងគ្រោះនិងក្រុមគ្រួសាររបស់ពួកគេ<br>• សុខុមាលភាពកុមារនិងការស្តារនីតិសម្បទាយុវជន<br>• សេវាកម្មការគាំទ្រផ្លូវចិត្តកុមារកំព្រាន កុមារជួបការលំបាក និងកុមារតាមចិញ្ចើមផ្លូវ<br>• ការបណ្តុះបណ្តាល សេវាពិគ្រោះយោបល់សម្រាប់ស្ត្រីដែលជាជនរងគ្រោះនៃការរំលោភបំពានឬ ការជួញដូរផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារដើម្បីស្តារស្ថានភាព |

*__ប្រភព៖__ ផ្អែកលើកម្រងសំណួរឆ្លើយដោយក្រសួងឆ្នាំ 2016*

### ២.២.៣ ថវិកាកម្មវិធីយុវជន (Youth programme budget)

ផ្តើមនៅឆ្នាំ 2016 រាជរដ្ឋាភិបាលបានបង្កើនថវិកាយ៉ាងសំខាន់សម្រាប់ក្រសួងក្នុងការទទួលខុសត្រូវចំពោះការអភិវឌ្ឍធនធានមនុស្ស និងយុវជន។ ទោះបីជាថវិកាតាមវិស័យជាក់លាក់សម្រាប់កម្មវិធីយុវជនមិនអាចគណនាបានក៏ដោយ ក៏កំណើនថវិកាជាតិរួមបានសង្កត់ធ្ងន់លើការអភិវឌ្ឍធនធានមនុស្ស និងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (TVET) ដែលជាបញ្ហាសំខាន់ពាក់ព័ន្ធនឹងយុវជន (យោងតាម ច្បាប់ថវិកាជាតិ ឆ្នាំ2016) ។ ការបែងចែកថវិកាក្នុងឆ្នាំ 2016 ទៅឱ្យក្រសួងអប់រំ យុវជន និងកីឡា (អយក.) បានកើនឡើងចំនួន 37 ភាគរយ និងទៅឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) បានកើនឡើងចំនួន 50 ភាគរយ បើធៀបទៅនឹងឆ្នាំមុនៗ។ នៅឆ្នាំ 2016 ប្រាក់ចំណូលក្នុងស្រុកត្រូវបានគេប៉ាន់ប្រមាណថា មានចំនួន 17,5 ភាគរយ នៃផលិតផលក្នុងស្រុកសរុប (ដែលឡើង 22 ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំ 2015) ដែលអាចមានចន្លោះសារពើពន្ធថែមទៀតសម្រាប់ការវិនិយោគ។

ដើម្បីបង្កើនប្រសិទ្ធភាពលើការចំណាយថវិកា រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តថវិកាកម្មវិធី (Programme-based Budgeting ហៅកាត់ថា ភីប៊ី) ក្នុងក្រសួង ស្ថាប័នពាក់ព័ន្ធទាំង 25 ។ គេរំពឹងថា ថវិកាភីប៊ី នឹងធ្វើអោយទំនាក់ទំនងរវាងគោលនយោបាយ និងថវិកាបានប្រសើរឡើង និងអាចពិនិត្យតាមដានលើការចំណាយថវិកា និងលទ្ធផលរំពឹងទុក រួមទាំងថវិកាពាក់ព័ន្ធនឹងយុវជន។ ប្រព័ន្ធបែងចែកថ្នាក់ថវិកាបច្ចុប្បន្នមិនអាចបែងចែកឱ្យបានជាក់លាក់ ទាំងថវិកាសម្រាប់យុវជន ទាំងបញ្ហាឆ្លងផ្នែកយេនឌ័រ។ ដោយមានថវិកាភីប៊ី គេអាចពិនិត្យតាមដានលើការចំណាយជាក់លាក់សម្រាប់យុវជនដោយការបង្កើតតារាងនៃធាតុចំនួនថវិកាដែលមានស្រាប់ ប៉ុន្តែដើម្បីដំណើរការនេះប្រព្រឹត្តទៅបាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ) ត្រូវចូលរួមជាមួយនឹងក្រសួងខ្សែបណ្តោយ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ដែលទទួលបន្ទុកកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Reform Program ហៅកាត់ថា PFMRP)។

តារាង 18 (2-3) ការប្រតិបត្តិនិងការបែងចែកថវិកាជាតិ (គិតជា លានដុល្លារអាមេរិក)

| ថវិកាតាមវិស័យ / ឆ្នាំ | 2013 | ភាគរយ | 2014 | ភាគរយ | 2015 | ភាគរយ | 2016 | ភាគរយ |
|---|---|---|---|---|---|---|---|---|
| ចំណាយចរន្ត ថ្នាក់ជាតិសរុប | 1,820 | 100 | 2,051 | 100 | 2,243 | 100 | 2,789 | 100 |
| MoEYS | 264 | 14.5 | 324 | 15.8 | 370 | 16.5 | 507 | 18.2 |
| MoH | 213 | 11.7 | 206 | 10.1 | 234 | 10.5 | 277 | 10.0 |
| MoLVT | 25 | 1.4 | 22 | 1.1 | 28 | 1.3 | 42 | 1.5 |
| MoSVY | 99 | 5.5 | 128 | 6.3 | 149 | 6.7 | 178 | 6.4 |
| MoWA | 7 | 0.4 | 7 | 0.4 | 7 | 0.4 | 10 | 0.4 |

***ប្រភព***៖ *របាយការណ៍ប្រតិបត្តិថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (2011-2015), ច្បាប់ថវិកាជាតិ (ឆ្នាំ 2016)*

***ចំណាំ***៖ *ទិន្នន័យសម្រាប់ 2013-2015 គឺជាថវិកាប្រតិបត្តិ ខណៈដែលឆ្នាំ 2016 គឺតួលេខគ្រោងទុក*

## ២.៣ កំណែទម្រង់ស្ថាប័នយុវជន

### ២.៣.១ ថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រសួង ស្ថាប័នដែលមានថ្នាក់ជាតិ (National Administrations ហៅកាត់ថា NA) និងថ្នាក់ក្រោមជាតិ (Sub-national Administrations ហៅកាត់ថា SNA) ។ SNA មានបីកម្រិត ដោយចាប់ផ្តើមពីរដ្ឋបាលរាជធានី ខេត្ត (Capital- Provincial administrations ហៅកាត់ថា CP)បន្ទាប់មកគឺ រដ្ឋបាល ក្រុង ខណ្ឌ (District Administrations ហៅកាត់ថា DM) និងចុងក្រោយគឺ រដ្ឋបាលឃុំ សង្កាត់ (Communes and Sangkats ហៅកាត់ថា CS) ។ CP ត្រូវបានបែងចែកជាខណ្ឌដែលមិនមានរដ្ឋបាលដាច់ដោយឡែកនោះទេ។ នៅឆ្នាំ 2016 SNA រួមមាន រាជធានីចំនួន 01 ខេត្តចំនួន 24 ខណ្ឌចំនួន 12 ក្រុងខណ្ឌចំនួន 185 និងឃុំសង្កាត់ចំនួន 1633 (សូមមើល រូបភាពទី 2.1) និងមានភូមិសរុបចំនួន 14139 ភូមិ នៅក្រោមការគ្រប់គ្រងរបស់ឃុំសង្កាត់ទាំងនោះ ប៉ុន្តែមិនមានរដ្ឋបាលដាច់ដោយឡែកនោះទេ។

ដោយមានគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (NYDP) និង ផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP ) គេរំពឹងថា អាជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ជាអ្នកអនុវត្តគោលនយោបាយអភិវឌ្ឍន៍យុវជនបានល្អ។ ដំណើរការនេះតម្រូវឱ្យមានធនធានមនុស្ស និងហិរញ្ញវត្ថុនៅថ្នាក់មូលដ្ឋានស្របគ្នានឹងរបៀបវារៈនៃការអភិវឌ្ឍ ព្រមទាំងមានកំណែទម្រង់វិមជ្ឈការដែលដឹកនាំដោយគណៈកម្មាធិការជាតិដើម្បីការអភិវឌ្ឍដោយប្រជាធិបតេយ្យ (National Committee for Sub-National Democratic Development ហៅកាត់ថា NCDD)។

**រូបភាព 18 (2-1) រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិនៅកម្ពុជា**




***ប្រភព***៖ *អឃក. ឆ្នាំ 2016*

នៅឆ្នាំ 2010 រាជរដ្ឋាភិបាលបានរចនាឡើង និងអនុម័តបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រាប់ផែនការ 10 ឆ្នាំ (10-year National Programme for Sub-National Democratic Development ហៅកាត់ថា NP-SNDD 2010-2019) (យោងតាម RGC, 2010)។ NP-SNDD មានគោលបំណងផ្ទេរមុខងារ និងធនធាន និងកសាងសមត្ថភាពនៅថ្នាក់មូលដ្ឋាន ប៉ុន្តែរហូតមកដល់ពេលនេះរដ្ឋបាលថ្នាក់ក្រោម (SNA) មានតួនាទី ឬថវិកាមិនសូវច្បាស់លាស់ដើម្បីបំពេញតម្រូវការប្រជាពលរដ្ឋ និងយុវជននោះទេ ។ រដ្ឋបាលឃុំសង្កាត់(CS) ទទួលបានជំនួយឥតលក្ខខណ្ឌប្រហែល 30.000 ដុល្លារក្នុងមួយឆ្នាំ ដើម្បីធ្វើការវិនិយោគក្នុងវិស័យជាច្រើនជាពិសេសការ

អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ រដ្ឋបាលស្រុក ខណ្ឌ (DM) ក៏ទទួលបានមូលនិធិស្រដៀងគ្នានេះដែរ ដែលមូលនិធិនេះត្រូវបានគេហៅថា មូលនិធិស្រុក ខណ្ឌ (District/Municipal Fund ហៅកាត់ថា DMF) ដែលមានចំនួនប្រហែល 110.000 ដុល្លារអាមេរិកក្នុងមួយឆ្នាំ ហើយប្រហែល 80 ភាគរយ នៃមូលនិធិនេះគឺសម្រាប់ការចំណាយលើដំណើរការរដ្ឋបាល។ CS និង DM មិនមានប្រភពប្រាក់ចំណូលផ្ទាល់ខ្លួនទេ។ ខេត្តក៏ពឹងផ្អែកទាំងស្រុងលើការផ្ទេរថវិកាពីថ្នាក់ជាតិដែរ ទោះបីជាខេត្តមានសិទ្ធិបង្កើនពន្ធ និងថ្លៃឈ្នួលផ្សេងៗក៏ដោយ។ ការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនប្រហែល 12 ភាគរយ នៃចំនួនសរុបនៃការចំណាយចរន្តជាតិ (យោងតាម NCDD ឆ្នាំ2014) ។

ចាប់តាំងពីឆ្នាំ 2013 រដ្ឋាភិបាលបានខិតខំប្រឹងប្រែងដើម្បីពន្លឿនដំណើរវិមជ្ឈការ។ នៅឆ្នាំ 2015 មានការយល់ព្រមថា មុខងារសំខាន់ៗមួយចំនួនរួមទាំងការអប់រំកម្រិតបឋម សុខាភិបាលបឋម ការផ្គត់ផ្គង់ទឹក និងអនាម័យជនបទ និងការថែទាំគាំពារកុមាររងគ្រោះនឹងត្រូវផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ ដែលបានចាប់ផ្ដើមដោយគម្រោងសាកល្បងនៅក្នុងខេត្ត ស្រុក និងក្រុងខណ្ឌទិសដៅមួយចំនួន។ ការផ្ទេរមុខងារនេះនឹងត្រូវបានធ្វើក្នុងលក្ខណៈជាបណ្ដើរៗ ដោយសារតែសមត្ថភាពបាថ្នាក់ក្រោមជាតិមានកម្រិត។ ដូច្នេះ ខណៈពេលដែលចង់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) មានតួនាទីសកម្មក្នុងការអនុវត្ត និង/សម្របសម្រួលឬគោលនយោបាយអភិវឌ្ឍន៍យុវជនការអនុវត្ត ការពង្រឹងសមត្ថភាពនៅថ្នាក់នោះចាំបាច់ត្រូវមានការយល់ដឹងពីដំណើរការវិមជ្ឈការបែបនោះដែរ។

### ២.៣.២ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ)

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចាត់ទុកយុវជនជាធនធានគន្លឹះ និងមានតម្លៃបំផុតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងការរក្សាសន្តិភាពទាំងបច្ចុប្បន្ន និង អនាគត។ ក្នុងបរិបទសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយរបស់កម្ពុជា យុវជន គឺជាជនប្រុស ស្រី ទាំងអស់ដែលមានសញ្ជាតិខ្មែរ និងមានអាយុពី ១៥ ដល់ ៣០ ឆ្នាំ។ ដើម្បីឲ្យព្រះរាជាណាចក្រកម្ពុជា មានធនធានមនុស្សប្រកបដោយសមត្ថភាព គុណភាព និងគុណធម៌សម្រាប់ការអភិវឌ្ឍប្រទេសជាតិ រាជរដ្ឋាភិបាលមានចក្ខុវិស័យវែងឆ្ងាយ ដោយប្រមូលផ្ដុំកម្លាំងពីគ្រប់មជ្ឈដ្ឋាន និងកៀរគរធនធានសំដៅរួមចំណែកក្នុងការអភិវឌ្ឍយុវជន ឲ្យពួកគេក្លាយជាធនធានដ៏មានសក្ដានុពល និងមានតម្លៃរបស់ប្រទេសជាតិ។ ដើម្បីសម្រេចបាន ចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានរៀបចំឯកសារដ៏សំខាន់មួយគឺ គោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា នៅឆ្នាំ ២០១១។

អនុវត្តតាមផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា (NYDP) ឡើងនៅក្នុងឆ្នាំ 2014 ដែលជាស្ថាប័នឯករាជ្យមួយដើម្បី៖ (i) ជាយន្តការថ្នាក់ជាតិសម្រាប់សម្របសម្រួល និងអនុវត្ត NYDP (ii) អនុម័តផែនការសកម្មភាពជាតិ (NAP) សម្រាប់ការអនុវត្ត NYDP (iii) ជំរុញ និងបញ្ជ្រាបការអភិវឌ្ឍយុវជនទៅក្នុងគោលនយោបាយជាតិ និងកម្មវិធីអភិវឌ្ឍរបស់រាជរដ្ឋាភិបាល (iv) ណែនាំ ចង្អុលបង្ហាញ និងសម្របសម្រួលដល់ការចូលរួមរបស់យុវជនក្នុងវិស័យសេដ្ឋកិច្ច និងការសម្រេចបាននូវការអប់រំ និងការបណ្ដុះបណ្ដាល (v) ប្រមូលផ្ដុំកម្លាំងយុវជនគ្រប់មជ្ឈដ្ឋាន និងកៀរគរធនធានសម្រាប់គាំទ្រ និងអភិវឌ្ឍយុវជនកម្ពុជា (vi) សិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ វាយតម្លៃ ផ្ដល់អនុសាសន៍ និងធ្វើរបាយការណ៍ពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការអនុវត្ត NYDP ជូនរាជរដ្ឋាភិបាល (យោងតាមព្រះរាជក្រឹត្យលេខ/នស/រកត/០២១៣/141 ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ2013) ដោយមាន **សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ជាប្រធាន ឧបនាយករដ្ឋមន្ត្រីមួយរូបជាអនុប្រធាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាអនុប្រធានប្រចាំការ និងមានសមាជិកមកពីក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល ឬសហគមដែលធ្វើការងារយុវជនចំនួន 32 ។ សហភាពសហព័ន្ធយុវជនកម្ពុជា (ហៅកាត់ថា ស.ស.យ.ក.) ដែលជាតំណាងមកពីអង្គការយុវជនជាសមាជិក។ អគ្គលេខាធិការដ្ឋានត្រូវបានបង្កើតឡើងដើម្បីជួយ ក.ជយ. ជាទូទៅ ក្រសួងគឺជាសេនាធិការសម្រាប់ដំណើការការងារប្រចាំថ្ងៃនៅក្នុងក្រុមប្រឹក្សាជាតិកម្ពុជា (ក.ជ.យ) ក្នុងការប្រតិបត្តិការងារប្រចាំថ្ងៃ។ ដោយសារអគ្គលេខាធិការដ្ឋានតាំងនៅក្នុងសួងអប់រំ យុវជន និងកីឡា ជាទូទៅ ក្រសួងគឺជាសេនាធិការសម្រាប់ដំណើការការងារប្រចាំថ្ងៃនៅក្នុង ក.ជ.យ . និងទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងវាយតម្លៃ។

**រូបភាព 19 (2-2) រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ហៅកាត់ថា ក.ជ.យ)**




***ប្រភព*៖ *សម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់នៅក្រសួងអប់រំយុវជននិងកីឡា (ខែឧសភា 2016)***

សមាជិក និងតំណាងក្រុមប្រឹក្សាជួបប្រជុំពីរដងក្នុងមួយឆ្នាំ និងរាយការណ៍ជូនអង្គប្រជុំក្រោមអធិបតីភាព របស់**សម្តេចប្រធាន** អំពីលទ្ធផលនៃការអនុវត្តការងារដែលត្រូវសម្របសម្រួល និងអនុសាសន៍ដែលក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនត្រូវដាក់ចេញ។ ក្រុមប្រឹក្សាមានសិទ្ធិក្នុងការទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល អង្គការជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ដើម្បីចូលរួមប្រជុំផ្តល់យោបល់និងគាំទ្រ ឬចូលរួមតាមការអញ្ជើញរបស់ ក.ជ.យ .។ ក្រុមប្រឹក្សានេះសម្រេចបង្កើតដោយព្រះរាជក្រឹត្យដើម្បីបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនអន្តរក្រសួង (ហៅកាត់ថា MYC) និងគណៈកម្មាធិការជំនាញជាតិ (ហៅកាត់ថា NTC) (តាមវិស័យអាទិភាពនីមួយៗ) ដើម្បីជួយគាំទ្រដល់ការសម្របសម្រួល និងការអនុវត្តភារកិច្ច និងសកម្មភាពនានានៅក្នុងក្រសួងចំណុះ រួមមាន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ហៅកាត់ថា ក.ជ.យ) ។

អគ្គលេខាធិការដ្ឋានមានផ្នែកចំណុះចំនួនបី (ផ្នែកនីមួយៗថ្នាក់ស្មើនាយកដ្ឋាន) គឺផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ផ្នែកអនុវត្តគោលនយោបាយ និងផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ផ្នែកនីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ (មិនទាន់បង្កើត)។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋានបាន និងកំពុងពិនិត្យ ពិភាក្សា រៀបចំបង្កើតផ្នែកចំណុះចំនួនពីរបន្ថែមទៀត គឺផ្នែកសេវាកម្មយុវជន និងផ្នែកទំនាក់ទំនងអន្តរជាតិ។ អគ្គលេខាធិការដ្ឋានកំពុងស្នើសុំបង្កើតគណៈកម្មការជំនាញអន្តរក្រសួងបួនដើម្បីធានាការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាក្នុងវិស័យអាទិភាពចំនួនបួនដែលត្រូវបានជ្រើសរើសដូចជា (១)ការអប់រំការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍សមត្ថភាពរបស់យុវជន (២) ការងារយុវជន (៣) សុខភាពយុវជន និង (៤) យុវជនស្ម័គ្រចិត្ត។ គណៈកម្មាធិនេះនឹងមានក្រសួងពាក់ព័ន្ធ អង្គការយុវជន ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងវិស័យឯកជន។ និងមានការស្នើសុំឱ្យក្រសួងតែងតាំងសមាជិកស្នូលសម្រាប់គណៈកម្មាធិការនីមួយៗ។

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួងស្ថាប័ន (Ministerial Youth Development Council ហៅកាត់ថា MYDC)៖ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ ០៣ ក.ជ.យ. ចុះថ្ងៃទី 27 ខែកញ្ញា ឆ្នាំ 2016 ដើម្បីយន្តការសម្របសម្រួល ទំណនាក់ទំនងរវាងក្រសួងស្ថាប័ន នេះ មានលេខាធិការដ្ឋានមួយជាសេនាធិការ ក្នុងការបំពេញការងារប្រចាំថ្ងៃ។ ក្រោយចេញសេចក្តីសម្រេចលេខ ០៣ ក.ជ.យ. អគ្គលេខាធិការដ្ឋាន ក.ជ.យ. បានចេញលិខិតស្នើសុំឲ្យក្រសួង ស្ថាប័ន ចំនួន ៣២ រៀបចំបញ្ជីសមាសភាពក្រុមប្រឹក្សា ហើយផ្ញើបញ្ជីសមាសភាពនោះ មកអគ្គលេខាធិការដ្ឋានវិញ ដើម្បីរៀបចំសេចក្តីសម្រេចស្នើសុំតែងតាំងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថានប័ននីមួយៗ ពី **សម្តេច**ប្រធាន ក.ជ.យ. ហើយការងារនេះគ្រោងនឹងបញ្ចប់នៅខែ សីហា ឆ្នាំ ២០១៧។

នៅថ្នាក់ជាតិ ក.ជ.យ. មានស្ថាប័នចំណុះសរុបចំនួន ៣៦ ស្ថាប័ន ដែលត្រូវធ្វើការសម្របសម្រួល ហើយចំនួននេះ អាចមានការកើនឡើងបន្ថែមទៀតក្នុងករណីមានការចាំបាច់។

ក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ហៅកាត់ថា ក.ជ.យ.) ក្រសួង ស្ថាប័ននីមួយៗត្រូវចាត់តាំងជនបង្គោល ឬតំណាងមកសម្របសម្រួលនិងទាក់ទងជាមួយ ក.ជ.យ. ដើម្បីអនុវត្តផែនការសកម្មភាពបានជោគជ័យ។ អង្គការយុវជនដែលពាក់ព័ន្ធនឹង ក.ជ.យ .រួមមាន សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក. ) សមាគមកម្មវិធីនាវាយុវជនអាស៊ីប៉ូព៌ានៅកម្ពុជា (Ship for Southeast Asian and Japanese Youth Program ហៅកាត់ថា SSEAYP) និងគណៈកម្មាធិការយុវជនសម្រាប់ឯកភាពនិងការអភិវឌ្ឍ (Youth Committee for Unity and Development ហៅកាត់ថា YCUD) ដែលជាសម្ព័ន្ធរបស់អង្គការយុវជនលេចធ្លោ (ដូចជា សមាគមយុវជនខ្មែរ យុវសន្តិភាព ក្រុមប្រឹក្សាយុវជនកម្ពុជា កម្មវិធីអភិវឌ្ឍធនធានយុវជន អង្គការយុវជនខ្មែរដើម្បីការអភិវឌ្ឍសង្គម វិទ្យាស្ថានខ្មែរសំរាប់អភិវឌ្ឍន៍ជាតិ និងមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព)។ កិច្ចសហប្រតិបត្តិការជាមួយសាលារៀន សាកលវិទ្យាល័យ និងវិស័យឯកជនមិនទាន់បានបង្កើតឡើងនៅឡើយទេ។

ព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៤១ ក៏បង្កើតការបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជននៅ 25 រាជធានីខេត្តផងដែរ។ ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនខេត្តត្រូវមានបុគ្គលិកនៅក្នុងមន្ទីរអប់រំ យុវជន និងកីឡា។ អភិបាលនៃរាជធានីខេត្តនឹងធ្វើជាអនុប្រធានក្រុមប្រឹក្សា។ សមាជិកនៃក្រុមប្រឹក្សាទាំងនេះគួរមានតំណាងមកពីមន្ទីរ នៃក្រសួងពាក់ព័ន្ធទាំងនោះ។ ឧទាហរណ៍៖ សមាសភាពនៃក្រុមប្រឹក្សាយុវជនរាជធានីភ្នំពេញដែលមានឯកឧត្តមអភិបាលរាជធានីជាប្រធាន ឯកឧត្តមអភិបាលរងជាអនុប្រធាន ប្រធានមន្ទីររាជធានីភ្នំពេញ នៃក្រសួងអប់រំ យុវជន និងកីឡា ជាអនុប្រធានអចិន្ត្រៃយ៍ និងប្រធាន ឬតំណាងនាយកដ្ឋានផ្សេងទៀតនៅរាជធានីភ្នំពេញជាសមាជិក ។ល។ នេះជាតួនាទីរំពឹងទុកនៃក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ គឺស្រដៀងគ្នានឹងតួនាទីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍យុវជនអន្តរក្រសួងដែរ លើកលែងតែថាក្រុមប្រឹក្សាទាំងនេះប្រតិបត្តិការនៅថ្នាក់ក្រោមជាតិ។ ផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) បានសង្កត់ធ្ងន់លើតួនាទីជាក់លាក់របស់ក្រុមប្រឹក្សាយុវជនមូលដ្ឋានដែលនៅក្នុងករណីនេះសំដៅលើថ្នាក់ឃុំ និងស្រុក។

ហេតុផលនៃការបង្កើតឱ្យមានប្រព័ន្ធវិមជ្ឈការតាមស្ថាប័ននេះ គឺដោយសារតែរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA)និងអង្គការសហគមន៍មូលដ្ឋាន (CBOs) នៅកៀកជាមួយយុវជន ដូច្នេះគួរតែមានតួនាទីយ៉ាងសំខាន់បន្ថែមទៀតដើម្បីអនុវត្តផែនការសកម្មភាព។ ដូច្នេះ គេរំពឹងថា រដ្ឋបាលថ្នាក់មូលដ្ឋាន នឹងធ្វើសមាហរណកម្មបញ្ហាយុវជនចូលក្នុងផែនការអភិវឌ្ឍន៍យុវជនមូលដ្ឋានរបស់ខ្លួន និងជូនដំណឹងនិងកៀរយុវជនតាមហ្នឹងដែរ។ គេរំពឹងផងដែរថា រដ្ឋបាលមូលដ្ឋាននឹងតែងតាំងមន្ត្រីបង្គោលដើម្បីធ្វើការវាយតម្លៃតម្រូវការ កត្តាអាទិភាព និងគោលដៅរបស់យុវជន រៀបចំថវិកា និងរាយការណ៍ស្តីពីសកម្មភាពអភិវឌ្ឍពាក់ព័ន្ធនឹងយុវជន។ តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍយុវជនមូលដ្ឋាន គេរំពឹងថា SNA នឹងឆ្លុះបញ្ចាំងពីតម្រូវការនៃការអភិវឌ្ឍយុវជននៅក្នុងរបៀបវារៈនៃការអភិវឌ្ឍមូលដ្ឋានឱ្យបានប្រសើរជាងមុនជូនរាជរដ្ឋាភិបាល។

#### ២.៣.៣ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែ កុម្ភៈ ឆ្នាំ២០១៣។ អគ្គលេខាធិការដ្ឋានមានផ្នែកចំណុះចំនួនបី (ផ្នែកនីមួយៗថ្នាក់ស្មើនាយកដ្ឋាន) គឺផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ផ្នែកអនុវត្តគោលនយោបាយ និងផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ផ្នែកនីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ (មិនទាន់បង្កើត)។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋានបាន និងកំពុងពិនិត្យ ពិភាក្សា រៀបចំបង្កើតផ្នែកចំណុះចំនួនពីរបន្ថែមទៀត គឺផ្នែកសេវាកម្មយុវជន និងផ្នែកទំនាក់ទំនងអន្តរជាតិ។ អគ្គលេខាធិការដ្ឋាន ក.ជ.យ. មានមន្ត្រីបម្រើការងារមកពីក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីរាជការនៅក្នុងក្របខណ្ឌមុខងារសាធារណៈផ្សេងទៀត ហើយក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋានអាចមានអ្នកជំនាញការ និងមន្ត្រីជាប់កិច្ចសន្យាសម្រាប់ជួយបំពេញការងារ។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋានមានមន្ត្រីរាជការបម្រើការងារចំនួន ០៩ រូប គឺ៖ អគ្គលេខាធិការ ០១ រូប អគ្គលេខាធិការរង ០៦ រូប និងប្រធានផ្នែក ០២ រូប។ អគ្គលេខាធិការដ្ឋានបាន និងកំពុងស្នើសុំមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាបន្ថែមទៀត សម្រាប់បំពេញតួនាទីជាអនុប្រធានផ្នែក ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីសម្រាប់បម្រើការងារក្នុងផ្នែក និងការិយាល័យនីមួយៗ។ អគ្គលេខាធិការដ្ឋានបានលើកឡើងថា ដើម្បីអនុវត្តផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) ត្រូវការមន្ត្រីដែលមានសមត្ថភាពផ្នែក IT ស្ថិតិ គ្រប់គ្រងគម្រោង និងសមត្ថភាពតាមដាននិងវាយតម្លៃ និងត្រូវមានកន្លែងសម្រាប់តម្កល់ឯកសារពាក់ព័ន្ធយុវជនទាំងអស់។ បច្ចុប្បន្ននេះ មានមជ្ឈមណ្ឌលយុវជនចំនួនដប់កំពុងប្រតិបត្តិការ ប៉ុន្តែមិនទាន់បានប្រើប្រាស់ឱ្យអស់លទ្ធភាពទេ។

គណៈកម្មាធិការជំនាញមួយត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ ៣ ក.ជ.យ។. ដើម្បីគាំទ្រដល់អគ្គលេខាធិការដ្ឋានក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន និងការកាត់បន្ថយភាពក្រីក្រ។ ការពិភាក្សារបស់អង្គការមួយបង្ហាញថា បញ្ហាលំបាកដែលអគ្គលេខាធិការដ្ឋានកំពុងប្រឈមគឺការខ្វះតំណាងយុវជននៅក្នុងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) ។ ទោះបីជា ក.ជ.យ .កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក. ) ដែលជាអង្គការយុវជនយ៉ាងធំមួយក៏ដោយ ប៉ុន្តែជារឿយៗ ស.ស.យ.ក បានផ្សារភ្ជាប់នឹងការជំរុញបែបនយោបាយដែលធ្វើឱ្យភាពតំណាងយុវជនលម្អៀងតិចតួច។ នៅថ្នាក់ជាតិ ការសម្របសម្រួលរបស់អន្តរក្រសួងមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអនុវត្តផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) ឱ្យទទួលបានជោគជ័យ ប៉ុន្តែរចនាសម្ព័ន្ធស្រដៀងគ្នានេះធ្លាប់កើតមានក្នុងប្រធានបទផ្សេងទៀតដែរ។ កិច្ចប្រជុំសម្របសម្រួលអន្តរក្រសួងតាមស្ថាប័នមួយចំនួនមិនទាន់ទៀងទាត់ ជនបង្គោលដែលទើបតែងតាំងក៏មានភាពស្ទាក់ស្ទើរក្នុងការទទួលយកទំនួលខុសត្រូវថ្មីដែរ។ នៅថ្នាក់ក្រោមជាតិដំណើរការវិមជ្ឈការមិនទាន់ពេញលេញ

មន្ត្រីថ្នាក់ក្រោមជាតិមានសមត្ថភាពមិនទាន់ច្បាស់លាស់ក្នុងការអនុវត្ត NYAP នៅថ្នាក់មូលដ្ឋាន ដោយមិនគិតពីរបៀបវារៈអភិវឌ្ឍន៍ដែលមានស្រាប់។ យ៉ាងណាមិញ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) ទទួលបានការគាំទ្រពីសំណាក់ **សម្តេចអគ្គមហាសេនាបតីរដ្ឋមន្ត្រី** និងជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើឱ្យអគ្គលេខាធិការដ្ឋានក្លាយជាតំណាងដ៏មានសក្តានុពល និងមានប្រសិទ្ធិភាពរបស់ដៃគូអភិវឌ្ឍពាក់ព័ន្ធ។

**Figure 1** (2-3) **ការវិភាគ SWOT លើអគ្គលេខាធិការដ្ឋាន ក.ជ.យ.**

| **ភាពខ្លាំង** | **ឱកាសការងារ** |
|---|---|
| • ទទួលបានការគាំទ្រយ៉ាងខ្លាំងពីថ្នាក់ដឹកនាំរាជរដ្ឋាភិបាល (ឧទាហរណ៍៖ មាននាយករដ្ឋមន្ត្រីជាប្រធាន ក.ជ.យ )<br>• ក្របខណ្ឌច្បាប់រឹងមាំ<br>• អាចប្រមូលផ្តុំការគាំទ្រពីភាគីពាក់ព័ន្ធ–អង្គការសង្គមស៊ីវិល អង្គការយុវជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ<br>• អគ្គនាយកដ្ឋានយុវជនជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>• គ្របដណ្តប់ទូទាំងប្រទេស មានន័យថា ក.ជ.យ .មានអាណត្តិដើម្បីបង្កើតបណ្តាញក្រុមប្រឹក្សារបស់ខ្លួនដល់ថ្នាក់រដ្ឋាភិបាលមូលដ្ឋាន<br>• មាននិរន្តរភាពនៃសកម្មភាព (ព្រោះមន្ត្រីត្រូវបានរៀបចំ និងបង្កើតឡើងដោយរាជរដ្ឋាភិបាល) | • ភាគលាភបានមកពីប្រជាសាស្ត្រ<br>• កំពុងមានកំណើនសេដ្ឋកិច្ច<br>• មានប្រព័ន្ធផ្សព្វផ្សាយដែលអាចប្រើបានរួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម (ងាយស្រួលរកព័ត៌មាននិងអន្តរកម្ម)<br>• ការតភ្ជាប់តំបន់-អាចធ្វើសមាហរណកម្មជាមួយនឹងផែនការការងារយុវជនអាស៊ាន បណ្តាញនាវាយុវជនអាស៊ីប៉ូពា៉<br>• សហការជាមួយអង្គការយុវជនជាច្រើន |
| **ភាពខ្សោយ** | **ការគំរាមកំហែង** |
| • រចនាសម្ព័ន្ធមិនច្បាស់លាស់ និងការយល់ដឹងពីតួនាទី និងការទទួលខុសត្រូវនៅមានកម្រិត<br>• រចនាសម្ព័ន្ធមិនទាន់គ្រប់គ្រាន់ដូចជា សម្ភារការិយាល័យ បន្ទប់ប្រជុំ ផបសាយមូលដ្ឋានទិន្នន័យ ។ល។<br>• ក្របខ័ណ្ឌថវិកាមិនច្បាស់លាស់<br>• បុគ្គលិកជាមន្ត្រីរាជការដែលមានបន្ទុកការងារលើសច្រើន<br>• មានមន្ត្រីបង្គោលសកម្មតិចតួច<br>• ពិបាកក្នុងការស្វែងរកមន្ត្រីសម្រាប់តំណែងដែលត្រូវការ សមត្ថភាពរបស់បុគ្គលិកដែលបានចាត់តាំងនៅមានកម្រិត (ឧទាហរណ៍៖ បទពិសោធន៍ធ្វើការជាមួយយុវជន)<br>• មានការគុំកួនពីមន្ត្រីចាស់ដែលមិនត្រូវបានចាត់តាំងទៅបម្រើការងារនៅអគ្គលេខាធិការដ្ឋាន (ឧទាហរណ៍៖ តែងតាំងបេក្ខជននយោបាយមកពី ស.ស.យ.ក. ) | • រងឥទ្ធិពលនយោបាយ (ឧទាហរណ៍៖ មានទំនាក់ទំនងជាមួយ ស.ស.យ.ក. នាវាយុវជនអាស៊ីប៉ូពា៉ និងអង្គការយុវជននយោបាយផ្សេងទៀត)<br>• មានសហជីពយុវជនមានស្រាប់ជាច្រើន (អាណត្តិប្រកួតប្រជែង ថវិកា)<br>• ការខ្វះខាតភាពតំណាងយុវជននិងការចូលរួមនៅក្នុង ក.ជ.យ ជាប់គាំងដោយសារបរិស្ថានការងារយឺតយ៉ាវ មានលក្ខណៈការិយាធិបតេយ្យនិងឋានានុក្រម<br>• ការសម្របសម្រួលអន្តរក្រសួងពិបាក<br>• សមត្ថភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិទាប<br>• មន្ត្រីបង្គោលថ្មីនៅក្នុងក្រសួងគិតដល់បញ្ហានេះថា ជាបន្ទុកបន្ថែម |

***ប្រភព***៖ *ដោយផ្អែកលើបទសម្ភាសជាមួយ អយក.*

ដើម្បីបង្ហាញភាពស្របច្បាប់ដល់ដៃគូអភិវឌ្ឍយុវជនពាក់ព័ន្ធនឹងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) នៅដំណាក់កាលដែលទើបតែបង្កើតឡើងនេះ ដំបូងត្រូវកែលម្អភាពតំណាងយុវជននៅក្នុងរចនាសម្ព័ន្ធនេះឱ្យប្រសើរឡើង។ ការអនុវត្តរបស់ ក.ជ.យ. និងការអនុវត្តផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) អាស្រ័យលើ ថាតើប្រព័ន្ធក្រុមប្រឹក្សានេះបានធ្វើសមាហរណកម្មនិងការទទួលឥទ្ធិពលលើគោលនយោបាយពីក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិបានកម្រិតណា។ វាក៏អាស្រ័យលើរបៀបវារៈយុវជនដែលមិនត្រឹមតែត្រូវបានបញ្ច្រាបទៅក្នុងសេចក្តីថ្លែងការណ៍គោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសកម្មភាពជាក់ស្តែង និងការបែងចែកថវិកាច្បាស់លាស់ផងដែរ។ ទំនាក់ទំនងខ្សែទទឹងរវាង ក.ជ.យ .និងក្រុមប្រឹក្សាខេត្ត រាជធានី ជាពិសេសក្រុមប្រឹក្សាស្រុក ខណ្ឌ និងឃុំ មានសារៈសំខាន់ណាស់ក្នុងការធានាឱ្យការអនុវត្តផែនការសកម្មភាមានប្រសិទ្ធិភាពខ្ពស់។ ការបញ្ជ្រាបបញ្ហារបស់យុវជនទៅក្នុងរដ្ឋបាលថ្នាក់ក្រោម (SNA) តម្រូវស្ថាប័នមានមន្ត្រីថ្មីៗដែលមានមុខងារ និងសមត្ថភាពធ្វើការជាមួយយុវជន ដោយធ្វើឱ្យពួកគេក្លាយជាផ្នែកមួយ នៃការដឹកនាំនៅ SNA ជាផ្លូវការ។ ដំណើរការនេះគួរធ្វើឡើងតាមរយៈដំណើរការនៃការធ្វើកំណែទម្រង់វិមជ្ឈការដែលមានស្រាប់។

យន្តការរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ) មានភាពស្រដៀងគ្នាច្រើនទៅនឹងសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.)។ ស.ស.យ.ក. មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ មានសាខាក្នុងក្រសួងនីមួយៗ និងមានការិយាល័យនៅតាមខេត្តនីមួយ។ គណៈកម្មាធិការកណ្តាលដែលមានសមាជិកចំនួន 78 នាក់ ជួបប្រជុំជាទៀងរាល់ឆ្នាំដើម្បីពិភាក្សាអំពីការអនុវត្ត និងការធ្វើផែនការសកម្មភាពយុវជន។ ស.ស.យ.ក.. មានតំណាងមកពីសហគ្រាស ក្រសួង ស្ថាប័ន និងមានប្រធានការិយាល័យ ស.ស.យ.ក. នៅតាមខេត្ត ព្រមទាំងសមាជិកសរុបចំនួន 200 000 នាក់។ តួនាទី និងសកម្មភាពមួយចំនួនរបស់ ស.ស.យ.ក. គឺជាន់គ្នាជាមួយនឹងសកម្មភាពរបស់ ក.ជ.យ.ដូចជា ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបំណិនជីវិតដល់យុវជន ការលើកកម្ពស់ការអប់រំប្រកបដោយគុណភាព និងសមភាពពាក់ព័ន្ធនឹងការថែទាំសុខភាព និងសុខភាពរូបវ័ន្ត និងការធ្វើសមាហរណកម្មតម្រូវការរបស់យុវជនចូលទៅក្នុងផែនការអភិវឌ្ឍគ្រប់កម្រិត។ គេយល់ថា ស.ស.យ.ក. មានឥទ្ធិពលនយោបាយ ដោយសារតែប្រធានរបស់ ស.ស.យ.ក. ត្រូវបានបោះឆ្នោតដោយតំណាងនៃការិយាល័យនីមួយៗនៅតាមខេត្ត។ ប្រធានរបស់ ស.ស.យ.ក. បច្ចុប្បន្នគឺជាកូនប្រុសរបស់**សម្តេចអគ្គមហាសេនាបតី** ហ៊ុន សែន **រដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) ទទួលស្គាល់ជាផ្លូវការថា ស.ស.យ.ក. ជាសមាជិកសំខាន់ក្នុងគណៈកម្មាធិការក្រុមប្រឹក្សា ហើយសមាជិកមួយចំនួនរបស់ ស.ស.យ.ក. ត្រូវបានតែងតាំងជាមន្ត្រីមានតំណែងនៅក្នុង អគ្គលេខាធិការដ្ឋាន ក.ជ.យ.។ ជាបណ្តើរៗ គួរញែកការងាររវាង ក.ជ.យ .និង ស.ស.យ.ក. ឱ្យដាច់ពីគ្នាច្បាស់លាស់។

## ២.៤ ការចូលរួមរបស់យុវជនក្នុងដំណើរការបង្កើតគោលនយោបាយ

កំណើនសេដ្ឋកិច្ចរឹងមាំ និងភាគលាភដែលបានមកពីប្រជាសាស្ត្រគួបផ្សំនឹងប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញសង្គមហ្វេសប៊ុកទូលំទូលាយនាពេលបច្ចុប្បន្នកំពុងសម្រួលដល់ការចូលរួមរបស់យុវជននៅក្នុងវិស័យនយោបាយ និងការអភិវឌ្ឍ។ ការចូលរួមរបស់ប្រទេសកម្ពុជាក្នុងសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ផែនការការងារយុវជនអាស៊ាន និងបណ្តាញសមាគមយុវជននាវាអាស៊ីប៉ូពា៉អន្តរជាតិ ក៏បានជំរុញយុវជនចូលរួមក្នុងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ) និង ផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) ផងដែរ។ កម្រិតសេរីភាពនៃការបញ្ចេញមតិ និងការចូលរួមនៅតែជាបញ្ហាចោទនៅឡើយ ប៉ុន្តែទោះយ៉ាងណា សព្វថ្ងៃនេះយុវជនមានលទ្ធភាពចូលទៅរកព័ត៌មានទាក់ទងនឹងគោលនយោបាយ

ប្រសើរ និងអាចបញ្ចេញមតិ និងពិភាក្សាលើបញ្ហាសាធារណៈបានយ៉ាងងាយ។

### ២.៤.១ ការចូលរួមតាមរយៈអង្គការ និងផទិកាយុវជន

អង្គការធំៗដូចជាសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក. ) គឺផទិកាដំបូងដែលយុវជនអាចចូលរួមក្នុងសកម្មភាពសង្គម និងនយោបាយ។ ស.ស.យ.ក. រៀបចំកម្មវិធីការងារសង្គមដើម្បីលើកទឹកចិត្តយុវជនឱ្យរួមចំណែកដល់សង្គម។ ជាធម្មតា យុវជនចូលរួមព្រោះពួកគេចង់សប្បាយ និងទទួលបានបទពិសោធន៍ការងារមួយចំនួននៅក្នុងសកម្មភាពសង្គម និងការអភិវឌ្ឍ។ យុវជនមួយចំនួនផ្សេងទៀត ចូលរួមដោយសារតែអង្គការធំទាំងនេះមានទំនាក់ទំនងល្អទៅនឹងបណ្ដាញ នៃអ្នកនយោបាយថ្នាក់ខ្ពស់ក្នុងរាជរដ្ឋាភិបាល។

អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធនឹងយុវជនគឺជាបាតុភូតថ្មីមួយនៅក្នុងសង្គមកម្ពុជា។ ក្នុងឆ្នាំ 2014 មានអង្គការក្រៅរដ្ឋាភិបាលចំនួន 35 បានចុះបញ្ជី និងធ្វើការយ៉ាងសកម្មលើបញ្ហាយុវជន ។ ភាគច្រើននៃអង្គការទាំងនេះធ្វើការផ្ដោតលើការបង្កើនជំនាញ និងឱកាសការងារ ព្រមទាំងពង្រីកលទ្ធិប្រជាធិបតេយ្យ ឧទាហរណ៍៖ លើកទឹកចិត្តយុវជនក្នុងការបញ្ចេញមតិ ។ យុវជនខ្លះបានបង្កើតសមាគមខ្លួនឯង ដូចជាអង្គការ CamPro និង Politikoffee ដើម្បីផ្លាស់ប្ដូរព័ត៌មានអំពីនយោបាយ និងបញ្ហាសង្គម និងសេដ្ឋកិច្ច ខណៈពេលដែលអ្នកផ្សេងទៀតផ្ដោតលើព័ត៌មានអំពីឱកាសធុរៈកិច្ចសម្រាប់សមាជិករខ្លួន ឧទាហរណ៍៖ អង្គការ JIC Cambodia។

ការលេចឡើងនូវអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធនឹងយុវជនសម្បូរបែបនេះគឺជាសញ្ញាវិជ្ជមាននៃការអភិវឌ្ឍ ប៉ុន្តែរាល់ពិភាក្សាត្រូវឱ្យមានការស្រាវជ្រាវជាក់ស្ដែងបន្ថែមទៀត និងមានភស្តុតាងគាំទ្រ។ ស្រាវជ្រាវពាក់ព័ន្ធនឹងសង្គម និងគោលនយោបាយនៅកម្ពុជាមិនទាន់គ្រប់គ្រាន់នៅឡើយ ហើយជាទូទៅ យុវជនពុំសូវមានទម្លាប់អានកាសែត ឬវិភាគនយោបាយសង្គមនោះទេ។ ការស្រាវជ្រាវ និងទិន្នន័យដែលអាចទុកចិត្តបានមិនបានបំពេញតម្រូវការនៃការពិភាក្សាទេ ដែលពេលខ្លះធ្វើឱ្យអ្នកបង្កើតគោលនយោបាយយល់ថា អំណះអំណាងរបស់យុវជនធ្វើតាមអារម្មណ៍ និងមានលក្ខណនយោបាយ។

### ២.៤.២ ការចូលរួម តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងគណបក្សនយោបាយ

ប្រព័ន្ធផ្សព្វផ្សាយសង្គមបានលើកកម្ពស់សមត្ថភាពយុវជនឱ្យទទួលបានព័ត៌មាន បញ្ចេញមតិរបស់ខ្លួន និងចូលរួមដំណើរការគោលនយោបាយគ្រប់ដំណាក់កាល។ ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោតឆ្នាំ 2013 ជាសារមួយបង្ហាញគណបក្សកាន់អំណាចឱ្យយល់កាន់តែច្បាស់ថា មិនអាចមិនអើពើ និងមើលរំលងយុវជននោះទេ។ សំលេងយុវជនបានដុះដាលបន្ទាប់ពីការបោះឆ្នោតតាមរយៈប្រព័ន្ធផ្សព្វ ផ្សាយសង្គម អ៊ីនធើណិត និងទូរស័ព្ទដៃ។ ប្រជាជនកម្ពុជាប្រហែល 40 ភាគរយ មានលទ្ធភាពប្រើប្រាស់អ៊ីនធើណិតខ្លួនឯងផ្ទាល់ នៅក្នុងឆ្នាំ 2015 (លទ្ធភាពនេះកើនឡើងជិតពីរដង ពីឆ្នាំ 2013 មក) ដែលធ្វើឱ្យប្រព័ន្ធផ្សព្វផ្សាយថ្មីនេះក្លាយជាឆានែលសំខាន់បំផុតទីពីរសម្រាប់ប្រជាជនកម្ពុជាទទួលព័ត៌មាន បន្ទាប់ពីទូរទស្សន៍ (យោងតាម TAF & USAID ឆ្នាំ2015)។ ចាប់តាំងពីការបោះឆ្នោតមក ចំនួននៃអ្នកនយោបាយ និងអ្នកបង្កើតគោលនយោបាយកំពុងកើនឡើង ក្នុងនោះ**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ក៏កំពុងប្រើប្រាស់ហ្វេសប៊ុកដើម្បីទំនាក់ទំនងផ្ទាល់ជាមួយប្រជាពលរដ្ឋផងដែរ (យោងតាម VOA ឆ្នាំ2015) ។ ហ្វេសប៊ុកត្រូវបានប្រើជាទៀងទាត់ដើម្បីផ្សាយបន្តផ្ទាល់សុន្ទរកថារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ទទួលយកព័ត៌មាន មតិយោបល់ និងផ្ដល់ចម្លើយតបវិញភ្លាមៗ។

ប្រព័ន្ធផ្សព្វផ្សាយសង្គមបានក្លាយជាមធ្យោបាយដ៏មានប្រសិទ្ធិភាព ដើម្បីលើកឡើងនូវបញ្ហា

សាធារណៈជាច្រើន ដូចជា សុវត្ថិភាពសាធារណៈ ការអប់រំនិងអំពើពុករលួយ និងការពិភាក្សា។ កិច្ចពិភាក្សា

តាមប្រព័ន្ធផ្សព្វផ្សាយសង្គមមួយចំនួនបាននាំឱ្យមានការដកហូតតំណែង ឬការផ្ដន្ទាទោសដល់មន្ត្រីជាន់ខ្ពស់ទៀតផង (យោងតាម CARE ឆ្នាំ2015) ។ ជាក់ស្ដែងគឺថា ប្រព័ន្ធផ្សព្វផ្សាយសង្គមបានធ្វើឱ្យយុវជនមានសម្លេងកាន់តែច្រើនពាក់ព័ន្ធនឹងបញ្ហាដូចជាអំពើពុករលួយជាដើម។ ការស្ទង់មតិថ្មីមួយសិក្សាដោយអង្គការតម្លាភាពអន្តរជាតិកម្ពុជា (Transparency International Cambodia ហៅកាត់ថា TIC) បានរកឃើញថា 98 ភាគរយនៃយុវជនកម្ពុជាបានយល់ស្របថា អំពើពុករលួយគឺជាឧបសគ្គសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ទោះជាយ៉ាងណា ក្នុងនោះក៏មានយុវជនមួយចំនួនយល់ផ្ទុយពីនេះដែរ ពោលគឺ 27 ភាគរយ រាយការណ៍ថា បានផ្ដល់សំណូកដើម្បីទទួលបានសេវាព្យាបាល និង 48 ភាគរយ យល់ថា សំណូកបែបនោះសំខាន់សម្រាប់ពួកគេ និងគ្រួសារ (យោងតាម Graham និង Serey Vicheth ឆ្នាំ2015)។

ចលនា និងសកម្មភាពយុវជនកំពុងកើនឡើង ប៉ុន្តែបើសំដៅលើការចូលរួម សេរីភាព នៃការបញ្ចេញមតិ និងសារ ចលនា និងសកម្មភាពទាំងនេះ នៅតែជាដំណាក់កាលដំបូងនៅឡើយ។ គំនិតផ្ដួចផ្ដើម និងចលនាទាំងនេះបង្កើតឡើងដោយគណបក្សកាន់អំណាច និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដើម្បីកៀរគរយុវជនឱ្យចូលរួមក្នុងបញ្ហាសាធារណៈជាក់លាក់ណាមួយ។ ឧទាហរណ៍៖ ក្រុមយុវជនស្ម័គ្រចិត្តវាស់វែងដីធ្លី ដែលផ្ដួចផ្ដើមឡើងដោយ **សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** អនុវត្តដោយសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) ដែលដឹកនាំដោយកូនប្រុសរបស់ **សម្ដេច** និងសមាគមជាច្រើនទៀតដែលដែលមានទំនាក់ទំនងជាមួយគណបក្សកាន់អំណាច។ ចលនា នេះបានចល័តយុវជនរាប់ពាន់នាក់ដើម្បីចុះវាស់វែង និងកំណត់ព្រំដីនៅតំបន់ជនបទ ដែលជាផ្នែកមួយនៃកំណែទម្រង់កម្មសិទ្ធិដីធ្លីរបស់រាជរដ្ឋាភិបាល (យោងតាម Pak និង Tim ឆ្នាំ 2014) ។

សេរីភាព នៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអ៊ីនធើណិតគឺជាបញ្ហាមួយដែលក្រុមសិទ្ធិមនុស្សព្រួយបារម្ភ។ ខណៈពេលដែលអាចគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយសង្គម រាជរដ្ឋាភិបាលបានចេញសារព្រមានថា៖ អ្នកប្រើប្រាស់ដែលបំពានលើសេរីភាពនៃការបញ្ចេញមតិតាមរយៈហ្វេសប៊ុកអាចប្រឈមមុខនឹងការចោទប្រកាន់ (យោងតាម CD 2015, VOA ឆ្នាំ2015)។ គំនិតផ្ដួចផ្ដើមដោយអង្គការក្រៅរដ្ឋាភិបាលតូចៗមួយចំនួនក៏លើកទឹកចិត្តយុវជនក្នុងការបញ្ចេញមតិផងដែរ និងបង្រៀនពួកគេអំពីលទ្ធិប្រជាធិបតេយ្យ និងស្រឡាញ់សង្គម និងផលិតបទដ្ឋានសង្គម ដូចជា ការរំលោភបំពានដោយគ្រឿងស្រវឹង និងគ្រឿងញៀន ឬអំពើហិង្សាប្រឆាំងនឹងស្ត្រី។ ទោះយ៉ាងណា ទំហំនៃការអនុវត្តសកម្មភាពទាំងនេះមិនដូចគ្នានឹងគំនិតផ្ដួចផ្ដើមដោយគណបក្សកំពុងកាន់អំណាចនោះទេ។ យុវជនមួយភាគធំ ជាពិសេសយុវជនដែលរស់នៅក្នុងតំបន់ជនបទ ឬនៅបរទេសជាពលករចំណាកស្រុកមិនបានដឹងពីចលនានិងគំនិតផ្ដួចផ្ដើមទាំងនេះទេ និងត្រូវបានគេទាត់ចោលជារឿយៗ (យោងតាម អង្គការ CARE ឆ្នាំ2015)។ សេរីភាព នៃការបញ្ចេញមតិត្រូវបានរឹតត្បិតនៅកម្ពុជា (អង្គការផ្ទះសេរីភាព ឆ្នាំ 2016) ។

### ២.៤.៣ ការចូលរួមក្នុងស្ថាប័នរាជរដ្ឋាភិបាល និងការអភិវឌ្ឍមូលដ្ឋាន

ចំនួនយុវជនដែលកំពុងធ្វើការងារនៅក្នុងជួររាជរដ្ឋាភិបាលកំពុងកើនឡើង។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ2013 រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើបញ្ហាយុវជនក្នុងការបង្កើតគោលនយោបាយ និងបានផ្ដល់តំណែងសំខាន់ដល់យុវជនដែលមានសមត្ថភាពនៅក្នុងស្ថាប័នសាធារណៈ ។ ការលេចឡើងនូវអ្នកបង្កើតគោលនយោបាយ និងអ្នកបច្ចេកទេសវ័យក្មេង មិនត្រឹមតែនាំមកនូវគំនិតថ្មី និងថាមភាពសម្រាប់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចឱ្យអ្នកជំនាញវ័យក្មេងដទៃទៀតដែលនៅក្រៅរដ្ឋាភិបាលផ្ដល់យោបល់របស់ខ្លួនតាមរយៈមិត្តភក្តិនៅក្នុងជួររាជរដ្ឋាភិបាល។ ទាហរណ៍៖ បណ្ដាញ CamPro ដែលមានសមាជិកប្រហែល 400 នាក់ ទាំងមន្ត្រីសាធារណៈ និងអ្នកជំនាញក្រៅរដ្ឋាភិបាល បានបើកការពិភាក្សាក្រៅផ្លូវការមួយស្ដីពីបញ្ហាគោលនយោបាយសំខាន់ៗ ដូចជា ការអប់រំ និងការងារ ជាដើម។ ទោះបីជាគ្រាប់ពូជថ្មីនេះកំពុងផ្ដល់ក្ដីសង្ឃឹមថា បញ្ហាយុវជននឹងមានទ្រង់ទ្រាយលេចធ្លោក្នុងរបៀបវារៈអភិវឌ្ឍន៍ក៏ដោយ ក៏គម្លាត និងភាពតានតឹងរបស់គ្រប់ពូជថ្មីនេះនៅក្នុងជួររាជរដ្ឋាភិបាលនៅតែមាននៅឡើយ ដោយសារតែអ្នកបង្កើតគោលនយោបាយចាស់ៗគ្រប់គ្រងដំណើរការនៃសម្រេចចិត្ត និងប្រកាន់ខ្ជាប់ទម្លាប់ចាស់ (យោងតាម Hunt ឆ្នាំ2015)។

នៅកម្រិតមូលដ្ឋាន សាលារៀន និងរដ្ឋបាលមូលដ្ឋាន គឺជាចំណុចពីរសម្រាប់យុវជនចូលរួម។ សាលារៀនបង្រៀនអំពីអភិបាលកិច្ច និងការប្រឆាំងអំពើពុករលួយ (យោងតាម PPP ឆ្នាំ2015) ប៉ុន្តែជាទូទៅ នៅសាលាមធ្យមសិក្សា កិច្ចពិភាក្សានយោបាយមិនត្រូវបានលើកទឹកចិត្តនោះទេ (យោងតាម VOD ឆ្នាំ 2015) ។ យោងតាមគោលនយោបាយវិមជ្ឈការ គេរំពឹងថា យុវជនអាចបញ្ចេញមតិ និងរួមចំណែកក្នុងការអភិវឌ្ឍមូលដ្ឋាន និងដំណើរការនៃការសម្រេចចិត្ត។ ធាតុពិត យុវជនបង្ហាញចំណាប់អារម្មណ៍តិចតួចនៅក្នុងបញ្ហានេះ លើកលែងតំបន់ដែលមានសកម្មភាពយុវជនគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាល។ ហេតុផលមួយគឺ ដោយសាររដ្ឋបាលមូលដ្ឋាន ជារឿយៗ មិនមានធនធានគ្រប់គ្រាន់ និងខ្វះឆន្ទៈក្នុងការដោះស្រាយបញ្ហារបស់យុវជន ( យោងតាម NLCS ឆ្នាំ2013, Save the Children Cambodia

ឆ្នាំ2014, Save the Children ឆ្នាំ2015)។ ឪពុកម្តាយក៏ទទួលខុសត្រូវមួយចំណែកផងដែរ ព្រោះពួកគាត់ហាក់ដូចជាមិនគាំទ្រឱ្យយុវជនចូលរួមក្នុងនយោបាយ ឬការស្ម័គ្រចិត្តនោះទេ ដោយហេតុថា ពួកគាត់គិតថា យុវជនអាចមានគ្រោះថ្នាក់ និងឃ្លាតឆ្ងាយពីការសិក្សា។

**ប្រអប់ 2 (2-1) ការរកឃើញសំខាន់ៗពីការសិក្សាពាក់ព័ន្ធនឹងការចូលរួមរបស់យុវតីក្នុងវិស័យនយោបាយ**

> ក្នុងឆ្នាំ 2014 សម្ព័ន្ធជាតិឃុំ/សង្កាត់ (National League of Communes/Sangkats ហៅកាត់ថា NLCS) បានធ្វើការស្ទង់មតិមួយដោយមានយុវតីចំនួន 181 នាក់ មកពីសាកលវិទ្យាល័យចំនួនពីរ គឺមួយនៅក្នុងរាជធានីភ្នំពេញ និងមួយទៀតនៅខេត្តបាត់ដំបង អំពីការយល់ឃើញនិងការចូលរួមក្នុងនយោបាយក្នុងស្រុករបស់ពួកគេ។ ការរកឃើញសំខាន់ៗរបស់សម្ព័ន្ធនេះមានដូចខាងក្រោម៖
>
> - ការព្រួយបារម្ភសំខាន់បំផុតសម្តែងដោយយុវតីរួមមានបញ្ហាប្រឈមនឹងការស្វែងរកការងារ (32 ភាគរយ), បញ្ហាហិរញ្ញវត្ថុគ្រួសារ (15 ភាគរយ) និងការព្រួយបារម្ភពីសុវត្ថិភាពរបស់សហគមន៍ដូចជា ក្រុមជនពាល និងគ្រឿងញៀន (24 ភាគរយ);
> - វិទ្យុទំនងជាល្អមធ្យមសម្រាប់យុវតីចូលរួម ជាងពាក់កណ្តាលនៃស្ត្រីវ័យក្មេងស្តាប់វិទ្យុជារៀងរាល់ថ្ងៃ។ តាមការប្រៀបធៀប 37 ភាគរយ មើលទូរទស្សន៍ជារៀងរាល់ថ្ងៃ ជិតមួយភាគបួនអាចប្រើប្រាស់អ៊ីនធើណិតប្រចាំថ្ងៃ និង 12 ភាគរយ អានកាសែតប្រចាំថ្ងៃ
> - ជាងពាក់កណ្តាល (57 ភាគរយ) នៃយុវតីមិនបានចូលរួមដោះស្រាយបញ្ហានៅក្នុងសហគមន៍របស់ពួកគេ។ 77 ភាគរយ មានបំណងចង់ជួយ ប៉ុន្តែនិយាយថា ពួកគេមិនដឹងពីរបៀបជួយ
> - ការកសាងផ្លូវ និងស្ពានសម្រាប់យុវតីគឺជាសមិទ្ធិផលធំបំផុតក្នុងឃុំ/សង្កាត់របស់ពួកគេ (78 ភាគរយ);
> - គ្រូបង្រៀន និងមេឃុំមានឥទ្ធិពលធំបំផុតលើយុវជន
> - ស្ទើរតែទាំងអស់គ្នាមានជំនឿយ៉ាងខ្លាំងថា ស្ត្រីគួរតែពាក់ព័ន្ធក្នុងនយោបាយមូលដ្ឋានបន្ថែមទៀត
> - មូលហេតុកំពូលដែលបានរៀបរាប់ខាងលើបង្ហាញថា ស្ត្រីមានសមត្ថភាពការងារស្មើភាពគ្នានឹងបុរសដែរ និងអាចជួយលើកកម្ពស់ម្លៃស្ត្រី
> - ឧបសគ្គធំបំផុតក្នុងការចូលរួមក្នុងនយោបាយមូលដ្ឋានគឺកម្រិតអប់រំទាប ការខ្វះខាតទំនុកចិត្តក្នុងការដោះស្រាយជាមួយនឹងការរើសអើង និងការខ្វះខាតពេលវេលាដោយសារតែមានកាតព្វកិច្ចក្នុងគ្រួសារ
> - 87 ភាគរយ នៃអ្នកផ្តល់ចម្លើយបានលើកឡើងថា ពួកគេគ្រោងនឹងចូលរួមក្នុងរដ្ឋបាលមូលដ្ឋានតាមរយៈការបោះឆ្នោតក្នុងតំបន់នាពេលខាងមុខនេះ ចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍សហគមន៍ និង/ឬជួយដល់ក្រុមប្រឹក្សាប្រសិនបើស្នើសុំឱ្យជួយ។

*ប្រភព៖ NLCS ឆ្នាំ 2013*

#### ២.៤.៤ ការចូលរួមតាមរយៈការងារស្ម័គ្រចិត្ត

ការងារស្ម័គ្រចិត្តគឺជាអាទិភាពមួយក្នុងចំណោមអាទិភាពដែលបានបន្ទូចនៅក្នុងផែនការសកម្មភាពដើម្បីអភិវឌ្ឍយុវជនព្រមទាំងនៅក្នុងផែនការការងារយុវជនអាស៊ាន។ ការងារស្ម័គ្រចិត្តកំពុងត្រូវបានអ្នកបង្កើតគោលនយោបាយទទួលស្គាល់ថា ជាទម្រង់មួយយ៉ាងសំខាន់សម្រាប់ការចូលរួមរបស់យុវជន។ ហេតុផលដែលជំរុញឱ្យមានការលើកកម្ពស់ការងារស្ម័គ្រចិត្តគឺថា យុវជនមិនត្រឹមតែរួមចំណែកជាវិជ្ជមានដល់សង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចអភិវឌ្ឍខ្លួនឯងទាំងជំនាញរឹង និងជំនាញទន់។ ការងារស្ម័គ្រចិត្តត្រូវបានលើកម្ពស់ទូទាំងអាស៊ាន។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍន៍យុវជនកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (United Nations Volunteers in Cambodia ហៅកាត់ថា UNV) និងបណ្តាញ VolCam ដើម្បីលើកកម្ពស់ការងារស្ម័គ្រចិត្តនៅកម្ពុជា។ UNV គ្រោងនឹងបង្ហាញគម្រោងថ្មីស្តីពីការអភិវឌ្ឍយុវជន និងជំនាញការងារតាមរយៈការស្ម័គ្រចិត្ត។ គម្រោងនេះនឹងពិនិត្យលើគំនិតផ្តួចផ្តើមរបស់យុវជនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើតការងារ និងសហគ្រិនភាព។

### ២.៥ សន្និដ្ឋាន និងអនុសាសន៍

យុវជនគឺជាកម្លាំងជំរុញយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ហើយការចូលរួមរបស់ពួកគេក្នុងដំណើរការបង្កើតគោលនយោបាយមានសារសំខាន់បំផុត។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ 2013 រាជរដ្ឋាភិបាលបាន និងកំពុងយកចិត្តទុកដាក់បន្ថែមទៀតលើបញ្ហាយុវជន។ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (NYDP) និង ផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) បានឆ្លុះបញ្ចាំងពីការចូលរួមក្នុងគោលនយោបាយនេះ ប៉ុន្តែនៅខ្វះការបញ្ជ្រាបជាលក្ខណៈប្រព័ន្ធទៅក្នុងដំណើរការថវិកា និងយន្តការចែកចាយសេវានៅថ្នាក់ក្រោមជាតិ។ ការបង្កើតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ) បានបង្ហាញពីការប្តេជ្ញាចិត្តបន្ថែមទៀតរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញរបៀបវារៈយុវជន។ ស្ថាប័នដែលទើបតែបង្កើតថ្មីទាំងនេះត្រូវតែទទួលបានថវិកាសមស្របសម្រាប់ដំណើរការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដោយសារការចូលរួមរបស់យុវជន ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមបានការរីករាលដាលយ៉ាងឆាប់រហ័សក្នុងចំណោមយុវជនកម្ពុជា ដែលធ្វើឱ្យពួកគេកាន់តែទទួលបានព័ត៌មានប្រសើរជាងមុន និងក្លាយជាពលរដ្ឋសកម្មក្នុងការបញ្ចេញមតិ។ ប្រសិនបើគិតថា កម្រិត នៃការចូលរួមរបស់យុវជនអាចបែងចែកជាបួនកម្រិត ពីទម្រង់អសកម្មទៅទម្រង់សកម្ម (ការចែករំលែកព័ត៌មាន ការពិគ្រោះយោបល់ ការសហការ និងការផ្តល់សិទ្ធិអំណាច) នោះយុវជនកម្ពុជាភាគច្រើនស្ថិតនៅក្នុងដំណាក់កាល នៃការចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់។ ការសហការគ្នាមានតែនៅក្នុងអង្គការធំៗមួយចំនួនដែលមានទំនាក់ទំនងល្អនឹងគ្នា ដូចជា ស.ស.យ.ក. ជាដើម។ ដូច្នេះ គុណភាពនៃការចូលរួមរបស់យុវជនពាក់ព័ន្ធនឹងការពិភាក្សាតាមប្រព័ន្ធផ្សព្វផ្សាយសង្គមចាំបាច់ត្រូវតែធ្វើឱ្យប្រសើរឡើង ព្រោះថា មាតិកានិងការសន្ទត់ជាច្រើនមិនត្រូវបានធ្វើឡើងដោយឈរលើភស្តុតាងជាមូលដ្ឋាននោះទេ ប៉ុន្តែត្រូវបានគេយល់ថា ជាការធ្វើតាមអារម្មណ៍ទៅវិញ។ ក្រុមអ្នកបង្កើតគោលនយោបាយស្តីពីយុវជន និងអង្គការយុវជនគួរតែវិនិយោគក្នុងការស្រាវជ្រាវសង្គម និងនយោបាយឱ្យបានជាក់លាក់បន្ថែមទៀត។

ការងារស្ម័គ្រចិត្តមាននិន្នាការកំពុងកើនឡើង ដោយមានយុវជនកាន់តែច្រើនចូលរួមនៅក្នុងការងារសង្គម និងអភិវឌ្ឍសហគមន៍។ ការងារស្ម័គ្រចិត្តត្រូវបានចាត់ទុកថា ជាបទពិសោធន៍វិជ្ជមានសម្រាប់យុវជនព្រោះពួកគេអាចទទួលបានទាំងជំនាញទន់ និងរឹងដែលមានប្រយោជន៍សម្រាប់ការងារនៅពេលក្រោយ។ ទោះយ៉ាងណា ការស្ម័គ្រចិត្តរបស់យុវជនត្រូវគេយល់ថា មានទំនាក់ទំនងជាមួយនឹងចលនានយោបាយ តាមរយៈការអង្គការយុវជនធំៗ។ យុវជនគួរតែទទួលបានការជូនដំណឹងច្បាស់លាស់អំពីអង្គការ ឬសកម្មភាពដែលពួកគេចូលរួម។

ដើម្បីពង្រឹងស្ថាប័ននេះ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) គួរកៀរគរជំនួយបច្ចេកទេសពីគូរដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធដើម្បីជួយជំរុញការសម្របសម្រួល និងការអនុវត្តឯកសារច្បាប់មូលដ្ឋាន និងគោលនយោបាយពាក់ព័ន្ធ ដូចជា ផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) ដែលបានមកពីក្រសួងពាក់ព័ន្ធ។ ស្ថាប័នូបនីយកម្ម និងការប្រតិបត្តិនៃ ក.ជ.យ. អាចសម្រេចជោគជ័យអាស្រ័យមានការចូលរួមពីក្រសួងពាក់ព័ន្ធ និងអង្គការយុវជនធំៗ។ ភាពតំណាងអាចជាចំណុចសំខាន់មួយដែលយុវជនបានលើកឡើងអំពីរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ) ព្រោះថា ស.ស.យ.ក.គឺជាស្ថាប័នយុវជនតែមួយគត់ដែលមានតំណាងនៅក្នុងក្រុមប្រឹក្សានេះ។ កម្មវិធី និងថវិកាសម្រាប់សកម្មភាពយុវជនគួរតែបញ្ជាក់ឱ្យបានលាស់ជាងនេះ និងវិភាគ ដើម្បីយល់អំពីកម្មវិធី និងគម្លាតនៃការផ្តល់ថវិកា ក៏ដូចជាកម្មវិធីដែលជាន់គ្នាជាមួយក្រសួងដទៃដែរ។ សមត្ថភាពរបស់រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិនឹងត្រូវបានពង្រឹង ប្រសិនបើវិធីសាស្ត្រវិមជ្ឈការត្រូវបានលើកយកមកដើម្បីអនុវត្តផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា (NYAP) ។

ភាពជាតំណាងប្រហែលជាចំណុចសំខាន់បំផុតដែលយុវជនបានលើកឡើងអំពីរចនាសម្ព័ន្ធថ្មីរបស់ ក.ជ.យ. ពីព្រោះនៅឆ្នាំ 2015 ស.ស.យ.ក. នៅតែជាស្ថាប័នយុវជនតែមួយគត់ដែលមានតំណាងនៅក្នុងក្រុមប្រឹក្សានេះ។ ខណៈពេលដែល ក.ជ.យ. តាំងនៅក្នុងក្រសួង អយក. ឋានៈឯករាជ្យរបស់ក្រុមប្រឹក្សានេះពុំសូវច្បាស់លាស់។ ដើម្បីធានាឱ្យមានការសម្របសម្រួលមិនលម្អៀងក្នុងចំណោមអ្នកពាក់ព័ន្ធផ្សេងៗ គួរបង្កើតឱ្យមាននីតិវិធីទំនាក់ទំនងរដ្ឋបាលផ្ទៃក្នុង និងខាងក្រៅឱ្យច្បាស់លាស់រវាងរាជរដ្ឋាភិបាលកម្ពុជា ក្រសួងខ្សែបណ្តោយ និងថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ។ គួររៀបចំការពិគ្រោះជាទៀងទាត់ជាមួយយុវជនផងដែរ។ ក.ជ.យ. គួរតែបង្កើតយន្តការពិគ្រោះយោបល់មួយជាមួយយុវជនដូចជា កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្តប្រចាំត្រីមាស ការប្រឹក្សាតាមតំបន់រយៈពេលប្រាំមួយខែម្តង និងសន្និបាតយុវជនជាតិប្រចាំឆ្នាំដែលមានភារកិច្ចនៅក្នុង ក.ជ.យ. ។

**សម្គាល់៖** 1 សមាមាត្រ នៃអត្រាភាពក្រីក្រជាតិគឺជាភាគរយ នៃចំនួនប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ នៃភាពក្រីក្រ។

# ឯកសារយោង

Bylander, M. (2013), "The Growing Linkages Between Migration and Microfinance", Migration Policy Institute website, www.migrationpolicy.org/article/growing-linkages-between-migration-and- microfinance.

CARE (2015), Duty bearers and violence against women. Phnom Penh, Cambodia.

CCASVA (2015), State of migration and impact on children Phnom Penh, Cambodia

Graham, C. and C. Serey Vicheth (2015), *Questioning Corruption: A National Survey on Youth Perceptions of Corruption and Integrity in Cambodia*, Transparency International Cambodia, Phnom Penh.

Hunt, L. (2015), "Cambodia: A Generation Gap Divides a Struggling Nation – Recent surveys offer some interesting insights into Cambodian life and politics", *The Diplomat*, 7 December.

Kane, G. (2015), Cambodia Factsheet: Facts on Cambodia's Garment Industry, Clean Clothes Campaign, https://cleanclothes.org/resources/publications/factsheets/cambodia-factsheet-february-2015.pdf.

Khemara, S. (2015), "Media Experts Warn Against a Cyber-Crime Law That Hurts Online Freedom", *Voice of America Cambodia*, https://www.voacambodia.com/a/media-experts-warn-against-a- cyber-crime-law-that-hurts-online-freedom/3002439.html.

MoH (2008), *Health Strategic Plan 2008-2015: Accountability Efficiency Quality Equity*, Ministry of Health, Kingdom of Cambodia, Phnom Penh.

NCDD (2014), *3-Year Implementation Plan, Phase II (2015-17) of the Nationa Program for Sub-national Democrative Development (IP3-II)*, 14 December, National Committee for Sub-National Democratic Development, Phnom Penh, http://www.ncdd.gov.kh/jdownloads/Strategic%20plan- policy/final_ip3-ii_english_13_jan_2015.pdf.

FCM International (2013), *Encouraging and Supporting Women's Participation in Cambodian Local Politics*, Federation of Canadian Municipalities International, Phnom Penh. https://www.fcm.ca/Documents/reports/International/Encouraging_and_Supporting_Women s_Part icipation_in_Cambodian_Local_Politics_EN.pdf.

ODM (2009), *Situation analysis of youth in Cambodia*, Open Development Mekong website, https://data.opendevelopmentmekong.net/library_record/situation-analysis-of-youth-in-cambodia.

OECD/CDRI (2017), *Interrelations between Public Policies, Migration and Development in Cambodia*, OECD Publishing, Paris.

Pak, K. and K. Tim (2014), The political settlement and the land sector in Cambodia. Phnom Penh.

Phong, K. and J. Solá (2015), Mobile phones and Internet in Cambodia 2015, Research Study, November, United States Agency for International Development and The Asia Foundation, Phnom Penh.

RGC (2015a), *Cambodia industrial development policy 2015-2025*, The Royal Government of Cambodia, Phnom Penh.

RGC (2015b), *National Employment Policy 2015-2025*, The Royal Government of Cambodia, Phnom Penh.

RGC (2014), *Labour migration policy*, The Royal Government of Cambodia, Phnom Penh.

RGC (2013), *Rectangular Strategy Phase III*, The Royal Government of Cambodia, Phnom Penh.

RGC (2010), *National Program for Sub-National Democratic Development (NP-SNDD) 2010-2019*, 23 May, Royal Government of Cambodia, Phnom Penh, http://www.gafspfund.org/sites/gafspfund.org/files/Documents/Cambodia_9_of_16_SATR ATEG Y_National_Program_for_Sub-National_Democratic_Development_0.pdf.

Save the Children (2015), *Program Based Budget Reform and Commnity Participation in Primary Education in Cambodia*, Save the Children in Cambodia, Phnom Penh.

Save the Children (2014), "Empowering children to participate in commune development process in Kampong Cham", cited in *Program Based Budget Reform and Commnity Participation in Primary Education in Cambodia*, Save the Children in Cambodia, Phnom Penh, p. 50.

Socheata, H. (2015), "Government Officials Increasingly on Facebook", *Voice of American Cambodia*, https://www.voacambodia.com/a/government-officials-increasingly-on-facebook/3084608.html.

Sotheary, P. and S. Phak (2015), "Anti-graft programmes launch", The Phnom Penh Post, 25 June, http://m.phnompenhpost.com/national/anti-graft-programs-launch.

Turton, S. (2015), "Garment sector weighs new reforms", The Phnom Penh Post, 9 December, http://www.phnompenhpost.com/national/garment-sector-weighs-new-reforms.

UN (2009), *Strengthening Life Skills for Positive Youth Health Behaviour: An Overview and Discussion Paper*, United Nations Economic and Social Commission for Asia and the Pacific, Bangkok.

UNDP (2015), *Human Development Report 2015: Work for human development*, United Nations Development Programme, New York.

Wilwohl, J. (2015), "Facebook users may face charges, Gov't says", cited in Multimedia Journalism Portfolio, Prepared for Paul Bradshaw, Birmingham School of Media, Birmingham

# ជំពូកទី ៣៖ ចរិតលក្ខណៈ និងផ្លូវជីវិត នៃអ្នកការបោះបង់ការសិក្សា

# ជំពូកទី ៣៖

## ចរិតលក្ខណៈ និងផ្លូវជីវិត នៃអ្នកការបោះបង់ការសិក្សា

ការចូលរួមរបស់យុវជននៅកម្ពុជានឹងក្លាយជាជាភាគលាភយ៉ាងធំធេង ជាពិសេសការទាញយកសក្តានុពលពីប្រជាសាស្ត្រវ័យក្មេង ប្រសិនបើពួកគេអាចចូលទៅក្នុងទីផ្សារការងារដោយមានការអប់រំនិងជំនាញល្អ ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះ 63 ភាគរយ នៃយុវជនដែលមានអាយុរៀននៅមធ្យមសិក្សា និងឧត្តមសិក្សា (12 ឆ្នាំទៅ 22 ឆ្នាំ) បានចាកចេញពីប្រព័ន្ធអប់រំរួចទៅហើយ (សូមមើល ជំពូកទី 1)។ អត្រានៅក្រៅសាលា នៃយុវជនដែលមានអាយុរៀននៅអនុវិទ្យាល័យ (12 ទៅ 17 ឆ្នាំ) គឺ 23 ភាគរយ ក្នុងឆ្នាំ 2015។ អត្រានៃការចុះឈ្មោះចូលរៀននៅបឋមសិក្សាខិតជិតដល់អត្រាសកលគឺ 94 ភាគរយ ប៉ុន្តែអត្រានេះធ្លាក់ចុះដល់ 39 ភាគរយ នៅអនុវិទ្យាល័យ និង 19 ភាគរយនៅវិទ្យាល័យ (យោងតាម អយក.ឆ្នាំ 2015/16)។ ស្ត្រីយុវតីជាច្រើនទំនងជាចាកចេញពីសាលាដើម្បីជួយការងារផ្ទះ ឬរៀបការទាំងវ័យក្មេង។ យុវជននៅតាមជនបទក៏ទំនងជាបោះបង់កាសិក្សាដើម្បីទៅរកការងារធ្វើនៅទីក្រុងផងដែរ ប៉ុន្តែដោយសារតែគ្មានជំនាញមូលដ្ឋាន ពួកគេមានឱកាសតិចតួច ក្នុងការលើកកម្ពស់សុខុមាលភាពសង្គម និងសេដ្ឋកិច្ចរបស់ពួកគេ។

ជំពូកនេះពិនិត្យអំពីហេតុផលនៃការបោះបង់ការសិក្សា និងជម្រើសជីវិតរបស់យុវជនដែលបានចាកចេញពីប្រព័ន្ធអប់រំជាផ្លូវការ។ ជំពូកនេះនឹងរៀបរាប់អំពីផលវិបាកនៃការបោះបង់សាលាដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ក្រុមយុវជនផ្សេងគ្នា និងស្វែងរកជម្រើសគោលនយោបាយ ដើម្បីលើកកម្ពស់ទិដ្ឋភាពការងារយុវជនដែលបានបោះបង់ការសិក្សាទាំងនោះ។ ដើម្បីអនុវត្តការវិភាគនេះ គេប្រើប្រាស់ទិន្នន័យពីក្រសួងអប់រំ យុវជន និងកីឡា (អយក.) ទិន្នន័យពីការស្ទង់មតិសេដ្ឋកិច្ចសង្គមនៅកម្ពុជា (CSES) និងគម្រោងផ្លាស់ប្តូរពីសាលាទៅការងាររបស់អង្គការ ILO (យោងតាម NIS ឆ្នាំ2015) ។

### ៣.១ និន្នាការ នៃបោះបង់ការសិក្សា

របបខ្មែរក្រហមក្នុងទសវត្សរ៍ឆ្នាំ 1970 បានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តរបស់កម្ពុជាស្ទើរតែទាំងស្រុង រួមទាំងធនធានមនុស្ស ជាពិសេសអ្នកជំនាញ បញ្ញវន្ត និងគ្រូបង្រៀន។ ដើម្បីកសាងប្រទេសឡើងវិញ ការអប់រំត្រូវបានផ្តល់ជាវិស័យអាទិភាពក្នុងចំណោមគោលនយោបាយអភិវឌ្ឍន៍នានា ជាពិសេសតាមរយៈការបង្កើនចំនួនសាលាបឋមសិក្សា មធ្យមសិក្សា និងមហាវិទ្យាល័យ។ ចន្លោះឆ្នាំ 2005 និងឆ្នាំ 2015ចំនួនសាលារៀនបានកើនឡើងចំនួន 32 ភាគរយ គឺពី 6 990 សាលា ក្នុងឆ្នាំ 2005 ដល់ 9232 សាលា ក្នុងឆ្នាំ 2015 (យោងតាម អយក. ឆ្នាំ 2015/16) ។ ទោះបីជាមានការវិនិយោគទាំងនេះក៏ដោយ ក៏អត្រានៃអ្នកឆាប់បោះបង់ការសិក្សាគឺជាបាតុភូតមួយដែលនៅតែបន្តកើតមាន។

អង្គការយូណេស្កូ (UNESCO) បានកំណត់និយមន័យថា សិស្សដែលបោះបង់ការសិក្សា គឺជាសិស្សដែលបានចុះឈ្មោះចូលរៀននៅឆ្នាំសិក្សាណាមួយ ប៉ុន្តែមិនបានចុះឈ្មោះចូលរៀននៅឆ្នាំបន្ទាប់ ទោះបីជាពួកគេបានបញ្ចប់ ឬមិនបានថ្នាក់នោះក៏ដោយ។ និយមន័យផ្សេងទៀតបានចាត់ទុកថា សិស្សដែលបោះបង់ការសិក្សាគឺជាបុគ្គលដែលបានចាកចេញពីសាលារៀនមុនពេលបញ្ចប់ថ្នាក់ ឬមុនពេលតម្រូវ ដោយមិនរាប់អ្នកដែលផ្ទេរទៅឱ្យសាលាផ្សេងទេ (យោងតាម Wiliams 1987; Yokozeki ឆ្នាំ 1996) ។ ការសិក្សានេះប្រើប្រាស់និយមន័យរបស់អង្គការយូណេស្កូ ដែលផ្តោតលើអ្នកដែលមិនបានបញ្ចប់វដ្តនៃសិក្សាពេញលេញ។

អត្រាបោះបង់ការសិក្សានៅសាលាបឋមសិក្សានៅតែថេរដដែល នៅចន្លោះឆ្នាំ 2009 និងឆ្នាំ 2013 គឺប្រហែល 8 ភាគរយ ដោយធ្លាក់ចុះមកត្រឹម 6,2 ភាគរយ ប៉ុណ្ណោះ ក្នុងឆ្នាំ 2014/15។ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិក៏នៅថេរដែរ គឺជុំវិញ 20 ភាគរយ ។ ទោះជាយ៉ាងណា ចាប់តាំងពីឆ្នាំ 2012 មក អត្រាបោះបង់កាសិក្សានៅមធ្យមសិក្សាទុតិយភូមិបានកើនឡើងពី 10 ភាគរយ ក្នុងឆ្នាំ 2011 ដល់ប្រហែល 24 ភាគរយ ក្នុងឆ្នាំ 2014 ។ នេះប្រហែលជាមកពីឧស្សាហកម្មសម្លៀកបំពាក់ និងស្បែកជើងកំពុងរីកលូតលាស់ និងកំពុងត្រូវការកម្លាំងពលកម្មដែលមានជំនាញទាប។ វាមានភាពខុសគ្នាតិចតួចប៉ុណ្ណោះរវាងយុជន និងយុវតី ទោះបីជាយុវតីមានភាព ប្រសើរជាងបន្តិចក៏ដោយ។ នេះជាលទ្ធផលគួរឱ្យភ្ញាក់ផ្អើលនៅពេលដែលគិតដល់បទដ្ឋានសង្គមពាក់ព័ន្ធនឹងតួនាទីយេនឌ័រនៅក្នុងប្រទេសកម្ពុជា (សូមមើល ជំពូកទី 4)។

**រូបភាព 20 (3-1) អត្រាសិស្សបោះបង់សាលាតាមកម្រិតសិក្សា និងភេទ (ឆ្នាំសិក្សា 2009/10 និង 2014/15)**




*ប្រភព៖ អយក. ឆ្នាំ2009 / 10-2015 / 16*

ក្នុងចំណោមសិស្សប្រាំនាក់ដែលបានចុះឈ្មោះចូលរៀននៅបឋមសិក្សា មានតែម្នាក់គត់ដែលបានបញ្ចប់វិទ្យាល័យ។ អត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សាខិតជិតនឹងអត្រាសកល ប៉ុន្តែធ្លាក់ចុះនៅមធ្យមសិក្សាបឋមភូមិ ទោះបីវាជាកាតព្វកិច្ចក៏ដោយ។ ដូចមានបង្ហាញក្នុងជំពូកទី 1 អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅបឋមសិក្សានៅតែមានកម្រិតខ្ពស់គឺ ជុំវិញ 94 ភាគរយ នៅចន្លោះឆ្នាំ 2009 និងឆ្នាំ 2015 គឺពុំមានភាពខុសគ្នារវាងកុមារា និងកុមារីនោះទេ។ ទោះជាយ៉ាងណាក្តី អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅបឋមសិក្សាបានធ្លាក់ចុះដល់ 39 និងមធ្យមសិក្សាបានធ្លាក់ចុះដល់ 19 ភាគរយ ។ ក្នុងចំណោមសិស្សដែលបានចុះឈ្មោះចូលរៀននៅបឋមសិក្សា មានសិស្សចំនួន 81 ភាគរយ បានបញ្ចប់វដ្តសិក្សាពេញលេញ។ នៅមធ្យមសិក្សាបឋមភូមិមានសិស្ស 39 ភាគរយ និងនៅមធ្យមសិក្សាទុតិយភូមិមានសិស្សចំនួន 19 ភាគរយ បានបញ្ចប់វដ្តសិក្សាពេញលេញ ។ ការបញ្ចូលគ្នារវាងអត្រាចុះឈ្មោះចូលរៀន និងបញ្ចប់បង្កើតបាន រូបភាពទី 3.2 ដែលបង្ហាញពីការធ្លាក់ចុះនិទស្សន្ត (exponential decline) ឬការធ្លាក់ចុំអត្រាអត្រាកំណើនកុមារ និងយុវជននៅតាមសាលា ។

**រូបភាព 21 (3-2) អត្រាសរុបនៃចុះឈ្មោះចូលរៀននិងបញ្ចប់ (ភាគរយ) ឆ្នាំសិក្សា 2010 / 11-2015 / 16**




*ប្រភព៖ អយក. ឆ្នាំ 2009/10 និង 2015/16*

ឪពុកម្តាយ និងយុវជនយល់ឃើញថា តម្លៃឱកាសនៃការទៅសាលារៀនគឺខ្ពស់។ យុវជនកាន់តែចាស់ កាន់តែមិនចង់នៅរៀន ឬកាន់តែចង់រកការងារមានប្រាក់ខែ។ ដោយសារតែកាតព្វកិច្ចអប់រំមិនត្រូវបានពង្រឹងពេញលេញ ឪពុកម្តាយក៏យល់ថា តម្លៃឱកាសនៃការបញ្ជូនកូនទៅសាលារៀនគឺខ្ពស់ និងសុខចិត្តឱ្យកូនជួយការងារគ្រួសារ ឬរកការងារមានប្រាក់ខែវិញ។ ស្ថានភាពនេះចេះតែបន្ត ព្រោះថា គុណភាពនៃការអប់រំ និងការលើកទឹកចិត្តគ្រូបង្រៀននៅតិចតួច ជាពិសេសនៅតំបន់ជនបទ ខណៈពេលដែលតម្រូវពលកម្មជំនាញទាបកើនឡើង។ ក្រៅពីរាជធានី អត្រាបោះបង់កាសិក្សានៅតែខ្ពស់នៅតាមតំបន់ទាំងអស់ (សូមមើល តារាង 3.1) ។ អត្រាបោះបង់កាសិក្សាខ្ពស់ អត្រាចុះឈ្មោះចូលរៀនទាប និងអត្រាបញ្ចប់ថ្នាក់ទាបនៅតាមសាលាមធ្យមសិក្សាគឺជាការគំរាមកំហែងដល់យុវជនមិនឱ្យមានចំណេះដឹង និងជំនាញមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចូលក្នុងទីផ្សារការងារ។

**តារាង 19 (3-1) អត្រាបោះបង់ការសិក្សា (គិតជាភាគរយ) តាមតំបន់ ក្នុងឆ្នាំសិក្សា 2009 / 10-2014 / 15**

| | 2009/10 | 2010/11 | 2011/12 | 2012/13 | 2013/14 | 2014/15 |
|---|---|---|---|---|---|---|
| **បឋមសិក្សា** | | | | | | |
| ភ្នំពេញ | 5.2 | 5.0 | 5.5 | 6.9 | 3.8 | 4.1 |
| វាលទំនាប | 6.5 | 6.1 | 5.5 | 8.5 | 6.3 | 4.6 |
| ទន្លេសាប | 10.7 | 10.1 | 8.8 | 12.5 | 10.7 | 7.3 |
| តំបន់ឆ្នេរ | 9.4 | 8.9 | 10.2 | 11.2 | 8.1 | 6.4 |
| ខ្ពង់រាបនិងភ្នំ | 11.2 | 11.8 | 12.4 | 12.5 | 11.5 | 7.3 |
| **អនុវិទ្យាល័យ** | | | | | | |
| ភ្នំពេញ | 9.1 | 11.3 | 14.9 | 13.7 | 13.7 | 12.4 |
| វាលទំនាប | 21.1 | 22.6 | 21.7 | 21.9 | 21.8 | 19.5 |
| ទន្លេសាប | 20.9 | 22.8 | 23.0 | 22.3 | 22.2 | 19.9 |
| តំបន់ឆ្នេរ | 17.7 | 21.0 | 16.6 | 18.8 | 20.4 | 18.3 |
| ខ្ពង់រាបនិងភ្នំ | 16.5 | 17.7 | 20.7 | 19.6 | 20.2 | 19.0 |
| **វិទ្យាល័យ** | | | | | | |
| ភ្នំពេញ វិទ្យាល័យ | 5.4 | 4.4 | 7.1 | 5.7 | 18.5 | 16.6 |
| វាលទំនាប | 13.2 | 14.1 | 15.3 | 15.7 | 29.0 | 26.3 |
| ទន្លេសាប | 14.2 | 16.9 | 19.3 | 16.4 | 27.7 | 24.6 |
| តំបន់ឆ្នេរ | 12.5 | 15.0 | 15.8 | 11.3 | 29.8 | 21.6 |
| ខ្ពង់រាបនិងភ្នំ | 17.9 | 16.8 | 18.2 | 17.2 | 30.7 | 23.2 |

*ប្រភព៖ អយក. ឆ្នាំ 2009 /10-2015 /16*

## ៣.២ មូលហេតុ នៃការបោះបង់ការសិក្សា

កត្តាបុគ្គល គ្រួសារ និងសាលារៀនធ្វើឱ្យប៉ះពាល់ដល់ការបោះបង់កាសិក្សា។ កត្តាបុគ្គល ដូចជា ភេទ និងអាយុជាដើមអាចមានឥទ្ធិពលទៅលើការបោះបង់កាសិក្សា ប៉ុន្តែឪពុកម្តាយមានឥទ្ធិពលខ្លាំងជាងគេក្នុងមាគ៌ាអប់រំកូន។ ការសម្រេចចិត្តពាក់ព័ន្ធនឹងការអប់រំ ជារឿយៗ បានផ្សារភ្ជាប់ទៅនឹងកត្តាប្រវត្តិនៃសេដ្ឋកិច្ចសង្គមគ្រួសារ។ ជាក់ស្តែង អត្រាបោះបង់កាសិក្សាក្នុងចំណោមគ្រួសារក្រីក្រនៅគ្រប់កម្រិតនៃការអប់រំចំណេះទូទៅគឺខ្ពស់ជាងគ្រួសារដែលមានជីវភាពធូរធារ ដោយសារតែអ្នកក្រមិនសូវយល់ពីតម្លៃដែលបានមកពីការអប់រំ។ គេបានប្រើប្រាស់ការស្ទង់មតិសេដ្ឋកិច្ចសង្គមនៅកម្ពុជា (CSES) ដើម្បីវិភាគកត្តានៃការបោះបង់ការសិក្សា។ កម្រិតថ្នាក់ខ្ពស់បំផុតរបស់យុវជនម្នាក់ដែលបច្ចុប្បន្ននៅក្រៅសាលាអាចកំណត់បាននូវស្ថានភាពរបស់យុវជនដែលបានបោះបង់ការសិក្សាម្នាក់នោះ។

### ៣.២.១ លក្ខខណ្ឌបុគ្គល

អាយុរបស់យុវជនប៉ះពាល់ដល់បោះបង់ការសិក្សា។ នៅតំបន់ជនបទមួយចំនួន សិស្សចាប់ផ្តើមចូលរៀនយឺតពេល បើធៀបទៅនឹងអាយុរំពឹងទុកសម្រាប់ថ្នាក់នោះ។ ជារឿយៗនេះគឺដោយសារតែស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ក្រុមគ្រួសារ ដែលបានបង្ខំឱ្យពួកគេជួយធ្វើការងារផ្ទះ និងសកម្មភាពសេដ្ឋកិច្ច។ ការសិក្សាមួយដោយ Mike et al (ឆ្នាំ2008) បានរកឃើញថា ការដែលយុវជនម្នាក់មានវ័យចំណាស់ជាងមិត្តរួមថ្នាក់របស់ខ្លួននោះក៏រួមចំណែកដល់ការបោះបង់ការសិក្សាដែរ។ ក្នុងចំណោមសិស្សដែលមានអាយុពី 20 ឆ្នាំទៅ 24 ឆ្នាំ មានសិស្សចំនួន 31 ភាគរយ មិនបានបញ្ចប់ការសិក្សាបឋមភូមិ និង 31 ភាគរយ

ផ្សេងទៀតមិនបានបញ្ចប់បឋមសិក្សា។ ការរៀនត្រួតថ្នាក់ក៏រួមចំណែកដល់ការបោះបង់ការសិក្សាដែរ ព្រោះសិស្សបានក្លាយទៅជាអ្នកដែលមានអាយុចាស់ជាងមិត្តរួមថ្នាក់របស់ខ្លួន។ ក្នុងឆ្នាំសិក្សា 2014/15 អត្រាសិស្សបោះបង់ការសិក្សានៅថ្នាក់ទី 12 មានចំនួ 46 ភាគរយ និងអត្រារៀនត្រួតថ្នាក់មានចំនួន 8 ភាគរយ (យោងតាម ក្រសួងអយក. ឆ្នាំ 2015/16) ។

ភាពជាស្ត្រីក៏អាចនាំឱ្យមានការបោះបង់ការសិក្សាដែរ។ ទោះជាអាពាហ៍ពិពាហ៍វ័យក្មេងដែលមិនមែនជារឿងទូទៅនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏វាបានប៉ះពាល់ដល់ការបោះបង់ការសិក្សារបស់ស្ត្រីវ័យក្មេងផងដែរ។ ក្នុងចំណោមអ្នកបោះបង់ការសិក្សាដែលមានអាយុពី 15 ទៅ 24 ឆ្នាំ មានស្ត្រីចំនួន 26 ភាគរយ បានរៀបការរួច ឬបានលែងលះគ្នា។ ហើយក្នុងចំណោមអ្នករៀបការរួច ឬលែងលះគ្នាទាំងនោះ មានស្ត្រីចំនួន 2,5 ភាគរយ ប៉ុណ្ណោះ ដែលមានអាយុពី 15 ទៅ17 ឆ្នាំ (យោងតាម CSES 2014)។ តាមពិត អត្រាបោះបង់ការសិក្សារបស់ស្ត្រី ជារឿយៗ មានតិចតួចជាងបុរស បើទោះបីជាទូទៅបទដ្ឋានសង្គមនៅប្រទេសកម្ពុជាអនុគ្រោះដល់ការវិនិយោគក្នុងការអប់រំក្មេងប្រុសជាងក្មេងស្រីក៏ដោយ។ ដូចមានអត្រាកើនឡើងនៃក្មេងប្រុសចុះឈ្មោះចូលរៀននៅកម្រិតវិទ្យាល័យជាភស្តុតាង។

**តារាង 20 (3-2) ស្ថានភាពគ្រួសាររបស់ប្រជាជនមានអាយុពី 15 ទៅ 24 ឆ្នាំ ពីឆ្នាំ 2004-2014 (គិតជា ភាគរយ តាមប្រភេទ)**

| | ការបោះបង់សាលា | | | បច្ចុប្បន្នកំពុងរៀន | | |
|---|---|---|---|---|---|---|
| | 2004 | 2009 | 2014 | 2004 | 2009 | 2014 |
| មិនដែលរៀបការ/រស់នៅជាមួយគ្នា | 73.2 | 72.2 | 73.9 | 99.6 | 98.9 | 98.7 |
| រៀបការ | 25.4 | 26.0 | 24.1 | 0.4 | 0.7 | 1.1 |
| លែងលះគ្នា / មេម៉ាយ / បែកគ្នា | 1.4 | 1.8 | 1.9 | - | 0.4 | 0.1 |

*ប្រភព៖ CSES ឆ្នាំ2004 ឆ្នាំ2009 ឆ្នាំ2014*

ភាគច្រើន នៃអ្នកដែលបានបោះបង់ការសិក្សាទាំងនោះកំពុងធ្វើការ។ ក្នុងចំណោមអ្នកដែលបានបោះបង់កាសិក្សាដែលមានអាយុចន្លោះពី 10ទៅ24 ឆ្នាំ មាន 90 ភាគរយ កំពុងធ្វើការក្នុងឆ្នាំ 2014 ពោលគឺ កើនឡើងពី 84 ភាគរយ ក្នុងរយៈពេលដប់ឆ្នាំមុននេះ។ កាលពីឆ្នាំ 2004 ជាងពាក់កណ្ដាល នៃពួកគេបានធ្វើការនៅក្នុងវិស័យកសិកម្ម ហើយភាគរយនៃធ្វើការនៅក្នុងវិស័យកសិកម្មនេះបានធ្លាក់មកត្រឹម 37 ភាគរយ នៅឆ្នាំ 2014 ប៉ុន្តែភាគរយនៃអ្នកធ្វើការនៅក្នុងវិស័យឧស្សាហកម្មកើនឡើងដល់ 42 ភាគរយ (សូមមើល តារាង 3.3)។ ស្ត្រីត្រូវបានរកឃើញកំពុងធ្វើការនៅក្នុងវិស័យឧស្សាហកម្មច្រើនជាងបុរស ផ្ទុយមកវិញស្ត្រីដែលធ្វើការនៅក្នុងវិស័យកសិកម្មមានចំនួនតិច។ យុវជនដែលមានអាយុចន្លោះពី 10 ទៅ 15ឆ្នាំ ចំនួន 10 ភាគរយ កំពុងធ្វើការក្នុងចំណោមក្រុមមនុស្សដែលមានអាយុចន្លោះពី 10 ទៅ 24 ឆ្នាំ ។ ការងារខ្លះរបស់ក្រុមនេះត្រូវបានគេចាត់ទុកថា ជាពលកម្មកុមារ។ ក្នុងឆ្នាំ 2014 មានកុមារដែលមានអាយុពី 10 ទៅ 15 ឆ្នាំ ចំនួន 81 ភាគរយ កំពុងធ្វើការ គឺយ៉ាងហោចណាស់ក៏ធ្វើការមួយម៉ោងក្នុងមួយអាទិត្យដែរ ដែលជាការកើនឡើងពី 76 ភាគរយ ក្នុងឆ្នាំ 2004 ។ ជាងពាក់កណ្ដាលនៃក្រុមនេះ (58 ភាគរយ) កំពុងធ្វើការក្នុងវិស័យកសិកម្ម ដែលជាការថយចុះពីប្រហែល 70 ភាគរយ ក្នុងឆ្នាំ 2004 ។ និន្នាការវិជ្ជមានគឺថា ចំនួនកុមារដែល

កំពុងធ្វើការផងរៀនផងបានធ្លាក់ចុះពី 40 ភាគរយ នៅក្នុងឆ្នាំ 2009 មកត្រឹម 13 ភាគរយ នៅក្នុងឆ្នាំ 2014 ។

**តារាង 21 (3-3) ការបែងចែកចំនួនប្រជាជនដែលមានអាយុពី 10 ទៅ 24 ឆ្នាំ តាមវិស័យការងារ ស្ថានភាពភេទ និងការចូលសាលារៀន ឆ្នាំ 2004 ឆ្នាំ 2009 ឆ្នាំ 2014 (គិតជា ភាគរយ)**

| | 2004 | | 2009 | | 2014 | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| | ការបោះបង់សាលា | | | | | |
| កសិកម្ម | 62.2 | 50.8 | 62.1 | 50.6 | 41.8 | 32.3 |
| ឧស្សាហកម្ម | 17.3 | 26.3 | 21.7 | 29.8 | 36.9 | 47.7 |
| សេវាកម្ម | 20.5 | 22.8 | 16.1 | 19.6 | 21.3 | 19.9 |
| | បច្ចុប្បន្នកំពុងរៀន | | | | | |
| កសិកម្ម | 79.8 | 72.7 | 83.4 | 75.4 | 73.3 | 63.3 |
| ឧស្សាហកម្ម | 5.5 | 7.4 | 6.8 | 9.6 | 5.2 | 6.6 |
| សេវាកម្ម | 14.7 | 20.0 | 9.8 | 15.0 | 21.5 | 30.1 |

*ប្រភព៖ CSES ឆ្នាំ2004 ឆ្នាំ2009 ឆ្នាំ2014*

យុវជននៅតំបន់វាលទំនាប តំបន់ឆ្នេរសមុទ្រ និងតំបន់ភ្នំ/ខ្ពង់រាប បានចូលរួមក្នុងវិស័យឧស្សាហកម្មច្រើនជាងវិស័យឯទៀត (សូមមើល តារាង 3.4) ។ 10 ឆ្នាំមុន ពួកគេកំពុងធ្វើការនៅក្នុងវិស័យកសិកម្ម ប៉ុន្តែនៅឆ្នាំ 2014 ភាគច្រើនបានផ្លាស់ប្តូរទៅធ្វើការនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មវិញ ។ មានតែនៅក្នុងតំបន់ទន្លេសាបទេដែលភាគច្រើននៃយុវជននៅតែកំពុងធ្វើការក្នុងវិស័យកសិកម្ម ទោះជាភាគរយនៃអ្នកធ្វើការក្នុងវិស័យនេះបានថយចុះក៏ដោយ។

ស្ថានភាពការងាររបស់យុវជនដែលបោះបង់ចោលការសិក្សាបានផ្លាស់ប្តូរពីការងារផ្ទាល់ខ្លួន និងការងារគ្រួសារគ្មានប្រាក់ខែ ទៅជាការងារមានប្រាក់ខែវិញ បន្ទាប់ពីវិស័យឧស្សាហកម្មមានការរីកចម្រើន។ ជាទូទៅ កុមាររៀនផងធ្វើការផងត្រូវស្ថិតនៅក្នុងប្រភេទការងារផ្ទាល់ខ្លួន ឬការងារគ្រួសារគ្មានប្រាក់ខែ ។ អត្រា នៃយុវជនដែលបោះបង់ការសិក្សាដែលកំពុងធ្វើការងារក្នុងប្រភេទការងារងាយរងគ្រោះនៅតែមានចំនួនច្រើនជាង 60 ភាគរយ នៅចន្លោះឆ្នាំ 2004 និងឆ្នាំ 2009 ។ ចំនួននេះបានធ្លាក់ចុះត្រឹមតែ 38 ភាគរយ ក្នុងឆ្នាំ 2014 ខណៈដែលអត្រា នៃការងារប្រាក់ខែសមរម្យបានកើនឡើងដល់ 62 ភាគរយ (សូមមើលតារាង 3.5) ។

**តារាង 22 (3-4) ការបែងចែកអត្រាបោះបង់ការសិក្សា និងសិស្សដែលមានអាយុពី 10 ទៅ 24 ឆ្នាំ តាមវិស័យ ការងារ តាមតំបន់ ឆ្នាំ 2004 និងឆ្នាំ 2014 (ភាគរយ នៃចំនួនអ្នកធ្វើការសរុបដែលមានអាយុ 10 ទៅ 24ឆ្នាំ)**

| | 2004 | | | 2014 | | |
|---|---|---|---|---|---|---|
| | កសិកម្ម | ឧស្សាហកម្ម | សេវាកម្ម | កសិកម្ម | ឧស្សាហកម្ម | សេវាកម្ម |
| | ការបោះបង់ការសិក្សា | | | | | |
| ភ្នំពេញ | 2.4 | 40.4 | 57.2 | 0.9 | 61.7 | 37.4 |
| វាលទំនាប | 58.3 | 25.1 | 16.6 | 34.5 | 47.9 | 17.6 |
| ទន្លេសាប | 63.4 | 15.5 | 21.1 | 50.5 | 27.8 | 21.7 |

| | | | | | | |
|---|---|---|---|---|---|---|
| តំបន់ឆ្នេរ | 55.7 | 16.2 | 28.1 | 37.8 | 43.2 | 19.1 |
| ខ្ពង់រាបនិងភ្នំ | 63.9 | 21.3 | 14.7 | 36.5 | 48.2 | 15.3 |
| | បច្ចុប្បន្នកំពុងរៀន | | | | | |
| ភ្នំពេញ | 5.3 | 14.6 | 80.1 | 3.4 | 3.4 | 93.1 |
| វាលទំនាប | 81.7 | 6.4 | 11.9 | 74.1 | 8.2 | 17.7 |
| ទន្លេសាប | 78.0 | 5.4 | 16.6 | 73.4 | 3.9 | 22.7 |
| តំបន់ឆ្នេរ | 74.9 | 4.6 | 20.5 | 87.7 | 4.9 | 7.4 |
| ខ្ពង់រាបនិងភ្នំ | 84.4 | 6.2 | 9.4 | 74.9 | 5.8 | 19.3 |

*ប្រភព :NIS (2005) ការស្ទង់មតិសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ (CSES) ឆ្នាំ 2004 ។*

*NIS (2010) CSES ឆ្នាំ2009 ។ NIS (2015) CSES ឆ្នាំ 2014 ។*

**តារាង 23 (3-5) ការចែកស្ថានភាពការងាររបស់ប្រជាជនចាប់ពីអាយុ 10 ទៅ 24 ឆ្នាំ 2004 និងឆ្នាំ 2014 (គិតជា %)**

| | បោះបង់ការសិក្សា | | | កំពុងសិក្សា | | |
|---|---|---|---|---|---|---|
| | 2004 | 2009 | 2014 | 2004 | 2009 | 2014 |
| កម្មករមានប្រាក់ខែ | | 37.9 | 62.1 | 4.6 | 5.1 | 18.2 |
| កម្មករគ្មានប្រាក់ខែ/ការងារខ្លួនឯង | 68.3 | 61.6 | 37.7 | 94.1 | 94.7 | 81.7 |
| ផ្សេងៗ | 0.8 | 0.5 | 0.3 | 1.3 | 0.2 | 0.1 |
| សរុប | 100 | 100 | 100 | 100 | 100 | 100 |

*ប្រភព :NIS (2005) ការស្ទង់មតិសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ (CSES) ឆ្នាំ 2004 ។*

*NIS (2010) CSES ឆ្នាំ2009 ។ NIS (2015) CSES ឆ្នាំ 2014 ។*

ប្រាក់ខែបុគ្គលិកដែលជាយុវជនក៏បានកើនឡើងដែរនៅក្នុងឆ្នាំ 2014 បើធៀបនឹងឆ្នាំ2009 ។ កម្មករយុវជនដែលមានអាយុពី 10 ទៅ 24 ឆ្នាំ មានប្រាក់ខែមធ្យមចំនួន 355 992 រៀល ក្នុងមួយខែ នៅក្នុងឆ្នាំ 2014 គឺ 68 ភាគរយ ខ្ពស់ជាងឆ្នាំ 2009 ចំណែកកម្មករយុវជនដែលធ្វើការក្នុងប្រភេទការងារងាយរងគ្រោះទទួលបានប្រាក់ខែមធ្យមចំនួន 164039 រៀល ក្នុងមួយខែ ដែលកើនឡើងចំនួន 49 ភាគរយ។ យុវជនដែលបោះបង់ការសិក្សាទទួលបានប្រាក់ខែខ្ពស់ជាងយុវជនដែលធ្វើការងារផងរៀនផងចំនួន 5 ភាគរយ ហើយយុវជនដែលបោះបង់ការសិក្សាអាចបានធ្វើការយូរជាងយុវជនដែលធ្វើការងារផងរៀនផងចំនួន 18 ភាគរយ ពោលគឺ 53 ម៉ោងក្នុងមួយអាទិត្យ សម្រាប់ការងារគោល ។ ប្រាក់ខែ និងម៉ោងធ្វើការរបស់យុវជនដែលបោះបង់ការសិក្សានៅក្នុងឆ្នាំ 2014 គឺស្រដៀងគ្នាទៅនឹងអ្នកដែលបោះបង់ការសិក្សានៅឆ្នាំ2009។ ប្រាក់បៀវត្សរបស់យុវជនដែលបោះបង់ការសិក្សាហាក់ដូចជាត្រូវបានគេកិបកេង សូម្បីតែនៅក្នុងការងារផ្លូវការក៏ដោយ។ នៅក្នុងឆ្នាំ 2014 យុវជនចំនួន 63 ភាគរយ ដែលមានអាយុចន្លោះពី 10 ទៅ 24 ឆ្នាំ ដែលបានបោះបង់ការសិក្សា (ដែលក្នុងនោះមានស្ត្រី 66 ភាគរយ និងបុរសចំនួន 60 ភាគរយ) កំពុងធ្វើការ និងទទួលបានប្រាក់ខែទាបជាងប្រាក់ខែជាមធ្យម ។

### ៣.២.២ ស្ថានភាពសេដ្ឋកិច្ចគ្រួសារ

លក្ខខណ្ឌគ្រួសារមានឥទ្ធិពលយ៉ាងខ្លាំងលើការអប់រំរបស់កុមារ។ ទ្រព្យសម្បត្តិរបស់គ្រួសារ កម្រិតអប់រំរបស់ឪពុកម្តាយ មុខរបររបស់ឪពុកម្តាយ និងការយល់ដឹងអំពីតម្លៃនៃការអប់រំរបស់ឪពុកម្តាយ គឺកត្តាប៉ះពាល់ដល់លទ្ធផលនៃការអប់រំរបស់កូន ។ ទ្រព្យសម្បត្តិរបស់គ្រួសារគឺ ប្រហែលជាកត្តាដែលមានឥទ្ធិពលបំផុតពាក់ព័ន្ធនឹងការបោះបង់ការសិក្សា។ ទោះបីការអប់រំនៅកម្រិតមធ្យមសិក្សាក្នុងប្រទេសកម្ពុជាមិនគិតថ្លៃក៏ដោយ ក៏ការចំណាយពាក់ព័ន្ធនឹងការទៅសាលារៀនដូចជា ការចំណាយលើឯកសណ្ឋាន អាហារ សៀវភៅ និងចំណាយផ្សេងៗទៀត បានបន្ថែមបន្ទុកចំណាយរបស់គ្រួសារ។ សម្រាប់កុមារក្រីក្រដែលឪពុកម្តាយរបស់ពួកគេមិនអាចមានលទ្ធភាពចំណាយដូចខាងលើផ្ទាល់ ធ្វើឱ្យពួកគេគិតថា ពួកគេត្រូវចំណាយច្រើនសម្រាប់ការអប់រំ (យោយតាម Fall & Roberts 2012; Huisman & Smiths 2009; Mingat 2007; Ingrum n.d.) ។

ទ្រព្យសម្បត្តិរបស់គ្រួសារប៉ះពាល់យ៉ាងសំខាន់លើការអប់រំរបស់កូនចៅ។ នៅបឋមសិក្សា ទ្រព្យសម្បត្តិរបស់គ្រួសារមិនប៉ះពាល់ខ្លាំងលើការបោះបង់ការសិក្សានោះទេ។ ប៉ុន្តែនៅពេលដែលកុមារធំឡើង និងត្រូវឡើងថ្នាក់បន្តបន្ទាប់ យុវជនដែលមកពីគ្រួសារក្រីក្របំផុតនោះទំនងជាចង់បោះបង់សាលាទៅធ្វើការច្រើនជាងនៅរៀន (សូមមើល តារាង 3.6) ។ កត្តានេះត្រូវបានជំរុញដោយការយល់ឃើញថា តម្លៃឱកាសនៃការធ្វើការ ប្រសើជាងនៅរៀន។ គេបានរកឃើញថា យុវជនមានចំនួនច្រើនជាងមួយភាគបួន (ស្មើនឹង 28 ភាគរយ) បានរកការងារធ្វើភ្លាមបន្ទាប់ពីការចាកចេញពីសាលាគឺ មុនពេលពួកគេមានអាយុ 15 ឆ្នាំ (យោងតាម Kanol, Khemarin និង Elder ឆ្នាំ2013) ។

**តារាង 24 (3-6) អត្រាបោះបង់ការសិក្សាតាមស្ថានភាពទ្រព្យធន ឆ្នាំ 2004-14**

| | | 2004 | | 2009 | | 2014 | |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| សិក្សាបឋម | 1 (ក្រីក្របំផុត) | 0.68 | 1.08 | 2.07 | 3.06 | 2.88 | 1.09 |
| | 2 | 1.10 | 0.97 | 1.10 | 1.03 | 1.34 | 2.00 |
| | 3 | 0.61 | 1.18 | 0.84 | 0.92 | 0.40 | 0.66 |
| | 4 | 1.02 | 0.96 | 1.04 | 0.95 | 0.24 | 0.45 |
| | 5 (មានបំផុត) | 0.52 | 0.29 | 0.85 | 0.68 | 0.00 | 0.30 |
| អនុវិទ្យាល័យ | 1 (ក្រីក្របំផុត) | 7.14 | 18.18 | 20.97 | 19.10 | 6.05 | 13.29 |
| | 2 | 3.90 | 15.28 | 19.80 | 10.28 | 7.98 | 8.90 |
| | 3 | 5.26 | 9.62 | 9.30 | 11.38 | 7.49 | 5.49 |
| | 4 | 3.50 | 5.19 | 7.43 | 13.38 | 2.27 | 5.35 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **5 (មានបំផុត)** | 2.53 | 2.91 | 3.26 | 8.33 | 2.52 | 3.47 |
| **វិទ្យាល័យ** | **1 (ក្រីក្របំផុត)** | 50.00 | 33.33 | 18.18 | 75.00 | 18.57 | 21.52 |
| | **2** | 42.86 | 35.29 | 27.91 | 48.57 | 16.67 | 20.97 |
| | **3** | 17.50 | 27.59 | 18.31 | 30.51 | 10.20 | 21.35 |
| | **4** | 9.09 | 28.95 | 12.73 | 32.00 | 5.61 | 12.79 |
| | **5 (មានបំផុត)** | 12.50 | 7.64 | 3.18 | 9.41 | 5.19 | 10.57 |

*ប្រភព៖ CSES ឆ្នាំ2004 ឆ្នាំ2009 ឆ្នាំ2014*

តាមពិត ការចំណាយពាក់ព័ន្ធនឹងការទៅសាលារៀនគឺជាកត្តាដែលជំរុញឱ្យមានការបោះបង់ការសិក្សានៅបឋមវ័យ។ ភាគច្រើននៃករណីមិនចង់ទៅរៀនបន្តបានកើតឡើងនៅក្នុងចំណោមកុមារមកពីគ្រួសារក្រីក្រ គឺដោយសារតែពួកគេត្រូវជួយឪពុកម្តាយធ្វើកិច្ចការផ្ទះ ឬជួយបំពេញសេដ្ឋកិច្ចមូលដ្ឋានរបស់គ្រួសារ។ ជាពិសេសនៅក្នុងតំបន់ជនបទដែលមានភាពក្រីក្រខ្លាំង កុមារត្រូវជួយឪពុកម្តាយរបស់ពួកគេធ្វើកិច្ចការដូចជា សម្អាតផ្ទះ រែកទឹក និងពុសអុស ដើម្បីបង្កើនប្រាក់ចំណូលតាមរយៈធ្វើការនៅក្នុងវិស័យកសិកម្ម ឬឧស្សាហកម្មនៅក្នុងតំបន់។ ដោយសារយុវជនចូលរួមក្នុងសកម្មភាពនៅផ្ទះ ពួកគេអស់កម្លាំង និងអវត្តមានពីសាលាជាញឹកញាប់ ឬបាត់បង់អារម្មណ៍ទៅរៀន។ ហើយនៅទីបំផុត កត្តាទាំងនេះបានជំរុញឱ្យពួកគេចាកចេញពីសាលា (យោងតាម Jonker 2006, Kirazoglu 2009) ។

ការចំណាយខ្ពស់លើការសិក្សាដោយសារតែចំណាយក្រៅផ្លូវការ គឺជាកត្តាមួយផ្សេងទៀតដែលជំរុញឱ្យមានការបោះបង់កាសិក្សា (យោងតាម Tan 2007; USAID n.d.)។ ចំណាយបន្ថែមក្រៅផ្លូវការក៏បានបន្ថែមបន្ទុករបស់គ្រួសារក្រីក្រផងដែរ។ ជាទូទៅ ដោយសារតែប្រាក់ខែគ្រូបង្រៀនតិច គ្រូនៅបឋមសិក្សា និងមធ្យមសិក្សាជាច្រើនបានយកថ្លៃឈ្នួលបន្ថែមតាមរយៈការបង្រៀនគួរក្នុងអំឡុងពេលអាហារថ្ងៃត្រង់ ពេលល្ងាច ឬចុងសប្តាហ៍ ឬដោយការលក់មេរៀនយកចំណេញច្រើន។ ការចំណាយបន្ថែមនេះ ទោះបីជាមិនមែនជាការកំហិតក៏ដោយ ក៏បានដាក់សម្ពាធលើសិស្សក្រីក្រផងដែរ ព្រោះថា ប្រសិនបើពួកគេមិនទិញមេរៀន ឬមិនចូលរៀនគួរទេ ពួកគេនឹងត្រូវទុកមួយឡែក ឬរងភាពអយុត្តិធម៌។ បាតុភូតនេះគឺដោយសារតែប្រាក់ខែលើកទឹកចិត្តគ្រូនៅទាប (មានលម្អិតនៅចំណុច *បរិស្ថានសាលារៀន*) ។ ការស្ទង់មតិការស្តីពីការផ្លាស់ប្តូរពីសាលាទៅការងារបានបញ្ជាក់ថា ឧបសគ្គផ្នែកសេដ្ឋកិច្ច គឺជាមូលហេតុញឹកញាប់ជាងគេបំផុតដែលជំរុញឱ្យមានការបោះបង់ការសិក្សា (យោងតាម Kanol, Khemarin and Elder ឆ្នាំ2013)។

សម្រាប់ស្ត្រី តួនាទីយែនឌ័រពីបុរាណបានរឹតបន្តឹងឱកាសទទួលបានការអប់រំរបស់ពួកគេ។ នៅតំបន់ជនបទ ស្ត្រីត្រូវបានគេរំពឹងថា ជាអ្នកទទួលបន្ទុកភារកិច្ច និងការងារផ្ទះផ្សេងៗ ហេតុនេះហើយ អ្នកដែលយល់ថាស្ត្រីមានតម្រូវការការអប់រំកម្រិតណានោះ មានតិចណាស់។ លើសពីនេះ ដោយសារតែគេរំពឹងថា ស្ត្រីនឹងត្រូវបានមើលថែទាំដោយអនាគតប្តីខ្លួននោះ គេក៏យល់ថា ការចំណាយទុនសម្រាប់ការអប់រំស្ត្រី មិនសូវមានប្រយោជន៍សម្រាប់គ្រួសារទេ។ ជាលទ្ធផល អត្រាចុះឈ្មោះចូលរៀនរបស់ស្ត្រីធៀបនឹងបុរសបានធ្លាក់ចុះជាលំដាប់ចាប់តាំងពីមធ្យមសិក្សាឡើងទៅ ។ សិស្សចង់ឈប់រៀនទៅធ្វើការភ្លាមនៅពេលដែលពួកគេឈានដល់អាយុធ្វើការដំបូង គឺអាយុ 15 ឆ្នាំ ។ សិស្សភាគច្រើនចង់ចាប់ផ្តើមធ្វើការក្មេងជាងនេះទៀត រហូតលួចក្លែងបន្លំអត្តសញ្ញាណប័ណ្ណ ដើម្បីទទួលបានការងារនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ ដែលកំពុងកើនឡើង។ ការងារនៅក្នុងរោងចក្រកាត់ដេរត្រូវការជំនាញទាប ដូច្នេះវាបានទាក់ទាញយុវតីយ៉ាងខ្លាំង។ ប្រហែល 85 ទៅ 90 ភាគរយ នៃកម្មកររោងចក្រកាត់ដេរគឺជាស្ត្រីដែលមានការអប់រំតិចតួច ឬពុំបានទទួលការអប់រំតែម្តង (យោងតាម Derks ឆ្នាំ2008) ។

**រូបភាព 22 (3-3) មូលហេតុនៃការបោះបង់ការសិក្សា ក្នុងឆ្នាំ 2014**




*ប្រភព៖ ការស្ទង់មតិផ្លាស់ប្តូរពីសាលាទៅការងារនៅកម្ពុជា ឆ្នាំ 2014*

កម្រិតនៃការអប់រំរបស់ឪពុកម្តាយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសិក្សារបស់កូន។ ឪពុកម្តាយដែលចេះដឹងទំនងជាអាចមានការងារប្រសើរមួយ និងអាចធានាស្ថិរភាពហិរញ្ញវត្ថុគ្រួសារបាន។ នេះអាចកាត់បន្ថយអត្រានៃការបញ្ឈប់កូនពីសាលាបានកាន់តែច្រើន (យោងតាម Polesel et al, 2011)។ ឪពុកម្តាយដែលមានការចេះដឹងទំនងជាឱ្យតម្លៃអប់រំ និងលើកទឹកចិត្តកូនឱ្យទទួលបានការអប់រំយ៉ាងតិចបំផុតក៏អាចប្រហាក់ប្រហែលខ្លួនដែរ (យោងតាម Breen and Goldthorpe 1997; Osagi 2010)។ ស្ត្រីជាម្តាយដែលមានការអប់រំត្រឹមកម្រិតបឋមយ៉ាងហោចណាស់ក៏អាចជួយកូនរបស់ខ្លួនឱ្យធ្វើលំហាត់ និងត្រួតពិនិត្យការរីកចម្រើននៃការសិក្សារបស់កូន និងជាគំរូមួយសម្រាប់ឱ្យកូនស្រីបន្តការសិក្សាដែរ។ ពួកគេអាចលើកទឹកចិត្តកូន ជាពិសេសកូនស្រីឱ្យនៅរៀនបានយូរអង្វែង (យោងតាម Mike et al., 2008; Huisman et al., 2010)។

យោងតាមការវិភាគដោយការសិក្សាថ្មីមួយបានបង្ហាញថា ប្រូបាប៊ីលីតេនៃកុមារដែលបោះបង់ការសិក្សាបានថយចុះ ដោយសារតែកម្រិតនៃការអប់រំរបស់ឪពុកម្តាយកើនឡើង ពោលគឺ ឪពុកម្តាយមួយចំនួនទទួលបានការអប់រំដល់កម្រិតមធ្យមសិក្សា ឬខ្ពស់ជាងនេះ ។ កុមារដែលមានឪពុកម្តាយរៀនបានត្រឹមកម្រិតបឋម ឬតិចជាងនេះហាក់ដូចជាបោះបង់ការសិក្សាច្រើន។ ក្នុងឆ្នាំ 2014 ច្រើនជាងពាក់កណ្តាលនៃកុមារដែលបានបោះបង់ការសិក្សា គឺជាកុមារមកពីគ្រួសារកសិករ ចំណែក 23 ភាគរយ ទៀត គឺជាកុមារមកពីគ្រួសារដែលមានមុខរបរផ្នែកសេវាកម្ម។ ភាគរយ នៃកុមារដែលបានបោះបង់ការសិក្សាបែបនេះនៅតែបន្តកើតមានក្នុងចន្លោះឆ្នាំ 2004 និងឆ្នាំ 2014 (សូមមើល តារាង 3.7)។

លទ្ធផលរំពឹងទុកដែលបានមកពីការវិនិយោគនៅក្នុងវិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការបន្តឱ្យកូនចៅទៅរៀន។ ទៅរៀនគួរតែទទួលបានផលមកវិញជាការងារល្អមួយ និងមានប្រាក់ខែប្រសើរផងដែរ ទោះជាយ៉ាងណា ឪពុកម្តាយ និងយុវជនជាច្រើនមិនបានយល់ថា ការអប់រំមានតម្លៃគួរវិនិយោគនោះទេ (យោងតាម Tan ឆ្នាំ2007)។ សូម្បីតែការសិក្សានៅសាកលវិទ្យាល័យក៏ត្រូវគេយល់ថា

ជាការខ្ជះខ្ជាយពេលវេលាដែរដោយសារអត្រាគ្មានការងារនៃនិស្សិតដែលបានបញ្ចប់ការសិក្សាមានកម្រិតខ្ពស់។ នៅក្នុងវិស័យសាធារណៈវិញ ការឡើងឋានៈដោយគុណវុឌ្ឍិគឺពិបាកអនុវត្តបន្តិច ព្រោះថា អតីតភាពការងារ ទ្រព្យសម្បត្តិ និងជំហរសង្គមរបស់បុគ្គលម្នាក់សំខាន់ជាងគុណវុឌ្ឍិ។ បើបុគ្គលម្នាក់គ្មានស្នាដៃ និងឥទ្ធិពលនៅក្នុងសង្គមទេគឺពិបាកនឹងបញ្ចុះបញ្ចូលអ្នកដទៃឱ្យវិនិយោគក្នុងវិស័យអប់រំណាស់។

**តារាង 25 (3-7) លក្ខខណ្ឌគ្រួសារ នៃយុវជនដែលមានអាយុចន្លោះពី 6 ឆ្នាំ ទៅ 24 ឆ្នាំ នៅក្នុងឆ្នាំ 2004, 2009 និង 2014**

| | ការបោះបង់ការសិក្សា | | | បច្ចុប្បន្នកំពុងរៀន | | |
|---|---|---|---|---|---|---|
| | **2004** | **2009** | **2014** | **2004** | **2009** | **2014** |
| ទំហំគ្រួសារ (មធ្យម) | 6.0 | 5.8 | 5.5 | 6.2 | 5.9 | 5.4 |
| **ការអប់រំរបស់មេគ្រួសារ (ភាគរយ)** | | | | | | |
| ការអប់រំតិចជាងបឋមសិក្សា | 24.1 | 23.4 | 24.2 | 21.6 | 19.2 | 17.6 |
| ការអប់រំត្រឹមបឋមសិក្សា | 50.4 | 52.0 | 49.1 | 44.2 | 44.9 | 40.7 |
| ការអប់រំដល់មធ្យមសិក្សា | 21.6 | 22.5 | 24.0 | 29.0 | 30.4 | 31.0 |
| ការអប់រំដល់ឧត្តមសិក្សា ឬមិនចាត់ថ្នាក់ | 3.9 | 2.1 | 2.7 | 5.2 | 5.6 | 10.7 |
| ការអប់រំរបស់មេគ្រួសារ (ឆ្នាំមធ្យម) | 5.6 | 4.7 | 4.6 | 5.9 | 5.6 | 6.3 |
| **មុខរបររបស់មេគ្រួសារ (ភាគរយ)** | | | | | | |
| កសិកម្មនេសាទនិងព្រៃឈើ | 52.5 | 57.0 | 52.5 | 48.7 | 51.8 | 40.7 |
| ឧស្សាហកម្ម | 9.5 | 12.0 | 13.3 | 10.0 | 11.7 | 15.3 |
| សេវាកម្ម | 24.6 | 20.8 | 22.5 | 32.5 | 29.9 | 35.7 |
| គ្មានការងារ | 13.5 | 10.3 | 11.7 | 8.9 | 6.6 | 8.3 |
| **ស្ថានភាពការងាររបស់មេគ្រួសារ (ភាគរយ)** | | | | | | |
| ស៊ីឈ្នួល | 17.0 | 20.4 | 26.0 | 23.4 | 24.3 | 34.0 |
| ការងារខ្លួនឯង | 65.7 | 68.2 | 61.8 | 64.3 | 67.9 | 57.0 |
| កម្មករក្រុមគ្រួសារគ្មានប្រាក់ខែ | 2.9 | 0.7 | 0.3 | 2.5 | 0.7 | 0.3 |
| ផ្សេងៗ ក្រីក្របំផុត | 14.4 | 10.7 | 11.9 | 9.8 | 7.1 | 8.6 |
| **ស្ថានភាពការប្រើប្រាស់ក្នុងគ្រួសារ (ភាគរយ)** | | | | | | |
| **1st (ក្របំផុត)** | 18.1 | 21.6 | 25.8 | 19.2 | 19.7 | 19.8 |
| **2nd** | 21.2 | 22.8 | 24.4 | 20.5 | 20.3 | 19.5 |
| **3rd** | 21.3 | 21.5 | 21.9 | 19.9 | 19.9 | 20.3 |
| **4th** | 22.1 | 19.9 | 16.7 | 19.2 | 19.5 | 20.3 |
| **5th** | 17.4 | 14.2 | 11.3 | 21.1 | 20.6 | 20.1 |

*ប្រភព៖ CSES ឆ្នាំ 2004 ឆ្នាំ 2009 ឆ្នាំ 2014*

### ៣.២.៣ បរិស្ថានសាលារៀន

បរិយាកាសនៃការសិក្សានៅក្នុងសាលារៀនគឺជាកត្តាលើកទឹកចិត្តយ៉ាងសំខាន់សម្រាប់ការ

សិក្សារៀនសូត្រ។ ទំហំថ្នាក់ និងសមាមាត្រគ្រូនិងសិស្សគឺជាទិដ្ឋភាពនៃគុណភាពអប់រំដែលត្រូវបានគេលើកយកមកពិភាក្សាយ៉ាងច្រើន។ ជាញឹកញាប់ ថ្នាក់ទំហំតូចត្រូវបានគេយល់ថា ជាបរិស្ថានបង្រៀនយ៉ាងល្អប្រសើរព្រោះគ្រូបង្រៀនអាចផ្តោតការយកចិត្តទុកដាក់បន្ថែមលើតម្រូវការរបស់សិស្សម្នាក់ៗ និងចំណេញពេលសម្រាប់ដោះស្រាយបញ្ហា។ ខណៈដែលមានភស្តុតាងមួយចំនួនថា ទំហំថ្នាក់តូចអាចផ្តល់អត្ថប្រយោជន៍ដល់ក្រុមសិស្សមួយចំនួនដូចជា សិស្សដែលធ្លាប់ជួបការលំបាកក្នុងការសិក្សាក៏ដោយ (យោងតាម Krueger ឆ្នាំ2002)។ សរុបមក ភស្តុតាងដែលថា ទំហំថ្នាក់ប៉ះពាល់ទៅលើសកម្មភាពសិស្សមានតិចណាស់ ប៉ុន្តែមានភស្តុតាងជាច្រើនដែលគាំទ្រដល់ទំនាក់ទំនងវិជ្ជមានរវាងទំហំថ្នាក់តូច បរិស្ថានថ្នាក់ លក្ខខណ្ឌការងារ និងលទ្ធផលបង្រៀនរបស់គ្រូ ដូចជា អាចឱ្យមានភាពបត់បែន សកម្មភាពច្នៃប្រឌិតនៅក្នុងថ្នាក់រៀនច្រើនជាងមុន ការលើកកម្ពស់ក្រមសីលធម៌គ្រូបង្រៀន និងមនសិការវិជ្ជាជីវៈ (យោងតាម Hattie, 2009; OECD, 2009)។

ដោយសារថ្នាក់រៀននៅកម្ពុជាមានសិស្សច្រើនពេក និងការខ្វះខាតការយកចិត្តទុកដាក់ពីគ្រូបង្រៀនផងនោះ វាបានបង្កឱ្យមានផលប៉ះពាល់អវិជ្ជមាន និងអវត្តមានរបស់សិស្ស។ តាមទិន្នន័យរដ្ឋបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំសិក្សា 2015/16 បានឱ្យដឹងថា សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យសរុបមានចំនួន 9 232 ខ្នង ដែលជាការកើនឡើងពី 8363 ខ្នង ក្នុងពេល 5ឆ្នាំ (សូមមើល តារាង 3.8) ។ ជាមធ្យម សាលាមួយខ្នងមានចំនួន 7,4 បន្ទប់ សម្រាប់សិស្សចំនួន 240,7 នាក់ និងគ្រូបង្រៀន 7,2 នាក់។ ថ្នាក់រៀននៅបឋមសិក្សាមិនសូវមានសិស្សច្រើនដូចកម្រិតខ្ពស់ទេ។ សមាមាត្រសិស្ស និងថ្នាក់រៀនគឺ ថ្នាក់រៀនមួយមានសិស្សចំនួន 48 នាក់ នៅកម្រិតបឋម និង 49 នាក់ នៅកម្រិតមធ្យម។ សមាមាត្រសិស្សនិងគ្រូនៅកម្រិតបឋមគឺ គ្រូម្នាក់បង្រៀនសិស្សចំនួន 45 នាក់ ក្នុងមួយថ្នាក់។ នៅអនុវិទ្យាល័យ គ្រូម្នាក់បង្រៀនសិស្សចំនួន 20 នាក់ ក្នុងមួយថ្នាក់ និង 21 នាក់ ក្នុងមួយថ្នាក់ នៅវិទ្យាល័យ។ តាមការប្រៀបធៀប ប្រទេសសមាជិកមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD ទំហំថ្នាក់ជាមធ្យមនៅអនុវិទ្យាល័យគឺ 23 នាក់ ក្នុងមួយថ្នាក់ ហើយសមាមាត្រគ្រូនិងសិស្សជាមធ្យមនៅបឋមសិក្សាគឺ 16 នាក់ ក្នុងមួយថ្នាក់ និងនៅមធ្យមសិក្សាគឺ 14 នាក់ ក្នុងមួយថ្នាក់ (យោងតាម OECD ឆ្នាំ 2011)។

**តារាង 26 (3-8) សាលារៀន ថ្នាក់រៀន និងគ្រូបង្រៀន តាមកម្រិត និងតាមឆ្នាំសិក្សា 2010/11-2015/16**

| | **2010/11** | | | | **2015/16** | | | |
|---|---|---|---|---|---|---|---|---|
| | មត្តេយ្យ | បឋម | អនុវិទ្យាល័យ | វិទ្យាល័យ | មត្តេយ្យ | បឋម | អនុវិទ្យាល័យ | វិទ្យាល័យ |
| ចំនួនសាលា | 2 092 | 6 767 | 1 189 | 407 | 3 706 | 7 085 | 1 684 | 4 63 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំនួនថ្នាក់ | 3 343 | 5 697 | 12 504 | 6 786 | 5 974 | 60 224 | 12 590 | 6 020 |
| ចំនួនសិស្ស | 103 315 | 2 191 192 | 560 868 | 334 734 | 173 893 | 2 010 673 | 558 621 | 266 449 |
| គ្រូបង្រៀន | 3 711 | 56 339 | 30 012 | 11 686 | 4 537 | 44 844 | 28 354 | 12 570 |

***ប្រភព៖*** *អយក. 2010/11, 2015/16*

តំបន់លំនៅដ្ឋានក៏ជាបញ្ហាសម្រាប់ការសិក្សាដែរ។ អត្រាបោះបង់ការសិក្សាមានភាពខុសគ្នាខ្លាំងរវាងតំបន់រាជធានី និងតំបន់មិនមែនរាជធានី ជាពិសេសពេលថ្នាក់កាន់តែខ្ពស់ឡើង (សូមមើល តារាង 3.9)។ នៅរាជធានីភ្នំពេញ ថ្នាក់រៀននៅបឋមសិក្សា និងមធ្យមសិក្សាមានសិស្សច្រើនបំផុត ខណៈដែលនៅតំបន់ឆ្នេរ ថ្នាក់រៀនមានសិស្សតិចបំផុត។ នៅតំបន់ណាដែលមានរោងចក្រឧស្សាហកម្មច្រើន សិស្សទំនងជាឆាប់បោះបង់ការសិក្សាទៅធ្វើការងារជំនាញទាប។ រោងចក្រកាត់ដេរ និងរោងចក្រស្បែកជើងស្រូបយកសិស្សវ័យក្មេងយ៉ាងច្រើន ប៉ុន្តែក៏នៅមានឧស្សាហកម្មផ្សេងទៀតដែរដែលត្រូវការកម្មករជំនាញទាប រួមមាន សំណង់ និងកសិឧស្សាហកម្ម។ នាយកវិទ្យាល័យម្នាក់នៅខេត្តស្វាយរៀងដែលជាខេត្តមានតំបន់សេដ្ឋកិច្ចពិសេស និងរោងចក្រជាច្រើននោះ បានសម្តែងការព្រួយបារម្ភរបស់លោកអំពីអត្រាបោះបង់ការសិក្សាខ្ពស់ក្នុងចំណោមសិស្សរបស់គាត់ដែលបានទៅធ្វើការនៅរោងចក្រនៅក្បែរនោះ។ នៅខេត្តដែលលេចធ្លោខាងវិស័យកសិកម្មដូចជា ខេត្តក្រចេះ លំនាំនៃការបោះបង់ការសិក្សាគឺមានតាមរដូវកាល។ ជាធម្មតា នៅក្នុងអំឡុងរដូវប្រមូលផល ឪពុកម្តាយសុំឱ្យកូនមិនទៅរៀនពីរបីអាទិត្យដើម្បីជួយប្រមូលផល។ ហើយជាធម្មតា មួយរយៈពេលនៃការឈប់រៀននេះបានជំរុញឱ្យសិស្សបោះបង់ការសិក្សាទាំងស្រុងតែម្តង
ព្រោះថា ពេលពួកគេត្រឡប់ទៅចូលរៀនវិញ ពួកគេមិនអាចរៀនទាន់សិស្សឯទៀតឡើយ។

ឧបសគ្គធំបំផុតចំពោះគុណភាពអប់រំគឺគុណវុឌ្ឍិរបស់គ្រូបង្រៀន។ សម័យខ្មែរក្រហមបានបណ្តាលឱ្យកម្ពុជាបាត់បង់គ្រូបង្រៀនស្ទើរគ្មានសល់ ហើយការកសាងគ្រូមានសមត្ថភាពឡើងវិញត្រូវការពេលវេលា។ កម្ពុជាបានធ្វើឱ្យមានការរីកចម្រើនយ៉ាងខ្លាំង តាមរយៈការលើកកម្ពស់សមត្ថភាពរបស់គ្រូបង្រៀន ដែលកាលណោះ គ្រូបឋមមានតែ 3 ភាគរយ ប៉ុណ្ណោះ (យោងតាម អយក. ឆ្នាំ 2014)។ ទោះយ៉ាងណា 35 ភាគរយ នៃគ្រូបឋមសិក្សាទទួលបានការអប់រំត្រឹមអនុវិទ្យាល័យនៅឡើយ និងមានតែមួយភាគតូចទេ ដែលទទួលបានការអប់រំដល់វិទ្យាល័យ (យោងតាម ADB ឆ្នាំ2015) ។ លើសពីនេះ លក្ខខណ្ឌការងារមិនល្អរបស់គ្រូបង្រៀនដូចជា ប្រាក់ខែទាប ការរស់នៅក្នុងតំបន់ដាច់ស្រយាល និងហេដ្ឋារចនាសម្ព័ន្ធមិនល្អ បានធ្វើឱ្យអាជីពគ្រូបង្រៀនក្លាយជាជម្រើសមួយដែលមិនមានភាពទាក់ទាញ។ ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀនជំនាន់ថ្មីនៅតែត្រូវការ ប៉ុន្តែក៏ត្រូវការពេលវេលាដែរ។ កិច្ចការបន្ទាន់នោះគឺលើកកម្ពស់គ្រូបង្រៀនបច្ចុប្បន្នឱ្យល្អប្រសើរឡើង តាមរយៈការផ្តល់ប្រាក់ខែច្រើនជាងមុនជាការលើកទឹកចិត្ត និងការបណ្តុះបណ្តាលជំនាញដល់គ្រូបង្រៀន។

**តារាង 27 (3-9) សមាមាត្រសិស្សនិងគ្រូ និងសមាមាត្រសិស្ស និងថ្នាក់រៀនតាមកម្រិត ក្នុងឆ្នាំសិក្សា 2010 /11-2015 /16**

| | បឋមសិក្សា | | | | | | មធ្យមសិក្សា | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2010/11 | | 2013/14 | | 2015/16 | | 2010/11 | | 2013/14 | | 2015/16 | |
| | សមាមាត្រសិស្សនិងគ្រូ | សមាមាត្រសិស្សនិងថ្នាក់រៀន | សមាមាត្រសិស្សនិងគ្រូ | សមាមាត្រសិស្សនិងថ្នាក់រៀន | សមាមាត្រសិស្សនិងគ្រូ | សមាមាត្រសិស្សនិងថ្នាក់រៀន | សមាមាត្រសិស្សនិងគ្រូ | សមាមាត្រសិស្សនិងថ្នាក់រៀន | សមាមាត្រសិស្សនិងគ្រូ | សមាមាត្រសិស្សនិងថ្នាក់រៀន | សមាមាត្រសិស្សនិងគ្រូ | សមាមាត្រសិស្សនិងថ្នាក់រៀន |
| ភ្នំពេញ | 32.2 | 62.3 | 32.3 | 57.8 | 35.3 | 62.6 | 18.6 | 66.0 | 14.8 | 66.4 | 14.3 | 64.1 |
| តំបន់វាលទំនាប | 49.7 | 50.1 | 50.1 | 47.3 | 51.8 | 46.6 | 27.6 | 47.1 | 22.7 | 46.1 | 23.3 | 46.6 |
| ទន្លេសាប | 49.9 | 54.9 | 45.7 | 49.9 | 42.4 | 46.7 | 25.4 | 50.6 | 20.4 | 47.4 | 20.4 | 47.5 |
| តំបន់ឆ្នេរ | 40.1 | 50.3 | 34.0 | 44.4 | 30.3 | 40.8 | 21.0 | 44.4 | 16.8 | 43.5 | 16.2 | 42.2 |
| ភ្នំនិងខ្ពង់រាប | 48.9 | 50.4 | 43.4 | 45.8 | 40.1 | 44.5 | 23.1 | 44.6 | 17.2 | 44.5 | 17.0 | 45.9 |
| ទូទាំងប្រទេស | 48.3 | 53.7 | 46.2 | 49.7 | 44.8 | 47.7 | 25.2 | 50.5 | 20.4 | 48.8 | 20.2 | 48.7 |

***ប្រភព៖*** *អយក. 2010/11, 2013/14, 2015/16*

***ចំណាំ៖*** ** 2 សាលាប្តូរវេន*

គ្រូបង្រៀនជាច្រើនក្នុងប្រទេសកម្ពុជារស់នៅក្នុងភាពក្រីក្រ និងគ្មានធនធានគ្រប់គ្រាន់ដើម្បីរៀបចំ និងបង្រៀនឱ្យអស់ពីសមត្ថភាព (យោងតាម CITA ឆ្នាំ2013) ។ សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាបានវាយតម្លៃលើវិជ្ជាជីវៈគ្រូបង្រៀនថា គ្រូបង្រៀនទទួលបានប្រាក់ខែមូលដ្ឋានមិនគ្រប់គ្រាន់ ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃការអប់រំ។ ដូចជា នៅក្នុងឆ្នាំ 2012 គ្រូបឋមទទួលបានប្រាក់ខែ 60 $ ក្នុងមួយខែ និងគ្រូអនុវិទ្យាល័យទទួលបានពី $ 80- 110 $ ក្នុងមួយខែ ។ គ្រូដែលទើបតែងតាំងថ្មីគ្មានបទពិសោធន៍ចាប់ផ្តើមជាមួយនឹងប្រាក់ខែ $ 50 ។ ដោយសារតែ $ 20 នៃប្រាក់ខែ ចាំបាច់ត្រូវទុកសម្រាប់បំពេញតម្រូវការកាឡូរីមូលដ្ឋាននោះ កម្រិតប្រាក់ខែខាងលើមិនអាចឱ្យគ្រូបង្រៀនចំណាយលើជីវភាពរស់នៅផ្សេងទៀតដូចជា ការជួលផ្ទះ សម្លៀកបំពាក់ និងថ្នាំសង្កូវ។ល។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អគុណភាពអប់រំ នៅឆ្នាំ 2016 រាជរដ្ឋាភិបាលបានប្រកាសថា ប្រាក់ខែរបស់គ្រូបង្រៀននឹងកើនឡើងដល់ $ 200 សម្រាប់គ្រូបឋមនិង $ 250 សម្រាប់គ្រូមធ្យម។ សមាមាត្រសិស្សគ្រូ ឬទំហំថ្នាក់រៀនតូចក៏មិនអាចគ្រប់ល្មមសម្រាប់កែលម្អគុណភាពអប់រំដែរ ប្រសិនបើលក្ខខណ្ឌការងាររបស់គ្រូបង្រៀនមិនត្រូវបានលើកកម្ពស់ ។ ដូចនេះ ដំឡើងប្រាក់ខែឱ្យគ្រូបង្រៀនខ្ពស់ជាងមុន លើកកម្ពស់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ បណ្តុះបណ្តាគ្រូបង្រៀន វិនិយោគក្នុងវិធីសាស្ត្របង្រៀន និងប្រើប្រាស់គ្រូជំនួយ និងអ្នកជំនាញផ្សេងទៀត ដើម្បីឱ្យមានការផ្លាស់ប្តូរ។

## ៣.៣ ក្តីរំពឹងរបស់និស្សិតដែលបានបបញ្ចប់ និងអ្នកបោះបង់ការសិក្សា

ក្តីរំពឹងមួយក្នុងចំណោមក្តីរំពឹងសំខាន់បំផុតដែលបានមកពីការអប់រំគឺ ឱកាសការងារសមរម្យ។
ទោះយ៉ាងណា យុវជនកម្ពុជាមានគំនិតទុទិដ្ឋិនិយមចំពោះលទ្ធផលដែលបានមកពីការវិនិយោគក្នុងវិស័យអប់រំ។ តាមពិត ប្រាក់ខែរបស់សិស្សដែលបានបញ្ចប់មធ្យមសិក្សាធៀបនឹងប្រាក់ខែរបស់សិស្សដែលបានបោះបង់ការសិក្សាគឺមិនខុសគ្នាទេ បើខុសគ្នាក៏មិនច្រើនដែរ។ បើបញ្ចូលគ្រប់កម្រិតនោះ លទ្ធផលការងាររបស់សិស្សដែលបានបញ្ចប់ថ្នាក់គ្រប់កម្រិតទាំងអស់គឺប្រសើរជាងអ្នកដែលបានបោះបង់ការសិក្សា ប៉ុន្តែនៅកម្រិតឧត្តមសិក្សា ភាពខុសគ្នានេះមានកាន់តែច្រើន។ មួយភាគធំនៃសិស្សដែលបានបញ្ចប់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សា ទីបំផុតពួកគេធ្វើការងារឱ្យគ្រួសារគ្មានប្រាក់ខែ ឬប្រាក់ខែទាប។ នៅក្នុងឆ្នាំ 2014 គេបានប្រើប្រាស់ការស្ទង់មតិស្តីពីការផ្លាស់ប្តូរពីសាលាទៅការងារដោយផ្តោតលើលទ្ធផលការងាររំពឹងទុក និងបទពិសោធន៍របស់យុវជនចំនួន 3303 នាក់ ដែលមានអាយុចន្លោះពី 15 ទៅ 29 ឆ្នាំ ដើម្បីវិភាគលទ្ធផលការងាររបស់សិស្សដែលបានបញ្ចប់ការសិក្សា ធៀបនឹងសិស្សដែលបានបោះបង់ការសិក្សា។

### ៣.៣.១ ស្ថានភាពការងារ

យុវជនដែលបានបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សា ឬខ្ពស់ជាងនេះ អាចរកបានការងារដែលមានស្ថិរភាព និងពេញចិត្ត។ ក្នុងអំឡុងនៃការផ្លាស់ប្តូរពីសាលាទៅការងារ ពេលវេលាសម្រាប់និស្សិតដែលកំពុងសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាខ្លីជាងអ្នកដែលបានបញ្ចប់ការអប់រំនៅកម្រិតទាបជាងនេះ។ អ្នកដែលមិនបានចូលរៀន ឬរៀនក្រោមកម្រិតបឋមចំណាយពេលជាមធ្យមចំនួន 123,7 ខែក្នុងអំឡុងអន្តរកាល ។ សិស្សដែលបានបញ្ចប់ការសិក្សាកម្រិតបឋមចំណាយពេលជាមធ្យមចំនួន 89 ខែ សិស្សដែលបានបញ្ចប់មធ្យមសិក្សាចំណាយពេល 57,4 ខែ និស្សិតដែលបានបញ្ចប់សាកលវិទ្យាល័យ ឬខ្ពស់ជាងនេះចំណាយពេល 21,5 ខែ (យោងតាម ILO SWTS ឆ្នាំ2013)។ អន្តរកាលនេះត្រូវចាត់ទុកថា បានបញ្ចប់នៅពេលដែលយុវជនរកបានការងារមានស្ថេរភាពតាមកិច្ចសន្យា ឬធ្វើការឱ្យខ្លួនឯង ឬការងារបណ្តោះអាសន្នដែលខ្លួនពេញចិត្ត។

នៅក្នុងឆ្នាំ 2014 យុវជនចំនួន 64 ភាគរយ ដែលបោះបង់ការសិក្សាបានធ្វើការនៅក្នុងប្រភេទការងារងាយរងគ្រោះ (40 ភាគរយ ជាការងារគ្រួសារគ្មានប្រាក់ខែ និង 23 ភាគរយ ជាការងារខ្លួនឯង) ខណៈដែល 36 ភាគរយទៀតជាការងារមានប្រាក់ខែសមរម្យ។ តាមការប្រៀបធៀប 52 ភាគរយ នៃនិស្សិតដែលបានបញ្ចប់ការសិក្សាក៏ស្ថិតក្នុងប្រភេទការងារងាយរងគ្រោះដែរ (16 ភាគរយ ជាការងារខ្លួនឯង និង 36 ភាគរយ ជាការងារគ្រួសារគ្មានប្រាក់ខែ)។ អត្រាខ្ពស់ នៃសិស្សដែលបានបញ្ចប់ការសិក្សាមានការងារមានប្រាក់ខែសមរម្យគឺ 47 ភាគរយ (យោងតាម តារាង 3.10)។

**តារាង 28 (3-10) ភាគរយនៃស្ថានភាពការងាររបស់យុវជនក្នុងក្រុមអាយុពី 15 ទៅ 29 ឆ្នាំ ដែលបានបញ្ចប់ការសិក្សានិងបោះបង់ការសិក្សានៅឆ្នាំ 2014**

| ភាគរយ | 2014 | |
|---|---|---|
| | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
| ប្រាក់ខែ | 47.1 | 35.5 |
| និយោជក | 0.6 | 0.8 |
| ការងារខ្លួនឯង | 16.3 | 23.2 |
| ការងារគ្រួសារគ្មានប្រាក់ខែ | 36.0 | 40.4 |
| ផ្សេងទៀត | 0.0 | 0.1 |
| សរុប | 100 | 100 |
| សរុប (ចំនួន) | 497 | 1 645 |

***ប្រភព៖*** *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

ការអប់រំមានឥទ្ធិពលខ្លាំងទៅលើការងារនៅពេលដែលយុវជនម្នាក់បានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សា ឬគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ។ បានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សា ឬគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអាចឱ្យយុវជនភាគច្រើនមានឱកាសរកការងារមានប្រាក់ខែសមរម្យគឺជាការងារដែលយុវជនភាគច្រើនពេញចិត្ត ។ 62 ភាគរយ នៃនិស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សា និង 78 ភាគរយ នៃនិស្សិតដែលបញ្ចប់ពីគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអាចរកបានការងារមានប្រាក់ខែសមរម្យ បើប្រៀបធៀបគ្នា អ្នកដែលបានបោះបង់ការសិក្សាមានចំនួន 33 ភាគរយ និងអ្នកដែលបានបោះបង់ការបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន 38 ភាគរយ ប៉ុណ្ណោះ ដែលអាចរកបានការងារមានប្រាក់ខែសមរម្យ ។ មានភាពខុសគ្នាតិចតួចនៅក្នុងការស្វែងរកការងារមានប្រាក់ខែ ទោះជាអ្នកនោះបានបញ្ចប់ការសិក្សានៅបឋមសិក្សា ឬអនុវិទ្យាល័យ ឬមិនបានចូលរៀនក៏ដោយ (សូមមើល តារាង 3.11) ។ អត្រានៃសិស្សដែលបានបញ្ចប់ការសិក្សា និងការបោះបង់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាមានលក្ខណៈប្រហាក់ប្រហែលគ្នា ដែលទីបំផុតពួកគេបានត្រឹមធ្វើការឱ្យក្រុមគ្រួសារគ្មានប្រាក់ខែ និងការងារខ្លួនឯង ដែលគេចាត់ទុកថា ជាប្រភេទការងារងាយរងគ្រោះ (សូមមើល តារាង 3.11) ។

**តារាង 29 (3-11) ស្ថានភាពការងារនៃនិស្សិតបានបញ្ចប់ការសិក្សា និងបោះបង់ការសិក្សាដែលមានអាយុពី 15 ទៅ 29 ឆ្នាំ តាមកម្រិតការអប់រំ (ឆ្នាំ 2014)**

| | និស្សិតបានបញ្ចប់ការសិក្សា | | | | | និស្សិតបោះបង់ការសិក្សា | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | បឋមសិក្សា | មធ្យមសិក្សា | ឧត្តមសិក្សា | បណ្តុះបណ្តាលវិជ្ជាជីវៈ | ផ្សេងទៀត | បឋមសិក្សា | មធ្យមសិក្សា | ឧត្តមសិក្សា | បណ្តុះបណ្តាលវិជ្ជាជីវៈ | ផ្សេងទៀត |
| ប្រាក់ខែ | 35.1 | 42.5 | 62.4 | 78.7 | 0 | 33.5 | 39.1 | 33.3 | 38.1 | 41.7 |
| ការងារខ្លួនឯង | 21.6 | 15.4 | 14.1 | 12.8 | 50 | 24.8 | 21.9 | 16.7 | 14.3 | 22.2 |
| ការងារគ្រួសារគ្មានប្រាក់ខែ | 43.3 | 42.1 | 23.5 | 8.5 | 50 | 41.7 | 39 | 50 | 47.6 | 36.1 |
| សរុប | 100 | 100 | 100 | 100 | 100 | 100 | 100 | 100 | 100 | 100 |

***ប្រភព៖*** *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

មួយភាគធំនៃនិស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើការជាអ្នកជំនាញ ឬជាអ្នកលក់ និងផ្តល់សេវាកម្ម។ និស្សិតដែលបានបោះបង់ការសិក្សានៅឧត្តមសិក្សា និងសាលាវិជ្ជាជីវៈក៏អាចទទួលបានការងារក្នុងផ្នែកលក់ និងសេវាកម្ម និងយ៉ាងហោចណាស់ត្រឹមជំនួយការស្មៀនដែរ។ ប៉ុន្តែក្នុងចំណោមពួកគេ ពុំមាននរណាម្នាក់ធ្វើការជាអ្នកជំនាញ ឬជាអ្នកគ្រប់គ្រងនោះទេ។ ធៀបនឹងអ្នកដែលបានបញ្ចប់ និងបោះបង់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សា មានភាពខុសគ្នាតិចតួចដែរ។ យុវជនទាំងពីរប្រភេទនេះ ភាគច្រើនធ្វើការក្នុងវិស័យកសិកម្ម ។ ក្នុងចំណោមអ្នកដែលបានបោះបង់ការសិក្សា មានធ្វើការនៅក្នុងវិស័យកសិកម្មចំនួន 44 ភាគរយ នៅក្នុងវិស័យសិប្បកម្ម និងពាណិជ្ជកម្មចំនួន 22 ភាគរយ និងនៅក្នុងផ្នែកលក់ និងសេវាកម្មមានចំនួន 17 ភាគរយ (សូមមើល តារាង 3.12) ។

**តារាង 30 (3-12) មុខរបរ និងកម្រិតអប់រំរបស់យុវជនដែលមានអាយុពី 15 ទៅ 29 ឆ្នាំ ក្នុង ឆ្នាំ 2014**

| ភាគរយ | និស្សិតបានបញ្ចប់ការសិក្សា | | | | | និស្សិតបោះបង់ការសិក្សា | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | បឋមសិក្សា | មធ្យមសិក្សា | ឧត្តមសិក្សា | ការបណ្តុះបណ្តាលវិជ្ជាជីវៈ | ផ្សេងទៀត | បឋមសិក្សា | មធ្យមសិក្សា | ឧត្តមសិក្សា | ការបណ្តុះបណ្តាលវិជ្ជាជីវៈ | ផ្សេងទៀត |
| កងកម្លាំងប្រដាប់អាវុធ | - | - | 3.5 | 4.3 | - | 0.4 | 0.1 | - | - | - |
| អ្នកគ្រប់គ្រង | - | 0.4 | 4.7 | 2.1 | - | - | 0.8 | - | - | - |
| អ្នកជំនាញ | 1.0 | 4.1 | 22.4 | 66.0 | - | 0.6 | 0.8 | - | 9.5 | - |
| អ្នកបច្ចេកទេសនិងវិជ្ជាជីវៈពាក់ព័ន្ធ | - | 2.6 | 5.9 | 2.1 | - | 1.3 | 1.4 | - | 4.8 | - |
| ជំនួយការស្មៀន | - | 2.3 | 12.9 | 6.4 | - | 0.2 | 1.3 | 33.3 | - | - |
| សេវាកម្មនិងលក់ដូរ | 15.5 | 22.2 | 28.2 | 10.6 | - | 13.5 | 20.1 | 66.7 | 33.3 | 19.4 |
| ការងារជំនាញកសិកម្ម | 45.4 | 36.5 | 11.8 | 6.4 | 50.0 | 52.3 | 37.0 | - | 23.8 | 38.9 |
| សិប្បកម្មនិង ពាណិជ្ជកម្មពាក់ព័ន្ធ | 20.6 | 24.4 | 10.6 | 2.1 | 50.0 | 17.8 | 27.8 | - | 23.8 | 16.7 |
| អ្នកប្រតិបត្តិការរោងចក្រនិងម៉ាស៊ីន | 1.0 | 2.3 | - | - | - | 2.5 | 4.6 | - | 4.8 | - |
| ការងារបឋម | 16.5 | 5.3 | - | - | - | 11.4 | 6.1 | - | - | 25.0 |

***ប្រភព៖*** *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

ការបែងចែកមុខរបរតាមក្រុមអាយុបានបង្ហាញថា ប្រាក់ខែរបស់យុវជនដែលមានអាយុចន្លោះពី 15 ទៅ 19 ឆ្នាំ ដែលបានបញ្ចប់បឋមសិក្សាក៏មិនច្រើនជាងប្រាក់ខែរបស់យុវជនដែលបានបោះបង់ការសិក្សាណាស់ណាដែរ។ 43 ភាគរយ នៃសិស្សដែលបានបញ្ចប់បឋមសិក្សា និង 53 ភាគរយ នៃសិស្សដែលបានបោះបង់បឋមសិក្សាធ្វើការនៅក្នុងវិស័យកសិកម្ម និងមានសិស្សដែលបានបញ្ចប់បឋមសិក្សាចំនួន 21 ភាគរយផ្សេងទៀតធ្វើការនៅក្នុងប្រភេទការងារបឋម គឺច្រើនជាងអ្នកដែលបោះបង់បឋមសិក្សាតែ 14 ភាគរយ ប៉ុណ្ណោះ (សូមមើល តារាង 3.13) ។ មួយភាគធំ នៃសិស្សដែលបានបញ្ចប់មធ្យមសិក្សា និងបានបោះបង់មធ្យមសិក្សាក៏

ត្រូវបានគេឃើញថា កំពុងធ្វើការក្នុងផ្នែកលក់ និងសេវាកម្ម កសិកម្ម និងពាណិជ្ជកម្មផងដែរ។ ទោះជាយ៉ាងណា 9,1 ភាគរយ នៃយុវជនដែលមានអាយុពី 15 ទៅ 29 ឆ្នាំ ដែលបានបញ្ចប់មធ្យមសិក្សាអាចរកបានការងារជំនាញខ្ពស់ ដូចជា សាស្ត្រាចារ្យ ជំនួយការបច្ចេកទេស និងស្មៀនច្រើនជាងសិស្សដែលបានបោះបង់ការសិក្សានៅមធ្យមសិកស្សាដែលមានតែ 3,1 ភាគរយ ប៉ុណ្ណោះ (សូមមើល តារាង 3.12) ។

**តារាង 31 (3-13) មុខរបររបស់សិស្សបានបញ្ចប់ និងបោះបង់បឋមសិក្សា ដែលមានអាយុពី 15 ទៅ 19 ឆ្នាំ ក្នុងឆ្នាំ 2014**

| | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| អ្នកគ្រប់គ្រង | 0.0 | 0.0 |
| អ្នកជំនាញ | 3.6 | 0.4 |
| អ្នកបច្ចេកទេសនិងវិជ្ជាជីវៈពាក់ព័ន្ធ | 0.0 | 1.3 |
| ជំនួយការស្មៀន | 0.0 | 0.0 |
| សេវាកម្មនិងការលក់ដូរ | 10.7 | 10.2 |
| ការងារជំនាញក្នុងវិស័យកសិកម្ម នេសាទ ព្រៃឈើ | 42.9 | 52.8 |
| សិប្បកម្មនិង ពាណិជ្ជកម្មពាក់ព័ន្ធ | 21.4 | 20.4 |
| អ្នកប្រតិបត្តិការរោងចក្រនិងម៉ាស៊ីន | 0.0 | 0.9 |
| កាងារបឋម | 21.4 | 14.0 |
| **ចំនួនសរុប** | **28** | **235** |

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

ទាំងយុវជន និងយុវតីដែលមានអាយុចន្លោះពី 15 ទៅ 19 ឆ្នាំ ដែលទទួលបានការអប់រំត្រឹមកម្រិតបឋមមានមុខរបរជាការងារគ្មានជំនាញ ខណៈដែលយុវតីភាគច្រើនជាកម្មករជំនាញដោយដៃ (សូមមើល តារាង 3.14) ។ កម្មករទាំងពីរភេទនេះកំពុងជួយធ្វើការងារកសិកម្ម ឬធុរៈកិច្ចគ្រួសារ ឬការងារស៊ីឈ្នួល ។ មានតិចតួចទេដែលគេសង្កេតឃើញថា កំពុងធ្វើការឱ្យខ្លួនឯង (សូមមើល តារាង 3.15) ។

**តារាង 32 (3-14) កម្រិតជំនាញ នៃសិស្សបានបញ្ចប់ និងបោះបង់បឋមសិក្សា ដែលមានអាយុពី 15 ទៅ 19 ក្នុងឆ្នាំ 2014**

| | យុវតី | | យុវជន | |
|---|---|---|---|---|
| | បានបញ្ចប់ការសិក្សា | បោះបង់ការសិក្សា | បានបញ្ចប់ការសិក្សា | បោះបង់ការសិក្សា |
| ជំនាញខ្ពស់ មិនដោយដៃ | 10.0 | 3.1 | 1.4 | - |
| ជំនាញទាប មិនដោយដៃ | 20.0 | 12.3 | 5.6 | 7.6 |
| ជំនាញដោយដៃ | 50.0 | 75.4 | 59.9 | 72.4 |
| គ្មានជំនាញ | 20.0 | 9.2 | 33.1 | 20.0 |
| សរុប | 100 | 100 | 100 | 100 |
| សរុបរួម | 10 | 130 | 142 | 105 |

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

**តារាង 33 (3-15) ស្ថានភាពការងាររបស់សិស្សដែលបានបញ្ចប់ និងបោះបង់បឋមសិក្សាដែលមានអាយុពី 15ទៅ19ឆ្នាំ ក្នុងឆ្នាំ 2014**

| | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| ប្រាក់ខែ | 46.4 | 36.6 |
| និយោជក | 0.1 | 0.0 |
| កម្មករគណនីផ្ទាល់ខ្លួន | 7.1 | 4.3 |
| កម្មករគ្រួសារគ្មានប្រាក់ខែ | 46.4 | 59.1 |
| សរុប | **100** | **100** |

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

សិស្សដែលបានបញ្ចប់ការសិក្សារកការងារជំនាញខ្ពស់បានច្រើនជាងសិស្សដែលបានបោះបង់ការសិក្សា (សូមមើល តារាង 3.16) ។ សិស្សដែលបានបញ្ចប់មធ្យមសិក្សាអាចរកការងារមានប្រាក់ខែបានច្រើនជាងការងារផ្សេងៗ។ ប៉ុន្តែការងារមានប្រាក់ខែរបស់សិស្សដែលបានបោះបង់ការសិក្សានៅចន្លោះឆ្នាំ 2014 និងឆ្នាំ 2012 មានចំនួនតិចជាងការងារគ្មានប្រាក់ខែ (សូមមើល តារាង 3.16/17) ។

**តារាង 34 (3-16) កម្រិតជំនាញសិស្សដែលបានបញ្ចប់និងបោះបង់មធ្យមសិក្សា ដែលមានអាយុពី 20ទៅ24 ឆ្នាំ ក្នុងឆ្នាំ 2014**

| | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| ជំនាញខ្ពស់ មិនដោយដៃ | 5 | 2.6 |

| | | |
|---|---|---|
| ជំនាញទាប មិនដោយដៃ | 16.7 | 7.9 |
| ជំនាញដោយដៃ | 70 | 78.3 |
| គ្មានជំនាញ | 8.3 | 11.2 |

***ប្រភព***៖ *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

**តារាង 35 (3-17) ស្ថានភាពការងារសិស្សដែលបានបញ្ចប់និងបោះបង់មធ្យមសិក្សា ដែលមានអាយុពី 20ទៅ24 ឆ្នាំ ក្នុងឆ្នាំ 2014**

| | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| ជំនាញខ្ពស់ មិនដោយដៃ | 48.7 | 36.7 |
| ជំនាញទាប មិនដោយដៃ | 0 | 0 |
| ជំនាញដោយដៃ | 12 | 22.3 |
| គ្មានជំនាញ | 39.3 | 40.8 |

***ប្រភព***៖ *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

មួយភាគធំ នៃនិស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សាធ្វើការជាអ្នកជំនាញ។ និស្សិតដែលបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សារកក៏អាចរកបានការងារនៅក្នុងផ្នែកលក់ និងសេវាកម្ម និងផ្នែកសិកម្មផងដែរ ប៉ុន្តែតិចតួចណាស់ដែលរកបានការងារជំនាញ។ និស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សាមានតិចតួចទេដែលកំពុងធ្វើការនៅក្នុងវិស័យសិប្បកម្ម និងរបរពាក់ព័ន្ធនឹងសិប្បកម្ម ចំណែកនិស្សិតដែលបានបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សាមានចំនួនរហូតដល់ 12 ភាគរយ ដែលកំពុងធ្វើការនៅក្នុងវិស័យនេះ (សូមមើល តារាង 3.18) ។

**តារាង 36 (3-18) មុខរបររបស់និស្សិតដែលបានបញ្ចប់និងបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សា ដែលមានអាយុពីឆ្នាំ 25ទៅ29ឆ្នាំ ក្នុងឆ្នាំ 2012-14**

| | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| **កងកម្លាំងប្រដាប់អាវុធ** | 5.7 | n/a |
| **អ្នកគ្រប់គ្រង** | 5.7 | n/a |
| **អ្នកជំនាញ** | 40 | 12.5 |
| **អ្នកបច្ចេកទេសនិងវិជ្ជាជីវៈដែលទាក់ទង** | 7.1 | 0 |
| **ជំនួយការស្មៀន** | 10 | 12.5 |
| **សេវាកម្មនិងការលក់ដូរ** | 21.4 | 62.5 |
| **ការងារជំនាញក្នុងវិស័យកសិកម្ម នេសាទ ព្រៃឈើ** | 4.3 | n/a |
| **សិប្បកម្មនិង ពាណិជ្ជកម្មពាក់ព័ន្ធ** | 5.7 | 12.5 |
| **អ្នកប្រតិបត្តិការរោងចក្រនិងម៉ាស៊ីន** | n/a | n/a |
| **កាងារបឋម** | n/a | n/a |

***ប្រភព***៖ *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

ជារួមមក ទាំងនិស្សិតដែលបានបញ្ចប់ និងបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សាអាចរកបានការងារសមរម្យ។ 76 ភាគរយ នៃនិស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សារកបានការងារមានប្រាក់ខែ ទាំងជំនាញខ្ពស់ និងជំនាញទាបមិនដោយដៃ។ មួយភាគបួន នៃនិស្សិតដែលបានបោះបង់ការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាមានការងារជំនាញទាបមិនដោយដៃ និងមួយភាគប្រាំបីមានការងារជំនាញខ្ពស់មិនដោយដៃ។ ប៉ុន្តែនិស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សារកបានការងារល្អច្រើនជាង ពោលគឺ ជាងពាក់កណ្តាលនៃពួកគេមានការងារជំនាញខ្ពស់មិនដោយដៃ។ ហើយជាធម្មតា ទាំងនិស្សិតដែលបានបញ្ចប់ និងបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សាមានការងារមានប្រាក់ខែសមរម្យ។ កម្រមាននិស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សាធ្វើការងារគ្រួសារគ្មានប្រាក់ខែណាស់ ប៉ុន្តែអត្រាការងារគ្រួសារគ្មានប្រាក់ក្នុងចំណោមនិស្សិតដែលបានបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សាមានខ្ពស់គួរឱ្យកត់សម្គាល់ដែរ (សូមមើល តារាង 3.19) ។

**តារាង 37 (3-19) កម្រិតជំនាញរបស់និស្សិតដែលបានបញ្ចប់ និងបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សាដែលមានអាយុពី 25ទៅ29 ឆ្នាំ ក្នុងឆ្នាំ2014**

| | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| **ជំនាញខ្ពស់ មិនដោយដៃ** | 52.9 | 12.5 |
| **ជំនាញទាប មិនដោយដៃ** | 37.1 | 75 |
| **ជំនាញដោយដៃ** | 10 | 12.5 |
| **គ្មានជំនាញ** | - | - |
| **ប្រាក់ខែ** | 75.7 | 37.5 |
| **ការងារខ្លួនឯង** | 14.3 | 12.5 |
| **ការងារគ្រួសារគ្មានប្រាក់ខែ** | 10 | 50 |

***ប្រភព***៖ *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

**តារាង 38 (3-2) ស្ថានភាពការងាររបស់និស្សិតដែលបានបញ្ចប់និងបោះបង់ការសិក្សានៅកម្រិតឧត្តមសិក្សាដែលមានអាយុពី 25ទៅ29 ឆ្នាំក្នុងឆ្នាំ 2014**

| | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| **ប្រាក់ខែ** | 75.7 | 37.5 |
| **ការងារខ្លួនឯង** | 14.3 | 12.5 |
| **ការងារគ្រួសារគ្មានប្រាក់ខែ** | 10 | 50 |

***ប្រភព***៖ *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

### ៣.៣.២ ប្រាក់ខែ/ប្រាក់ឈ្នួល

សម្រាប់ការងារជាច្រើន សិស្សដែលបានបោះបង់បឋមសិក្សា និងមធ្យមសិក្សាអាចរកប្រាក់ចំណូលបានច្រើនជាងសិស្សដែលបានបញ្ចប់ការសិក្សានៅបឋម និងមធ្យមសិក្សា។ សិស្សដែលបានបោះបង់បឋមសិក្សាអាចរកប្រាក់ចំណូលបានបីដងច្រើនជាងសិស្សដែលបានបញ្ចប់បឋមសិក្សាដែលធ្វើការងារជំនាញទាបមិនដោយដៃ។ សិស្សបោះបង់ការសិក្សានៅមធ្យមសិក្សារកប្រាក់ចំណូលបានពីរដងច្រើនជាងសិស្សដែលបានបញ្ចប់ការសិក្សាពីមធ្យមសិក្សាដែលស្ថិតធ្វើការងារជំនាញខ្ពស់មិនដោយដៃ (សូមមើល តារាង 3.20) ។ នេះអាចបង្ហាញថា ភាគច្រើន នៃសិស្សដែលបានបញ្ចប់ពីសាលាចំណេះទូទៅ នៅទីបំផុតមានមុខរបរប្រហាក់ប្រហែលគ្នានឹងសិស្សដែលបោះបង់ការសិក្សាចំណេះទូទៅដែរ ទោះបីពួកគេបានបញ្ចប់ការសិក្សាពេញលេញក៏ដោយ។ ស្សិសដែលបានបោះបង់ការសិក្សាអាចរកប្រាក់ចំណូលបានច្រើនជាង ដោយសារតែបទពិសោធន៍របស់គេកើនឡើងច្រើនឆ្នាំ។ មានតែការបញ្ចប់ការសិក្សាពីគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈទេដែលអាចរកប្រាក់ចំណូលបានច្រើនជាងសិស្សដែលបោះបង់ការសិក្សា។

**តារាង 39 (3-21) ប្រាក់ខែតាមកម្រិតសាលា និងជំនាញរបស់យុវជនដែលមានអាយុពី 15 ទៅ 29 ឆ្នាំ 2014 (រៀល / ម៉ោង)**

| | សិស្សបានបញ្ចប់ការសិក្សា | | | | |
|---|---|---|---|---|---|
| | បឋមសិក្សា | មធ្យមសិក្សា | ឧត្តមសិក្សា | បណ្តុះបណ្តាលវិជ្ជាជីវៈ | ផ្សេងៗ |
| ជំនាញខ្ពស់ មិនដោយដៃ | 5177 | 3608 | 5623 | 5746 | - |
| ជំនាញទាប មិនដោយដៃ | 1474 | 2800 | 5002 | 4724 | - |
| ជំនាញដោយដៃ | 3260 | 4146 | 10563 | - | - |
| គ្មានជំនាញ | 5553 | 3212 | - | - | - |
| | សិស្សបោះបង់ការសិក្សា | | | | |
| ជំនាញខ្ពស់ មិនដោយដៃ | 2265 | 7878 | - | 4393 | - |
| ជំនាញទាប មិនដោយដៃ | 4733 | 2337 | 4115 | 1244 | 4375 |
| ជំនាញដោយដៃ | 3554 | 3963 | - | 3333 | 1962 |
| គ្មានជំនាញ | 3580 | 4440 | - | - | 3977 |

***ប្រភព*៖** *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

***ចំណាំ*៖** *1 ដុល្លារអាមេរិកគឺប្រហែល 4000 រៀល*

ក្នុងឆ្នាំ 2014 ប្រាក់ម៉ោងរបស់សិស្សដែលបានបោះបង់បឋមសិក្សាដែលមានអាយុពី 15 ទៅ 19 ឆ្នាំគឺ 37 ភាគរយ ច្រើនជាងប្រាក់ម៉ោងរបស់សិស្សដែលបានបញ្ចប់កម្រិតនោះ។ ប្រាក់ខែរបស់ស្ត្រីដែលបានបញ្ចប់ការសិក្សាខ្ពស់ជាងប្រាក់ខែរបស់បុរស (សូមមើល តារាង 3.22)។ ករណីនេះគឺមិនដូចគ្នាទេ ចំពោះស្ត្រីដែលបោះបង់ការសិក្សា។ បើគិតតាមតំបន់ ប្រាក់ខែខ្ពស់បំផុតសម្រាប់សិស្សដែលបានបញ្ចប់ការសិក្សាគឺនៅរាជធានីភ្នំពេញ ខណៈដែលប្រាក់ខែខ្ពស់បំផុតសម្រាប់សិស្សដែលបានបោះបង់ការសិក្សា គឺនៅតំបន់បឹងទន្លេសាប។ ប្រាក់ខែទាបបំផុតសម្រាប់សិស្សដែលបានបញ្ចប់បឋមសិក្សា គឺនៅក្នុងតំបន់វាលទំនាប ខណៈដែលប្រាក់ខែទាបបំផុតសម្រាប់សិស្សដែលបានបោះបង់ការសិក្សាគឺនៅរាជធានីភ្នំពេញ (សូមមើល តារាង 3.23)។

**តារាង 40 (3-22) ប្រាក់ខែរបស់សិស្សដែលបានបញ្ចប់ និងបោះបង់ការសិក្សានៅកម្រិតបឋម ដែលមានអាយុពី 15 ទៅ 19 ឆ្នាំ តាមភេទ ក្នុងឆ្នាំ 2014**

| រៀល/ម៉ោង | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| ប្រុស | 2056.9 | 4176.0 |
| ស្រី | 2969.9 | 3121.5 |
| ប្រាក់ខែមធ្យមសរុប | **2548.5** | **3501.6** |

***ប្រភព*៖** *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

**តារាង 41 (3-23) ប្រាក់ខែរបស់សិស្សដែលបានបញ្ចប់ និងបោះបង់ការសិក្សានៅកម្រិតបឋម ដែលមានអាយុពី 15 ទៅ 19 ឆ្នាំ តាមតំបន់ ក្នុងឆ្នាំ 2014 (រៀល/ម៉ោង)**

| រៀល/ម៉ោង | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| ភ្នំពេញ | 3937.4 | 1860.1 |
| វាលទំនាប | 1666.7 | 2612.2 |
| ទន្លេសាប | 2235.5 | 6677.7 |
| តំបន់ឆ្នេរ | 2544.1 | 2818.4 |
| ភ្នំនិងខ្ពង់រាប | - | 2451.9 |

***ប្រភព*៖** *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

សម្រាប់សិស្សដែលបានបញ្ចប់មធ្យមសិក្សា ប្រាក់ខែខ្ពស់បំផុតគេសង្កេតឃើញមាននៅក្នុងតំបន់ទំនាប ភាពខុសគ្នានៅក្នុងតំបន់ទាំងនោះក៏មិនច្រើនដែរ។ ប្រាក់ម៉ោងរបស់សិស្សដែលបានបញ្ចប់មធ្យមសិក្សាដែលរស់នៅក្នុងតំបន់ទន្លេសាបគឺពីរដងច្រើនជាងសិស្សដែលរស់នៅតំបន់ផ្សេងៗ ដោយសារតែ តំបន់នេះជាតំបន់ប្រមូលផ្តុំរោងចក្រកាត់ដេរ ។ អ្នកធ្វើការនៅតំបន់ខ្ពង់រាប និងភ្នំបានទទួលប្រាក់ខែតិចបំផុតក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សា។ ប៉ុន្តែនៅក្នុងរាជធានីភ្នំពេញ សិស្សដែលបោះបង់ការសិក្សាបានទទួលប្រាក់ខែទាបបំផុត ។

**តារាង 42 (3-24) ប្រាក់ខែរបស់សិស្សដែលបានបញ្ចប់និងបោះបង់ការសិក្សានៅមធ្យមសិក្សា ដែលមានអាយុពី 20 ទៅ 24 ឆ្នាំ ក្នុងឆ្នាំ 2014 (រៀល / ម៉ោង)**

| រៀល/ម៉ោង | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| ភ្នំពេញ | 3334.4 | 3379.1 |
| វាលទំនាប | 5659.8 | 4089.2 |
| ទន្លេសាប | 4328.9 | 9766.1 |
| តំបន់ឆ្នេរ | 2853.3 | 5383.0 |
| ភ្នំនិងខ្ពង់រាប | 2557.0 | 4580.9 |

***ប្រភព*៖** *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

នៅកម្រិតឧត្តមសិក្សា មានសញ្ញាបត្រ និងមិនមានសញ្ញាបត្រគឺខុសគ្នាក្រាស់ក្រៃលដែរ។ ក្នុងឆ្នាំ 2014 ប្រាក់ខែមធ្យមរបស់និស្សិតដែលបានបោះបង់ការសិក្សាតិចជាងប្រាក់ខែរបស់និស្សិតបានបញ្ចប់ការសិក្សាចំនួន 46 ភាគរយ ។

**តារាង 43 (3-25) ប្រាក់ខែរបស់និស្សិតដែលបានបញ្ចប់និងបោះបង់ការសិក្សានៅឧត្តមសិក្សា ដែលមានអាយុពី 20 ទៅ 24 ឆ្នាំ តាមភេទនិងតំបន់ ក្នុងឆ្នាំ 2014 (រៀល/ម៉ោង)**

| រៀល/ម៉ោង | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
|---|---|---|
| ប្រុស | 6995.7 | 5150.0 |
| ស្រី | 9392.9 | 2500.0 |
| តំបន់ | | |
| ភ្នំពេញ | 5530.5 | - |
| វាលទំនាប | 13681.0 | 5300.0 |
| ទន្លេសាប | 5139.8 | - |
| តំបន់ឆ្នេរ | 6758.1 | - |
| ភ្នំនិងខ្ពង់រាប | 4657.7 | 3750.0 |

***ប្រភព***៖ *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

### ៣.៣.៣ ការពេញចិត្តនឹងការងារ

មានគម្លាតយ៉ាងធំរវាងបំណងប្រាថ្នារបស់យុវជន និងអ្វីដែលពួកគេកំពុងធ្វើ។ សរុបមក ភាគច្រើន នៃយុវជនចំនួន (95 ភាគរយ) ដែលកំពុងធ្វើការអះអាងថា ពួកគេពេញចិត្តនឹងការងារដែលខ្លួនកំពុងធ្វើបច្ចុប្បន្ន។ ទោះជាយ៉ាងណា នៅពេលដែលសួរបន្ថែមថា តើពួកគេចង់បន្តធ្វើការងារបច្ចុប្បន្នរបស់គេរហូតទេ? តិចជាងពាក់កណ្តាលនៃពួកគេ (47 ភាគរយ) បានឆ្លើយថា ពួកគេចង់បន្ត។ លក្ខខណ្ឌនៃការពេញចិត្តនេះពុំមានភាពខុសគ្នាច្រើនទេ រវាងសិស្សដែលបានបានបញ្ចប់ និងអ្នកបោះបង់ការសិក្សា គ្រាន់តែ អ្នកដែលបានបោះបង់ការសិក្សាមានការពេញចិត្តនឹងការងារច្រើនជាងអ្នកដែលបានបញ្ចប់មធ្យមសិក្សា និងឧត្តមសិក្សាបន្តិច។

ក្នុងចំណោមសិស្សរៀននៅមធ្យមសិក្សា កម្រិតនៃការមិនពេញចិត្តនឹងការងាររបស់សិស្សដែលបានបញ្ចប់ និងបោះបង់ការសិក្សាស្ទើរតែដូចគ្នា គឺជុំវិញ 5.9 ភាគរយ ។ ការមិនពេញចិត្តនឹងការងារកម្រមានណាស់ក្នុងចំណោមកម្មករជំនាញខ្ពស់មិនដោយដៃ។ និស្សិតដែលបានបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សាដែលមិនសូវពេញចិត្តនឹងការងារខ្លួនមានចំនួនតែ 1.4 ភាគរយ ប៉ុណ្ណោះ។ ការមិនពេញចិត្តនឹងការងារជាទូទៅកើតមានចំពោះកម្មករជំនាញទាបមិនដោយដៃ។

**តារាង 44 (3-26) កម្រិតពេញចិត្តនឹងការងាររបស់និស្សិតបានបញ្ចប់ និងបោះបង់ការសិក្សាតាមកម្រិតអប់រំ ក្នុងឆ្នាំ 2014**

| | បឋមសិក្សា | | មធ្យមសិក្សា | | ឧត្តមសិក្សា | |
|---|---|---|---|---|---|---|
| | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
| ពេញចិត្តណាស់ | 46.4 | 44.7 | 46.2 | 53.9 | 75.7 | 87.5 |
| ពេញចិត្តខ្លះ | 50.0 | 48.1 | 47.9 | 40.1 | 22.9 | 12.5 |
| មិនពេញចិត្តខ្លះ | 0.0 | 6.4 | 5.1 | 4.7 | 1.4 | 0.0 |
| មិនពេញចិត្តខ្លាំង | 3.6 | 0.9 | 0.9 | 1.3 | 0.0 | 0.0 |

***ប្រភព***៖ *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

កម្មវិធីសិក្សាដែលយុវជនពេញចិត្តគឺកម្មវិធីទូទៅ។ ការស្ទង់មតិស្តីពីការផ្លាស់ប្តូរពីសាលាទៅការងារឆ្នាំ 2012 បានបង្ហាញថា 40 ភាគរយ នៃយុវជនដែលមានអាយុពី 15 ទៅ 29 ឆ្នាំ ឆ្លើយថាពួកគេចង់សិក្សាកម្មវិធីទូទៅ ដូចជា ធុរៈកិច្ចជាដើម ហើយមានតែ 15 ភាគរយ ប៉ុណ្ណោះដែលបានជ្រើសយកវិទ្យាសាស្ត្រពិតដូចជា គណិតវិទ្យា និងកុំព្យូទ័រ។ តិចជាង 5 ភាគរយ បានជ្រើសយកវិស្វកម្ម ការផលិត និងសំណង់ និងមានតែ 3 ភាគរយ ប៉ុណ្ណោះ បានជ្រើសយកវិស័យកសិកម្ម និងពេទ្យសត្វ។ ដោយឃើញថា វិស័យកសិកម្មបានរួមចំណែកជិតមួយភាគបីនៃផលិតផលសរុបក្នុងស្រុក គម្លាតនៃការពេញចិត្តនឹងការងារបែបនេះគឺជាបញ្ហាគួរឱ្យបារម្ភ។ គម្លាតនេះកំពុងតែប្រទាញគ្នារវាងបំណងប្រាថ្នារបស់និស្សិត (ដែលមានអាយុពី 15 ទៅ 29 ឆ្នាំ) និងស្ថានភាពការងារពិតរបស់ពួកគេ ។ ភាគច្រើននៃនិស្សិតដែលមានអាយុពី 15ទៅ 29 ឆ្នាំ (63,3 ភាគរយ) ចង់បានការងារដែលមានជំនាញខ្ពស់ ប៉ុន្តែតាមការពិតមានតែ 5,4 ភាគរយ នៃពួកគេប៉ុណ្ណោះដែលទទួលបានការងារបែបនេះ។ មានតែ 32,8 ភាគរយ ប៉ុណ្ណោះដែលមានបំណងចង់បានការងារដែលមានជំនាញមធ្យម ប៉ុន្តែជាក់ស្តែង 88 ភាគរយ នៃពួកគេនៅទីបំផុតបែរជាទទួលបានការងារដែលមានជំនាញមធ្យមទៅវិញ (សូមមើលរូបភាព 3.4) ។ ការរកឃើញទាំងនេះមិនត្រឹមតែចោទទៅលើគុណភាពនៃការអប់រំប៉ុណ្ណោះទេ ប៉ុន្តែក៏ចង្អុលបង្ហាញពីកង្វះនៃការណែនាំអាជីព និងការគ្រប់គ្រងសេចក្តីប្រាថ្នាផងដែរ។ យ៉ាងណាមិញ គម្លាតនៃបំណងប្រាថ្នានៅក្នុងចំណោមនិស្សិតដែលបានទទួលការអប់រំនៅកម្រិតឧត្តមមានតិចតួចប៉ុណ្ណោះ ពោលគឺ 66 ភាគរយ ចង់បានការងារដែលមានជំនាញខ្ពស់ ហើយ 63 ភាគរយ នៃពួកគេទទួលបានការងារបែបនោះ។ ការអប់រំថ្នាក់ឧត្តមសិក្សាកំពុងទទួលបានជោគជ័យ។

**រូបភាព 23 (3-4) គម្លាតនៃសេចក្ដីប្រាថ្នារបស់យុវជន**




***ប្រភព*៖** *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

***ចំណាំ*៖** *និស្សិតកម្រិតឧត្តមសិក្សាអាយុពី 15-29 ឆ្នាំ ត្រូវបានសាកសួរអំពីសេចក្ដីប្រាថ្នាលើលក្ខខណ្ឌនៃការងារជំនាញ និងការប្រៀបធៀបជាមួយនឹងការងារបច្ចុប្បន្ននៃនិស្សិតបានបញ្ចប់ការសិក្សាដែលមានអាយុ 15ទៅ29 ឆ្នាំ។*

កម្មករកម្រិតបឋមស្ទើរតែមិនបានទទួលការបណ្ដុះបណ្ដាលដើម្បីបំប៉នជំនាញ និងលើកកម្ពស់ការងាររបស់ខ្លួនឡើយ ក្រៅអំពីកម្មសិក្សាស្ម័គ្រចិត្ត។ មានតែ 2.6 ភាគរយ នៃសិស្សដែលបានបញ្ចប់មធ្យមសិក្សាប៉ុណ្ណោះទទួលបានការបណ្ដុះបណ្ដាលរយៈពេលខ្លី ជាពិសេសអ្នកដែលមានការងារមិនដោយដៃ។ ក្នុងចំណោមនិស្សិតដែលបានបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា មានតែ 11 ភាគរយ ប៉ុណ្ណោះ បានចូលរួមវគ្គបណ្ដុះបណ្ដាលពាក់ព័ន្ធនឹងការងារដែលខ្លួនកំពុងធ្វើ។ ទោះយ៉ាងណា គ្មាននិស្សិតដែលបានបោះបង់ការសិក្សាកម្រិតឧត្តមសិក្សាណាម្នាក់ទទួលបាន ឬកំពុងស្វែងរកការបណ្ដុះបណ្ដាលនោះទេ ។

**តារាង 45 (3-27) ភាគរយនៃយុវជនដែលទទួលបានការបណ្ដុះបណ្ដាលពាក់ព័ន្ធនឹងការងារដែលខ្លួនកំពុងធ្វើ ក្នុងរយៈពេល 12 ខែចុងក្រោយ ក្នុងឆ្នាំ 2014**

| | បឋមសិក្សា | | មធ្យមសិក្សា | | ឧត្ដមសិក្សា | |
|---|---|---|---|---|---|---|
| | សិស្សបោះបង់ការសិក្សា | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា | សិស្សបោះបង់ការសិក្សា | សិស្សបានបញ្ចប់ការសិក្សា | សិស្សបោះបង់ការសិក្សា |
| **បាទ, បច្ចុប្បន្នកំពុងហ្វឹកហ្វឺន / កម្មសិក្សា** | 3.6 | 1.7 | 4.3 | 3.4 | 10.0 | 0.0 |
| **បាទ, មិនកំពុងហ្វឹកហ្វឺន / កម្មសិក្សាទេ** | 0.0 | 0.4 | 2.6 | 0.0 | 11.4 | 0.0 |
| **មិនទទួលបានការបណ្ដុះបណ្ដាល** | 96.4 | 97.9 | 93.2 | 96.6 | 78.6 | 100.0 |
| **សរុប** | 100 | 100 | 100 | 100 | 100 | 100 |

***ប្រភព*៖** *ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យ SWTS-Cambodia ឆ្នាំ 2014*

### ៣.៣.៤ ការងារសមរម្យ

គុណភាពនៃជីវិត និងសុខុមាលភាពរបស់បុគ្គលម្នាក់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការងារ។ នៅក្នុងប្រទេសសមាជិកមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD មនុស្សម្នាក់ចំណាយពេលធ្វើការជាមធ្យម 37 ម៉ោងក្នុងមួយសប្ដាហ៍ និងចំណាយពេលធ្វើការកាន់តែច្រើនពេលពួកគេកាន់តែពេញវ័យ ។ លើសពីនេះ គុណភាពការងារគឺជាកត្តាយ៉ាងសំខាន់ជំរុញឱ្យមានការចូលរួមបង្កើនកម្លាំងពលកម្ម ផលិតភាព និងសេដ្ឋកិច្ច។ យុវជនគ្មានការងារធ្វើនៅកម្ពុជាមានអត្រាទាប ប៉ុន្តែធនាគារពិភពលោកបានប៉ាន់ប្រមាណថា 73 ភាគរយ នៃកម្មករវ័យក្មេងគឺស្ថិតក្នុងប្រភេទការងារងាយរងគ្រោះ (យោងតាម World Bank, n.d. ) ។ អង្គការពលកម្មអន្តរជាតិបានកំណត់និយមន័យនៃការងារសមរម្យថា ជាការងារដែលផ្ដល់ឱ្យកម្មករនូវប្រាក់ចំណូលសមរម្យ សុវត្ថិភាពការងារ ការគាំពារសង្គមដល់ក្រុមគ្រួសាររបស់ពួកគេ លទ្ធផលរំពឹងទុកសម្រាប់ការអភិវឌ្ឍខ្លួននិងសមាហរណកម្មសង្គម សេរីភាពក្នុងការបញ្ចេញមតិ រៀបចំនិងចូលរួមក្នុងការសម្រេចចិត្តណាដែលអាចប៉ះពាល់ដល់ជីវិតរបស់ពួកគេ និងសមភាពនៃឱកាស និងការប្រព្រឹត្តស្មើគ្នារវាងបុរសស្ត្រី។

មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD បានបង្កើតក្របខ័ណ្ឌដើម្បីវាស់ស្ទង់ និងវាយតម្លៃគុណភាពការងារដោយផ្ដោតលើទំហំបីដែលអាចវាស់វែងបាន (three measurable dimensions)គឺ៖ “**គុណភាពប្រាក់ចំណូល** (Earnings quality)” សំដៅលើវិសាលភាពដែលប្រាក់ចំណូលនោះអាចរួមចំណែកដល់សុខុមាលភាពរបស់កម្មករក្នុងលក្ខខណ្ឌប្រាក់ចំណូលមធ្យម និងការបែងចែកស្របកម្លាំងពលកម្ម។ “**សន្តិសុខទីផ្សារការងារ** (Labour market security)” សំដៅលើទិដ្ឋភាពស្ថិរភាពសេដ្ឋកិច្ចពាក់ព័ន្ធនឹងហានិភ័យនៃការបាត់បង់ការងារ និងចំណាយសេដ្ឋកិច្ចរបស់កម្មករ។ អាចកំណត់បានថា ជាហានិភ័យពាក់ព័ន្ធនឹងការគ្មានការងារធ្វើ និងអត្ថប្រយោជន៍ដែលទទួលបាន ក្នុងករណីដែលគ្មានការងារធ្វើ។ “**គុណភាពនបរិស្ថានការងារ** (Quality of the working environment)” សំដៅលើទិដ្ឋភាពការងារដែលមិនមែនសេដ្ឋកិច្ច រាប់ទាំងធម្មជាតិ និងខ្លឹមសារនៃការងារដែលបានធ្វើ ការរៀបចំធ្វើម៉ោងធ្វើការ និងទំនាក់ទំនងនៅនឹងកន្លែងធ្វើការ។ នេះអាចថា ជាឧប្បត្តិហេតុនៃសម្ពាធការងារក៏ដូចជា តម្រូវការការងារខ្ពស់ជាងធនធានការងារ។ សរុបមក ទំហំទាំងបីអាចវាយតម្លៃគុណភាពការងារបានទូលំទូលាយ។

កម្មករគណនីផ្ទាល់ខ្លួន និងកម្មករគ្រួសារគ្មានប្រាក់ខែដែលចាត់ទុកថា ជាប្រភេទការងារងាយរងគ្រោះគឺជាផ្នែកមួយយ៉ាងសំខាន់នៃកម្លាំងពលកម្មនៅក្នុងប្រទេសកម្ពុជា។ ចាប់ពីឆ្នាំ 2009 ដល់ឆ្នាំ 2014 ភាគរយ នៃកម្មករគ្រួសារគ្មានប្រាក់ខែបានថយចុះពី 24 ភាគរយ មកត្រឹម 6 ភាគរយ ប៉ុន្តែ 43 ភាគរយ នៃកម្មករគណនីផ្ទាល់ខ្លួននៅតែជាអត្រាខ្ពស់ ដែលថយចុះតែបន្តិចប៉ុណ្ណោះ ពី 49 ភាគរយ នៅក្នុងឆ្នាំ 2009 (យោងតាម NIS 2015) ។ ពលកម្មកុមារគឺជាក្ដីបារម្ភមួយផ្សេងទៀតនៅក្នុងប្រទេសនេះ។ ចំនួននៃកុមារកំពុងធ្វើការនៅតែខ្ពស់ ដោយសារតែកុមារជាច្រើនបានបោះបង់ការសិក្សាដើម្បីជួយកិច្ចការផ្ទះ ឬធុរៈកិច្ចគ្រួសារ។ យោងតាមស្ថិតិវិទ្យាស្ថានជាតិ (NIS) អត្រានៃពលកម្មកុមារនៅឆ្នាំ 2014 មានចំនួន 19 ភាគរយ នៅក្នុងឆ្នាំ 2014 ដែលថយចុះតែបន្តិចប៉ុណ្ណោះពី 24 ភាគរយ នៅក្នុងឆ្នាំ 2012 ។ លើសពីនេះទៀត ការរងគ្រោះដោយសារការងារនៅកម្ពុជាកំពុងកើនឡើង (យោងតាម ILO 2012) ។ បើគ្មានឱកាសទទួលបានការងារសមរម្យទេ ការវិនិយោគក្នុងវិស័យអប់រំគឺមិនត្រូវបានគេឱ្យតម្លៃនោះទេ។ ការអនុវត្តច្បាប់តឹងរ៉ឹងប្រឆាំងនឹងពលកម្មកុមារ និងការកែលម្អលក្ខខណ្ឌការងារអាចជួយទប់ស្កាត់ការបោះបង់ការសិក្សារបស់កុមារ ។

## ៣.៤ ការអប់រំក្រៅប្រព័ន្ធ

ប្រព័ន្ធអប់រំនៅកម្ពុជារួមមាន ការអប់រំផ្លូវការ (formal education) និងការអប់រំក្រៅប្រព័ន្ធ (non-formal education)។ ដោយសារតែអត្រាអនក្ខរកម្ម និងអត្រាបោះបង់ការសិក្សារបស់យុវជនខ្ពស់ ការអប់រំក្រៅប្រព័ន្ធគឺជាជម្រើសយ៉ាងសំខាន់ដើម្បីផ្តល់ឱកាសអប់រំលើកទីពីរដល់យុវជនដែលបានចាកចេញពីប្រព័ន្ធអប់រំផ្លូវការ។ យោងតាមផែនការសកម្មភាពជាតិសម្រាប់ការអប់រំក្រៅប្រព័ន្ធឆ្នាំ 2008-2015 (Non-Formal Education National Action Plan 2008-2015) បានឱ្យដឹងថា ផែនការនេះគោលបំណងពង្រីកឱកាសទទួលបានការអប់រំឥតគិតថ្លៃ និងប្រកបដោយគុណភាពសម្រាប់កុមារដែលងាយរងគ្រោះ កុមារដែលបានបោះបង់សាលា ក្រុមជនជាតិភាគតិច និងអនក្ខរកម្មមនុស្សចាស់។ ការអប់រំក្រៅប្រព័ន្ធនៅប្រទេសកម្ពុជាគ្របដណ្តប់កម្មវិធីបីសំខាន់គឺ អក្ខរកម្ម (literacy) ការបន្តការអប់រំ (continuing education) និងការអប់រំសហគមន៍ (community education)។ គោលបំណងនៃការអប់រំក្រៅប្រព័ន្ធគឺដើម្បីបំពាក់ឱ្យអ្នកទាំងនោះមានជំនាញជាមូលដ្ឋាន ដើម្បីឱ្យពួកគេអាចបង្កើនជីវភាពរស់នៅ និងដើម្បីផ្តល់ឱកាសឱ្យយុវជនក្រៅសាលាបានចូលទៅក្នុងប្រព័ន្ធអប់រំផ្លូវការលើកទីពីរ។

### ៣.៤.១ ថ្នាក់អក្ខរកម្ម

នៅក្នុងផែនការសកម្មភាពជាតិសម្រាប់ការអប់រំក្រៅប្រព័ន្ធឆ្នាំ 2008-2015 ក្រសួងអប់រំបានកំណត់ទិសដៅបើកថ្នាក់អក្ខរកម្មឱ្យបានចំនួន 2400 ថ្នាក់ និងមានសិស្សចំនួន 60 000 នាក់ ជារៀងរាល់ឆ្នាំ។ គោលបំណងនេះ គឺដើម្បីជួយដល់មនុស្សមួយចំនួនធំដែលមិនបានរៀនដោយសារតែសង្គ្រាមចាប់ពីដើមទសវត្សរ៍ឆ្នាំ 1970 ដល់ចុងទសវត្សរ៍ឆ្នាំ 1990 ។ ថ្នាក់អក្ខរកម្មនេះមានតួនាទីបង្រៀនសិស្សឱ្យចេះអាន និងចេះគណនាកម្រិតមូលដ្ឋាន។ កម្មវិធីទាំងអស់ផ្តល់ហិរញ្ញប្បទានដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា។

ចំនួនសិស្សស្រីខ្ពស់ជាងសិស្សប្រុសច្រើនណាស់។ ចំនួនថ្នាក់រៀនបានថយចុះពីកម្រិតខ្ពស់បំផុតនៅក្នុងឆ្នាំ 2005 ប៉ុន្តែចំនួនសិស្សមធ្យមក្នុងមួយថ្នាក់គឺ 22 នាក់ ។ ចំនួនសិស្សដែលមានអាយុចន្លោះពី 25 ទៅ 45 ឆ្នាំ គឺលេចធ្លោ (យោងតាម ក្រសួងអយក. ឆ្នាំ 2014) ។

**តារាង 46 (-28) ថ្នាក់អក្ខរកម្ម ឆ្នាំ 2000-14**

| ឆ្នាំ | ចំនួនថ្នាក់ | ចំនួនសិស្ស | | | ចំនួនសិស្សបានបញ្ចប់ការសិក្សា | | | ចំនួនសិស្សក្នុងមួយថ្នាក់ |
|---|---|---|---|---|---|---|---|---|
| | | សរុប (ចំនួន) | ប្រុស (ភាគរយ) | ស្រី (ភាគរយ) | សរុប (ភាគរយ) | ប្រុស (ភាគរយ) | ស្រី (ភាគរយ) | |
| **2000** | 1574 | 30,449 | 24 | 76 | 55 | 66 | 51 | 19 |
| **2005** | 5410 | 119,686 | 41 | 59 | 64 | 51 | 74 | 22 |
| **2010** | 1314 | 30,806 | 35 | 65 | 82 | 80 | 83 | 23 |
| **2014** | 1190 | 26,601 | 32 | 68 | 83 | 80 | 84 | 22 |

*ប្រភព៖ អយក. ឆ្នាំ 2014*

### ៣.៤.២ ការបន្តការអប់រំ

ការបន្តការអប់រំមានបំណងជួយអ្នកដែលមានជំនាញមូលដ្ឋានមួយចំនួនបានបន្តការសិក្សា។ បណ្ណាល័យសម្រាប់ថ្នាក់ក្រោយអក្ខរកម្មត្រូវបានបង្កើតឡើងដើម្បីជួយរក្សាចំណេះដឹងរបស់អ្នកដែលបានបញ្ចប់ថ្នាក់អក្ខរកម្មមិនឱ្យចុះខ្សោយ។ កម្មវិធីអប់រំជាថ្មី មានគោលបំណងនាំយកកុមារដែលបានបោះបង់ការសិក្សាតិចជាងបីឆ្នាំត្រឡប់ទៅការអប់រំជាផ្លូវការឡើងវិញ។ គោលដៅពិសេសរបស់កម្មវិធីគឺយុវតីដែលបានចាកចេញពីសាលាទៅជួយការងារគ្រួសារ។ ពួកគេត្រូវទទួលបានការបណ្តុះបណ្តាលរយៈពេលពីរខែ មុនពេលបញ្ចូលទៅក្នុងការអប់រំផ្លូវការឡើងវិញ។ កម្មវិធីទីបី គឺជាកម្មវិធីសមមូលនឹងបឋមនិងមធ្យមសិក្សា។ កម្មវិធីនេះផ្តល់ឱកាសលើកទីពីរឱ្យយុវជននិងមនុស្សចាស់ដែលបានចាកចេញពីបឋមសិក្សានិងមធ្យមសិក្សាបានសិក្សាម្តងទៀត និងទទួលបានសញ្ញាបត្រសមមូល។ កម្មវិធីនេះអាចអនុវត្តក្រៅម៉ោង ដើម្បីឱ្យអ្នកធ្វើការអាចចូលរួមបាន។

### ៣.៤.៣ ការអប់រំសហគមន៍/មជ្ឈមណ្ឌលសិក្សាសហគមន៍

គោលដៅរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ (Community Learning Centres ហៅកាត់ថា CLC) គឺសិក្សាក្រៅផ្លូវការរបស់មនុស្សចាស់ ។ CLC ផ្តល់ការបណ្តុះបណ្តាលលើជំនាញបង្កើតប្រាក់ចំណូលមូលដ្ឋាន រួមទាំង ការធ្វើកសិកម្ម និងការគ្រប់គ្រងធនធានក្នុងមូលដ្ឋាន។ CLC មិនត្រឹមតែផ្តល់ឱ្យសហគមន៍នូវព័ត៌មានអំពីបទពិសោធន៍ផ្សេងៗក្នុងការបង្កើតប្រាក់ចំណូលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្រៀនអំពីសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ សមភាពយេនឌ័រ កសិកម្ម និងអនាម័យ។ សិស្សភាគច្រើនគឺជាស្ត្រី។ ក្នុងឆ្នាំ 2014 មាន CLC ចំនួន 344 កន្លែងដែលភាគច្រើនប្រតិបត្តិការដោយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន។ ក្រសួងអប់រំ យុវជន និងកីឡា គ្រោងនឹងបង្កើត CLC យ៉ាងហោចណាស់ឱ្យបានមួយៗនៅក្នុងឃុំទាំង 1600 ឃុំ ។

**តារាង 47 (3-29) CLC និងសិស្ស ឆ្នាំ 2006 ឆ្នាំ 2010 និងឆ្នាំ 2014**

| ឆ្នាំ | ចំនួនមជ្ឈមណ្ឌល | | ចំនួនសិស្ស | | | ចំនួនសិស្សបានបញ្ចប់ការសិក្សា | |
|---|---|---|---|---|---|---|---|
| | សរុប | ប្រតិបត្តិការ | សរុប | ប្រុស ភាគរយ | ស្រី ភាគរយ | ប្រុស ភាគរយ | ស្រី ភាគរយ |
| **2006** | 57 | 57 | 2155 | 33 | 67 | 33 | 67 |
| **2010** | 217 | 164 | 6994 | 44 | 56 | 46 | 54 |
| **2014** | 347 | 334 | 9916 | 37 | 63 | 37 | 63 |

*ប្រភព៖ ក្រសួងអយក.ឆ្នាំ 2014*

(យោងតាម CRCC, 2015) ការពិនិត្យឡើងវិញលើមជ្ឈមណ្ឌលសិក្សាសហគមន៍ (CLC) បានរកឃើញថា CLC គ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលបានផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលជំនាញច្រើនជាង CLC ដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ CLC ដែលគ្រប់គ្រងដោយរដ្ឋាភិបាលផ្តោតសំខាន់ទៅលើការនាំសិស្សឱ្យចូលទៅក្នុងការអប់រំផ្លូវការ និងអក្ខរកម្ម។

ចំណែកការបណ្តុះបណ្តាលជំនាញដែលផ្តល់ដោយ CLC របស់អង្គការក្រៅរដ្ឋាភិបាលមានមុខវិជ្ជាច្រើនដូចជា ការដេរ ការធ្វើសក់ ការដាំដុះស្រូវនិងបន្លែ ការត្បាញសូត្រនិងកន្ទេល ការកែច្នៃម្ហូបអាហារ គម្រោងបង្កើតប្រាក់ចំណូល ជួសជុលម៉ូតូ ជួសជុលឧបករណ៍អគ្គិសនី ចម្លាក់ តន្ត្រីនិងសិល្បៈ។ ការផ្តល់ហិរញ្ញប្បទានជាបញ្ហាសំខាន់សម្រាប់ CLC គ្រប់គ្រងដោយរដ្ឋ។ មូលនិធិបម្រុងសរុបសម្រាប់ CLC គឺមានតែ 1 ភាគរយ នៃថវិកាអប់រំសរុបប៉ុណ្ណោះ។

កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីផ្សេងទៀតផ្តល់ដោយរាជរដ្ឋាភិបាលរួមមាន ជំនាញសហគ្រិនមូលដ្ឋានដើម្បីចាប់ផ្តើមសកម្មភាពបង្កើនប្រាក់ចំណូល ឬអាជីវកម្មខ្នាតតូច បណ្តុះបណ្តាលជនក្រីក្របំផុតអំពីសុខភាព អនាម័យ បរិស្ថាននិងកសិកម្ម និងការកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ខេត្ត និងស្រុក និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល។

### ៣.៤.៤ ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ

នៅឆ្នាំ 2014 ក្នុងចំណោមនិស្សិតបញ្ចប់ថ្នាក់ក្រោយមធ្យមសិក្សាចំណេះទូទៅចំនួន 250 000 នាក់ មានតែ 3 ភាគរយ ប៉ុណ្ណោះ ដែលបានសិក្សាវិជ្ជាជីវៈបច្ចេកទេសដូចជា កសិកម្ម វិទ្យាសាស្ត្រ និងវិស្វកម្ម ខណៈដែល 50 ភាគរយ បានសិក្សាផ្នែកគ្រប់គ្រងពាណិជ្ជកម្ម (ក្រសួង អយក. ឆ្នាំ 2015)។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (Ministry of Labour and Vocational Training ហៅកាត់ថា MOLVT) បានប៉ាន់ប្រមាណថា បច្ចុប្បន្នមានសិស្សចំនួន 36 120 នាក់ បានចូលរៀននៅនៅក្នុងកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (technical and vocational education and training ហៅកាត់ថា TVET) សាធារណៈទាំង 39 និងស្ថាប័ននានាដែលបានចុះបញ្ជីក្នុងជាមួយ MOLVT (កម្មវិធីរួមគ្នា) ដែលក្នុងនោះ 80 ភាគរយ នៃពួកគេមានអាយុចន្លោះពី 15 ឆ្នាំទៅ 29 ឆ្នាំ (យោងតាមស្ថិតិ TVET ឆ្នាំ2015-16 )។ បើធៀបនឹងចំនួនយុវជនក្រៅសាលានៅក្នុងប្រទេសកម្ពុជា TVET មានអត្រាចុះឈ្មោះចូលរៀនទាបណាស់។ មួយផ្នែកគឺដោយសារតែគុណភាព នៃស្ថាប័នទាំងនេះ ប៉ុន្តែមូលហេតុធំគឺថា ឪពុកម្តាយគិតថា TVET បណ្តុះបណ្តាលសម្រាប់ការងារជំនាញទាប និងមិនមែនជំនាញខ្ពស់ទេ។ ដោយហេតុនេះ សក្តានុពលរបស់ TVET ក្នុងជួយការជួយបណ្តុះបណ្តាលយុវជនដើម្បីបំពេញតាមតម្រូវការនៃទីផ្សារការងារ ពួកគាត់មិនយល់ទេ។

បន្ទាប់ពីបានបញ្ចប់ការសិក្សានៅអនុវិទ្យាល័យ សិស្សអាចជ្រើសយកការបន្តការអប់រំចំណេះទូទៅបីឆ្នាំទៀត ដើម្បីទទួលបានសញ្ញាបត្របាក់ឌុប ឬអាចចុះឈ្មោះចូលរៀនក្នុងកម្មវិធី TVET ជាផ្លូវការ។ កម្មវិធី TVET មធ្យមសិក្សានេះ មានរយៈពេលតែមួយឆ្នាំគត់ ហើយសិស្សនឹងទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេស រួមមាន ការជួសជុលរថយន្ត មេកានិចទូទៅ មេកានិចកសិកម្ម អគ្គិសនី អេឡិចត្រូនិច ជួសជុលម៉ាស៊ីនត្រជាក់ សំណង់ស៊ីវិល និងបច្ចេកវិទ្យាកុំព្យូទ័រ។ TVET ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ MoLVT ដែលមានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តជាស្ថាប័នប្រតិបត្តិ ។ កម្មវិធី TVET ផ្សារភ្ជាប់ទៅកម្មវិធីអប់រំចំណេះទូទៅផ្តល់ដោយកសួងអប់រំ យុវជន និងកីឡា។

តារាង 48 (3-30) ការចុះឈ្មោះចូលរៀនតាមកម្រិតបណ្តុះបណ្តាល (ស្ថាប័នចុះបញ្ជីជាមួយ TVET និង MoLVT)

| ចំនួនសរុបនៃស្ថាប័ន 39 (ទូទាំងប្រទេស) | វគ្គខ្លី | C1 | C2 | C3 | សញ្ញាបត្រ បាក់ឌុប | បរិញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | បណ្ឌិត |
|---|---|---|---|---|---|---|---|---|
| *សរុប* | 12 074 | 1 478 | 309 | 203 | 6 888 | 15 116 | 52 | 0 |
| *ស្រី* | 6 601 | 358 | 41 | 23 | 948 | 3 412 | 2 | 0 |

***ប្រភព៖*** *ក្រសួងការងារ 2015-16*

***ចំណាំ៖*** *C1, C2 និង C3 គឺជាកម្រិតទាំង 3 នៃវិញ្ញាបនប័ត្រវិជ្ជាជីវៈ បច្ចេកទេស។*

សិស្សដែលបានបញ្ចប់មធ្យមសិក្សាចំណេះទូទៅអាចចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (TVET) ។ ទោះជាយ៉ាងណា កម្មវិធី TVET កម្រិតមធ្យម មិនដូចគ្នានឹងមធ្យមសិក្សាចំណេះទូទៅទេ ព្រោះរយៈពេលនៃការបណ្តុះបណ្តាលនៅ TVET អាស្រ័យលើកម្មវិធី និងមានរយៈពេលយ៉ាងហោចណាស់មួយឆ្នាំ។ ឧទាហរណ៍៖ កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសត្រូវផ្តល់ការបណ្តុះបណ្តាលដល់ទៅពីរ ឬបីឆ្នាំ និងបន្ទាប់ពីបញ្ចប់ការសិក្សា និស្សិតនឹងទទួលបាន "សញ្ញាបត្របច្ចេកទេស" ។

កម្មវិធី TVET ផ្លូវការនិងក្រៅប្រព័ន្ធផ្តល់ជូននូវវគ្គសិក្សាខ្លីៗ ដោយមានគោលបំណងជួយកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ។ រយៈពេលបណ្តុះបណ្តាលខ្លី គឺពីមួយខែទៅបួនខែ និងប្រតិបត្តិការនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ ការការបណ្តុះបណ្តាលមានដូចជា ផលិតកម្មកសិកម្មមូលដ្ឋាន សំណង់ ជំនាញជួសជុលម៉ូតូ សិប្បកម្ម និងការកែច្នៃម្ហូបអាហារ។

ទំនាក់ទំនងរវាង TVET និងការអប់រំចំណេះទូទៅនឹងបង្ហាញក្នុងតារាងខាងក្រោម៖

តារាង 49 (3-31) TVET ផ្លូវការ និងប្រព័ន្ធអប់រំចំណេះទូទៅ

| ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ | ប្រព័ន្ធអប់រំចំណេះទូទៅ | ប្រព័ន្ធ TVET | ប្រព័ន្ធអប់រំឧត្តមសិក្សា |
|---|---|---|---|
| 8 | | សញ្ញាបត្របណ្ឌិត | សញ្ញាបត្របណ្ឌិត |
| 7 | | បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក បច្ចេកវិទ្យា/អាជីវកម្ម | បរិញ្ញាបត្រជាន់ខ្ពស់ |
| 6 | | បរិញ្ញាបត្រផ្នែកបច្ចេកវិទ្យា/ វិស្វកកម្ម/អាជីវកម្ម | បរិញ្ញាបត្រ |
| 5 | | សញ្ញាបត្រលើបាក់ឌុបផ្នែក បច្ចេកវិទ្យា/អាជីវកម្ម | បរិញ្ញាបត្ររង |
| 4 | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | សញ្ញាបត្រ TVET កម្រិត III | |
| 3 | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | សញ្ញាបត្រ TVET កម្រិត II | |

| | | | |
|---|---|---|---|
| 2 | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | សញ្ញាបត្រ TVET កម្រិត I | |
| 1 | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | សញ្ញាបត្រវិជ្ជាជីវៈជំនាញ | |

*ប្រភព៖ CRCC ឆ្នាំ2015*

### ៣.៤.៥ បទពិសោធន៍ពីបរទេស

នៅក្នុងផ្នែកនេះ នឹងពិពណ៌នាឧទាហរណ៍នៃការបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (TVET) និងការអប់រំក្រៅផ្លូវការពីបណ្តាប្រទេសផ្សេងៗ។

#### *៣.៤.៥.១ ការអប់រំ និង TVET នៅប្រទេសហ្គាណា*

នៅប្រទេសហ្គាណា ក្រុមប្រឹក្សាសម្រាប់ការអប់រំ និងបណ្តុះវិជ្ជាជីវៈបច្ចេកទេស (Council for Technical and Vocational Education and Training ហៅកាត់ថា COTVET) បានបង្កើតឡើងក្នុងឆ្នាំ 2006 ដើម្បីសម្របសម្រួល និងត្រួតពិនិត្យគ្រប់ទិដ្ឋភាពទាំងអស់ នៃការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (TVET) នៅក្នុងប្រទេសនេះ។ នៅពេលបានបញ្ចប់ការសិក្សានៅអនុវិទ្យាល័យ យុវជនអាចជ្រើសបន្តការសិក្សានៅវិទ្យាល័យ ឬចូលរៀននៅសាលាជាន់ខ្ពស់ សាលាបច្ចេកទេសកម្រិតមធ្យម ឬវិទ្យាស្ថានបច្ចេកទេសណាមួយ។ មានការផ្តល់ការបណ្តុះបណ្តាលក្រៅប្រព័ន្ធផងដែរ ដែលភាគច្រើនតាមរយៈការហាត់រៀនជាមួយសិប្បករ ខណៈដែលវគ្គបណ្តុះបណ្តាលក្រៅផ្លូវការជាច្រើនទៀតត្រូវបានផ្តល់ដោយអង្គការសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលជាពិសេស។ ប្រទេសហ្គាណាបានខិតខំប្រឹងប្រែងដើម្បីបង្កើតក្របខ័ណ្ឌគុណវុឌ្ឍិជាតិតាមរយៈ TVET ដោយមានគោលបំណងលើកកម្ពស់អាជីពរបស់និស្សិតដែលបានបញ្ចប់ TVET ។ COTVET ក៏ទទួលខុសត្រូវចំពោះការអនុវត្តកម្មវិធីជាតិហ្វឹកហ្វឺន (National Apprenticeship Programme ហៅកាត់ថា NAP) ផងដែរ។ NAP ជាកម្មវិធីបណ្តុះបណ្តាលរយៈពេលមួយឆ្នាំដែលផ្តួយុវជនដែលមានការអប់រំត្រឹមកម្រិតណាមួយជាមួយនឹងគ្រូបង្រៀនដែលកំពុងប្រតិបត្តិការអាជីវកម្មខ្នាតតូចណាម្នាក់។ កម្មវិធីនេះភាគច្រើនមានគោលដៅលើយុវជនដែលមិនអាចបន្តការសិក្សាថ្នាក់ក្រោយអនុវិទ្យាល័យ។ ដូចគ្នាជាមួយនឹងម៉ូដែលហ្វឹកហ្វឺនពីបុរាណដែរ COTVET បានប្តេជ្ញាបង់ប្រាក់ឱ្យគ្រូបង្រៀន និងផ្តល់ឯកសារដល់កូនសិស្សដែលកំពុងរៀនជាមួយ។ NAP ក៏មានបញ្ចូលគម្រោងថវិកាស្នាដៃច្នៃប្រឌិតជូនដល់គ្រូបង្រៀនដែលបានបណ្តុះបណ្តាលកូនសិស្សទទួលបានលទ្ធផលល្អតាមកម្រិតជំនាញផងដែរ។ NAP នឹងផ្តល់ឱកាសឱ្យសិស្សបានហ្វឹកហាត់នៅក្នុងវិស័យក្រៅប្រព័ន្ធ។

#### *៣.៤.៥.២ មជ្ឈមណ្ឌលសិក្សាសហគមន៍នៅប្រទេសឥណ្ឌូណេស៊ី*

រដ្ឋាភិបាលឥណ្ឌូណេស៊ីមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍ (Community Learning Centres ហៅកាត់ថា CLC) ដូចមានភ័ស្តុតាងបង្ហាញថា ចំនួន CLC កើនឡើងពី 484 ក្នុងឆ្នាំ 1999 ទៅ 3064 ក្នុងឆ្នាំ 2008 ដែលបានរៀបចំនៅទូទាំងប្រទេស។ កម្មវិធីសំខាន់រួមមាន អក្ខរកម្មមុខងារ ការអប់រំកុមារតូច ការអប់រំសមមូល ជំនាញវិជ្ជាជីវៈ សហគ្រិនភាព កីឡានិងការកម្សាន្ត និងការអប់រំស្ត្រី។ CLC ត្រូវបានគេរកឃើញថា មានប្រសិទ្ធភាពក្នុងការលើកកម្ពស់ចំណេះដឹងសហគមន៍។ ប្រសិទ្ធភាពរបស់ CLC ត្រូវបានវាស់ផ្អែកលើសូចនាករដូចជាវត្តមានរបស់សិស្ស ស្ថានភាពសង្គមរបស់សិស្ស ប្រវត្តិគ្រូបង្រៀន និងប្រភេទនៃអគារ CLC ។ ផលប៉ះពាល់វិជ្ជមានក៏ត្រូវបានគេរកឃើញផងដែរ គឺថា តាមរយៈកម្មវិធី CLC សហគមន៍អាចកែលម្អស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេ។ យុវជនមានឱកាសចូលបន្តការសិក្សាជាផ្លូវការឡើងវិញបន្ទាប់ពីបានចូលរួមវគ្គសិក្សានៅ CLC ។ តាមរយៈកម្មវិធីបង្កើតប្រាក់ចំណូល (income-generating programme) យុវជនអាចបង្កើតជាក្រុមបើកហាងមេកានិកមួយ និងបង្កើតឧស្សាហកម្មខ្នាតតូចផ្សេងទៀត។ តាមរយៈកម្មវិធីអប់រំនិងគាំពារកុមារតូច (early childhood care and education) ឪពុកម្តាយមានទឹកចិត្តក្នុងការបញ្ជូនកូនទៅសាលារៀន។ តាមរយៈកម្មវិធីការអប់រំគ្រួសារ និងកីឡានិងការកំសាន្ត (family education and sport and recreation programmes) សហគមន៍បានចាប់ផ្តើមអនុវត្តបែបផែនជីវិតរស់នៅប្រកបដោយសុខភាពល្អ (យោងតាម UNESCO 2008b) ។

CLC នៅឥណ្ឌូណេស៊ីភាគច្រើនផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាល ដែលមិនអាចទ្រទ្រង់មជ្ឈមណ្ឌលបានយូរអង្វែងទេ។ ការវាយតម្លៃរបស់ UNESCO បានរកឃើញថា តម្លាភាពក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃ CLC ទាក់ទងទៅនឹងនិរន្តរភាព។ ដូច្នេះ ការចូលរួមរបស់សហគមន៍ និងការចូលរួមចំណែកពីសិស្សដល់ថវិកាប្រតិបត្តិការ CLC អាចបង្កើននិរន្តរភាពរបស់វាបាន។

មេរៀនសំខាន់ដែលអាចរៀនបានពីបទពិសោធន៍របស់ប្រទេសឥណ្ឌូណេស៊ីគឺ បុគ្គលិក CLC និងការគ្រប់គ្រងគួរតែបន្តវាយតម្លៃតម្រូវការរបស់សហគមន៍ ជាពិសេសសម្រាប់កម្មវិធីបង្កើតប្រាក់ចំណូល។ បែបនេះអាចឱ្យមជ្ឈមណ្ឌលផ្តល់នូវជំនាញតាមតម្រូវការដល់សហគមន៍។ លើសពីនេះទៀតអ្នកគ្រប់គ្រង និងបុគ្គលិកទីនោះគួរមានសមត្ថភាពក្នុងការបង្កើតប្រាក់ចំណូលសម្រាប់មជ្ឈមណ្ឌលនេះ ដោយមិនមែនពឹងផ្អែកខ្លាំងពេកលើមូលនិធិពីរដ្ឋាភិបាលនោះទេ ហើយក៏ត្រូវបង្កើតប្រាក់ចំណូលសម្រាប់សហគមន៍ផងដែរ។

#### *៣.៤.៥.៣ គម្រោងផ្តួចផ្តើមជីវភាពយុវជនក្រៅសាលា (IDEJEN) នៅប្រទេសហៃទី*

គម្រោងផ្តួចផ្តើមជីវភាពយុវជនក្រៅសាលារបស់ហៃទីឈ្មោះថា (*Initiative pour le développement des jeunes en dehors du milieu scolaire* ហៅកាត់ថា IDEJEN (2003 11) មានគោលដៅលើយុវជនក្រៅសាលាដែលមានអាយុពី 15 ទៅ 24 ឆ្នាំ។ គម្រោងនេះមានគោលបំណងអភិវឌ្ឍជំនាញអក្ខរកម្មរបស់យុវជនដែលបានសិក្សាតិចតួច ឬមិនបានសិក្សាតាមរយៈការអប់រំក្រៅប្រព័ន្ធមូលដ្ឋាន ។ IDEJEN ប្រើប្រាស់វិធីសាស្ត្រប្រព័ន្ធសិក្សារួមអាចបត់បែនបាន ដែលបញ្ចូលអក្ខរកម្មនិងការរៀនលេខ អប់រំបំណិនជីវិត ការបណ្តុះបណ្តាលបច្ចេកទេស និងការរៀបចំសម្រាប់ឱកាសជីវិតនានា ។ មជ្ឈមណ្ឌលយុវជនបង្រៀននិស្សិតអំពីការអប់រំមូលដ្ឋាន បំណិនជីវិត និងការអប់រំវិជ្ជាជីវៈ/បច្ចេកទេស ដែលតាមតាមរយៈនេះ អ្នកសិក្សាអាចគ្រប់គ្រងជំនាញយ៉ាងសំខាន់ត្រៀមសម្រាប់ការងារ។ យុវជនត្រូវបានបំពាក់ដោយជំនាញស្នូល (ឧទាហរណ៍៖ ជំនាញដែលបង្រៀនពួកគេអំពីរបៀបរៀនធ្វើពាណិជ្ជកម្ម) និងជំនាញពាណិជ្ជកម្មជាក់លាក់ណាមួយ ដែលពួកគេអាចប្រើប្រាស់ដើម្បីគាំទ្រជីវភាពរស់នៅរបស់ពួកគេ។ ការបណ្តុះបណ្តាលអំពីការងារមូលដ្ឋាន ត្រូវបន្តដោយដំណាក់កាលអនុវត្តស្របគ្នានឹងជីវភាពរស់នៅរយៈពេលប្រាំមួយខែ ដែលក្នុងអំឡុងពេលនេះ បុគ្គលិកបណ្តុះបណ្តាលត្រូវផ្តល់ការគាំទ្រដែលជាស្ពានសម្រាប់ពួកគេ ការប្រឹក្សា និងសេវាផ្សេងៗព្រោះថា យុវជនអាចត្រឡប់ទៅសាលារៀនវិញ ឬស្វែងរកការងារនៅក្នុងវិស័យសេដ្ឋកិច្ចផ្លូវការ ឬមិនផ្លូវការ។

#### *៣.៤.៥.៤ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ នៅអាហ្វ្រិកខាងត្បូង*

អាហ្វ្រិកខាងត្បូងបានអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិក្នុងឆ្នាំ 1998។ វាត្រូវបានរចនាឡើងជាប្រព័ន្ធរួមដោយមានរបៀបវារៈផ្លាស់ប្តូរដើម្បីលើកកម្ពស់ការសិក្សាសម្រាប់អាហ្វ្រិកខាងត្បូងតាមបែបលទ្ធិប្រជាធិបតេយ្យមិនប្រកាន់ភេទ និងជាតិសាសន៍។ ក្របខ័ណ្ឌនេះមានបំណងបង្កើតក្របខ័ណ្ឌថ្នាក់ជាតិរួមតែមួយសម្រាប់សមិទ្ធផលសិក្សា ជួយសម្រួលដល់ដំណើរការចល័ត និងការរីកចម្រើននៅក្នុងវិស័យអប់រំ ការបណ្តុះបណ្តាលនិងអាជីព

បង្កើនគុណភាពអប់រំនិងបណ្តុះបណ្តាល និងការពន្លឿនការលុបបំបាត់ការរើសអើងមិនត្រឹមត្រូវកន្លងមក។ រដ្ឋាភិបាលបានធ្វើការកែទម្រង់ថ្មីនៅក្នុងក្របខ័ណ្ឌនេះដើម្បីសម្រួលនិងកំណត់ការរីកសាយនៃគុណវុឌ្ឍិផ្សេងគ្នា។ ក្របខ័ណ្ឌគុណវុឌ្ឍិថ្មីនេះបែងចែកកម្រិតនៃសមិទ្ធផលចំនួនដប់ និងបានកំណត់អនុក្របខ័ណ្ឌបីទៀតគឺ (១) គុណវុឌ្ឍិអប់រំចំណេះទូទៅនិងការអប់រំនិងការបណ្តុះបណ្តាលបន្ថែម (General and Further Education and Training Qualifications) (២) គុណវុឌ្ឍិឧត្តមសិក្សា (Higher Education Qualifications) និង (៣) គុណវុឌ្ឍិការងារ និងពាណិជ្ជកម្ម (Trades and Occupations Qualifications)។ ការធ្វើកំណែទម្រង់ទាំងនេះមានគោលបំណងដើម្បីលើកកម្ពស់ការផ្លាស់ប្តូរពីសាលាទៅការងារ និងដើម្បីផ្តល់ការណែនាំអាជីពឱ្យមានប្រសិទ្ធភាពជាងមុន និងការទទួលស្គាល់ការសិក្សាកន្លងមក។ គោលបំណងមួយទៀតនៃកំណែទម្រង់នេះគឺដើម្បីបង្កើនការសម្របសម្រួលក្នុងចំណោមស្ថាប័នផ្សេងគ្នា និងភាគីពាក់ព័ន្ធនៅក្នុងប្រព័ន្ធអប់រំ។ គោលនយោបាយ និងការវាយតម្លៃបញ្ចប់ស្តីពីការទទួលស្គាល់ការរៀនមុនៗ ការចុះបញ្ជីគុណវុឌ្ឍិ ការទទួលស្គាល់គុណភាពស្ថាប័នជំនាញ ការប្រមូលផ្តុំ និងការផ្ទេរឥណទានត្រូវបានបង្កើតឡើង។ គម្រោងសេវាដំបូន្មានអាជីពជាតិត្រូវបានបង្កើតឡើងដើម្បីជួយដល់អ្នកប្រើប្រាស់ស្វែងរកប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាល មានឃ្លាំងព័ត៌មានតម្កល់សមិទ្ធផលសិក្សា និងផ្តល់នូវការយល់ដឹងទៅក្នុងស្ថានភាពនៃប្រព័ន្ធនេះ នេះបើយោងតាមទិន្នន័យកំណត់ត្រាថ្នាក់ជាតិរបស់អ្នកសិក្សា (National Learners' Records Database) ។

៣.៥ សន្និដ្ឋាន និងអនុសាសន៍

អត្រាបោះបង់ការសិក្សាក្នុងចំណោមសិស្សមធ្យមសិក្សាទុតិយភូមិនៅតែមានកម្រិតខ្ពស់។ ប្រសិនបើបញ្ចូលគ្នាជាមួយនឹងអត្រាចុះឈ្មោះចូលរៀនទាបផងនោះ ភាគរយនៃក្មេងជំទង់ដែលមានអាយុរៀននៅមធ្យមសិក្សាទុតិយភូមិដែលនៅក្រៅសាលាមានចំនួនជិតមួយភាគបួន។ កត្តាជំរុញឱ្យមានការបោះបង់ការសិក្សានេះគឺស្មុគស្មាញ និងមានច្រើន រាប់ចាប់តាំងពីតម្លៃទាបដែលឪពុកម្តាយមើលឃើញក្នុងការវិនិយោគនៅក្នុងវិស័យអប់រំ ដោយសារតែគុណភាពអប់រំនៅទាប។

តាមពិត គុណភាពអប់រំដែលវាយតម្លៃតាមរយៈប្រភេទការងារដែលយុវជនអាចរកបានបន្ទាប់ពីការបញ្ចប់ការសិក្សានោះមិនអាចទាក់ទាញឪពុកម្តាយឱ្យទុកកូននៅរៀនក្នុងសាលានោះទេ។ ប្រការនេះវាពិតមួយភាគដែរ ជាពិសេសសម្រាប់គ្រួសារក្រីក្រតែម្តង ព្រោះថា យុវជនមានវ័យកាន់តែចាស់កាន់តែចង់រកការងារមានប្រាក់ខែ និងចង់រួមចំណែករកប្រាក់ចំណូលសម្រាប់គ្រួសារ។ ដោយសារតែភាគច្រើន នៃយុវជនដែលបានបោះបង់បឋម និងមធ្យមសិក្សាអាចរកបានការងារមានប្រាក់ខែបានធ្វើ តម្លៃឱកាសនៃការបញ្ជូនកូនទៅសាលារៀនក្លាយជាខ្ពស់ ពិសេសពេលដែលគុណភាពការងារមិនខុសគ្នាច្រើនរវាងអ្នកបានបញ្ចប់ ឬមិនបានបញ្ចប់មធ្យមសិក្សា។ ឧបសគ្គផ្នែកហិរញ្ញវត្ថុ គឺជាមូលហេតុលេខមួយដែលបណ្តាលឱ្យយុវជនបោះបង់ការសិក្សា។ ដូច្នេះ គោលនយោបាយត្រូវតែមានគោលបំណងជួយដល់ក្រុមគ្រួសារទាំងនោះឱ្យជម្នះឧបសគ្គផ្នែកហិរញ្ញវត្ថុក្នុងការបញ្ជូនកូនទៅសាលារៀន។ កម្មវិធីផ្តល់ប្រាក់កម្ចីមានលក្ខខណ្ឌដែលអាចផ្តល់ប្រយោជន៍ដល់ការសិក្សារបស់កុមារ អាចមានប្រសិទ្ធិភាពក្នុងការបន្តឱ្យកុមារនៅរៀន និងជួយឱ្យពួកគេប្រឹងប្រែងរៀនសូត្រទៀតផង។

ថ្លៃសាលាក្រៅផ្លូវការក៏ជាកត្តាជំរុញឱ្យមានការបោះបង់ការសិក្សាដែរ ព្រោះវាបានបន្ថែមលើបន្ទុកហិរញ្ញវត្ថុរបស់គ្រួសារក្រីក្រ។ បាតុភូតនេះផ្សារភ្ជាប់ទៅនឹងប្រាក់ខែលើកទឹកចិត្តគ្រូបង្រៀននៅទាបដែលជំរុញឱ្យពួកគេបើកថ្នាក់គួរដើម្បីរកប្រាក់សម្រាប់គ្រួសារក្រីក្ររបស់ពួកគេ។ ផលពិបាកគឺ គ្រូគ្មានពេលវេលាដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលបង្កើនជំនាញបង្រៀនផ្ទាល់ខ្លួន ដែលធ្វើឱ្យវដ្តនៃការអប់រំដែលមានគុណភាពទាបនៅតែបន្ត។ គុណភាព នៃការអប់រំលើកកម្ពស់តាមរយៈវិធីសាស្ត្រទូលំទូលាយដោះស្រាយទាំងប្រាក់ខែទាប និងជំនាញរបស់គ្រូបង្រៀន។ ត្រូវការប្រាក់ខែខ្ពស់ជាងមុន បង្កើនការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការបណ្តុះបណ្តាគ្រូបង្រៀន ការវិនិយោគក្នុងបច្ចេកវិទ្យាបង្រៀន និងការប្រើប្រាស់គ្រូជំនួយ និងជំនួយនៃអ្នកជំនាញផ្សេងទៀត ដើម្បីឱ្យមានការផ្លាស់ប្តូរ ។

យុវជនកម្ពុជាខ្លួនឯងផ្ទាល់មានគំនិតទុទ្ទិដ្ឋិនិយមពាក់ព័ន្ធនឹងលទ្ធផលដែលបានមកពីការវិនិយោគក្នុងវិស័យអប់រំ។ មួយភាគធំនៃសិស្សដែលបានបញ្ចប់បឋម និងមធ្យមសិក្សា ទីបំផុតពួកគេនៅតែមានការងារដែលងាយរងគ្រោះ (ទាំងការងារគ្រួសារគ្មានប្រាក់ខែ ឬការងារផ្ទាល់ខ្លួន) ។ ភាគរយនេះគឺខ្ពស់ជាងបន្តិចក្នុងចំណោមអ្នកបោះបង់ការសិក្សានៅមធ្យមសិក្សា ហើយតាមពិត ការងារមួយចំនួនត្រូវការជំនាញទាបដែលធ្វើឱ្យអ្នកបោះបង់ការសិក្សានៅបឋមសិក្សាអាចរកប្រាក់ចំណូលបានច្រើនជាងអ្នកដែលបានបញ្ចប់ការសិក្សាទៅវិញ។ សញ្ញាបត្រពីកម្រិតឧត្តមសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចធ្វើឱ្យមានកម្រិតខុសគ្នានៃប្រាក់ខែ ។ នៅទីបំផុត ទោះបីយុវជនទាំងអស់មិនត្រូវបានបង្ខំឱ្យទៅបន្តការសិក្សានៅកម្រិតឧត្តមសិក្សាក៏ដោយ ក៏ (អ្នកបោះបង់ និងអ្នកបានបញ្ចប់ការសិក្សា) ត្រឹមកម្រិតបឋម និងមធ្យមសិក្សាអាចរកបានតែការងារជំនាញទាបមានប្រាក់ខែទាប ចំណែកអ្នកដែលបានបញ្ចប់ថ្នាក់ឧត្តមសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចរកបានការងារមានប្រាក់ខែខ្ពស់ជាងយ៉ាងពិតប្រាកដ។

សក្តានុពលដែលបានមកពីការបណ្តុះបណ្តាលវិជ្ជាជីវៈគឺមិនអាចប៉ាន់ប្រមាណបានឡើយ។ ប្រព័ន្ធ TVET មួយដ៏ល្អដោយមានស្ថាប័នដែលមានទទួលស្គាល់ដំណើរការតាមបទដ្ឋានជំនាញថ្នាក់ជាតិអាចស្រូបយកចំនួនយ៉ាងច្រើន នៃយុវជននៅក្រៅសាលា យុវជនដែលមានជំនាញទាប និងបណ្តុះបណ្តាលពួកគេដើម្បីការងារនៅក្នុងវិស័យឯកជន និងឧស្សាហកម្ម ព្រមទាំងរៀបចំជំរុញឱ្យពួកគេក្លាយជាសហគ្រិនតាមរយៈការផ្តល់ឱកាស ។ កម្មវិធី TVET នឹងធ្វើការពិចារណាពីទម្រង់ខុសគ្នា នៃយុវជននៅក្រៅសាលា និងផ្តល់ការអភិវឌ្ឍជំនាញអាជីវកម្ម ព្រមទាំងជំនាញអក្ខរកម្ម និងគណិតវិទ្យាថ្នាក់មូលដ្ឋាន។ ការបណ្តុះបណ្តាលការងារនៅក្នុងក្រុមហ៊ុនធំៗបានបង្ហាញនូវជោគជ័យដោយមានកម្មករជំនាញខ្ពស់យ៉ាងមានសក្តានុពល។ គម្រោងបណ្តុះបណ្តាលធំៗសម្រាប់ឧស្សាហកម្មមួយចំនួនដែលកំពុងលូតលាស់ (ដូចជា ទេសចរណ៍ សេវាកម្ម) និងចង្កោមអាជីវកម្ម (business clusters) កសិអាជីវកម្ម (agro-food business) អាចជួយឱ្យក្រុមហ៊ុនរកបានកម្មករយុវជនក្រៅសាលាដែលទទួលបានបណ្តុះបណ្តាល និងមានសញ្ញាបត្រត្រឹមត្រូវ។ ដោយសារតែការងារក្នុងវិស័យក្រៅផ្លូវការគឺជារឿងធម្មតាសម្រាប់យុវជនដែលមានជំនាញទាប គួរតែមានគម្រោងទទួលស្គាល់ជំនាញមួយដែលអាចធ្វើឱ្យបទពិសោធន៍ក្រៅផ្លូវការរបស់យុវជនមានសុពលភាព និងអាចជួយនិយោជកក្នុងការធ្វើការសម្រេចចិត្តជ្រើសរើសយុវជនទាំងនោះជាបុគ្គលិក។

# ឯកសារយោង

ឯកសារយោង


ADB and ILO (2015), *Cambodia: Addressing the Skills Gap: Employment Diagnostic Study*, Asian Development Bank and International Labour Organization, Manila and Geneva, https://www.adb.org/sites/default/files/publication/176283/cambodia-addressing-skills-gap.pdf.

Breen, R. and J.H, Goldthorpe (1997), "Explaining Educational Differentials: Towards a Formal Rational Action Theory", *Rationality and Society* 9: 3: 275-305.

CITA (2013), *Teachers' Salary and Terms & Conditions*, *Position Paper 2013-2015*, Cambodia Independent Teachers Association, Phom Penh.

CRCC (2015), Final *Report on Desktop Study on Non-Formal Education in Cambodia*, Cambodian Research and Consultancy Center Co. Ltd, Phnom Penh.

Derks, A. (2008), *Khmer Women on the Move: Exploring Work and Life in Urban Cambodia*, University of Hawai'i Press, Honolulu.

Fall A-M. and G. Roberts (2012), "High school dropouts: interactions between social context, self- perceptions, school engagement, and student dropout", *Journal of Adolescence*, Vol. 35, No. 4, pp. 787-98.

Hattie, J. (2009), *Visible Learning: A Synthesis of Over 800 Meta-Analyses Relating to Achievement*,
Routledge, London.

Huisman, J. and J. Smits (2009), *Keeping Children in School: Household and District-level Determinants of School Dropout in 363 Districts of 30 Developing Countries*, Nijmegen Center for Economics, Institute for Management Research, Radboud University Nijmegen, Nijmegen, The Netherlands.

Huisman J., U. Rani and J. Smits (2010), *School characteristics, socio-economic status and culture as determinants of primary school enrolment in India*, Nijmegen Center for Economics, Institute for Management Research, Radboud University Nijmegen, Nijmegen, The Netherlands.

ILO (2013), *Global Employment Trends for Youth 2013: A generation at risk*, International Labour Office, International Labour Organization, Geneva, http://www.ilo.org/wcmsp5/groups/public/---dgreports/---dcomm/documents/publication/wcms_212423.pdf.

ILO (2012), *Decent Work Country Profile CAMBODIA*, International Labour Organization, Geneva. Ingrum, A. (2006), "High School Dropout Determinants: The Effect of Poverty and Learning
Disabilities", *The Park Place Economist*, Vol. 14, pp. 73-9.

Jonker, E.F (2006), "School hurts: refrains of hurt and hopelessness in stories about dropping out at a vocational school for care work", *Journal of Education and Work*, Vol. 19, No. 2, pp. 121-40.

Kanol, H., K. Khemarin and S. Elder (2013), *Labour market transitions of young men and women in Cambodia*, International Labour Office, International Labour Organization, Geneva.

Kirazoglu, C. (2009), "The investigation of school-dropout at the secondary level of formal education: the stated reasons by the school administrators and school counsellors: a preliminary study", *Procedia Social and Behavioral Sciences*, Vol. 1, pp. 905-14.

Krueger, A.B. and D.M. Whitmore (2002), "Would Smaller Classes Help Close the Black-White Achievement Gap?" in *Bridging the Achievement Gap*, Brookings Institution Press.

Mike O.I., A. Nakajjo and D. Isoke (2008), *Socioeconomic determinants of primary school dropout: the logistic model analysis*, Munich Personal RePEc Archive, Munich University Library, Munich.

Mingat, A. (2007), "Social disparities in Education in Sub-Saharan African Countries: Gender, Geographical Location and Family income", in Teese, R., S. Lamb, M. Duru-Bellat (eds), *International Studies in Educational Inequality, Theory and Policy – Volume 1: Educational Inequality: Persistence and Change*, pp. 223-55, Springer Publishing, New York.

MoEYS (2015/16), *Education Indicators and Statistics.* Ministry of Education, Youth and Sport, Phnom Penh. MoEYS (2015), *The education, youth and sport performance in the academic year 2013-2014 and goals for the academic year 2014-2015*, Ministry of Education, Youth and Sport, Phnom Penh.

MoEYS (2014), *Non-Formal Education Statistics & Indicators 2014*, Planning and NFE-MIS Office, Department of Non-Formal Education, Ministry of Education Youth and Sport, Phnom Penh.

MoEYS (2010/11-2014/15), *Education Statistics & Indicators*, EMIS Office. Department of Planning.
Ministry of Education, Youth and Sport, Phnom Penh.

MoEYS (2008), *Non-Formal Education National Action Plan 2008-2015*, Ministry of Education, Youth and Sport, Phnom Penh.

MoLVT (2017), *Technical and Vocational Education and Training Statistics 2015-16*, TVETMIS Office, Department of Labour Market Information, , Ministry of Labour and Vocational Training, Phnom Penh, http://www.tvetmis.com/public/docs/TVET_statistics_2015_2016_EN.pdf.

NIS (2015), *Cambodia Socio-Economic Survey 2014*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2010), *Cambodia Socio-Economic Survey 2009*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2005), *Cambodia Socio-Economic Survey 2004*, National Institute of Statistics, Ministry of Planning, Phnom Penh.

OECD (2011), *Education at a Glance 2011: OECD Indicators*, OECD Publishing, Paris, http://dx.doi.org/10.1787/eag-2011-en.

OECD (2009), *Education at a Glance 2009: OECD Indicators*, OECD Publishing, Paris, http://dx.doi.org/10.1787/eag-2009-en.

Polesel J., A. Nizinska and E. Kurantowicz (2011), "Pathways to Completion for School Dropouts", in S. Lamb et al. (eds), *School Dropout and Completion: International Comparative Studies in Theory and Policy*, Springer Publishing, New York, pp. 357-67.

Tan, C. (2007), "Education reforms in Cambodia: issues and concerns", in *Educational Research for Policy and Practice*, Vol. 6, No. 1, pp. 15-24.

UNESCO (2008), *Community Learning Centres: Country Reports from Asia*, United Nations Educational, Scientific and Cultural Organization, Asia and Pacific Regional Bureau for Education, Bangkok.

USAID (2015), School Dropout Prevention Pilot Programme, United States Agency for International Development – Cambodia, Phnom Penh, http://schooldropoutprevention.com/country-data-activities/cambodia/ (accessed 19 January 2016).

Williams, P.A. (1987), *Standardizing School Dropout Measures*, Rutgers University, Center for Policy Research in Education, New Brunswick NJ.

World Bank (n.d.), *World Development Indicators* (database) (accessed 22 January 2016).

Yokozeki, Y. (1996), "The Causes, Processes and Consequences of Student Drop-out from Junior
Secondary School (JSS)" in "Ghana: the case of Komenda-Edina-Eguafo-Abrem (K.E.E.A.)
district", PhD Philosophy thesis, University of London, London.

# ជំពូកទី ៤៖ បញ្ហាប្រឈមក្នុងការងារដែលស្ត្រីកម្ពុជាជួបប្រទះ

# ជំពូកទី ៤:

## បញ្ហាប្រឈមក្នុងការងារដែលស្ត្រីកម្ពុជាជួបប្រទះ

ប្រទេសកម្ពុជាបានធ្វើឱ្យមានការរីកចំរើនយ៉ាងធំធេងសម្រាប់ការផ្តល់សិទ្ធិអំណាចរបស់ស្ត្រីចាប់តាំងពីចុងទសវត្សឆ្នាំ 1990 ។ គម្លាតយេនឌ័រ (Gender disparities) នៅក្នុងវិស័យអប់រំត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនៅគ្រប់កម្រិតទាំងអស់ដោយមានយុវតីច្រើនជាងយុវជនបានបញ្ចប់បឋម និងមធ្យមសិក្សា។ យុវតីកម្ពុជាពេលបច្ចុប្បន្ននេះទំនងជាមានលទ្ធភាពទៅសាលារៀន និងចេះអានចេះសរសេរជាងជំនាន់មុន។ ស្ត្រីចូលរួមកម្លាំងពលកម្មបានកើនឡើងផងដែរចាប់តាំងពីឆ្នាំ 2004 មក ប៉ុន្តែគម្លាតអត្រាចូលរួមកម្លាំងពលកម្មរវាងស្ត្រី និងបុរសនៅតែមានដដែលគឺប្រហែល 12% ក្នុង 2014។ បើទោះជាមានសមិទ្ធផលទាំងនេះក៏ដោយ ក៏ភាគច្រើននៃការងាររបស់យុវតីទាំងនោះគឺជាការងារគ្រួសារគ្មានប្រាក់ខែ និងជាការងារក្រៅផ្លូវការដែលមានលក្ខខណ្ឌការងារមិនស្ថិតស្ថេរ និងមានចំណូលមិនទៀងទាត់ ឬចំណូលទាប ឬមានហានិភ័យ នៃការជួញដូរ និងការកេងប្រវ័ញ្ច (យោងតាម ADB ឆ្នាំ 2013) ។ ចំណែកនៃយុវតីអសកម្ម និងនៅក្រៅសាលាខ្ពស់ជាងយុវជន ។ លើសពីនេះ ស្ត្រីមានលទ្ធភាពក្នុងការទទួលបាននិងការគ្រប់គ្រងធនធាននិងឱកាសតិចតួច សម្រាប់បង្កើនជំនាញ និងការសម្រេចចិត្តរបស់ពួកគេនៅខាងក្រៅផ្ទះ ខណៈបទដ្ឋានសង្គមក៏ជះឥទ្ធិពលដល់ការសម្រេចចិត្តការងារសម្រាប់ស្ត្រីដែរ។

ជំពូកនេះបង្ហាញអំពីបញ្ហាប្រឈមនឹងការងារសម្រាប់ស្ត្រីយុវតីនៅកម្ពុជា តាមរយៈលទ្ធផលនៃការពិភាក្សាក្រុមគោលដៅ (Focus Group Discussions ហៅកាត់ថា FGD) ចំនួន 18 ក្រុមដែលមានស្ត្រីចំនួន 125 នាក់ ភាគច្រើនមានអាយុចន្លោះពី 15 ទៅ 30 ឆ្នាំ ដែលរស់នៅក្នុងតំបន់ទីក្រុង និងជនបទ។ គោលបំណងគឺដើម្បីស្វែងយល់ឱ្យបានប្រសើរជាងមុនអំពីស្ថានភាពរបស់យុវតីនៅក្នុងនិងក្រៅទីផ្សារការងារ និងកត្តាប៉ះពាល់លើការសម្រេចចិត្តរបស់ពួកគេក្នុងការចូលរួម ឬមិនចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ច។ ការពិភាក្សាបានផ្តោតលើស្ថានភាពទីផ្សារការងារក្នុងតំបន់នៅក្នុងសហគមន៍ដែលបានសម្ភាស ភាពផ្លូវការ បទដ្ឋានសង្គមវប្បធម៌ (socio-cultural norms) នៅលើតួនាទីរបស់ស្ត្រី លទ្ធភាពទទួលបានការគាំទ្រពីបណ្តាញសង្គម និងឱកាសនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ផ្នែកនៅសល់ នៃជំពូកនេះត្រូវបានរៀបចំឡើងជាបួនផ្នែកគឺ៖ ទីមួយ បង្ហាញពីស្ថានភាពទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជា។ ទីពីរ ពិនិត្យទីផ្សារការងារពិតសម្រាប់ស្ត្រី រួមទាំងភាពមិនផ្លូវការ (informality) បទដ្ឋានសង្គម គម្លាតពត៌មាននិងបណ្តាញសង្គម ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការផ្តល់សេវាការងារ និងការបោះបង់ការសិក្សា។ ទីបី បង្ហាញអំពីគោលនយោបាយ និងយុទ្ធសាស្ត្រអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកម្ពស់ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រី និងកំណើននៃការចូលរួមនៅក្នុងសកម្មភាពសង្គម។ ទីបួននិងជាចុងក្រោយ បង្ហាញពីការសន្និដ្ឋាន និងអនុសាសន៍ពាក់ព័ន្ធនឹងគោលនយោបាយសំខាន់ៗ ។

### ៤.១ ស្ថានភាពទីផ្សារការងារ

#### ៤.១១. កម្លាំងពលកម្ម

ចាប់តាំងពីឆ្នាំ 2010 ប្រទេសកម្ពុជាសម្រេចបាននូវអត្រាកំណើនមធ្យមប្រចាំឆ្នាំ 7 ភាគរយ (យោងតាម World Bank 2017) ។ កំណើននេះបានរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រឱ្យធ្លាក់មកត្រឹម 17,7 ភាគរយ ក្នុងឆ្នាំ 2012 ដែលដើមឆ្នាំ 2000 អត្រាក្រីក្រមានរហូត 50 ភាគរយ (យោងតាម World Bank 2017) ។ ជាមួយនឹងកំណើនសេដ្ឋកិច្ច ក៏មានការរីកចម្រើនក្នុងអត្រាការងារ គួរឱ្យកត់សម្គាល់ផងដែរ។ នៅក្នុងឆ្នាំ 2014 កម្ពុជាមានកម្លាំងពលកម្មចំនួន 8,26 លាននាក់ ដែលក្នុងនោះ 13 ភាគរយ ស្ថិតនៅក្នុងរាជធានីភ្នំពេញ 12 ភាគរយ នៅក្នុងតំបន់ក្រុងផ្សេងទៀត និងនៅសល់ 75 ភាគរយ ស្ថិតនៅតំបន់ជនបទ (សូមមើល តារាង 4.1) ។ អត្រាចូលរួមកម្លាំងពលកម្មក្នុងឆ្នាំ 2014 មានចំនួន 83 ភាគរយ និងអត្រាអ្នកមានការងារធ្វើមានចំនួន 78 ភាគរយ ។ អត្រាការងារនៅតំបន់ជនបទខ្ពស់ជាងទីក្រុងផងដែរ។

**តារាង 50 (4-1) ប្រជាជននិងកម្លាំងពលកម្ម អាយុពី 15 ទៅ 64 ឆ្នាំ តាមភេទ និងភូមិសាស្រ្ត ឆ្នាំ 2014 (គិតជាភាគរយ)**

| | កម្ពុជា | រាជធានីភ្នំពេញ | ទីក្រុង | ជនបទ |
|---|---|---|---|---|
| ចំនួនប្រជាជនសរុប | 15,184 | 1,794 | 1,796 | 11,594 |
| ប្រជាជនក្នុងអាយុធ្វើការ សរុប | 10,001 | 1,361 | 1,219 | 7,421 |
| កម្លាំងពលកម្ម | 8,259 | 1,060 | 961 | 6,238 |
| អត្រាចូលរួមកម្លាំងពលកម្ម | | | | |
| ស្ត្រី | 77.5 | 72.2 | 71.1 | 79.6 |
| បុរស | 87.9 | 84.1 | 87.3 | 88.7 |
| ទាំងពីរភេទ | 82.6 | 77.9 | 78.8 | 84.1 |
| អត្រាការងារ | | | | |
| ស្ត្រី | 77.4 | 72.0 | 71.0 | 79.4 |
| បុរស | 87.8 | 84.0 | 86.9 | 88.6 |
| ទាំងពីរភេទ | 82.4 | 77.8 | 78.6 | 83.9 |

*ប្រភព៖ CSES 201*

បើនិយាយពីអត្រាចូលរួមកម្លាំងពលកម្មនៅក្នុងឆ្នាំ 2014 ក្រុមអាយុដែលសកម្មបំផុតគឺក្រុម អាយុពី 25 ទៅ 34 ឆ្នាំ (91 ភាគរយ) និងអាយុពី 35 ទៅ 44 ឆ្នាំ (91 ភាគរយ) ។ អត្រាចូលរួមកម្លាំងពលកម្មរបស់យុវជនដែលមានអាយុពី 15 ទៅ 24 ឆ្នាំ មានចំនួន 72 ភាគរយ ។ អត្រាចូលរួមកម្លាំងពលកម្មទាំងយុវតី និងយុវជនដែលមានអាយុពី 15 ទៅ 19 ឆ្នាំ នៅក្នុងឆ្នាំ 2014 មានចំនួន 60 ភាគរយ (សូមមើល តារាង 4.2) ។ ចាប់ពីអាយុ 20 ឆ្នាំទៅ អត្រាចូលរួមកម្លាំងពលកម្មរបស់បុរសខ្ពស់ជាងស្ត្រី 9 ភាគរយ ហើយភាពខុសគ្នានេះបន្តច្រើនឡើងៗនៅពេលពួកគេមានអាយុកាន់តែច្រើនដែរ។ អត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រីបានកើនឡើង 2,5 ភាគរយ ក្នុងឆ្នាំ 2014 ធៀបទៅនឹងឆ្នាំ 2004 ទោះជាមានការធ្លាក់ចុះនៅចន្លោះឆ្នាំ 2009-14 ក៏ដោយ។ អត្រាចូលរួមកម្លាំងពលកម្មក្នុងតំបន់ជនបទក៏ខ្ពស់ជាងនៅរដ្ឋធានី ឬទីក្រុងផ្សេងទៀត (សូមមើល តារាង 4.3) ។

**តារាង 51 (4-2) អត្រាចូលរួមកម្លាំងពលកម្ម តាមក្រុមអាយុ និងភេទ ឆ្នាំ 2014 គិតជាភាគរយ**

| ក្រុមអាយុ | 2014 | | |
|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ |
| **15-19** | 60.1 | 60.5 | 60.3 |
| **20-24** | 78.1 | 87.1 | 82.8 |
| **25-34** | 85.1 | 97.0 | 90.9 |
| **35-44** | 84.6 | 97.9 | 91.0 |
| **45-54** | 81.4 | 95.9 | 88.1 |
| **55-64** | 66.8 | 86.1 | 74.7 |
| សរុប **(15-64)** | 77.5 | 87.9 | 82.6 |

*ប្រភព៖ CSES 201*

**តារាង 52 (4-3) អត្រាចូលរួមកម្លាំងពលកម្ម តាមឆ្នាំ (2004, 2009 និងឆ្នាំ 2014) តាមភេទ និងតំបន់ គិតជាភាគរយ**

| | **2004** | **2009** | **2014** |
|---|---|---|---|
| សរុប (15-64) | 79.9 | 84.4 | 82.6 |
| ស្ត្រី | 75.0 | 80.3 | 77.5 |
| បុរស | 85.4 | 88.8 | 87.9 |
| ទីក្រុង | 67.7 | 68.7 | 77.9 |
| ទីក្រុងផ្សេងទៀត | 77.2 | 77.0 | 78.6 |
| ជនបទ | 82.4 | 87.6 | 84.1 |

*ប្រភព៖ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាឆ្នាំ 2008 ក្រសួងផែនការឆ្នាំ 2015*

ទោះបីជាមានអត្រាការងារខ្ពស់ក៏ដោយ ក៏ 47 ភាគរយ នៃចំនួនប្រជាជនបានរងគ្រោះដោយសារភាពក្រីក្រមានច្រើនកត្តា (multidimensional poverty) នេះបើតាមការគណនាដោយផ្អែកលើទិន្នន័យរបស់គ្រួសារខ្វះខាត (household deprivations) នៅក្នុងវិស័យការអប់រំ សុខភាព និងបទដ្ឋានរស់នៅ (យោងតាម HDR, 2015) ។ ដោយសារតែកំណើនសេដ្ឋកិច្ចកម្ពុជាមានមូលដ្ឋានតូចចង្អៀតនិងពឹងផ្អែកយ៉ាងខ្លាំងទៅលើការផ្លាស់ប្តូរក្នុងតម្រូវការ និងលំហូរមូលធនពីខាងក្រៅ ប្រទេសនេះបានប្រឈមនឹងបញ្ហាជាច្រើនក្នុងការធានាឱ្យមានការងារមានគុណភាពល្អ ដោយរាប់បញ្ចូលទាំងការធ្វើសេដ្ឋកិច្ចសម្បូរបែប ការទាក់ទាញការវិនិយោគ ការលើកកម្ពស់ជំនាញ និងការផ្លាស់ប្តូរមនុស្សពីការងារក្រៅផ្លូវការ និងងាយរងគ្រោះទៅជាការងារផ្លូវការវិញ។

អង្គការពលកម្មអន្តរជាតិ (International Labour Organization ហៅកាត់ថា ILO) បានកំណត់ថា ការងារសមរម្យ (Decent work) ត្រូវមានសមាសភាគបួនគឺ៖ (1) ការលើកកម្ពស់សិទ្ធិមូលដ្ឋានក្នុងការងារ (2) ការធានាជីវភាពគ្រប់គ្រាន់ (3) ការផ្តល់ការគាំពារសង្គម រួមទាំងបរិស្ថានការងារមានសុវត្ថិភាព និង (4) ការលើកកម្ពស់ការសន្ទនាសង្គមរវាងនិយោជក កម្មករ និងរាជរដ្ឋាភិបាល។ ការងារងាយរងគ្រោះដូចជា កម្មករគណនីផ្ទាល់ខ្លួន និងកម្មករគ្រួសារគ្មានប្រាក់ខែ មានចំនួនច្រើនជាងពាក់កណ្តាល (53.6 ភាគរយ) នៃការងារសរុបនៅក្នុងកម្ពុជា (យោងតាម Kanol, Khemarin and Elder 2013) ។

ការងាររបស់យុវតីច្រើនជួបលទ្ធផលលំបាកច្រើនជាងយុវជន។ ប្រហែល 60 ភាគរយ នៃកម្មករជាស្ត្រីស្ថិតនៅក្នុងប្រភេទការងារងាយរងគ្រោះនៅឆ្នាំ 2014 ធៀបបុរសមានតែ 51 ភាគរយប៉ុណ្ណោះ (យោងតាម ក្រសួងផែនការ ឆ្នាំ 2015)។ នេះគឺដោយសារតែហេតុផលជាច្រើន ដែលក្នុងនោះហេតុផលដ៏ធំមួយគឺ ស្ត្រីត្រូវទទួលបន្ទុកការងារផ្ទះជាច្រើនដែលជាការងារគ្មានប្រាក់ខែ។ កម្មករខ្មែរភាគច្រើនធ្វើមុខរបរបឋមនៅឡើយ ដូចជា (កសិកម្ម កាប់អុស និងនេសាទ) ដែលមានអត្រារហូតដល់ 45 ភាគរយ នៅក្នុងឆ្នាំ 2014 (សូមមើល តារាង 4.4) ។ ដោយមានការរីកចម្រើនផ្នែកវិស័យឧស្សាហកម្មកាត់ដេរ កម្មករមួយចំនួនធំ ជាពិសេសស្ត្រីអាចស្វែងរកការងារមានប្រាក់ខែដែលអាចបង្ហាញថា មានការកើនឡើងនូវនិយោជិតមានប្រាក់ខែ និងមានការធ្លាក់ចុះនូវការងារគ្រួសារគ្មានប្រាក់ខែ ក្នុងចន្លោះឆ្នាំ 2004 និង 2014 (សូមមើល តារាង 4.5) ។

**តារាង 53 (4-4) បំណែងចែកកម្លាំងពលកម្ម តាមវិស័យ (2004, 2009 និងឆ្នាំ 2014) គិតជាភាគរយ**

| | **2004** | **2007** | **2009** | **2014** | **Female** | **Male** |
|---|---|---|---|---|---|---|
| កសិកម្ម | 58.7 | 58.1 | 57.6 | 45.3 | 46.7 | 43.9 |
| ឧស្សាហកម្ម | 13.8 | 14.7 | 15.9 | 24.3 | 24.1 | 24.5 |
| សេវាកម្ម | 27.5 | 27.2 | 26.5 | 30.4 | 29.2 | 31.5 |

*ប្រភពទិន្នន័យ៖ CSES ឆ្នាំ 2004, 2007, 2009, និង 2014*

**តារាង 54 (4-5) បំណែងចែកកម្លាំងពលកម្មតាមមុខរបរសំខាន់ ឆ្នាំ 2004 - 2014 (គិតជា ភាគរយ)**

| | 2004 | 2007 | 2009 | 2014 | Female | Male |
|---|---|---|---|---|---|---|
| **និយោជិតមានប្រាក់ខែ** | 22.5 | 25 | 26.9 | 44.4 | 39.3 | 49.1 |
| **និយោជក** | 0.1 | 0.1 | 0.3 | 0.2 | 0.1 | 0.2 |
| **កម្មករគណនីផ្ទាល់ខ្លួន** | 38.7 | 38.7 | 49.2 | 49.6 | 54.2 | 45.4 |
| **កម្មករគ្រួសារគ្មានប្រាក់ខែ** | 38.2 | 36.2 | 23.5 | 5.6 | 6.1 | 5.2 |
| **ផ្សេងទៀត** | 0.5 | 0.1 | 0.1 | 0.2 | 0.2 | 0.2 |

*ប្រភពទិន្នន័យ៖ CSES ឆ្នាំ 2004, 2007, 2009, និង 2014*

ជាហេតុផលមួយដែលនាំឱ្យលទ្ធផលទីផ្សារការងាររបស់យុវជន និងយុវតីមិនស្មើគ្នា គឺគម្លាត នៃការទទួលបានការអប់រំ ។ ទោះបីជាអត្រាចុះឈ្មោះចូលរៀននៅកម្រិតបឋម និងមធ្យមសិក្សារបស់យុវតីខ្ពស់ជាងយុវជនក៏ដោយ ក៏និន្នាការនេះផ្ទុយគ្នាវិញ ចាប់ពីវិទ្យាល័យឡើង។ សមាមាត្រ នៃអត្រាយុវជននិងយុវតីដែលបានបញ្ចប់បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សាបានធ្លាក់ចុះពី 0,89 មកត្រឹម 0,56 ទៅ 0,33 រៀងគ្នា (យោងតាម ADB និង ILO 2013) ។ ដោយសារតែភាគច្រើន នៃកម្មករនៅក្នុងប្រទេសកម្ពុជារៀនបានត្រឹមបឋមសិក្សា និងអនុវិទ្យាល័យ (សូមមើល តារាង 4.6) វាជាការលំបាកសម្រាប់ពួកគេក្នុងការស្វែងរកការងារដែលមានជំនាញ។ ផ្នែកខាងក្រោមនេះបង្ហាញពីធាតុពិត នៃទីផ្សារការងាររបស់ស្ត្រីឱ្យស៊ីជម្រៅបន្ថែមទៀត ពិសេសសម្រាប់យុវតី ដែលមានអាយុចន្លោះពី 15 ទៅ 30 ឆ្នាំ។

**តារាង 55 (4-6) យុវជនកំពុងធ្វើការ ដែលមានអាយុ 15 ឆ្នាំឡើង តាមកម្រិតអប់រំ ឆ្នាំ 2012 (គិតជា ភាគរយ)**

| | 2012 | | |
|---|---|---|---|
| | **សរុប** | **ស្ត្រី** | **បុរស** |
| បច្ចុប្បន្នកំពុងសិក្សា | 11.8 | 10.2 | 13.6 |
| មិនដែលបានចូលរៀន (ឬបានខ្លះ) | 15.9 | 20.5 | 10.9 |
| បានបញ្ចប់បឋមសិក្សា | 40.4 | 43.5 | 37.0 |
| បានបញ្ចប់មធ្យមសិក្សា | 28.8 | 23.9 | 34.1 |
| បានបញ្ចប់សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | 1.0 | 0.6 | 1.5 |
| បានបញ្ចប់សាកលវិទ្យាល័យ | 2.1 | 1.3 | 3.0 |
| **សរុប** | 100 | 100 | 100 |

*ប្រភព៖ SWTS-Cambodia ឆ្នាំ 2012*

## ៤.២ ទីផ្សារការងារសម្រាប់ស្ត្រី

កំណើនការងារដែលសម្រេចបានអំឡុងពាក់កណ្តាលទស្សវត្សឆ្នាំ2000 មិនបានផ្តល់ជាប្រយោជន៍ឱ្យយុវជន និងយុវតីស្មើគ្នាទេ។ វិសមភាពយេនឌ័រ (Gender inequality) ក្នុងទីផ្សារការងារនៅកម្ពុជានៅតែបន្តកើតមានបើទោះបីជាអត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រី និងការទទួលបានការអប់រំរបស់ស្ត្រីកើនឡើងក៏ដោយ។ គម្លាតយេនឌ័រនៅក្នុងអត្រាចូលរួមកម្លាំងពលកម្ម (labour force participation rate ហៅកាត់ថា LFPR) នៅកម្ពុជាឆ្នាំ2014 មានចំនួន 12 ភាគរយ (NIS, 2015) និងធនាគារអភិវឌ្ឍន៍អាស៊ី (ឆ្នាំ 2013) រកឃើញថា គម្លាតប្រាក់ខែ (wage gap) រវាងបុរសស្ត្រីមានចំនួន 27 ភាគរយ ។ អត្រាស្ត្រីចូលរួមកម្លាំងពលកម្មទាបបែបនេះគឺបណ្តាលមកពីឧបសគ្គនៃទីផ្សារការងារដូចជា កង្វះភាពផ្លូវការ (informality) បទដ្ឋានសង្គមវប្បធម៌ដែលរារាំងតួនាទីរបស់ស្ត្រីកម្ពុជានៅក្នុងសង្គម កង្វះព័ត៌មានអំពីឱកាសការងារ និងបណ្តាញសង្គម លទ្ធភាពទទួលបានការអប់រំនិងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមានកម្រិត និងការបោះបង់ការសិក្សានៅកម្រិតដំបូង។

ផ្នែកនេះគូសបញ្ជាក់ពីការពិភាក្សាក្រុមគោលដៅ (focus group discussion-FGD) ដែលបានអនុវត្តនៅក្នុងខេត្តចំនួនបួន (រាជធានីភ្នំពេញ ខេត្តកំពត ខេត្តសៀមរាប និងខេត្តមណ្ឌលគិរី) ដើម្បីឱ្យស្ត្រីយល់ដឹងអំពីឧបសគ្គនៃទីផ្សារការងារទាំងនេះ។ មានស្ត្រីសរុបមានចំនួន 125 នាក់ត្រូវបានសម្ភាសតាមរយៈ FGD ទាំង 18 ក្រុម ដែលភាគច្រើនជាស្ត្រីមានអាយុចន្លោះពី 15 ទៅ 30 ឆ្នាំ ប៉ុន្តែក៏មានស្ត្រីវ័យចំណាស់មួយចំនួនផងដែរ ដែលអាចផ្តល់ការយល់ដឹងពាក់ព័ន្ធនឹងសង្គមវប្បធម៌ដែលជាកត្តាប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ច និងជីវិតរបស់ស្ត្រីវ័យក្មេង ។ សម្ភាសន៍ព័ត៌មានសំខាន់ (Key informant interviews-KII) ជាមួយប្រធានភូមិក៏ត្រូវបានធ្វើឡើងផងដែរ។ ពិធីការសម្ភាសន៍ត្រូវបានបង្កើតឡើងដើម្បីទាញយកព័ត៌មានផ្សេងៗ និងព័ត៌មានពាក់ព័ន្ធនឹងយេនឌ័រ និងឧបសគ្គចំពោះជម្រើសការងាររបស់ស្ត្រី (សូមមើលឧបសម្ព័ន 4.A1 សម្រាប់វិធីសាស្ត្រសម្ភាសន៍) ។ ផ្នែកបន្តនេះពិភាក្សាអំពីការយល់ដឹងរបស់ក្រុមការគោលដៅស្តីពីឧបសគ្គនៃទីផ្សារការងារ ។

### ៤.២.១ ភាពមិនផ្លូវការ (Informality)

សេដ្ឋកិច្ចកម្ពុជាមួយផ្នែកធំអាស្រ័យលើការងារក្រៅប្រព័ន្ធមានលក្ខណៈជាការងារមានគុណភាពទាប ដែលអង្គការពលកម្មអន្តរជាតិបានឱ្យចំណាត់ថ្នាក់ថា ជាប្រភេទការងារ ***"ងាយរងគ្រោះ*** (Vulnerable)" យោងតាម ILO & ADB, 2013 ។ ការងារងាយរងគ្រោះរួមមាន ការងារគណនីផ្ទាល់ខ្លួន (own-account work) ការងារគ្រួសារគ្មានប្រាក់ខែ (unpaid family work) ការងារក្នុងសហគ្រាសមិនផ្លូវការ ឬការងារនៅតាមផ្ទះ និងការងារកិច្ចសន្យារយៈពេលខ្លី (a short-term contract) ឬការងារគ្មានកិច្ចសន្យា (យោងតាម ILO, 2004b)។ ទំនងជាមានស្ត្រីច្រើនជាងបុរសស្ថិតក្នុងការងារមិនផ្លូវការ និងការងារងាយរងគ្រោះនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ និងអន្តរកាលសេដ្ឋកិច្ច។

យោងតាម ILO & ADB, 2013 បានឱ្យដឹងថា ភាគរយនៃការងារងាយរងគ្រោះនៅកម្ពុជាមានចំនួន 73 ភាគរយ សម្រាប់ស្ត្រី និង 64 ភាគរយ សម្រាប់បុរសក្នុងឆ្នាំ 2011 ។ កិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់ស្ថានភាពនេះដែលធ្វើឡើងក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះមានការរីកចម្រើនខ្លះហើយ។ ការងារមិនផ្លូវការនិងការងារងាយរងគ្រោះក៏បានកែលម្អដែរ។ ប៉ុន្តែគិតពីឆ្នាំ 2009 មក ការងារគណនីផ្ទាល់ខ្លួននៅតែមិនទាន់ថយចុះខ្លាំងទេ គឺនៅជុំវិញ 50 ភាគរយ នៅឡើយ ។ ភាគរយ នៃការងារគ្រួសារគ្មានប្រាក់ខែបានថយចុះយ៉ាងខ្លាំងពី 38.2 ភាគរយ ក្នុងឆ្នាំ 2004 មកត្រឹម 5.6 ភាគរយ ក្នុងឆ្នាំ 2014 (6.1ភាគរយ សម្រាប់ស្ត្រី) (យោងតាម CSES ឆ្នាំ 2014) ។ ការផ្លាស់ប្តូរនេះជាលទ្ធផលនៃកត្តាជំរុញផងនិងកត្តាទប់ស្កាត់ផង ដែលធ្វើឱ្យស្ត្រីជាពិសេសយុវតីស្វែងរកការងារមានាប្រាក់ខែមានស្ថេរភាពបន្ថែមទៀតដើម្បីបង្កើនប្រាក់ចំណូលគ្រួសារតាមគ្រប់រូបភាព។ ម្យ៉ាងទៀត

សម្ពាធសេដ្ឋកិច្ចដែលបណ្តាលមកពីការចំណាយខ្ពស់លើការរស់នៅ និងការថយចុះផលិតកម្មកសិកម្មជំរុញឱ្យស្ត្រីរកការងារមានប្រាក់ខែដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ។ ជាលទ្ធផល រាជរដ្ឋាភិបាលបានបង្វែទិសដៅសេដ្ឋកិច្ចកម្ពុជាពីវិស័យកសិកម្មទៅរកការបង្កើតការងារនៅក្នុងវិស័យសេវាកម្ម និងផលិតកម្មវិញ (យោងតាម ILO, 2004b) ។ កំណើននៃឱកាសទទួលបានការងារ (ស្ទើរតែទាំងស្រុង) សម្រាប់យុវតីនៅក្នុងវិស័យកាត់ដេរគឺជាឧទាហរណ៍មួយបញ្ជាក់ពីការផ្លាស់ប្តូរ ។

ការផ្លាស់ប្តូរមួយផ្នែកធំនៅក្នុងកម្លាំងពលកម្មស្ត្រីពីការងារគ្រួសារគ្មានប្រាក់ខែទៅជាការងារមានប្រាក់ខែ គឺជាកត្តាសំខាន់សម្រាប់សេដ្ឋកិច្ច ។ ទោះជាយ៉ាងណា នៅតាមតំបន់មួយចំនួន សមត្ថភាពស្រូបនៃសេដ្ឋកិច្ចនេះនៅមានកម្រិតនៅឡើយ បើតាមការបញ្ជាក់ពីអ្នកភូមិដែលចូលរួមនៅក្នុងក្រុមពិភាក្សាក្រុមគោលដៅ (FGD) ។ ដោយសារតែនៅជិតរាជធានី ជីវភាពរបស់ភូមិមួយចំនួនដែលនៅជាយរាជធានីភ្នំពេញមានការផ្លាស់ប្តូរយ៉ាងខ្លាំង ពីការធ្វើកសិកម្មទៅជាសេវាកម្ម និងកាត់ដេរ (យោងតាម FGD ក្រុម 1) ។ ភូមិទាំងនេះបានក្លាយជាទីប្រជុំភោជនីយដ្ឋានសម្រាប់អ្នកទីក្រុង និងជាលំនៅដ្ឋានសម្រាប់អ្នកភូមិដែលកំពុងធ្វើការនៅទីក្រុង។ ដូចគ្នានេះដែរ ភូមិទាំងនេះមានការរីកចម្រើនយ៉ាងខ្លាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ការទាក់ទាញការវិនិយោគ ជាពិសេសការបង្កើតរោងចក្រកាត់ដេរនៅក្នុងសហគមន៍នេះ។ កត្តាទាំងអស់នេះបានធ្វើឱ្យយុវតីជាច្រើនមានឱកាសទទួលបានការងារមានប្រាក់ខែ ទាំងការងារផ្លូវការ និងមិនផ្លូវការ (យោងតាម FGD1 និងការចុះអង្កេតដល់ទីតាំង) ។

ទោះជាយ៉ាងណា សម្រាប់ភូមិជនបទមួយនៅក្នុងខេត្តកំពតដែលបានលើកឡើងនៅជំពូកនេះមានការផ្លាស់តិចតួចប៉ុណ្ណោះ។ ជីវិតរបស់ស្ត្រីភាគច្រើននៅតែដូចកាលពីមុន។ ប្រពៃណីនៃការដាំដុះស្រូវ និងចិញ្ចឹមគោនៅតែជាជីវភាពស្នូលរបស់ភូមិនេះ។ ទោះជាយ៉ាងណា ភូមិនេះគឺខុសគ្នាពីភូមិជនបទផ្សេងទៀត គឺដោយសារតែយុវតីមួយចំនួនធំនៅភូមិនេះបានទៅធ្វើការនៅក្នុងរោងចក្រកាត់ដេរក្បែរៗនោះ។ ការដែលភូមិនេះនៅជិតក្រុងកំពតដែលជាកន្លែងទេសចរណ៍យ៉ាងពេញនិយមក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះអាចឱ្យស្ត្រីវ័យក្មេងមួយចំនួនស្វែងរកការងារនៅក្នុងអាជីវកម្មទេសចរណ៍។ គេបានរាយការណ៍ថាស្ត្រីវ័យក្មេងទាំងនេះមានការសាទរយ៉ាងខ្លាំងក្នុងការស្វែងរកការងារមានប្រាក់ខែ ពួកគេបានបោះបង់ការដាំដុះស្រូវតាមរដូវកាល ការងារសិប្បកម្មពីដូនតា (ការប្រមូលឬស្សីពីព្រៃនៅក្បែរៗនោះដើម្បីធ្វើជាកន្ត្រក) និងបានបង្កើតការផ្លាស់ប្តូរវិជ្ជមានសម្រាប់ភូមិ ទាំងតួនាទីយេនឌ័រ និងសេដ្ឋកិច្ច។

ខេត្តសៀមរាបដែលជាខេត្តក្រីក្រមួយនៅក្នុងប្រទេសនេះត្រូវបានបែងចែកជា ក្រុងសៀមរាបដែលលូតលាស់លឿន និងភូមិជនបទក្រីក្រ។ ក្រុងសៀមរាបជាចំណុចសំខាន់ដែលជារៀងរាល់ឆ្នាំទទួលភ្ញៀវទេសចរបានច្រើនបំផុតសម្រាប់ប្រទេស ។ ជាលទ្ធផល ការងារក្នុងវិស័យសេវាកម្មជាច្រើនត្រូវបានបង្កើតឡើង។ ភូមិមួយនៅជាយក្រុងនេះដែលបានលើកយកមកវិភាគនៅក្នុងជំពូកនេះ ក៏ទទួលបានប្រយោជន៍យ៉ាងច្រើនពីការរីកចំរើនវិស័យទេសចរណ៍នេះដែរ ទោះយ៉ាងណា ភាគច្រើន នៃអ្នកដែលមានអាយុធ្វើការនៅក្នុងភូមិនេះអាចរកបានការងារមានប្រាក់ខែសមរម្យទេ ប៉ុន្តែជាការងារក្រៅផ្លូវការប៉ុណ្ណោះ ព្រោះថាពួកគេទទួលបានការអប់រំទាប។ ជម្រើសការងារមានប្រាក់ខែស្ថិតស្ថេរបំផុតរបស់យុវតីនៅក្នុងភូមិនេះគឺការងារ ជាស្រីឡង់សេនៅបៀរហ្គាឌិន និងជាស្រីម៉ាស្សា ដែលការងារទាំងពីរនេះស្ថិតក្នុងប្រភេទការងារងាយរងគ្រោះបំផុត (យោងតាម FGD ក្រុម 5) ។ ភូមិជនបទនៅខេត្តសៀមរាបមួយនេះមានលក្ខណៈស្រដៀងគ្នានឹងភូមិជនបទមួយនៅខេត្តកំពតដែរ ដូចជា មានការដាំដុះស្រូវជារបរចម្បង ចំណែកស្ត្រីត្រូវបានបង្ខំដោយដោយប្រពៃណីតម្រូវឱ្យរួមចំណែកក្នុងការថែរក្សាកូនចៅ ធ្វើការងារផ្ទះ និងធ្វើកសិកម្ម។ មានការរាយការណ៍ថា យុវតីមួយចំនួនកំពុងធ្វើការនៅក្នុងក្រុងសៀមរាបជាអ្នកបម្រើតាមផ្ទះ និងជាអ្នករត់តុនៅក្នុងភោជនីយដ្ឋាន (យោងតាម FGD ក្រុម 6)[២] ។

សកម្មភាពជីវភាពស្នូល នៃភូមិជនបទនៅខេត្តមណ្ឌលគិរីដែលជាតំបន់ភ្នំ គឺការដាំដុះដំណាំកសិឧស្សាហកម្មដូចជា ដំឡូងមី ម្រេច និងដើមឈើហូបផ្លែ។ នេះធ្វើឱ្យស្ថានភាពរស់នៅបានប្រសើរជាងប្រជាជននៅភូមិជនបទផ្សេងទៀត (យោងតាមសង្កេតដល់ទីតាំងរបស់ FGDs 7 & 8) ។

សរុបមក លើកលែងតែអ្នកនៅក្រៅក្រុមពិភាក្សាគោលដៅ (FGD)[១] ភាគច្រើននៃស្ត្រីទាំងអស់នៅក្នុង FGD រស់នៅតំបន់ជនបទ និងធ្វើការឱ្យគ្រួសារគ្មានប្រាក់ខែតាមប្រពៃណី និងការងារក្រៅផ្លូវការមួយចំនួននៅឡើយ។ ទោះបីវិស័យកាត់ដេរជាជម្រើសការងារជាផ្លូវការដែលយុវតីនៅជនបទចូលចិត្ត និងចង់ធ្វើក៏ដោយ ក៏សមត្ថភាពនិងលទ្ធភាពស្រូបយករបស់វានៅមានកម្រិតដែរ គឺដោយសារតែបរិមាណការងារនៅក្នុងភូមិសាស្ត្ររបស់ពួកគេមានកម្រិត ។ ដែនកំណត់បែបនេះគួបផ្សំនឹងអវត្តមាន នៃជម្រើសការងារផ្លូវការផងនោះ បានដាក់កម្រិតយុវតីមិនឱ្យបោះបង់ការងារផ្ទះគ្មានប្រាក់ខែ ឬការងារមិនផ្លូវការណាមួយ (យោងតាម ILO & ADB ឆ្នាំ2013)។ គួបផ្សំនឹងអត្រាវិសមាមាត្រ (disproportionate share) នៃការងារមិនផ្លូវការទៀតនោះ ជារឿយៗ ស្ត្រីតែងជួបប្រទះនឹងលក្ខខណ្ឌការងារក្រោមស្តង់ដា (យោងតាម វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាឆ្នាំ 2006) ។

សម្រាប់យុវតី ការបង្កើតការងារសម្បូរបែប (employment diversification) នៅមានដែនកំណត់នៅឡើយ (សូមមើល ILO 2004b; EIC ឆ្នាំ 2006 ILO & ADB 2013 និង MoP 2015) ។ ផ្នែកបន្ទាប់នេះនឹងសិក្សាពីប្រភេទផ្សេងៗនៃការងារមិនផ្លូវការដែលយុវតីកំពុងធ្វើ និងជួបប្រទះ។

នៅក្នុងរាជធានី ទាំងកណ្តាលក្រុង និងតំបន់ជុំវិញ យុវតីមួយចំនួនធ្វើការងារមិនផ្លូវការ ដូចជា អ្នកលក់តាមផ្លូវ កម្មករសំណង់ អ្នករត់តុ (នៅក្នុងភោជនីយដ្ឋានក្នុងតំបន់) ជាងកាត់ដេរខ្លួនឯង និងជួយការងារគ្រួសារ (យោងតាម KIIs 1-2) ។ នៅក្នុងតំបន់សិក្សាបីផ្សេងទៀត ទាំងនៅក្នុងទីប្រជុំជននិងភូមិដាច់ស្រយាល យុវតីមួយចំនួនធ្វើការជា កសិករ និងកម្មករនៅក្នុងសកម្មភាពក្រៅពីកសិដ្ឋាន ដូចជា សិប្បកម្ម លក់ដូរតាមផ្លូវ កែច្នៃត្រី សំណង់ ការងារតាមផ្ទះ ភោជនីយដ្ឋាន (ជាអ្នករត់តុ និងជាស្រីឡង់សេ) និងតាមហាងម៉ាស្សា (យោងតាម FGDs 3-8) ។ យោងតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិក្នុងឆ្នាំ 2013 បានឱ្យដឹងថា កសិកម្មនៅតែជាវិស័យក្រៅប្រព័ន្ធលេចធ្លោដែលរួមចំណែកសេដ្ឋកិច្ច ក្នុងនោះកសិករ "ជាទូទៅគ្មានសន្តិសុខប្រាក់ចំណូល និងពុំសូវទទួលបានការគាំពារសង្គម" (យោងតាម cf. ILO 2013, p. 80)។ ក្រៅពីការងារកាត់ដេរនិងការងារក្រៅផ្លូវការមានប្រាក់ខែតិចតួច ភាគច្រើននៃយុវតីដែលសម្ភាសក្នុងការសិក្សានេះសុទ្ធតែពាក់ព័ន្ធនឹងការងារកសិកម្ម និងការងារបន្ទាប់បន្សំក្រៅពីសិកម្ម (យោងតាម FGDs 3, 4, & 6-8) ។

យុវតីមួយរូបមកពីខេត្តមណ្ឌលគិរីដែលបានបើកហាងលក់គ្រឿងទេសតូចមួយនៅក្នុងភូមិបានផ្តល់ចម្លើយក្នុង FGD 14 ដោយបង្ហាញអំពីការលំបាកពាក់ព័ន្ធនឹងការងារក្រៅផ្លូវការថា៖

> *«អាជីវកម្មនៅទីនេះ [ខណៈដែលនាងសំដៅលើហាងលក់គ្រឿងទេសតូចរបស់នាង] យ៉ាប់ទៅៗ។ វាជាការល្អកាលពីមុនព្រោះមិនមានហាងជាច្រើននៅជុំវិញនេះទេ។ ប៉ុន្តែនៅទីនេះស្ត្រីមិនមានជម្រើសច្រើន ដូច្នេះពួកគេគិតឃើញតែហាងលក់គ្រឿងទេសដូចខ្ញុំដែរ។ នៅទីនេះមិនមានរោងចក្រទេ។ ការធ្វើកសិកម្មគឺជាសកម្មភាពជីវភាពស្នូលរបស់យើង និងជាធម្មតាបុរសជាអ្នកទទួលបន្ទុក ហើយយើង (ស្ត្រី) ជួយដល់ពួកគេបន្ថែមលើភារកិច្ចគ្រួសារដូចជា ការចម្អិនអាហារនិងការសំអាត។ ប៉ុន្តែអ្នកដឹងទេថា ការអាស្រ័យលើទិន្នផលកសិកម្មគឺជាការព្រួយបារម្ភណាស់។ ការដាំដុះដំណាំរបស់យើងអាស្រ័យលើធម្មជាតិ (ទឹកភ្លៀង) ដែលមិនទៀងទាត់នោះទេ។ ដូចគ្នានេះផងដែរ តម្លៃនៅលើទីផ្សារសម្រាប់ការប្រមូលផលរបស់យើងគឺមិនអាចទាយទុកជាមុនបានទេ។ និយាយឱ្យខ្លី វាគឺជាការលំបាកណាស់សម្រាប់ពួកយើងជាពិសេសស្ត្រីដូចជាពួកយើង ព្រោះថា ជាធម្មតា យើងគិតអំពីសុខុមាលភាពគ្រួសារជាងបុរស»* ។

*«បញ្ហាគឺថា កម្មករក្រៅផ្លូវការប្រឈមនឹងលក្ខខណ្ឌការងារមិនល្អនិងមិនត្រូវបានការពារសិទ្ធិ។ ពួកគេមិនរីករាយជាមួយនឹងការការពារផ្នែកច្បាប់និងសង្គមនោះទេ ពួកគេមិនមានសិទ្ធិបញ្ចេញមតិដើម្បីការពារផលប្រយោជន៍ខ្លួននោះទេ» (យោងតាម វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា 2006, p.12) ។ បញ្ហាទាំងនេះគឺកាន់តែច្បាស់ថែមទៀតសម្រាប់ស្ត្រីវ័យក្មេងមានការងារមានប្រាក់ខែក្រៅផ្លូវការ និងការងារដែលមានហានិភ័យដូចជា ជាអ្នករត់តុនៅក្នុងភោជនីយដ្ឋាននៅជាយរាជធានីភ្នំពេញ ជាស្រីឡង់សេនៅក្នុងបៀរហ្គាឌិន និងជាអ្នកផ្តល់សេវាម៉ាស្សាតាមបែបប្រពៃណីក្នុងក្រុងសៀមរាប។ ដូចដែលស្ត្រីជំនួយការភូមិមួយរូបនៅក្នុងរាជធានីភ្នំពេញបានគូសបញ្ជាក់ថា៖*

*« [... ] ភោជនីយដ្ឋានក្នុងតំបន់នេះបានបង្កើតការងារជាច្រើនសម្រាប់យុវជនយុវតីនៅក្នុងសហគមន៍។ ទោះជាយ៉ាងណា មិនស្រួលដូចការងាររោងចក្រទេ ការរាងរក្នុងភោជនីយដ្ឋានគឺលំបាកណាស់យុវជនយុវតី ។ ជាធម្មតាយើងជាអ្នកដឹកនាំភូមិមានការប្រុងប្រយ័ត្នចំពោះការងាររបស់ពួកគេ ព្រោះការងារនេះអាចពាក់ព័ន្ធនឹងពលកម្មកុមារនិងការងារផ្លូវភេទដោយសម្ងាត់។ ទោះជាយ៉ាងណា យើង (អាជ្ញាធរភូមិ) យើងមិនអាចធានាថា ពួកគេទទួលបានបរិយាកាសការងារមានសុវត្ថិភាពនោះទេ។ យើងបានឮថា ដែលពួកគេ (យុវតី) បានប្រឈមនឹងការយាយីផ្លូវភេទពីភ្ញៀវ។ ហើយក៏មានការរាយការណ៍ផងដែរថា សេវាផ្លូវភេទដោយប្រយោលមាននៅក្នុងភោជនីយដ្ឋានមួយចំនួន និងជាប់ពាក់ព័ន្ធនឹងយុវតីអ្នករត់តុ និងស្ត្រីយុវតីក្នុងសហគមន៍ផងដែរ» ។*

អ្នកផ្តល់ព័ត៌មានសំខាន់របស់យើង (បុរស) មកពីភូមិមួយនៅក្នុងក្រុងសៀមរាបក៏បានចែករំលែកការព្រួយបារម្ភដូចគ្នានេះដែរថា៖

*« [... ] ដោយសារតែនៅជិតកណ្ដាលក្រុងសៀមរាបដែលជាកន្លែងផ្ដល់សេវាទេសចរណ៍ច្រើនប្រភេទនោះ មនុស្សជាច្រើននៅក្នុងភូមិនេះអាចមានការងារផ្អែកសេវាកម្ម ដោយមិនគិតពីកម្រិតអប់រំដែលពួកគេទទួលបាន។ តាមខ្ញុំសង្កេត ស្ត្រី (វ័យក្មេង) នៅភូមិនេះកំពុងធ្វើការជាស្រីឡង់សេនៅក្នុងបៀរហ្គាឌិន ឬជាអ្នកផ្ដល់សេវាម៉ាស្សា។ ដូចដែលអ្នកបានដឹងហើយថា ការងារទាំងពីរនេះធ្វើឱ្យពួកគេប្រឈម នឹងការយាយីផ្លូវភេទខ្ពស់ ឬបើធ្ងន់ធ្ងរជាងនេះទៀត ពួកគេអាចពាក់ព័ន្ធនឹងសេវាផ្លូវភេទប្រយោល។ ពួកគេនឹងជាងាយរងគ្រោះ បើមិនបានផ្ដល់ការពារដល់ពួកគេឱ្យទូលំទូលាយ» ។*

យោងតាមបទពិសោធន៍ និងកំណត់ត្រារបស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (Economic Institute of Cambodia) ឆ្នាំ2006 ស្ដីអំពីយុវតីដែលជាប់ពាក់ព័ន្ធនឹងការងារមិនផ្លូវការបានឱ្យដឹងថា សុវត្ថិភាពការងារពិបាកនឹងធានាណាស់ ប្រសិនបើស្ថាប័នមួយខ្វះយន្តការផ្តល់ការការពារ សន្តិសុខ ការរៀបចំ និងសិទ្ធិក្នុងការបញ្ចេញមតិ។ ច្បាប់ការងារកម្ពុជាមិនបានគ្របដណ្ដប់លើប្រភេទការងារទាំងអស់ទេ នេះបណ្ដាលឱ្យមានអវត្តមាននៃការការពារផ្នែកច្បាប់ដល់ក្រុមអ្នកធ្វើការដែលវិសមាមាត្រ រួមមាន កម្មករគណនីផ្ទាល់ខ្លួន និងកម្មករគ្រួសារ (យោងតាម ILO 2012) ។ ការងារមួយចំនួនធំដែលរាយការណ៍ដោយអ្នកចូលរួមរបស់យើង (ទាំង FGD និង KII) បានធ្លាក់ចូលក្នុងប្រភេទការងារអស្ថេរភាព ដែលអង្គការពលកម្មអន្តរជាតិបានកំណត់ថា "***ជាការងារតាមស្ថានភាពកិច្ចសន្យាធម្មតា តាមរដូវកាល បណ្ដោះអាសន្ន និងរយៈពេលខ្លី»*** (យោងតាម ILO 2012, p.53) គឺថា ជាការងារងាយរងគ្រោះ និងមានហានិភ័យសម្រាប់កម្មករ។ ភាពងាយរងគ្រោះទាំងនេះរឹតតែធ្ងន់ធ្ងរជាពិសេសចំពោះយុវតីដែលជាញឹកញាប់ប្រឈមនឹងការយាយីផ្លូវភេទនៅក្នុងទីផ្សារការងារមិនផ្លូវការដូចបានរៀបរាប់ខាងលើ។ ផ្នែកខាងក្រោមគឺអំពីបទដ្ឋានសង្គមដែលនឹងបង្ហាញនូវហេតុផលមួយចំនួនដែលរារាំងយុវតីកម្ពុជាឱ្យពិលំបាកចាកចេញពីទីផ្សារការងារក្រៅផ្លូវការ។

### ៤.២.២ បទដ្ឋានសង្គម (Social norms)

ក្រមសីលធម៌ប្រពៃណី (Traditional codes of conduct) នៅតែមានឥទ្ធិពលយ៉ាងខ្លាំងទៅលើតួនាទីរបស់ស្ត្រីក្នុងសង្គមកម្ពុជា។ តាមប្រពៃណីតួនាទីរបស់ស្ត្រីត្រូវបានចងភ្ជាប់ទៅនឹងការទទួលខុសត្រូវក្នុងគ្រួសារ រាប់ចាប់តាំងពី ការចម្អិនអាហារ ការសម្អាត រហូតដល់ការមើលថែរក្សាកូនចៅ ថែរក្សាឪពុកម្ដាយ និងសាច់ញាតិ។ ក្រមសីលធម៌ប្រពៃណីដូចជា **ច្បាប់ស្រី** (Chbap Srey) និងរឿងប្រជាប្រិយជាច្រើនបានជំរុញឱ្យមានការប្រតិបត្តិតាម គឺថា ស្ត្រីគួរតែសងគុណមនុស្សចាស់ដោយការថែរក្សាពួកគាត់នៅផ្ទះ និងគាំទ្រប្ដីគ្រប់កាលៈទេសៈ (យោងតាម Ledgerwood 1994; Jacobsen ឆ្នាំ2008) ។ បទដ្ឋានសីលធម៌ និងការរំពឹង (moral standards and expectations) បែបនេះបានបន្តប្រតិបត្តិនៅក្នុងជីវិតប្រចាំថ្ងៃ ក្នុងនយោបាយ (យោងតាម Ledgerwood ឆ្នាំ1996) ក្នុងការអប់រំបែបបុរាណ និងសម័យទំនើប (យោងតាម Ledgerwood ឆ្នាំ1994; Jacobsen 2008) ក្នុងការងារនិងការចល័ត (work and mobility) នេះបើយោងតាម Derks ឆ្នាំ2008; Brickell 2011b; Bylander 2015; Peou ឆ្នាំ 2016 និងក្នុងការកំសាន្ត (Peou ឆ្នាំ2009) ។ សង្គមនិងក្រុមគ្រួសាររំពឹងថា ស្ត្រីគឺជា "***ភរិយាល្អ*** (good wives)" ទោះជានាងមានការងារធ្វើ ឬគ្មានក៏ដោយ។ យុវតីម្នាក់ដែលមានការងារពេញម៉ោងនៅក្នុងភូមិបាក់ខែងជិតរាជធានីភ្នំពេញបានឱ្យដឹងថា៖

*"បន្ទាប់ពីវិលត្រឡប់មកពីធ្វើការវិញខ្ញុំចម្អិនអាហារ និងធ្វើការងារផ្ទះផ្សេងទៀត។ ប្ដីរបស់ខ្ញុំមិនចេះធ្វើកិច្ចការទាំងនេះទេ។ គាត់អង្គុយនៅមុខទូរទស្សន៍ពេលដែលខ្ញុំកំពុងចំអិនអាហារ...... ។ ចំពោះការងារផ្ទះដូចជាការបោកសម្លៀកបំពាក់ និងការសម្អាតផ្សេងទៀតដែលខ្ញុំមិនអាចធ្វើបានក្នុងអំឡុងធ្វើការ ខ្ញុំធ្វើវានៅចុងសប្ដាហ៍» ។*

ការមានការងារធ្វើបានក្លាយទៅជាបន្ទុកមួយទ្វេជាពីរសម្រាប់ស្ត្រីខ្មែរដែលរៀបការរួច ព្រោះថា ពួកគេត្រូវព្យាយាមរក្សាតុល្យភាពរវាងទំនួលខុសត្រូវក្នុងគ្រួសារ និងសកម្មភាពសេដ្ឋកិច្ចគ្រួសារ។ ការសិក្សាថ្មីៗបានបង្ហាញថា ទោះបីស្ត្រីកម្ពុជាមួយចំនួនបានធ្វើចំណាកស្រុកទៅធ្វើការនៅទីឆ្ងាយពីផ្ទះក៏ដោយ ក៏ជាញឹកញាប់ ចំណងអាពាហ៍ពិពាហ៍ និងភាពជាមាតាបិតាតម្រូវឱ្យពួកគេត្រឡប់មកផ្ទះវិញធ្វើជាស្ត្រីមេផ្ទះ ឬទទួលបន្ទុកទ្វេដងក្នុងការធ្វើអាជីវកម្មខ្នាតតូច និងការថែទាំផ្ទះសម្បែង (យោងតាម Derks 2008; Peou and Zinn 2015; Peou 2016) ។ សកម្មភាពរកប្រាក់ចំណូលនៅឆ្ងាយពីផ្ទះជាញឹកញាប់ជាស្ថានភាពបណ្ដោះអាសន្នសម្រាប់ស្ត្រី។ ភាគច្រើន នៃស្ត្រីគ្មានការងារធ្វើដែលមានអាយុពី 32 ទៅ 35 ឆ្នាំ រស់នៅតំបន់ជនបទនៃខេត្តសៀមរាបដែលត្រូវបានសម្ភាសបានយល់ស្របថា «ស្ត្រីមិនគួរធ្វើការងារដែលតម្រូវឱ្យនាងធ្វើដំណើរឆ្ងាយនោះទេ គឺមិនមែនត្រឹមតែបារម្ភអំពីបញ្ហាសុវត្ថិភាពប៉ុណ្ណោះទេ ប៉ុន្តែថែមបារម្ភក្លាចគេរិះគន់ថា ជា «***ស្ត្រីមិនល្អ (bad' woma )***» យុវតីម្នាក់នៅក្នុង FGD 6 ដែលមកពីខេត្តកំពតបានរៀបរាប់ស្ថានភាពរបស់នាងព្រមទាំងរបស់ស្ត្រីផ្សេងទៀតនៅក្នុងភូមិថា៖

*"នៅទីនេះ ជីវិតប្រចាំថ្ងៃរបស់ខ្ញុំត្រូវឆ្លាស់ចុះឡើងរវាងផ្ទះនិងកសិដ្ឋានតូចមួយរបស់ខ្ញុំ។ មិនមានការងារផ្សេងទៀតដែលខ្ញុំអាចធ្វើបានដើម្បីទទួលបានប្រាក់ចំណូលបន្ថែម (លើទិន្នផលប្រចាំឆ្នាំរបស់យើង)នោះទេ ។ ខ្ញុំបានគិតថា នឹងបើកហាងលក់គ្រឿងទេសមួយ ប៉ុន្តែមើលនៅជុំវិញនេះចុះ អ្នកអាចឃើញមានហាងជាច្រើនរួចទៅនៅក្នុងភូមិតូចមួយបែបនេះ។ ការទៅភ្នំពេញដើម្បីរកការងារនៅរោងចក្រកាត់ដេរ គឺជាជម្រើសល្អមួយ ប៉ុន្តែអ្នកដឹងទេថា វាមិនមែនជារឿងងាយស្រួលនោះទេសម្រាប់ស្ត្រីដែលបានរៀបការរួចដូចជាពួកយើង។ អ្នកដែលមិនទាន់រៀបការពួកគេមាន«ជើងវែង» [«**ជើងវែង (longer legs)**» ន័យធៀបជាភាសាខ្មែរសំដៅលើ «**អាចធ្វើដំណើរឆ្ងាយពីផ្ទះ**»]។ បុរសទោះរៀបការរួច ឬមិនរៀបការមាន «ជើងវែង» ។ ប៉ុន្តែខ្ញុំមិនអាចទេ ទោះជាខ្ញុំចង់យ៉ាងណាក៏ដោយ។ ខ្ញុំមានកូនតូចពីរក្នុងបន្ទុក! បើខ្ញុំទៅរកការងារនៅរាជធានីភ្នំពេញ គ្មាននរណាមើលថែរក្សាពួកគេនិងផ្ទះនោះទេ "។*

បទដ្ឋានសង្គមតាមប្រពៃណីពិបាកនឹងផ្លាស់ប្ដូរណាស់ព្រោះថា ទាំងស្ត្រីនិងបុរសជឿថា ការងារផ្ទះគឺជាការទទួលខុសត្រូវរបស់ស្ត្រីតែម្នាក់គត់ ចំណែកស្ត្រីវិញគិតថា ខ្លួនឯងមានសំណាងណាស់ប្រសិនបើបានស្វាមីជួយ។ លើសពីនេះ ស្ត្រីវ័យក្មេងគ្មានការងារធ្វើដែលបានសម្ភាសក្នុង FGDs ជាទូទៅបានចែករំលែកទស្សនៈថា ជាធម្មជាតិបុរសឆ្លាតជាងស្ត្រី ។ ជំរុញដោយទស្សនៈបែបនេះ ក្មេងប្រុសទំនងជាត្រូវបានអនុគ្រោះបន្ថែមទៀតនៅក្នុងក្រុមគ្រួសារដើម្បីទទួលបានការអប់រំកាន់តែច្រើន។ ដូចយុវតីគ្មានការងារធ្វើម្នាក់នៅកណ្ដាលក្រុងសៀមរាបបានរៀបរាប់ថា៖

*«ខ្ញុំនឹងអនុញ្ញាតឱ្យកូនប្រុសរបស់ខ្ញុំរៀន។ មនុស្សប្រុសដែលមានការអប់រំអាចរកបានការងារបានស្រួលជាងស្ត្រី។ ចំពោះកូនស្រី ទោះបីជានាងបានរៀនតិចតួចក៏ដោយ ក៏នាងអាចប្រកបរបរអាជីវកម្មខ្នាតតូចមួយ ... ។ ស្ត្រីអាចរៀនជំនាញ (កាត់ដេរ) ដើម្បីរកប្រាក់ ដូច្នេះមិនចាំបាច់រៀនច្រើនពេកទេ ... ។ ស្ត្រីអាចរៀនត្រឹមថ្នាក់ទី 7 ឬ 8 និងអាចចាប់ផ្តើមអាជីវកម្មខ្នាតតូច ឬរៀនជំនាញណាមួយ ដូចជា កាត់ដេរនិងតុបតែងការ។ ប៉ុន្តែសម្រាប់បុរស វាជាការលំបាក (ក្នុងការស្វែងរកការងារដូចមនុស្សស្រី) "។*

សហគមន៍ និងក្រុមគ្រួសារមួយចំនួននៅកម្ពុជាក៏មានការខ្វល់ខ្វាយអំពីសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់ស្ត្រីដែលជាលទ្ធផលពីការចល័តឆ្ងាយពីផ្ទះផងដែរ។ យុវតីនៅលីវដែលចាកចេញពីផ្ទះទោះទៅធ្វើការ ឬសិក្សា នឹងបង្កើនការព្រួយបារម្ភមិនត្រឹមតែលើបញ្ហាសន្តិសុខខាងកាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបទដ្ឋានផ្លូវចិត្តដែលត្រូវរក្សា "**ទឹកចិត្តបរិសុទ្ធ** (virtuous)" រួមទាំងព្រហ្មចារី (virgin) ផងដែរ (យោងតាម Derks 2008)។ វិធីតែមួយគត់ដែលអាចឱ្យស្ត្រីផ្លាស់ប្តូរទៅធ្វើការនៅក្នុងទីក្រុងបានគឺប្រសិនបើមានសាច់ញាតិ ឬអ្នកភូមិដែលអាចទុកចិត្តបានណាម្នាក់កំពុងរស់នៅក្នុងទីក្រុង ឬកន្លែងដែលនាងចង់ទៅធ្វើការនោះ (យោងតាម Peou 2016) ។ ការសិក្សាថ្មីៗបានលើកឡើងថា ការអប់រំនិងការចល័តរកការងារធ្វើបានធ្វើឱ្យបទដ្ឋានសង្គមទាក់ទងនឹងតួនាទីរបស់ស្ត្រីនៅផ្ទះផ្លាស់ប្តូរច្រើន (យោងតាម Derks 2008; Brickell 2011b; Bylander 2015) ។

ឱកាសទទួលបានការអប់រំ និងការងារថ្មីបានជំរុញឱ្យយុវតីជំនាន់ក្រោយដែលមានអាយុពី 20 ទៅ 29 ឆ្នាំ ដែលរស់នៅតំបន់ទីក្រុងឆ្ងាយពីមូលដ្ឋានយេនឌ័រ តាមរយៈសកម្មភាព និងការងាររំពឹងទុករបស់ពួកគេ (យោងតាម Brickell, 2011)។ នៅក្រុងសៀមរាបដែលជាកន្លែងសេវាកម្ម និងវិស័យទេសចរណ៍កំពុងរីកលូតលាស់នោះ យុវជនជំនាន់ក្រោយកំពុងជម្នះប្រពៃណី និងកំពុងធ្វើចំណាកស្រុកដើម្បីស្វែងរកការងារប្រាក់មានប្រាក់ខែនៅទីក្រុង។ ទោះជាយ៉ាងណា ឱកាសទទួលបានការងារជំនាញទាបដូចជា រត់តុនៅភោជនីយដ្ឋាន និងបារនីយដ្ឋាន ឬនៅក្នុងហាងម៉ាស្សា សណ្ឋាគារ ឬហាងលក់វត្ថុអនុស្សាវរីយ៍ ជារឿយៗ បានជំរុញឱ្យមានការមាក់ងាយដល់ស្ត្រីដែលធ្វើការឆ្ងាយពីផ្ទះ ។

កិច្ចខិតខំប្រឹងប្រែងដើម្បីផ្លាស់ប្តូរបទដ្ឋានសង្គមរើសអើងយេនឌ័រ (gender-based discriminatory social norms) ជួនកាលផ្តល់ផលមិនល្អដែរ។ ស្ត្រីដែលបានចូលរួមក្នុងការបណ្តុះបណ្តាលស្តីពីតួនាទីយេនឌ័រក្នុងសង្គមបានយល់ដឹងអំពីសិទ្ធិរបស់ពួកគេ។ ប៉ុន្តែនៅពេលដែលពួកគេព្យាយាមអនុវត្តសិទ្ធិរបស់ខ្លួន ប្តីប្រពន្ធអាចនឹងខឹងគ្នានិងមានអំពើហិង្សាកើតឡើង។ អាជ្ញាធរក្នុងតំបន់បានរាយការណ៍ថា ការបណ្តុះបណ្តាលយេនឌ័រទាំងនេះពិតជាបានបង្កើនអំពើហិង្សាក្នុងគ្រួសារ។ ច្បាស់ណាស់ថា ការធ្វើឱ្យបុរសស្ត្រីបានយល់ពីបញ្ហានេះគឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការអនុវត្តបែបនេះ។ យុវតីគ្មានការងារធ្វើមួយចំនួនដែលត្រូវសម្ភាសក្នុងការសិក្សានេះបានចែករំលែកបទពិសោធន៍របស់ពួកគេថា៖

*"មុនពេលដែលយើងបានដឹងអំពីសិទ្ធិរបស់យើង យើងតែងស្ងាត់ស្ងៀម និងអន់ជាងប្តី....។ ឥឡូវនេះស្ត្រីជាច្រើននៅក្នុងភូមិធ្វើការតស៊ូមតិជាមួយប្តីរបស់ពួកគេដើម្បីសិទ្ធិនិងស្ថានភាពរបស់ពួកគេ។ ប្តីរបស់ពួកគេបែរជាខឹងខ្លាំងរហូតពេលខ្លះពួកគេបានប្រើអំពើហិង្សាប្រឆាំងនឹងស្ត្រី.....។ ខ្ញុំគិតថា វគ្គបណ្តុះបណ្តាលនេះគួរតែផ្តល់ទៅឱ្យបុរសផងដែរដើម្បីឱ្យពួកគេយល់ដឹងអំពីសិទ្ធិនិងឋានៈស្ត្រី។ បើមិនដូច្នេះទេ វាហាក់ដូចជាកាន់តែបង្កគ្រោះថ្នាក់ច្រើនជាងប្រយោជន៍ »។*

យុវតីដែលរស់នៅតំបន់ទីក្រុងទំនងជាមានឯករាជ្យផ្នែកហិរញ្ញវត្ថុ និងក្រៀបការជាងយុវតីនៅតំបន់ជនបទ។ នៅតំបន់ជនបទដូចជាខេត្តមណ្ឌលគិរី យុវតីអាចរៀបការនៅអាយុ 16 ឆ្នាំ ដែលអាចប៉ះពាល់ដល់ការសិក្សា និងមានគភ៌វ័យក្មេងពេក។ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេចង់ឱ្យយុវតីឆាប់រៀបការ។ ស្ត្រីនៅរាជធានី ជាពិសេសស្ត្រីដែលមានការងារធ្វើបានលើកឡើងថា ពួកគេចង់មានឯករាជ្យផ្នែកហិរញ្ញវត្ថុ និងការសម្រេចចិត្តមួយសម្រាប់ខ្លួនឯង។ ពួកគេសុខចិត្តក្រៀបការតាមតែអាចធ្វើទៅបាន ជាទូទៅដល់វ័យជិត 30 ឆ្នាំ ដើម្បីមានការងារធ្វើ និងមានស្ថេរភាពប្រាក់ខែ មុនពេលរៀបការ។

ទោះបីជាមានភស្តុតាងវិជ្ជមានដែលបង្ហាញថា ស្ត្រីមានឯករាជ្យផ្នែកហិរញ្ញវត្ថុច្រើនក៏ដោយ ក៏ឧបសគ្គសំខាន់ចំពោះជម្រើសការងារ និងការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅតែមាន ដោយសារទស្សនៈវប្បធម៌សង្គមដែលចាក់ឫសជ្រៅលើតួនាទីយេនឌ័រ និងការអនុវត្តនៅក្នុងសង្គមដូចបានឆ្លុះបញ្ចាំងតាមរយៈការបែងការងារក្នុងគ្រួសារ ការកំណត់អាយុរៀបការ ជម្រើសរបស់ឪពុកម្តាយសម្រាប់ការអប់រំរបស់ស្ត្រី គួបផ្សំនឹងការខ្វះខាតធនធានសម្ព័ន្ធ/ស្ថាប័នគាំទ្រដើម្បីធានាថា ស្ត្រីមិនត្រូវបានចងភ្ជាប់ទៅនឹងការទទួលខុសត្រូវនៅក្នុងគ្រួសារ ។ ការសិក្សានេះបានរកឃើញថា ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាច្រើនឆ្នាំពីសំណាក់ភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ក៏ដោយ ក៏បទដ្ឋានវប្បធម៌សង្គមដែលអនុគ្រោះដល់បុរសជាងស្ត្រីក្នុងវិស័យវិនិយោគ វិស័យអប់រំ និងការងាររំពឹងរបស់ស្ត្រី មិនត្រូវបានគេផ្តោតការយកចិត្តទុកដាក់ខ្លាំងនោះទេ ជាពិសេសនៅសហគមន៍ជនបទ ។

### **៤.២.៣ គម្លាតព័ត៌មាន និងបណ្តាញសង្គម**

យុវតីទាំងមាន និងគ្មានការងារធ្វើនៅក្នុងក្រុមគោលដៅ ជាទូទៅ បានរាយការណ៍ថា ពួកគេពុំបានទទួលបានដំណឹងអំពីការជ្រើសរើសបុគ្គលិកធ្វើការនៅក្នុងសហគមន៍របស់ពួកគេនោះទេ។ សូម្បីតែដំណឹងជ្រើសរើសបុគ្គលិកនៅជាយរាជធានីភ្នំពេញក៏ផ្សព្វផ្សាយតាមបណ្តាញបិទជិត ពោលគឺតាមរយៈមិត្តភក្តិ និងសាច់ញាតិ។ មេឃុំ ឬអាជ្ញាធរមូលដ្ឋានបានជួយលើកកម្ពស់ឱកាសការងារនៅក្នុងសហគមន៍តិចតួចប៉ុណ្ណោះ ដែលធ្វើឱ្យប្រជាជនក្នុងតំបន់ជាពិសេសយុវតីពុំអាចទទួលបានដំណឹង ថាតើមានការងារអ្វីខ្លះ ការងារអ្វីដែលមានប្រាក់ខែ និងលក្ខខណ្ឌការងារល្អប្រសើរ ឬប្រហាក់ប្រហែលមុន និងទាមទារឱ្យមានជំនាញអ្វីខ្លះ។ ការពុំសូវមានវត្តមានរបស់ក្រុមហ៊ុនឯកជន និងអង្គការ គួបផ្សំនឹងការខ្វះខាតព័ត៌មានផងនោះ ធ្វើឱ្យស្ត្រីមានក្តីរំពឹងតិចតួចក្នុងការស្វែងរកការងារមានប្រាក់ខែ។ សម្រាប់យុវតីដែលរស់នៅឆ្ងាយពីរាជធានីភ្នំពេញប្រហែលត្រឹមតែ 10 ទៅ 15 គីឡូម៉ែត្រឡើង គម្លាតព័ត៌មានមានច្រើន ពួកគេទំនងជាបានដឹងតិចតួចអំពីប្រភេទការងារជំនាញដែលមាននៅក្បែរៗនោះ។

នៅក្នុងខេត្តដាច់ស្រយាលជុំវិញខេត្តមណ្ឌលគិរី ឱកាសការងារមានប្រាក់ខែផ្លូវការសម្រាប់ស្ត្រីស្ទើរតែមិនមាន។ ដោយមានដីប្រកបដោយជីជាតិ ភាគច្រើននៃប្រជាពលរដ្ឋក្នុងខេត្តមណ្ឌលគិរីប្រកបរបរជាកសិករ ឬកម្មករក្នុងចំការតាមរដូវកាល ឬជាម្ចាស់អាជីវកម្មខ្នាតតូច ដូចជា ហាងលក់គ្រឿងទេសជាដើម។ នៅសែនមនោរម្យដែលជាទីក្រុងនៃខេត្តមណ្ឌលគិរី ទោះបីស្ត្រីមួយចំនួនធ្វើការនៅក្នុងធនាគារ និងអង្គការក្រៅរដ្ឋាភិបាលក៏ដោយ ក៏ពួកគេទំនងជាមិនយល់អំពីការងារ និងជំនាញតម្រូវដែរ។ លទ្ធភាពទទួលបានព័ត៌មានពាក់ព័ន្ធនឹងការងារសំខាន់ៗអាចទទួលបានក្នុងរង្វង់តូចចង្អៀតតាមរយៈមិត្តភក្តិ ឬសាច់ញាតិ។

លទ្ធភាពទទួលបានព័ត៌មាន និងការងារមួយផ្នែកធំពឹងផ្អែកលើបណ្តាញសង្គមរបស់បុគ្គល ។ តាមរយៈ FGDs ដែលអនុវត្តសម្រាប់ការសិក្សានេះបានឱ្យដឹងថា មានភស្តុតាងតិចតួចពាក់ព័ន្ធនឹងការទទួលបានពីព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម វិទ្យុ ទូរទស្សន៍ និងបណ្តាញជំនាញសង្គមផ្លូវការផ្សេងទៀត។ ជាធម្មតា ព័ត៌មានការងារដឹងតាមរយៈប្រភពនៅក្នុងកន្លែងការងារ។ ស្ត្រីពឹងផ្អែកលើមិត្តភក្តិ ឬសាច់ញាតិដែលកំពុងធ្វើការដើម្បីព័ត៌មានការងារ និងមិនអាចពឹងផ្អែកលើអង្គការផ្លូវការ ឬមេដឹកនាំសហគមន៍ឡើយ។ ជាទូទៅ ទាំងស្ត្រីគ្មាននិងមានការងារធ្វើបានចែករំលែកបទពិសោធន៍របស់ខ្លួននៅក្នុងការសិក្សានេះ ។ ពិសេសយុវតីការងារធ្វើនៅខេត្តសៀមរាបបានសម្តែងការខកចិត្តរបស់ខ្លួនអំពីការខ្វះការគាំទ្រពីសាធារណៈក្នុងការស្វែងរកការងារ។ ស្ត្រី "**ដើរចូល** (walk in)" ទៅក្នុងការដ្ឋានសំណង់ ឬកន្លែងការងារដែលមានសក្តានុពលដើម្បីសុំឱ្យខ្លួនបានធ្វើការ។

### ៤.២.៤ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសោភកម្មការងារ

ជាញឹកញាប់ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដែលផ្តល់ដោយរដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាលមិនសូវស្របនឹងចិត្តរបស់យុវតីទេ។ ស្ត្រីដែលបានសម្ភាសបានត្អូញត្អែរថា ការបណ្តុះបណ្តាលដែលផ្តល់ឱ្យបានផ្តោតតែលើជំនាញទាបដូចជា ការដេរ ឬរត់តុ ដោយបន្សល់ទុកនូវក្តីរំពឹងតិចតួចសម្រាប់ការងារល្អជាងមុន។ ពួកគេមិនដែលទទួលបានការបណ្តុះបណ្តាលណាមួយស្តីពីជំនាញគ្រប់គ្រង និងសហគ្រិនភាព (managerial and entrepreneurial skills) នោះទេ។ នៅពេលដែលអាជ្ញាធរមូលដ្ឋាន ឬអង្គការក្រៅរដ្ឋាភិបាលផ្តល់ការគាំទ្រដូចជាសេវាផ្នែកពង្រីកកសិកម្ម មានមនុស្សមកចូលរួមតិចតួចណាស់ គឺថា ក្នុងចំណោមប្រាំនាក់ដែលបានចុះឈ្មោះ មានប្រហែលតែម្នាក់ទេដែលបានមករៀន។ បញ្ហានេះត្រូវបានស្ត្រី ទាំងក្នុងទីប្រជុំជន និងជាយក្រុងភ្នំពេញនិយាយតគ្នា។ ដោយហេតុថា ក្តីរំពឹងថានឹងបានធ្វើការក្នុងវិស័យផ្លូវការ (ដូចជាអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬក្រុមហ៊ុនឯកជន) នៅមានកម្រិតទាប យុវតីគ្មានការងារដែលរវល់នឹងការងារផ្ទះសម្បែង និងការចិញ្ចឹមកូនចៅផងនោះយល់ថា វគ្គបណ្តុះបណ្តាលទាំងនេះមិនសមនឹងពួកគេទេ។

ពុំមានមជ្ឈមណ្ឌលអាជីពផ្លូវការ ឬសោភកម្មការងារដែលអាចជួយស្ត្រីក្នុងការស្វែងរកការងារបានសមរម្យនោះទេ។ យុវតីគ្មានការងារធ្វើម្នាក់កំពុងរស់នៅជាយក្រុងភ្នំពេញបានលើឡើងថា៖

*«វគ្គបណ្តុះបណ្តាលត្រូវគេបានផ្តល់ឱ្យដែរនៅក្នុងភូមិនេះ ប៉ុន្តែគឺសម្រាប់ការងារក្នុងរោងចក្រកាត់ដេរឬការរោងចក្រទឹកសុទ្ធ ស្ថានីយ៍ហ្គាស ឬភោជនីយដ្ឋាន។ មានតែស្ត្រីមានការអប់រំខ្ពស់មួយចំនួនតូចប៉ុណ្ណោះ ដែលអាចរកបានការងារល្អប្រសើរនៅក្នុងទីក្រុង។ នៅទីនេះអ្នកមិនអាចរកបានការងារល្អប្រសើរទេ។ រោងចក្រនឹងបណ្តុះបណ្តាអ្នកតែមួយរយៈខ្លី អ្នកនឹងអាចធ្វើការងារបានហើយ។*

ដោយសារការខ្វះខាតការរៀបចំការបណ្តុះបណ្តាលជាផ្លូវការ និងមធ្យោបាយស្វែងរកអាជីព គួបផ្សំនឹងភាគរយ នៃមនុស្សដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅផ្លូវការច្រើនផងនោះ ជាទូទៅ គេគួរតែអនុវត្តតាមរយៈការហ្វឹកហ្វឺនផ្ទាល់ (apprenticeship) ជាមួយនឹងវិស័យឯកជនក្នុងអាជីវកម្មខ្នាតតូច ដូចជា ហាងកាត់ដេរជាដើម។ ទស្សនៈអាជីពនឹងត្រូវបានបង្កើតឡើងបន្ទាប់ពីអ្នកហ្វឹកហាត់បានធ្វើការងារមួយ ហើយអ្នកនោះនឹងបន្តអភិវឌ្ឍចំណាប់ចាប់អារម្មណ៍ អភិវឌ្ឍជំនាញ និងបង្កើតបណ្តាញទំនាក់ទំនងដោយខ្លួនឯង (យោងតាម Peou ឆ្នាំ2016) ។ ការបណ្តុះបណ្តាល ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់អង្គការអាតហុកដែលមិនបានភ្ជាប់ទៅនឹងមធ្យោបាយស្វែងរកអាជីពមួយច្បាស់លាស់
គឺមិនមានប្រសិទ្ធិភាពនោះទេ ហើយត្រូវយុវវ័យមើលរំលងទៀតផង។

ការខ្វះខាតមធ្យោបាយធ្វើដំណើរទៅកាន់មជ្ឈមណ្ឌលបណ្តុះបណ្តាលដែលមានស្រាប់ គឺជាឧបសគ្គបន្ថែមទៀតក្នុងការចូលទៅដល់ការបណ្តុះបណ្តាល។ មជ្ឈមណ្ឌលបណ្តុះបណ្តាលជាធម្មតាស្ថិតក្នុងទីប្រជុំជនចំណែកស្ត្រីមកពីតំបន់ជនបទ។ ស្ត្រីគ្មានការងារធ្វើនៅក្នុងខេត្តសៀមរាប និងខេត្តកំពត បានរាយការណ៍ថា ការបណ្តុះបណ្តាលតម្រូវឱ្យចូលរៀនពេញមួយថ្ងៃ ដែលមិនអាចទៅរួចទេសម្រាប់ស្ត្រីមានកូន និងមានការងារផ្ទះ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈភាគច្រើនសម្រាប់តែស្ត្រីមិនទាន់រៀបការដែលអាចលះបង់ពេលវេលា និងថាមពលសម្រាប់ការអភិវឌ្ឍអាជីពបន្ថែម។ លទ្ធភាពចូលទៅដល់ការបណ្តុះបណ្តាល និងភាពពាក់ព័ន្ធទៅនឹងបណ្តុះបណ្តាលនោះនៅតែឧបសគ្គសំខាន់សម្រាប់ស្ត្រីដែលកំពុងស្វែងរកការអភិវឌ្ឍ ឬជំនាញថ្មី និងការងារល្អប្រសើរជាងមុន។

### ៤.២.៥ ការបោះបង់ការសិក្សា

អត្រាយុវតីចុះឈ្មោះចូលរៀនខ្ពស់ជាងយុវជននៅបឋមសិក្សា និងអនុវិទ្យាល័យដែលការចុះឈ្មោះនេះជាកាតព្វកិច្ច ។ ទោះជាយ៉ាងណា និន្នាការនេះនឹងផ្ទុយវិញចាប់ពីវិទ្យាល័យឡើងទៅ។ នៅឆ្នាំ 2014 ភាគរយ នៃយុវតីចូលរៀននៅបឋមសិក្សានិងអនុវិទ្យាល័យមានចំនួន 89 ភាគរយ ធៀបនឹងយុវជនមានតែ 87 ភាគរយ ប៉ុណ្ណោះ (យោងតាម CSES, 2014) ។ នេះគឺជាបានប្រសើរជាងកាលពីឆ្នាំ 2004 ដែលពេលនោះអត្រាយុវតីចុះឈ្មោះចូលរៀនមានចំនួន 81 ភាគរយ និងយុវជនមានចំនួន 83 ភាគរយ ។ ទោះជាយ៉ាងណា ចាប់ពីអាយុ 15 ទៅ 24 ឆ្នាំ (អាយុរៀន នៅវិទ្យាល័យ និងឧត្តមសិក្សា) អត្រាចូលរៀនរបស់យុវតីបានធ្លាក់ចុះដល់ 26 ភាគរយ និងអត្រាចូលរៀនរបស់យុវជនមានចំនួន 29 ភាគរយ (យោងតាម CSES ឆ្នាំ2014) ។ ការបោះបង់ការសិក្សានៅបឋមសិក្សាធ្វើឱ្យយុវតីមានជម្រើសការងារតិចតួច ដែលនៅទីបំផុតពួកគេត្រូវធ្វើការងារផ្ទះគ្មានប្រាក់ខែ ឬការងារមានប្រាក់ខែជំនាញទាប ដោយសារតែកម្រិតអប់រំរបស់ពួកគេទាបដែរ។ ទិន្នន័យប្រើពេលវេលាបង្ហាញថា បន្ទុកនៃការងារផ្ទះអាចជាឧបសគ្គដល់ទាំងការអប់រំ និងការស្វែងរកការងារមានប្រាក់ខែរបស់ស្ត្រី នៅពេលក្រោយ។ ការដែលយុវតីទទួលបានការអប់រំទាបធ្វើឱ្យមានវិសមភាពយេនឌ័រនៅក្នុងទីផ្សារការងារ។ ដោយសារឥទ្ធិពលនៃជំនឿតាមប្រពៃណី និងតម្លៃពាក់ព័ន្ធនឹងតួនាទីយេនឌ័រ ឪពុកម្តាយមានចិត្តគាំទ្រយ៉ាងខ្លាំងលើការអប់រំរបស់កូនប្រុស និងទុកកូនស្រីឱ្យធ្វើការងារផ្ទះ។ មូលហេតុដែលគេនិយាយជាញឹកញាប់បំផុតពាក់ព័ន្ធនឹងការមិនចូលរៀនរបស់យុវជនយុវតីដែលមានអាយុពី 6 ទៅ 17 ឆ្នាំ គឺ «**ត្រូវរួមចំណែករកប្រាក់ចំណូលគ្រួសារ**» បន្ទាប់មកទៀតគឺ «**មិនចង់ទៅរៀន**» (យោងតាម CSES, 2014) ។ ការដែលត្រូវរួមចំណែករកប្រាក់ចំណូលគ្រួសារជាហេតុផលដែលនាំឱ្យ 34 ភាគរយ នៃយុវតីមិនចូលរៀន ធៀបទៅនឹងយុជនមានតែ 25 ភាគរយ ប៉ុណ្ណោះ ។ នេះបង្ហាញថា តម្លៃទាបដែលឪពុកម្តាយផ្តល់លើការអប់រំ និងទម្ងន់នៃតម្លៃឱកាសក្នុងការបញ្ជូនកូនទៅសាលារៀនខ្ពស់ គឺជាកត្តាសម្រេចចិត្ត ។ គម្លាតការងារគ្មានប្រាក់ខែរបស់ស្ត្រីមានចំនួន 3.5 ម៉ោងក្នុងមួយថ្ងៃ ដែលធម្មតាគឺជាការងារផ្ទះ (យោងតាម ADB, 2013) ។

ស្ត្រីភាគច្រើននៅក្នុងតំបន់សិក្សាទាំងបួនបានរាយការណ៍ថា យុវតីច្រើនជាងយុវជនបានចាប់ផ្តើមបោះបង់ការសិក្សាមុនយុវជន ជាពិសេសនៅតាមតំបន់ជនបទ។ ឪពុកម្តាយខ្លះបានមើលឃើញឱកាសការងារសម្រាប់កូនប្រុសល្អប្រសើរជាងកូនស្រី។ នេះគឺដោយសារតែជាទូទៅបុរសមានការងារផ្លូវការ និងការសម្រេចចិត្ត ចំណែកស្ត្រីមានតែការងារក្រៅផ្លូវការ ការងារតាមរដូវកាល និងការងារផ្ទះ។ ទោះជាយ៉ាងណា ក្នុងចំណោមអ្នកផ្តល់ចម្លើយមានទស្សនៈលើកឡើងខុសៗគ្នា ។ ក្រុមយុវតីដែលកំពុងធ្វើការនៅកណ្តាលរាជធានីភ្នំពេញ និងនៅទីប្រជុំជន និងសូម្បីតែនៅក្នុងខេត្តមណ្ឌលគិរីដែលជាខេត្តដាច់ស្រយាលមួយនោះ បានអះអាងនៅក្នុងការសិក្សានេះថា ការអប់រំគឺសំខាន់សម្រាប់យុវជនទាំងពីរភេទ ហើយពួកគេបានមើលឃើញឱកាសការងារស្មើគ្នា ឬថា ស្ត្រីថែមទាំងមានឱកាសទទួលបានការងារប្រសើរជាងបុរសទៀតផង ។ ទោះជាយ៉ាងណា ស្ត្រីនៅតាមតំបន់ជនបទដាច់ស្រយាល ជាពិសេសក្រុមស្ត្រីគ្មានការងារដែលភាគច្រើនជាស្ត្រីមេផ្ទះនោះ ទំនងជាប្រកាន់យកទស្សនៈផ្សេងពីនេះពាក់ព័ន្ធនឹងការអប់រំរបស់មនុស្សប្រុស។ ស្ត្រីមួយចំនួន(ដូចក្នុងករណីខេត្តសៀមរាប និងខេត្តកំពត) ត្រូវបានគេរាយការណ៍ថា បានបោះបង់ការសិក្សាដោយសារតែពួកគេចង់ឱ្យបងប្អូនប្រុសរបស់ពួកគេបានសិក្សារៀនសូត្រ ហើយក្រុមគ្រួសារចង់ឱ្យពួកគេជាស្រីៗជួយកិច្ចការផ្ទះ និងរកប្រាក់ចំណូលសម្រាប់ការអប់រំរបស់បងប្អូនប្រុសរបស់ខ្លួន។

នៅតំបន់ដាច់ស្រយាលដូចជាខេត្តមណ្ឌលគិរី ការអប់រំសម្រាប់ស្ត្រីមិនត្រូវបានគេចាត់ទុកថាជាការសំខាន់ទេ និងមានការលំបាកក្នុងការទទួលបានណាស់ ព្រោះថា បទដ្ឋានសង្គមសម្រាប់យុវតីគឺត្រូវរៀបអាពាហ៍ពិពាហ៍ទាន់នៅក្មេង។ សាលាមានទីតាំងស្ថិតនៅឆ្ងាយពីផ្ទះរបស់ប្រជាជន ជាពិសេសសាលាមធ្យមសិក្សា ដែលធ្វើឱ្យឪពុកម្តាយភាគច្រើនមានការប្រុងប្រយ័ត្នអំពីការបញ្ជូនកូនស្រីរបស់ខ្លួនទៅសាលា។ មនុស្សនៅទីនោះមិនសូវយល់តម្លៃ នៃការអប់រំថាអាចពាក់ព័ន្ធដល់ជីវភាពប្រចាំថ្ងៃរបស់ពួកគេនោះទេ ព្រោះឱកាសការងារសម្រាប់អ្នកដែលបានបញ្ចប់ឧត្តមសិក្សានៅក្នុងខេត្តនេះមានតិចតួចណាស់ ហើយនៅទៅនោះយុវតី ឬស្ត្រីខ្លួនឯង ក៏មិនមានតួនាទីគំរូដែរ។ ជាលទ្ធផល ពួកគេមើលមិនឃើញតម្លៃ នៃការបន្តការសិក្សាទៅឧត្តមសិក្សានោះទេ។ ឧទាហរណ៍៖ ក្រៅពីការងាររដ្ឋដែលមនុស្សមានចំណាប់អារម្មណ៍តិចតួចដោយសារតែឋានៈ និងប្រាក់ខែទាប ពួកគេពុំឃើញមានក្រុមហ៊ុនឯកជន ឬស្ថាប័នច្រើននៅក្នុងខេត្តដាច់ស្រយាលនេះទេ។ ស្ថាប័នតែមួយគត់ដែលមានគឺ ធម្មតាជា ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ។ ការងារនៅក្នុងស្ថាប័នទាំងនោះគឺសម្រាប់យុវជនជាចម្បង ព្រោះពួកគេចាំបាច់ត្រូវធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយដើម្បីជួបអតិថិជន។ ចំណែកស្ត្រីមានអារម្មណ៍ថា មានអសន្តិសុខក្នុងការកាន់មុខតំណែងបែបនេះ។
ស្ត្រីម្នាក់ ដែលកំពុងធ្វើការ (កម្មករគណនីខ្លួនឯង) បានសង្កេតឃើញថា៖

*"ស្ថានភាពហិរញ្ញវត្ថុសម្រាប់គ្រួសាររបស់ខ្ញុំគឺមិនមែនជាឧបសគ្គចម្បងដល់ការសិក្សារបស់ខ្ញុំទេ។ បញ្ហាចម្បងគឺ មិនមានវិទ្យាល័យនៅក្នុងភូមិរបស់ខ្ញុំនៅពេលនោះ ហើយខ្ញុំខ្លួនឯងពិតជាមិនចង់រៀនយូរដែរដោយសារតែ*

*យល់ឃើញថា សមត្ថភាពបង្កើតប្រាក់ចំណូលរវាងការបញ្ចប់បឋមសិក្សានិងអនុវិទ្យាល័យមិនមានភាពខុសគ្នាច្រើននោះទេ នេះជាមូលហេតុដែលខ្ញុំបានបោះបង់ការសិក្សានៅថ្នាក់ទី 5 ។ ឥឡូវនេះ ខ្ញុំសោកស្តាយបន្តិចដែរដែលខ្ញុំមិនបានបញ្ចប់ការអប់រំខ្ពស់ជាងនេះ។ ប្រសិនបើខ្ញុំមានចំណេះដឹងខ្ពស់ជាងនេះ ខ្ញុំអាចអាចគ្រប់គ្រងអាជីវកម្មផ្ទាល់ខ្លួនរបស់ខ្ញុំបានល្អប្រសើរជាងពេលបច្ចុប្បន្ន ប៉ុន្តែពេលនេះទោះជាខ្ញុំចង់រៀន ក៏ខ្ញុំមិនអាចដែរ ដោយសារតែខ្ញុំមានគ្រួសារដើម្បីថែរក្សា»* ។

គម្លាតនេះមិនមែនមានតែនៅក្នុងយេនឌ័រផ្ទុយគ្នាប៉ុណ្ណោះទេ ប៉ុន្តែ វាក៏កើតមាននៅក្នុងយេនឌ័រដូចគ្នានៅក្នុងទីតាំងផ្សេងគ្នាផងដែរ។ គម្លាតធនធានមនុស្សនេះកើតមានពីទីក្រុងទៅជនបទនិងខេត្តដាច់ស្រយាលហើយគួរឱ្យចាប់អារម្មណ៍ទៀតនោះគឺថា ក្រុមស្ត្រីផ្សេងគ្នាក៏ត្រូវបានគេរាយការណ៍មកថា មានគម្លាតផ្សេងគ្នាដែរ ផ្អែកលើសង្គមូបនីកម្មក្នុងចំណោមក្រុមពួកគេ។ ក្រុមស្ត្រីធ្វើការនៅតាមទីក្រុងត្រូវបានរាយការណ៍មកថា យុវតីដែលពួកគេបានស្គាល់ជាធម្មតាមានសញ្ញាបត្របាក់ឌុប ឬសញ្ញាបត្របរិញ្ញា ខណៈដែលក្រុមស្ត្រីគ្មានការងារធ្វើវិញបានលើកឡើងថា ស្ត្រីភាគច្រើនដែលពួកគេបានស្គាល់ភាគច្រើនរៀនបានត្រឹមកម្រិតអនុវិទ្យាល័យ ឬវិទ្យាល័យ។ នៅតាមតំបន់ជនបទដាច់ស្រយាល ការអប់រំរបស់ស្ត្រីមានការខុសគ្នារវាងឆ្នាំដំបូងនៃការអប់រំ និងឆ្នាំបញ្ចប់វិទ្យាល័យ។ លទ្ធផលសិក្សាបានបង្ហាញថា ស្ត្រីដែលមានវ័យជាង 30 ឆ្នាំ ហាក់ដូចជាទទួលបានការអប់រំទាបជាងក្មេងៗច្រើនណាស់។ លទ្ធភាពរកសាលារៀនគឺកម្រណាស់កាលពីរបីទសវត្សរ៍មុន ហើយការធ្វើកសិកម្មគឺជាមុខរបរសំខាន់ដែលធ្វើឱ្យតម្រូវការលើការអប់រំជាផ្លូវការធ្លាក់ចុះ។ ពេលនេះ ក្រុមក្មេងៗមានឱកាសទៅរៀនបានច្រើន ព្រោះសាលារៀនជាច្រើនត្រូវបានសាងសង់នៅជិតលំនៅដ្ឋាន ហើយការអប់រំក៏ចាប់ផ្តើមមានតម្លៃល្អប្រសើរជាងមុន។

ទោះជាយ៉ាងណា តាមរយៈការសង្កេតនិន្នាការទូទៅនៃការអភិវឌ្ឍវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាអាចឱ្យដឹងថា ការផ្លាស់ប្តូរបណ្តើរៗ នៃតម្លៃការអប់រំសម្រាប់យុវជនយុវតីអាចឃើញហើយ។ យុវតីបានចូលរៀនបានកាន់តែច្រើនហើយ ហើយអត្រាបោះបង់ការសិក្សារបស់យុវតីនៅបឋមសិក្សាក៏ទាបជាងក្មេងប្រុស។ នេះបង្ហាញថា មានការផ្លាស់ប្តូរបណ្តើរៗក្នុងការវិនិយោគក្នុងការអប់រំរបស់យុវតី។ បាតុភូតបែបនេះបានបង្ហាញតាមរយៈការសម្ភាសជាមួយមនុស្សចាស់ក្នុងខេត្តខេត្តមណ្ឌលគិរីដែលជាខេត្តដាច់ស្រយាល។ ដូចស្ត្រីវ័យចំណាស់ម្នាក់នៅក្នុងភូមិបានលើកឡើងថា៖

*«អនាគតគឺមិនប្រាកដប្រជាទេ។ ពេលខ្លះយើងចង់បើកអាជីវកម្ម ប៉ុន្តែសូម្បីតែអានអក្សរក៏យើងមិនចេះផង តើយើងធ្វើវាយ៉ាងម៉េច? ប្រសិនបើយើងបានសិក្សានោះវាធ្វើឱ្យយើងស្ថិតក្នុងស្ថានភាពល្អប្រសើរជាងមុន។ ខ្ញុំបានសម្រេចចិត្តឱ្យកូនរបស់ខ្ញុំទៅសាលារៀន ទោះបីជាកូនស្រីក៏ដោយ។ វាជាការពិបាកក្នុងការទស្សន៍ទាយអនាគត។ យើងមិនអាចពឹងផ្អែកលើប្តីរបស់យើងជារៀងរហូតទេ បើប្តីចេះរកលុយតែយើងមិនចេះ គឺពិបាកហើយ។ យើងត្រូវតែចេះរកលុយដែរ ទោះបីជាលក់គ្រឿងទេសតូចតាចនៅផ្ទះក៏ដោយ។ ... ខ្ញុំដឹងថាវាពិបាកណាស់ក្នុងការមិនចេះអានឬសរសេរភាសាខ្មែរ។ នោះហើយជាមូលហេតុដែលខ្ញុំចង់ឱ្យកូនស្រីរបស់ខ្ញុំទៅរៀន ... បើមិនដូច្នេះ វានឹងមានការលំបាកសម្រាប់ក្រុមគ្រួសាររបស់យើង ។"*

ប៉ុន្មានឆ្នាំចុងក្រោយនេះ ការចុះឈ្មោះចូលរៀនរបស់យុវតីបានកើនឡើងច្រើន ទាំងនៅក្នុងទីក្រុងនិងសហគមន៍ជនបទ (យោងតាម EMIS, 2005-15) ។ ឱកាសអប់រំប្រសើរឡើងសម្រាប់យុវតីនេះអាចជាលទ្ធផល នៃផលវិបាកដែលឪពុកម្តាយភាគច្រើន ជាពិសេសម្តាយតែម្តងបានជួបប្រទះនៅក្នុងឆាកជីវិតនៅពេលដែលពួកមិនចេះអក្សរ ឬមិនអាចធ្វើនព្វន្តសាមញ្ញមួយបាន។ ដូច្នេះ ពួកគេបានចាប់ផ្តើមបញ្ជូនកូនស្រីទៅសាលារៀន។ យុវតីមួយចំនួនថែមទាំងបានរាយការណ៍មកថា ឱកាសការងារថ្មីៗនេះបានអនុគ្រោះដល់ស្ត្រី ព្រោះប្រកាសការងារជាច្រើនទំនងជាផ្តល់អាទិភាពបន្ថែមដល់ស្ត្រី និងលើកទឹកចិត្តស្ត្រីឱ្យដាក់ពាក្យ។ ក្រុមយុវតីដែលមានការងារធ្វើនៅកណ្តាលរាជធានីភ្នំពេញបានអះអាងដោយមោទនភាពថា៖

*"បើធៀបទៅនឹងបុរស ស្ត្រីមិនមានបញ្ហាក្នុងការស្វែងរកការងារទេនៅពេលពួកគេមានចំណេះដឹង និងការអប់រំល្អ ឬក៏បុរស និងស្ត្រីមានលទ្ធភាពស្មើគ្នា ពាក់ព័ន្ធនឹងបញ្ញា និងសមត្ថភាព"* ។

ឪពុកម្តាយភាគច្រើនទំនងជាថ្លឹងថ្លែងរវាងការងារដំបូង និងការសិក្សារបស់កូនពួកគេ។ ដោយសារតែយុវតីសិក្សាបានពូកែនៅសាលា ឪពុកម្តាយបានវិនិយោគបន្ថែមក្នុងការអប់រំរបស់ពួកគេ។ ឧទាហរណ៍៖ អ្នកផ្តល់ចម្លើយភាគច្រើននៅជនបទក្នុងខេត្តកំពតបានឱ្យដឹងថា៖

*"ខ្ញុំនឹងគាំទ្រកូនរបស់ខ្ញុំដោយមិនគិតពីយេនឌ័រដើម្បីទទួលបានការអប់រំច្រើនតាមតែពួកគេអាចធ្វើបាន ដើម្បីឱ្យពួកគេមានអនាគតភ្លឺស្វាងជាងខ្ញុំ។ ប្រសិនបើពួកគេមិនប្រឹងប្រែងរៀនឱ្យបានល្អនៅក្នុងថ្នាក់ទេ ខ្ញុំនឹងពិចារណាបញ្ជូនពួកគេទៅរៀនជំនាញវិជ្ជាជីវៈណាមួយ ឬបញ្ជូនពួកគេទៅរកការងារបង្កើតប្រាក់ចំណូល "* ។

ទោះយ៉ាងណា យេនឌ័រនៅតែជាឧបសគ្គរាំងយុវតីមកពីគ្រួសារក្រីក្រមិនអាចបន្តការសិក្សារបស់ខ្លួន។ យុវតីមាននិងគ្មានការងារធ្វើនៅក្រុងសៀមរាបបានសម្តែងការសោកស្តាយរបស់ពួកគេចំពោះការដែលខ្លួនមិនអាចបន្តការសិក្សាដោយសារតែសង្គ្រាមនិងភាពក្រីក្រយ៉ាងដូច្នេះថា៖

*«ប្រសិនបើខ្ញុំអាចបង្វិលពេលវេលាត្រឡប់ក្រោយវិញបាននិងប្រសិនបើគ្មានសង្គ្រាម ឬឧបសគ្គណាមួយទេ ខ្ញុំចង់បន្តការសិក្សារបស់ខ្ញុំ។ ប្រសិនបើខ្ញុំមានឱកាសបន្ទាប់ពីខ្ញុំបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ (ដែលកាលនោះពួកគេមិនមានបំណងទៅសាកលវិទ្យាល័យ) ខ្ញុំចង់ក្លាយជាគ្រូបង្រៀន ឬបុគ្គលិកអង្គការ ឬការចាប់ផ្តើមអាជីវកម្មតូចមួយ។ ពួកគេក៏ជឿជាក់ផងដែរថា ប្រវត្តិការអប់រំខ្ពស់ជាងនេះជាប្រយោជន៍សម្រាប់ការទទួលបានការងារមានប្រាក់ខែល្អប្រសើរ ... ខ្ញុំសោកស្តាយណាស់។ ខ្ញុំច្រណែននឹងមនុស្សផ្សេងទៀតដែលមានឱកាសទៅសិក្សា។ ពេលនេះ ខ្ញុំចង់រៀន ប៉ុន្តែខ្ញុំមិនអាចទេ ... ប្រសិនបើក្រុមគ្រួសាររបស់ខ្ញុំមិនក្រីក្រទេ ខ្ញុំនឹងខិតខំរៀន ... ប្រសិនបើខ្ញុំអាចបង្វិលពេលវេលាត្រឡប់ក្រោយវិញបាន។ កាលដែលខ្ញុំនៅរៀន ខ្ញុំបានលក់បង្អែមបន្ទាប់ពីចេញពីរៀន ... ឪពុកម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំមិនឱ្យទៅរៀន។ ក្រុមគ្រួសាររបស់យើងក្រណាស់។ ខ្ញុំត្រូវជួយលក់របស់របរ។ ដូច្នេះខ្ញុំពិតជាមិនមានពេលវេលាដើម្បីទៅសាលារៀនទេ។ ខ្ញុំមិនចេះជិះកង់ ដូច្នេះខ្ញុំត្រូវដើរទៅសាលា"* ។

សរុបជារួម កំណត់ហេតុទាំងនេះផ្តល់នូវការយល់ដឹងយ៉ាងល្អចូលទៅក្នុងការតស៊ូដែលស្ត្រីកម្ពុជាប្រឈមនៅពេលចូលក្នុងទីផ្សារការងារផ្លូវការនិងព្យាយាមនៅបន្ត។ អត្រាលើសលុបនៃការងារមិនផ្លូវការសម្រាប់យុវតី គម្លាតព័ត៌មាន និងការខ្វះខាតបណ្តាញសង្គមដើម្បីលើកកម្ពស់ការស្វែងរកការងារ ការបណ្តុះបណ្តាលវិជ្ជាជីវៈមិនគ្រប់គ្រាន់ និងបទដ្ឋានប្រពៃណីពាក់ព័ន្ធនឹងសង្គមនិងយេនឌ័រដែលជំរុញឱ្យយុវតីឆាប់បោះបង់ការសិក្សាជាងយុវជន កត្តាទាំងអស់នេះរួមគ្នាបាន កម្រិតដែនអំណាចសេដ្ឋកិច្ចសម្រាប់ស្ត្រី។ ប្រធានភូមិម្នាក់ (ស្ត្រី) មកពីខេត្តមណ្ឌលគិរីបានរៀបរាប់ទាក់ទងនឹងបញ្ហាជាច្រើនដែលស្ត្រីកម្ពុជាប្រឈមដោយសង្ខេបថា៖

*"ខ្ញុំយល់ថា វាជាការពិបាកណាស់ក្នុងការពន្យល់អំពីលក្ខខណ្ឌ នៃយុវតីនៅក្នុងសហគមន៍របស់យើងតាមវិធីសាមញ្ញ។ ធាតុនីមួយៗតភ្ជាប់ទៅធាតុមួយផ្សេងទៀតដូចជាសំណាញ់ពីងពាងមួយអ៊ីចឹង។ ជាដំបូង ប្រហែលជាស្ត្រីទូទៅមិនមានការអប់រំខ្ពស់ដែលអាចនិយាយបានថា ជាមូលហេតុនាំឱ្យយើងស្វែងរកការងារមានប្រាក់ខែមិនបាន។ ទោះជាយ៉ាងណា នោះមិនមែនមានន័យថាយើងមិនចង់ឱ្យមានការអប់រំខ្ពស់នោះទេ។ ផ្ទុយទៅវិញ គឺយើងមើលមិនឃើញលទ្ធភាពទទួលបានការងារមានប្រាក់ខែ។ ប្រសិនបើអ្នកសម្លឹងមើលនៅជុំវិញនេះ ពួកយើងភាគច្រើនគឺជាកសិករមួយចំនួនតូចកំពុងបើកហាងតូចៗនៅក្នុងភូមិ។ តើការងារមានប្រាក់ខែទាំងនោះនៅឯណា? ហើយពាក់ព័ន្ធនឹង (ការសិក្សានិងការងារមានប្រាក់ខែ) យើងជាស្ត្រីត្រូវបានគេរំពឹងថា នឹងត្រូវធ្វើកិច្ចការផ្ទះនិងថែរក្សាផ្ទះ ដែលបានបង្អាក់វិសាលភាពការសិក្សារបស់យើង។ ឧបមាថា បើយើងមានការងារមានប្រាក់ខែមួយ យើងនឹងត្រូវជំពាក់វាក់វិនរវាងការងារនិងកិច្ចការថែទាំផ្ទះសម្បែង។ ជាពិសេសនៅពេលដែលយើងមានកូន យើងនឹងមិនអាចរកការងារមានប្រាក់ខែកើតទេ។ និយាយឱ្យខ្លី ជីវិតស្ត្រីខ្មែរគឺមានភាពស្មុគស្មាញណាស់ "* ។

## ៤.៣ គោលនយោបាយ និងយុទ្ធសាស្រ្តសម្រាប់កំណើនការងារនិងការចូលរួម

ដោយទទួលស្គាល់បញ្ហា និងឧបសគ្គដែលស្រ្តីកំពុងប្រឈមរាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តលើកកម្ពស់តួនាទី និងឋានៈសង្គមរបស់ស្រ្តីក្នុងការចូលរួមក្នុងការអភិវឌ្ឍសង្គម នយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេស។ ការប្តេជ្ញាចិត្តនេះបានឆ្លុះបញ្ចាំងនៅក្នុងរដ្ឋធម្មនុញ្ញជាតិមាត្រា 31 ដែលបានទទួលស្គាល់ថា៖

*"ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀតឡើយ ... "*

នេះក៏បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី III (Rectangular Strategy Phase III 2014-2018) របស់រដ្ឋាភិបាល។ ចតុកោណទាំងបួនសង្កត់ធ្ងន់លើវិស័យយុទ្ធសាស្រ្តសំខាន់ៗ រួមមាន (1) ការលើកស្ទួយវិស័យកសិកម្ម (2) ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, (3) ការអភិវឌ្ឍវិស័យឯកជននិងការងារ ជាពិសេសសម្រាប់យុវជននិង (4) ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្សជាមួយនឹងចក្ខុវិស័យបង្កើនប្រាក់ចំណូលប្រទេសឱ្យមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ 2050 ។ ផ្នែកមួយនៃយុទ្ធសាស្រ្តរបស់រដ្ឋាភិបាលបានទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមបុរសស្រ្តីក្នុងការបញ្ញាបចតុកោណ និងសេដ្ឋកិច្ចដោយធានាថា ពលរដ្ឋគ្រប់រូបទាំងបុរស និងស្ត្រីនៃប្រទេសនេះមានសមត្ថភាពក្នុងបង្កើនអាជីពរបស់ពួកគេដើម្បីឱ្យប្រទេសនេះអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំយ៉ាងហោចណាស់ 7 ភាគរយ (ដូចមានចែងក្នុងគោលបំណងយុទ្ធសាស្រ្តចតុកោណ)។ ការបញ្ចូលស្រ្តីទៅក្នុងការងារមានប្រាក់ខែសមរម្យត្រូវបានចាត់ទុកថា ជាការចាំបាច់ជាពិសេសសម្រាប់កំណើនប្រកបដោយចីរភាពនិងសមភាព។

ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការផ្តល់អំណាចដល់ស្រ្តីននៅក្នុងទីផ្សារការងារបានសម្តែងចេញនៅក្នុងគោលនយោបាយជាតិសំខាន់ពីរផ្សេងទៀតក្នុងគោលបំណងដើម្បីលើកកម្ពស់ការងារនិងផលិតភាពរបស់ប្រជាជន។ គោលនយោបាយជាតិអភិវឌ្ឍន៍ឧស្សាហកម្ម (National Industrial Development Policy ហៅកាត់ថា IDP) ឆ្នាំ 2015-2025[៧] និងគោលនយោបាយជាតិមុខរបរនិងការងារ (National Employment Policy ហៅកាត់ថា NEP) ឆ្នាំ 2015-2025[៨] ពួតដៃគ្នាធ្វើការដើម្បីលើកកម្ពស់កំណើននិងការអភិវឌ្ឍដោយផ្តល់ផលិតភាពខ្ពស់ និងអាជីពបង្កើតប្រាក់ចំណូលដល់ប្រជាជនទាំងពីរភេទ (យោងតាម រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ 2015)។ IDP មានគោលបំណងលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា និងដោយការកំណត់ផទិកាសម្រាប់យុវជនថ្មីចូលរួមបានទូលំទូលាយជាងនេះនៅក្នុងទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា ពិសេសការធ្វើឱ្យសម្បូរបែប នូវជម្រើសអាជីពរបស់ពួកគេលើសពីវិស័យកសិកម្មដែលលេចធ្លោ រោងចក្រកាត់ដេរ ឬស្បៀង និងវិស័យកែច្នៃអាហារ។ នៅក្នុងលក្ខណៈស្រដៀងគ្នានេះ NEP មានបំណង (1) ការបង្កើនឱកាសការងារផលិតភាពសមរម្យ (2) ការលើកកម្ពស់ជំនាញ និងការអភិវឌ្ឍធនធានមនុស្ស និង (3) ការលើកកម្ពស់អភិបាលកិច្ចទីផ្សារការងារ។ NEP ក៏គូសបញ្ជាក់ពីសារៈសំខាន់នៃការយល់ដឹងពីការងារដែលត្រូវការដោយយុវជនទាំងពីរភេទ និងលើកកម្ពស់ស្រ្តីក្នុងការចូលរួមនៅក្នុងមុខតំណែងដែលមានជំនាញខ្ពស់និងគ្រប់គ្រង។

---

[៨] *សម្រាប់សេចក្តីលម្អិតបន្ថែមទៀត សូមមើលគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម (IDP)ឆ្នាំ 2015-2025 របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ 2015 ។*

ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្រ្តី (The Women's Economic Empowerment ឬហៅកាត់ថា WEE) ដោយក្រសួងកិច្ចការនារី ( MOWA) បានកំណត់យុទ្ធសាស្រ្តចូលរួមមួយផ្សេងទៀតក្នុងគោលបំណងបង្កើតឱកាសរកប្រាក់ចំណូលសម្រាប់ស្រ្តីតាមរយៈការលើកកម្ពស់ការងារមានប្រាក់ខែសមរម្យ និងការអភិវឌ្ឍ[៧] សហគ្រាសមីក្រូហិរញ្ញវត្ថុខ្នាតតូច និងខ្នាតមធ្យម (small and medium-sized ហៅកាត់ថា MSME) ។ ស្របគ្នាជាមួយនឹងផែនការយុទ្ធសាស្រ្តនារីរតនៈដំណាក់កាលទី III (Neary Rattanaks III 2009-2013) និងទី IV (2014-2018) WEE គ្របដណ្តប់លើវិស័យគោលនយោបាយយ៉ាងហោចណាស់ចំនួនបួនដែលទាក់ទងទៅនឹងការងារមានប្រាក់ខែ ការអភិវឌ្ឍ MSME ការធ្វើចំណាកស្រុក និងការចិញ្ចឹមជីវិតនៅជនបទ ការធ្វើឱ្យវិសាលគមទូលំទូលាយ នៃឱកាសសេដ្ឋកិច្ច និងភាគរយនៃស្ត្រីប្រសើរជាងនេះ។ WEE បានដាក់ចេញជាផទិកាគាំទ្រដើម្បីបង្កើតឱកាសសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពសម្រាប់ស្ត្រីជាវិធីមួយដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យការងាររបស់ស្ត្រីក្នុងទីផ្សារ។ មិនត្រឹមតែតម្រូវឱ្យមានស្ត្រីចូលរួមនៅក្នុងសកម្មភាពអាជីវកម្ម ឬការងារមានប្រាក់ខែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ប្រយោជន៍ហើយស្ត្រីភ្នាក់ងារមានសិទ្ធិចូលរួមធ្វើការសម្រេចសំខាន់ៗទៀតផង។

ដើម្បីគាំទ្រគំនិតផ្តួចផ្តើមក្នុងការផ្តល់អំណាចដល់ស្ត្រី ក្រសួងកិច្ចការនារីបានដាក់ចេញនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (Millennium Development Goal ហៅកាត់ថា MDG) ផែនការសកម្មភាពក្របខ័ណ្ឌបង្កើនល្បឿនកម្ពុជា 2013-2015[៧] ដែលផ្តល់អតិភាពដល់វិស័យចំនួនបីគឺ៖

- *(i)* *ការផ្តល់ការបណ្តុះបណ្តាលសម្រាប់ការងារដល់ស្ត្រីស្របតាមតម្រូវការទីផ្សារ!*
- *(ii)* *ការលើកកម្ពស់សហគ្រាសមីក្រូហិរញ្ញវត្ថុខ្នាតតូច និងមធ្យមដែលដឹកនាំដោយស្ត្រីដើម្បីធានាឱ្យបានថា ស្ត្រីមានសមត្ថភាពដឹកនាំនិងធ្វើឱ្យសហគ្រាសរីកចម្រើន និងផ្លាស់ពីវិស័យមិនផ្លូវការទៅផ្លូវការ និង*
- *(iii)* *ការធ្វើឱ្យប្រសើរឡើងនូវជីវភាពនៅតាមសហគមន៍ជនបទជាពិសេសសម្រាប់ស្ត្រីក្រីក្រ។*

ក្រសួងកិច្ចការនារី (MOWA) ក៏បានបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី (Women's Development Centres ហៅកាត់ថា WDC) ក្នុងខេត្តចំនួន 13 ដើម្បីផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី។ ទោះជាយ៉ាងណា កម្មវិធីបណ្តុះបណ្តាល WDC មិនមានវិសាលភាពស្របនឹងពួកគេទេ ភាគច្រើនផ្តោតលើការផលិតសិប្បកម្ម ហាងអ៊ុតសក់ កាត់ដេរ និងការកែច្នៃម្ហូបអាហារ។ មាតិកា និងជំនាញពាក់ព័ន្ធទៅនឹងទីផ្សារការងារដូចជា ជំនាញការអភិវឌ្ឍសហគ្រាស សេវាកម្មអភិវឌ្ឍន៍អាជីវកម្ម ជំនាញអក្ខរកម្ម ព័ត៌មានស្តីពីការការពារផ្នែកច្បាប់ និងព័ត៌មានទីផ្សារនាពេលបច្ចុប្បន្ន នៅមានការខ្វះខាតនៅឡើយ ។ WDC មិនបានឈានដល់សក្តានុពលដែលមានគោលបំណងកាត់បន្ថយវិសមភាពយេនឌ័រ និងពង្រីកតួនាទីរបស់ស្ត្រី និងស្ថានភាពនៅក្នុងសេដ្ឋកិច្ចនោះទេ។ ដោយហេតុថាធម្មជាតិនៃវគ្គបណ្តុះបណ្តាលដែលរួមផ្សំជាមួយនឹងការខ្វះគ្រូមានសមត្ថភាពទំនើបផងនោះ ការចូលរួមរបស់ស្ត្រីក្នុងការងារសមរម្យនៅតែមានឧបសគ្គ។ MOWA កំណត់កម្រិតនៃ WDC ដូចខាងក្រោម៖

- WDC ផ្តល់តែជំនាញវិជ្ជាជីវៈតាមបែបប្រពៃណីមិនបានបណ្តុះបណ្តាលជំនាញសហគ្រិន សេវាកម្មអភិវឌ្ឍន៍អាជីវកម្ម ព័ត៌មានទីផ្សារនាពេលបច្ចុប្បន្ន ឬការទទួលបានឥណទាន ។
- ជំនាញដែលផ្តល់មិនស្របតាមតម្រូវការទីផ្សារក្នុងស្រុកហើយមានការខ្វះខាតគ្រូដែលមានចំណេះដឹងទំនើបពាក់ព័ន្ធនឹងការផ្គូផ្គងស្របតាមតម្រូវការទីផ្សារ និងដោះស្រាយតម្រូវការ និងបញ្ហាប្រឈមរបស់ស្ត្រីពិតប្រាកដ។

- ប្រព័ន្ធត្រួតពិនិត្យនិងតាមដាន WDC មិនគ្រប់គ្រាន់សម្រាប់វាយតម្លៃផលប៉ះពាល់ នៃការបណ្តុះបណ្តាលជំនាញ និង
- ការសម្របសម្រួលនៅមានកម្រិតរវាង WDC និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេង
  ទៀត (ដូចជា មជ្ឈមណ្ឌលដែលគ្រប់គ្រងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល)។

## ៤.៤ សន្និដ្ឋាន

ការសិក្សាស្តីពីគុណភាពនេះបានពិនិត្យឱកាស និងបញ្ហាដែលជាឧបសគ្គដល់យុវតីកម្ពុជាក្នុងការចូលទៅក្នុងទីផ្សារការងារឱ្យបានទៅលំទូលាយ។ បទដ្ឋានសង្គមតាមប្រពៃណីពាក់ព័ន្ធនឹងតួនាទីរបស់ស្ត្រីនៅក្នុងគ្រួសារ និងសង្គមត្រូវបានមនុស្សភាគច្រើនទទួលស្គាល់ ជាពិសេសអ្នកនៅតាមតំបន់ជនបទដាច់ស្រយាល។ គេនៅតែរំពឹងថា ស្ត្រីនឹងត្រូវរ៉ែកពុនការទទួលខុសត្រូវជាច្រើននៅក្នុងគ្រួសារ និងថែរក្សាកូនចៅ ដោយមិនបានគិតពួកគេមានស្ថានភាពណានោះទេ។ ការបែងចែកការងារក្នុងផ្ទះមិនបានចែកឱ្យស្មើគ្នារវាងបុរស និងស្ត្រីនោះទេ ដែលធ្វើឱ្យស្ត្រីជួបការលំបាកខ្លាំង។ បទដ្ឋានសង្គមតាមប្រពៃណីពាក់ព័ន្ធនឹងតួនាទីរបស់ស្ត្រីជា "ប្រពន្ធល្អ" និងការមាក់ងាយពីសង្គមប្រឆាំងនឹងការចល័តរបស់ស្ត្រីគឺជាបញ្ហាធ្វើឱ្យស្ត្រីមានការរុញរាក្នុងការចូលរួមការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬការអប់រំបន្ថែម និងមិនហ៊ានទៅធ្វើការនៅខាងក្រៅសហគមន៍។ ជំនឿនេះចាក់ឫសយ៉ាងជ្រៅជាពិសេសក្នុងចំណោមយុវតីគ្មានការងារធ្វើ ជាពិសេសស្ត្រីវ័យចំណាស់នៅតាមសហគមន៍ជនបទ។

អាពាហ៍ពិពាហ៍នៅវ័យក្មេងពេកជាឧបសគ្គយ៉ាងសំខាន់ចំពោះការចូលរួមរបស់ស្ត្រីក្នុងការងារមានប្រាក់ខែសមរម្យ។ ការសិក្សាបានរកឃើញថា ជំនឿដែលថា ស្ត្រីវ័យក្មេងគួររៀបចំការនោះនៅចាក់ជ្រៅក្នុងចំណោមស្ត្រីនៅតាមតំបន់ជនបទ។ ជំនឿបែបនោះមានឥទ្ធិពលលើទស្សនៈរបស់ប្រជាជនជនបទពាក់ព័ន្ធនឹងអនាគតនៃការអប់រំ និងការងាររបស់យុវតី។ ជារឿយៗ ការរៀបអាពាហ៍ពិពាហ៍វ័យក្មេងអាចបណ្តាលឱ្យយុវតីបោះបង់ការសិក្សា និងប៉ះពាល់ដល់ជីវភាពរបស់ពួកគេ និងមិនឱ្យទទួលបានការងារសមរម្យនៅពេលអនាគត។ ទោះក្នុងទីក្រុងនិងទីប្រជុំជន ភាពក្រីក្រ និងការខ្វះខាតតួនាទីគំរូអាចជាឧបសគ្គធំមួយចំពោះស្ត្រីក្នុងការស្វែងរកការងារមានប្រាក់ខែសមរម្យ។ ប៉ុន្តែ បទដ្ឋានវប្បធម៌សង្គមមិនសូវជាដើរតួនាទីសំខាន់ទេ នៅក្នុងបរិបទនៃអ្នកទីក្រុង។

ទាក់ទងនឹងគំរូការងារ ស្ត្រីភាគច្រើននៅក្រៅទីក្រុង ឬទីប្រជុំជនខេត្ត ហាក់ដូចជាមានដែនកំណត់ក្នុងការស្វែងរកការងារផ្លូវការ។ ទោះបីទទួលស្គាល់ថា "មានការងារធ្វើ" ក៏ដោយ ក៏ភាគច្រើននៃយុវតីជនបទមានការងារចម្បងជាកម្មករគណនីផ្ទាល់ ឬរួមចំណែកជួយការងារគ្រួសារដែរ។ ការងារ សាមញ្ញបំផុតដែលអាចរកបាននៅក្នុងសហគមន៍ ជាទូទៅ គឺការងាររោងចក្រកាត់ដេរ ឬសហគ្រាសខ្នាតតូច និងមធ្យម (SME)។ នៅតំបន់មួយចំនួនដែលជាយរាជធានីភ្នំពេញក៏អាចមានករណីបែបនេះផងដែរ។ ម្យ៉ាងទៀត ភាពក្រីក្រ និងការខ្វះខាតនៃការអប់រំក៏ជារនាំងចំពោះឱកាសការងារល្អនៅក្នុងជីវិតរបស់យុវតីផងដែរ ។ ទីផ្សារពលកម្មក្នុងមូលដ្ឋានមានកំណត់ និងការខ្វះខាតព័ត៌មានអំពីឱកាសការងារ ក៏ជាកត្តាដែលអាចឱ្យស្ត្រីក្នុងចូលរួមក្នុងការងារមិនផ្លូវការផងដែរ។ ការសិក្សានេះបានបង្ហាញថា ស្ថាប័នមួយចំនួនមិនមានរចនាសម្ព័ន្ធគ្រប់គ្រាន់ដើម្បីសម្រួលការងារស្ត្រីទេ សូម្បីតែតំបន់ខ្លះនៅជាយរាជធានីភ្នំពេញ។ ការងារក្នុងធនាគារ/ស្ថាប័នហិរញ្ញវត្ថុ និងការងារអង្គការក្រៅរដ្ឋាភិបាលមាននៅក្នុងមូលដ្ឋានរបស់ពួកគេក៏ដោយ ក៏យុវតីមួយចំនួនមិនដឹងថា តើត្រូវធ្វើដូចម្តេចដើម្បីទទួលបានការងារនៅក្នុងស្ថាប័នទាំងនោះ។ ស្ត្រីមួយចំនួនបានដឹងអំពីការងារតាមរយៈមិត្តភ័ក្តិ និងបណ្តាញសង្គមក្រៅផ្លូវការមួយភាគតូច ជាពិសេសក្នុងចំណោមយុវតីតែម្តង។

វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ស្ត្រីច្រើនមានតែពាក់ព័ន្ធនឹងវិស័យដូចជា កាត់ដេរ ចម្អិនអាហារ និងមេកានិច។ល។ ទោះជាយ៉ាងណា វគ្គបណ្តុះបណ្តាលទាំងនេះមានឥទ្ធិពលតិចតួចលើការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។ វគ្គបណ្តុះបណ្តាលទាំងនេះផ្តោតសំខាន់លើការងារជំនាញដោយដៃ (manual- skill jobs) គឺមិនបានរៀបចំឱ្យស្ត្រីក្លាយជាអ្នកគ្រប់គ្រង ឬសហគ្រិននោះទេ។ ម្យ៉ាងទៀត វគ្គបណ្តុះបណ្តាលទាំងនេះមិនបានធានាថា អាចមានការងារពាក់ព័ន្ធនឹងវគ្គនេះនៅក្នុងតំបន់របស់ពួកគេនោះទេ។ លើសពីនេះ វាហាក់ដូចជាថា កាលវិភាគ នៃវគ្គបណ្តុះបណ្តាលទាំងនេះមិនអំណោយផលសម្រាប់ស្ត្រីទាំងអស់គ្នា ជាពិសេសស្ត្រីដែលរៀបការរួចមានការងារផ្ទះ និងត្រូវថែទាំកូនចៅ ។ ជាទូទៅ វគ្គបណ្តុះបណ្តាលទាំងនេះមានភាពបត់បែន ឬការគាំទ្រចំពោះពួកគេបានតិចតួចដែលមិនអាចឱ្យពួកគេចូលរួមបានពេញលេញ ជាពិសេសនៅពេលដែលវគ្គបណ្តុះបណ្តាត្រូវធ្វើពេញមួយថ្ងៃ និងនៅឆ្ងាយពីផ្ទះរបស់ពួកគេ។

ជំពូកនេះវិភាគស្ថានភាពរបស់យុវតី (អាយុពី 15 ទៅ 30 ឆ្នាំ) ទាំងនៅក្នុង (និងក្រៅ) ទីផ្សារការងារនៅកម្ពុជា។ ការវិភាគនេះមានគោលបំណងពិសេសដើម្បីស្វែងយល់អំពីឧបសគ្គនិងឱកាសទីផ្សារការងារដែលស្ត្រីកម្ពុជាទាំងនៅជនបទ និងទីក្រុងកំពុងប្រឈម ក៏ដូចជាវិភាគរកផលប៉ះពាល់ នៃបទដ្ឋានសង្គមទៅលើការសម្រេចចិត្តរបស់ស្ត្រីក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច។ ការវិភាគនៅក្នុងជំពូកនេះដោយប្រាស់ការពិភាក្សាក្រុមគោលដៅស្តីពីគុណភាព ដើម្បីស្វែងយល់អំពីកត្តាពាក់ព័ន្ធមួយចំនួន ដូចជា លក្ខខណ្ឌទីផ្សារការងារមិនគាំទ្រ ការចូលរួមក្នុងបណ្តាញសង្គម និងការបណ្តុះបណ្តាលវិជ្ជាជីវៈមិនបានគ្រប់រូបភាព ការមាក់ងាយ ហានិភ័យ និងភាពងាយរងគ្រោះផ្សេងទៀតដែលស្ត្រីកំពុងប្រឈមនៅក្នុងទីផ្សារការងារ និងឱកាសមិនគ្រប់គ្រាន់ក្នុងការទទួលបានការអប់រំខ្ពស់ ។ ផ្អែកលើការវិភាគនេះ អនុសាសន៍គន្លឹះចំនួនប្រាំត្រូវបានស្នើឡើងដើម្បីជួយដោះស្រាយបញ្ហាការងារដែលយុវតីកម្ពុជាកំពុងប្រឈម៖

1. ឱកាសមិនគ្រប់គ្រាន់សម្រាប់ស្ត្រីក្នុងការទទួលបានការអប់រំនៅវិទ្យាល័យ និងឧត្តមសិក្សា គឺជាឧបសគ្គមួយចំពោះជម្រើសការងារល្អរបស់ពួកគេនាពេលអនាគត។ ដោយហេតុថា សាលារៀន និងលំនៅដ្ឋាននៅឆ្ងាយពីគ្នា គួបផ្សំនឹងការព្រួយបារម្ភអំពីសុវត្ថិភាពផងនោះ យុវតីទំនងជាត្រូវបានដកចេញពីការទទួលបានការអប់រំដែលមានកម្រិតស្មើនឹងយុវជន។ ឧទាហរណ៍៖ នៅខេត្តមណ្ឌលគិរី ស្ត្រីមួយចំនួនអាចមានលទ្ធភាពទៅសាលាដោយគ្មានបញ្ហាផ្នែកហិរញ្ញវត្ថុ ប៉ុន្តែវិទ្យាល័យមិននៅជិតលំនៅដ្ឋានរបស់គេ។ ដូច្នេះ ការធានាថា មានសាលារៀននៅជិតលំនៅដ្ឋាន គឺជាយុទ្ធសាស្ត្រគន្លឹះមួយដែលក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្ត។ ទន្ទឹមនឹងនេះ ដើម្បីផ្តល់សិទ្ធិអំណាចដល់យុវតី ចាំបាច់ត្រូវមានគម្រោងអាហារូបករណ៍បន្ថែមសម្រាប់គាំទ្រការអប់រំរបស់ពួកគេ ។ បើមិនអាចទទួលបានការអប់រំខ្ពស់ទេ គេពិតជាពិបាកព្យាករណ៍ណាស់ថា ស្ត្រីអាចទទួលបានឱកាសការងារល្អជាងមុន និងអាចក្លាយជាគំរូដល់យុវតីដទៃនៅក្នុងសហគមន៍របស់ពួកគេ ។
2. ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈនៅជិតផ្ទះមានសារៈសំខាន់ណាស់សម្រាប់ស្ត្រី និងអាចជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងលទ្ធភាពចូលរួមការបណ្តុះបណ្តាលរបស់ពួកគេទៀតផង ប៉ុន្តែការបណ្តុះបណ្តាលជំនាញមិនពាក់ព័ន្ធក៏អាចជាបញ្ហាផងដែរ។ ដូចការសិក្សាបានបញ្ជាក់ថា ការបណ្តុះបណ្តាមុនៗប្រហែលជាមិនបានផ្សារភ្ជាប់ទៅនឹងការងារសមរម្យនោះទេ គឺពាក់ព័ន្ធតែនឹងការងារក្រៅផ្លូវការនិងជំនាញទាប។ ករណីនេះ ជម្រៅ និងទំហំនៃការបណ្តុះបណ្តាលគួរតែអនុញ្ញាតឱ្យសិក្ខាកាមបង្កើនជំនាញជាក់លាក់មួយចំនួនដូចជា សហគ្រិនភាព គ្រប់គ្រងអាជីវកម្ម ឬជំនាញកសិកម្មចម្រុះបន្ថែមទៀត ដើម្បីបង្កើនផលិតភាពក្រៅពីការកាត់ដេរ ការចម្អិនអាហារ សេវាភោជនីយដ្ឋាន និងជំនាញមេកានិច ដែលជាទូទៅមិនបានបង្កើនលំដាប់នៅក្នុងជម្រើសទីផ្សារការងារ។
3. យន្តការគាំទ្រមិនទូលំទូលាយដូចជា ខ្វះការថែទាំកូន និងខ្វះការលើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល ដែលស្ត្រីនៅក្នុងពិភាក្សាក្រុមគោលដៅទាំងនេះក៏បានជួបបញ្ហានេះដែរ។ បើគ្មានការគាំពារសង្គមជាមូលដ្ឋាន និងគ្មានប្រព័ន្ធគាំទ្រចាំបាច់នៅនឹងកន្លែងទេ ស្ត្រីនឹងមានឱកាសតិចតួចក្នុងការបង្កើនការអប់រំ ជំនាញ និងសមត្ថភាពក្នុងការប្រកួតប្រជែងដើម្បីការងារសមរម្យ។ ដូច្នេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវផ្តល់ការគាំពារសង្គមជាមូលដ្ឋាន និងវិនិយោគក្នុងការបង្កើតមជ្ឈមណ្ឌលគាំពារកុមារសហគមន៍ដើម្បីធានាថា ស្ត្រីទទួលបានអត្ថប្រយោជន៍ពីការបណ្តុះបណ្តាល និងការអប់រំដែលបានផ្តល់ឱ្យ។
4. ការផ្តល់ជំនាញ និងការបណ្តុះបណ្តាលដាល់ស្ត្រីអាចនឹងមិនសូវទាក់ទាញ ព្រោះថា បច្ចុប្បន្នទីផ្សារការងារនៅជនបទនៅមានកម្រិត និងពុំមានសមត្ថភាពស្រូបគ្រប់គ្រាន់។ ក្នុងករណីនេះ រដ្ឋបាលក្រសួងស្ថាប័នចាំបាច់ត្រូវបង្កើតឧស្សាហកម្មឬស្ថាប័នក្នុងតំបន់នោះ ដើម្បីអនុភាពធនធាននៅក្នុងមូលដ្ឋាន និងបង្កើតការងារសមរម្យបន្ថែមទៀតសម្រាប់សេដ្ឋកិច្ចនៅក្នុងតំបន់នោះ។ នេះនឹងផ្តល់ឱកាសបន្ថែមទៀតដល់យុវតីប្រមើលមើលអនាគតបានច្បាស់អំពីទំនាក់ទំនងរវាងការអប់រំ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជីព ។
5. ការសិក្សាក្នុងជំពូកនេះរកឃើញថា ទោះបីស្ត្រីមួយចំនួនមានលទ្ធភាពទទួលបានការអប់រំ និងតួនាទីដឹកនាំទាំងក្នុងវិស័យសាធារណៈ និងឯកជនក៏ដោយ ក៏ការអនុវត្ត និងតួនាទីយេនឌ័រនៅតែមិនបានផ្លាស់ប្តូរនៅឡើយ ជាពិសេសក្នុងចំណោមមនុស្សចាស់ប្រុសស្ត្រីនៅជនបទដាច់ស្រយាល ។ បទដ្ឋានវប្បធម៌សង្គមដែលថា ស្ត្រីត្រូវតែឆាប់រៀបការ ស្ត្រីត្រូវតែទទួលខុសត្រូវក្នុងគ្រួសារ និងជួនកាលថា

ស្ត្រីមានបញ្ហាទាបជាងបុរសនោះ បានប៉ះពាល់មួយផ្នែកធំទៅលើជម្រើសរបស់គ្រួសារមួយចំនួន និងមិនការបញ្ជូនកូនស្រីទៅរៀន ឬមិនគាំទ្រកូនស្រីឱ្យប្រកួតប្រជែងដើម្បីការងារសមរម្យ។ ចំពោះបទដ្ឋានសង្គមបែបនេះ ទាមទារឱ្យស្ថាប័នអប់រំ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីផ្លាស់ប្តូរផ្នត់គំនិតរបស់ស្ត្រីក្នុងតំបន់នោះឱ្យជម្នះទៅនឹងប្រពៃណីតួនាទីរបស់ស្ត្រីនេះ។ ដូច្នេះ សិក្ខាសាលាស្តីពីការយល់ដឹងអំពីការអនុវត្ត និងតួនាទីយេនឌ័រ សិក្ខាសាលាស្តីពីស្ត្រី និងការងារ ប្រហែលជាយុទ្ធសាស្រ្តមានប្រយោជន៍ក្នុងការចូលរួមផ្លាស់ប្តូរផ្នត់គំនិតសាធារណៈជនដែលបានធ្វើឱ្យស្ត្រីជួបការលំបាកទាំងនោះ ។

***សម្គាល់៖***

[១] *ចម្ងាយផ្លូវដូចដែលបានលើកឡើង គឺជាឧបសគ្គរបស់យុវតីក្នុងការចល័តចេញពីភូមិដើម្បីរកការងារធ្វើនៅកន្លែងផ្សេងទៀតដូចជា នៅទីរួមខេត្ត ឬរាជធានីភ្នំពេញ។ គួរឱ្យចាប់អារម្មណ៍ វាមានចម្ងាយជាង 30 គីឡូម៉ែត្រពីភូមិមកក្រុងសៀមរាប។ បទពិសោធន៍ចេញពីសម្ភាសន៍ជាមួយនឹងយុវតីនៅខេត្តតាកែវ ខេត្តកណ្តាល និងខេត្តបាត់ដំបងបានបង្ហាញថា ចម្ងាយផ្លូវអាចមានបញ្ហាតិចតួច ប៉ុន្តែវាអាស្រ័យលើការយល់ឃើញរបស់យុវតីនិងក្រុមគ្រួសារ ដែលជាអ្នកកំណត់លើការសម្រេចចិត្តចល័តទៅកន្លែងផ្សេង ។ សំខាន់ ការយល់ឃើញរបស់ពួកគេអាស្រ័យលើបទពិសោធន៍ដែលពួកគេបានទទួលអំពីពិភពខាងក្រៅ (ឆ្ងាយពីតំបន់របស់ពួកគេ) ។ ហើយវាកាន់តែស្មុគស្មាញបន្ថែមទៀតដោយសារតែបទដ្ឋានសង្គមវប្បធម៌ដែលថាស្ត្រីមិនគួរធ្វើដំណើរឆ្ងាយពីក្រុមគ្រួសារទេ ព្រោះតែការព្រួយបារម្ភពីបញ្ហាសន្តិសុខ (យោងតាម KIIs 3, 5 & 6) ។*

[២] *ស្ត្រីជនបទក្រៅពីក្រុមពិភាក្សាគោលដៅដែលមាននៅក្នុងទីតាំងសិក្សានីមួយតំណាងឱ្យយុវតីកម្ពុជានៅជនបទដែលមានធនធាននិងឱកាសគ្រប់គ្រាន់ដើម្បីទទួលបានការអប់រំ។ ជាទូទៅពួកគេមានការងារផ្លូវការ។ ឧទាហរណ៍៖ នៅក្នុងជនបទនៃប្រទេសកម្ពុជា ស្ត្រីវ័យក្មេងមួយចំនួនជាគ្រូបង្រៀននៅតាមសាលារៀន ជាគិលានុបដ្ឋាយិកា ម្ចាស់អាជីវកម្មទំហំល្មម។ល។*

## ឯកសារយោង

ADB (2015), *Promoting Women's Empowerment in Cambodia*, Asian Development Bank, Mandaluyong City, Philippines.

ADB (2013), *Gender Equality in the Labor Market in Cambodia*, Asian Development Bank, Mandaluyong City, Philippines.

ADB (2014), *Cambodia: Country Poverty Analysis 2014*, Asian Development Bank, Mandaluyong City, Philippines.

Brickell, K. (2011a), "The 'Stubborn Stain' on Development: Gendered Meanings of Household (Non-) Participation in Cambodia", *The Journal of Development Studies*, Vol. 47, No. 9, pp. 1353–70.

Brickell, K. (2011b), " 'We don't forget the old rice pot when we get the new one': discourses on ideals and practices of women in contemporary Cambodia", *Signs*, Vol. 36, No. 2, pp. 437–62.

Bylander, M. (2015), "Contested mobilities: gendered migration pressures among Cambodian youth",
*Gender*, *Place & Culture*, Vol. 22, No. 8, pp. 1124–40.

Cambodian Government (2015), *National Employment Policy 2015-2025*, Phnom Penh.

Derks, A. (2008), *Khmer Women on the Move: Exploring Work and Life in Urban Cambodia*, University of Hawai'i Press, Honolulu.

Economic Institute of Cambodia (2008), *Cambodia Country Economic Memorandum: Sustaining Rapid Growth in a Challenging Environment – Cambodia's Labor Market and Employment*, Background paper prepared for the World Bank, Phnom Penh, http://siteresources.worldbank.org/INTDEBTDEPT/Resources/468980-1218567884549/5289593- 1224797529767/CambodiaDFSG02.pdf.

Economic Institute of Cambodia (2006), *Handbook on Decent Work in the Informal Economy in Cambodia*, International Labour Office, International Labour Organization, Bangkok, http://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/publication/wcms_bk_pb_126_en.pdf.

ILO (2013), *Global Employment Trends for Youth 2013: A generation at risk*, International Labour Office, International Labour Organization, Geneva, http://www.ilo.org/wcmsp5/groups/public/@dgreports/@dcomm/documents/publication/wcms_21 2423.pdf.

ILO (2012), *Decent Work Country Profile: Cambodia*, International Labour Organization, Geneva, http://www.ilo.org/wcmsp5/groups/public/---dgreports/---integration/documents/publication/wcms_185267.pdf.

ILO (2004), "Terms of reference for the literature review/handbook on decent work in the informal economy in Cambodia", in the ILO's Informal Economy, Poverty & Employment project, see the International Labour Organization website, http://www.ilo.org/beijing/what-we-do/projects/WCMS_142302/lang--en/index.htm.

Jacobsen, T. (2008), *Lost Goddesses: The Denial of Female Power in Cambodian History*, Nordic Institute of Asian Studies Press, University of Copenhagen, Copenhagen.

Ledgerwood, J.L. (1996), "Politics and gender: Negotiating conceptions of the ideal woman in present day Cambodia", *Asia Pacific Viewpoint*, No. 37, Vol. 2, pp. 139–52.

Ledgerwood, J.L. (1994), "Gender Symbolism and Culture Change: Viewing the Virtuous Woman in the Story of Mea Yoeng", in Ebihara, M.M., C.A. Mortland and J.L. Ledgerwood (eds), *Cambodian Culture since 1975: Homeland and Exile*, pp. 119–28, Cornell University Press, Ithaca NY.

NIS (2015), *Cambodia Socio-Economic Survey 2014*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2015), *Cambodia Socio-Economic Survey 2014*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2010), *Cambodia Socio-Economic Survey 2009*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2009), *General Population Census 2008: National Report on Final Census Results*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2008), *Cambodia Socio-Economic Survey 2007*, National Institute of Statistics, Ministry of Planning, Phnom Penh.

NIS (2005), *Cambodia Socio-Economic Survey 2004*, National Institute of Statistics, Ministry of Planning, Phnom Penh.

Peou, C. (2016), "Negotiating rural-urban transformation and life course fluidity: Rural young people and urban sojourn in contemporary Cambodia", *Journal of Rural Studies*, No. 44, pp. 177–86.

Peou, C. (2009), "Reconstructing tradition: Gender and generations in contemporary Cambodian film", *Media Asia*, Vol. 36, No.1, pp. 47–54.

Peou, C. and J. Zinn (2015), "Cambodian youth managing expectations and uncertainties of the life course – a typology of biographical management", *Journal of Youth Studies*, Vol. 18, No. 6, pp. 726– 42.

RGC (2015), Industrial Development Policy 2015-2025, The Royal Government of Cambodia, Phnom Penh.

RGC (2013), Rectangular Strategy Phase III (2014-2018), The Royal Government of Cambodia, Phnom Penh.

UNDP (2015), *Human Development Report 2015: Work for Human Development*, United Nations Development Programme, New York.

World Bank (2017), *World Development Indicators database*, The World Bank website, http://data.worldbank.org/data-catalog/world-development-indicators.

# ឧបសម្ព័ន្ធ

## 4A1. វិធីសាស្រ្ត នៃការពិភាក្សាក្រុមគោលដៅ

វិធីសាស្រ្តសំខាន់ នៃការសិក្សានេះ គឺការពិភាក្សាក្រុមគោលដៅ (Focus Group Discussions ហៅកាត់ថា FGDs) ដែលរួមមាន 16 FGDs ជាយុវតី (អាយុពី 15 ដល់ 30 ឆ្នាំ) និង 2 FGDs ជាស្រ្តីវ័យចំណាស់ដែលអាចផ្តល់នូវការយល់ដឹងក្នុងកត្តាវប្បធម៌សង្គមដែលកំពុងប៉ះពាល់ដល់ជីវភាព និងសកម្មភាពសេដ្ឋកិច្ចរបស់យុវតី។ ដើម្បីផ្តល់នូវគំរូសមហេតុផល នៃលក្ខណៈភូមិសាស្រ្ត សេដ្ឋកិច្ចសង្គម និងមនុស្ស ការសិក្សានេះបានជ្រើសយក FGDs ពីរាជធានីភ្នំពេញ និងខេត្តចំនួនបី គឺ៖ ខេត្តសៀមរាប ខេត្តកំពត និងខេត្តមណ្ឌលគិរី។

FGDs ទាំងអស់មានចំនួន 16 ក្រុម គឺជាយុវតី ទាំងមាននិងគ្មានការងារធ្វើ។ FGDs ចំនួន 2 ក្រុមទៀត គឺជាស្រ្តីវ័យចំណាស់ និងក្រុមអ្នកផ្តល់ចម្លើយសម្ភាសសំខាន់ (Key Informant Interviews ហៅកាត់ថា KIIs) 8 នាក់ទៀត ជាមួយថ្នាក់ដឹកនាំសហគមន៍ (មេភូមិនីមួយៗដែលបានជួបផង) ។ ការជ្រើសរើសអ្នកចូលរួមក្នុង FGDs មានគោលបំណងសន្មត់យកតែភាពខុសគ្នារវាងយុវតីដែលមាន និងគ្មានការងារធ្វើ។ មេដឹកនាំសហគមន៍ដែលស្គាល់ទីតាំងស្រ្តីវ័យក្មេងក្នុងសហគមន៍បានជួយមួយផ្នែកធំក្នុងការរៀបចំជំនួប FGDs ឱ្យប្រព្រឹត្តទៅសមរម្យ។

ពិធីការសម្ភាសន៍ត្រូវបានបង្កើតឡើងដើម្បីទាញយកព័ត៌មានពាក់ព័ន្ធនឹងយេនឌ័រ និងឧបសគ្គផ្សេងទៀតចំពោះជម្រើសការងាររបស់ស្រ្តី។ ពិធីការសម្ភាសន៍ទាំងនេះត្រូវបានប្រើសម្រាប់ទាំងក្រុមពិភាក្សាគោលដៅជាយុវតី ទាំងក្រុមពិភាក្សាគោលដៅជាស្រ្តីវ័យចំណាស់ និងទាំង KIIs ជាមួយថ្នាក់ដឹកនាំសហគមន៍ ក្នុងបំណងក្តោបយកវិសាលគម នៃឧបសគ្គ និងឱកាសទីផ្សារការងារជាពិសេសផលប៉ះពាល់ នៃបទដ្ឋានវប្បធម៌សង្គមទៅលើជម្រើសអាជីព និងដំណើរជីវិតរបស់ស្រ្តី (សូមមើលឧបសម្ព័ន្ធ B និង C) ។

ក្រុមពិភាក្សាគោលដៅ (FGD) និង ការសម្ភាសអ្នកផ្តល់ចម្លើយសំខាន់ (KIIs) ត្រូវបានបង្កើតឡើងដោយផ្អែកលើរបាយការណ៍មុនៗស្តីពីស្រ្តី និងវិសមភាពក្នុងទីផ្សារការងារ និងអត្ថបទផ្សេងៗស្តីពីបទដ្ឋានសង្គមដែលរឹតបន្តឹងការងារស្រ្តី និងផ្អែកលើព័ត៌មានសំខាន់ៗមួយចំនួនពីក្រុមសិក្សារបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD ផងដែរ ។ សំណួរត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ និងធ្វើឱ្យមានសុពលភាពតាមរយៈការពិភាក្សា និងការសង្កេតដល់ទីតាំង។ ដោយរួមបញ្ចូលគ្នារវាងការយល់ដឹងទាំងទ្រឹស្តី និងការអនុវត្តដែលឆ្លុះបញ្ចាំងពីការងារស្រ្តី សំណួរសម្រាប់ FGDs និង KIIs បានផ្តោតលើកត្តាទាក់ទងគ្នាធំៗ រួមមាន រចនាសម្ព័ន្ធ ឬស្ថាប័នគាំទ្រយុវតី ស្ថានភាពទីផ្សារការងារនៅមូលដ្ឋាន បទដ្ឋានវប្បធម៌សង្គម ហានិភ័យ និងភាពងាយរងគ្រោះដែលរារាំងស្រ្តីមិនឱ្យពាក់ព័ន្ធនឹងការងារសមរម្យ តួនាទីយេនឌ័រក្នុងក្រុមគ្រួសារនិងសង្គម គម្លាតយេនឌ័រក្នុងការងារ គម្លាតធនធានមនុស្សនិងលទ្ធភាពចូលទៅរកបណ្តាញសង្គម និងការបណ្តុះបណ្តាល។ ឧបករណ៍សម្ភាសន៍សិក្សាពិសេសលើបញ្ហាយេនឌ័រពាក់ព័ន្ធនឹងបទដ្ឋានវប្បធម៌សង្គម និងការងាររបស់ស្រ្តី ដែលកំពុងកើតឡើង។

**តារាង 56 (4A-1-1) ខេត្តគោលដៅ និងលក្ខណៈជ្រើសរើស**

| ខេត្តគោលដៅ | តំបន់ភូមិសាស្រ្ត | អត្រាភាពក្រីក្រ (2012)[6] | លក្ខណៈប្រជាសាស្រ្ត[6] | |
|---|---|---|---|---|
| | | | ភាគរយប្រជាជន | ដង់ស៊ីតេប្រជាជន |
| **ភ្នំពេញ** | ទំនាបកណ្តាល | 0.1 % | 9.9 % | 4,516 per km$^2$ |
| **កំពត** | តំបន់ឆ្នេរ | 20.4 % | 4.4 % | 120 per km$^2$ |
| **សៀមរាប** | ទន្លេសាប | 28.8 % | 6.7 % | 87 per km$^2$ |
| **មណ្ឌលគិរី** | តំបន់ភ្នំ | 32.9 % | 0.4 % | 4 per km$^2$ |

រាជធានីភ្នំពេញ និងខេត្តគោលដៅនីមួយៗតំណាងឱ្យតំបន់ភូមិសាស្រ្តបួននៅកម្ពុជា៖ តំបន់ទំនាបណ្តាល (ភ្នំពេញ) តំបន់ឆ្នេរសមុទ្រ (កំពត) តំបន់ទន្លេសាប (សៀមរាប) និងតំបន់ភ្នំ (មណ្ឌលគិរីខេត្ត) ។ រាជធានីភ្នំពេញនិងខេត្តគោលដៅនីមួយៗមានអត្រាក្រីក្រនិងលក្ខណៈសេដ្ឋកិច្ចគ្រួសារខុសគ្នាយ៉ាងខ្លាំង (សូមមើល តារាងទី 7 ខាងលើ)។ រាជធានីភ្នំពេញ គឺជាទីប្រជុំជនកម្រិតខ្ពស់ និងគ្របដណ្តប់ដោយសកម្មភាពឧស្សាហកម្ម និងសេវាកម្ម។ ខេត្តសៀមរាប គឺជាខេត្តជនបទនិងពឹងផ្អែកជាចម្បងលើវិស័យកសិកម្មតាមបែបប្រពៃណី ប៉ុន្តែក្រុងសៀមរាប គឺជាគោលដៅទេសចរណ៍ធំបំផុតនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ទេសចរជាតិនិងអន្តរជាតិ ហេតុនេះក្រុងនេះ គឺជាទីប្រជុំជននិងប្រមូលផ្តុំទៅដោយសកម្មភាពសេដ្ឋកិច្ចនិងសេវាកម្ម។ សេដ្ឋកិច្ចនៃខេត្តកំពត និងខេត្តមណ្ឌលគិរី ក៏ពឹងផ្អែកជាចម្បងលើវិស័យកសិកម្មដែរ ប៉ុន្តែសកម្មភាពកសិកម្មមានភាពខុសគ្នា ដោយសារលក្ខណៈភូមិសាស្រ្តរបស់ខេត្តទាំងពីរនេះ ឧទាហរណ៍៖ បន្ថែមលើស្រូវអង្ករ ក្នុងខេត្តកំពតមានម្រេច ចំណែកខេត្តមណ្ឌលគិរីមានកៅស៊ូ និងស្វាយចន្ទី។ ពាក់ព័ន្ធនឹងមនុស្ស រាជធានីភ្នំពេញមានប្រជាជនរស់នៅច្រើនកុះករ ដែលជាកន្លែងដែលមានប្រជាជនច្រើនបំផុតទីពីរនៅកម្ពុជា បន្ទាប់ពីខេត្តកំពង់ចាម។ ផ្ទុយពីនេះ ខេត្តមណ្ឌលគិរីបានជាប់ចំណាត់ថ្នាក់ជាខេត្តមានដង់ស៊ីតេប្រជាជនទាបបំផុត ចំណែកខេត្តកំពត និងខេត្តសៀមរាបជាប់ចំណាត់ថ្នាក់នៅចន្លោះរាជធាភ្នំពេញ និងខេត្តមណ្ឌលគិរី។ លើសពីនេះ បានប៉ាន់ប្រមាណថា 80 ភាគរយនៃប្រជាជននៅខេត្តមណ្ឌលគិរី គឺជាក្រុមជនជាតិដើមភាគតិច ចំណែកនៅរាជធានីភ្នំពេញ និងខេត្តគោលដៅពីរផ្សេងទៀតមានជនជាតិខ្មែរលើសលុប។

ខេត្តគោលដៅនីមួយៗ មានក្រុមពិភាក្សាគោលដៅយុវតីចំនួន 4 ក្រុម (4 FGDs) គឺ 2 FGDs នៅជនបទ និង 2 FGDs នៅទីក្រុង។ សម្រាប់តំបន់ជនបទ ឬទីក្រុងដែលបានជ្រើសនោះ មាន 1 FGD ជាយុវតីមានការងារធ្វើដែលមានអាយុពី 15 ទៅ 30 ឆ្នាំ និង 1 FGD ទៀត គឺជាយុវតីគ្មានការងារធ្វើដែលមានអាយុពី 15 ទៅ 30 ឆ្នាំ) ។ សម្រាប់ក្រុមពិភាក្សាគោលដៅ (FDG) ជាយុវតីមានការងារធ្វើនីមួយៗ ការពិភាក្សាត្រូវបានធ្វើឡើងក្នុងបំណងរួមបញ្ចូលស្ថានភាពការងារផ្សេងគ្នា រួមមាន កម្មករមានប្រាក់ខែ កម្មករគណនីផ្ទាល់ខ្លួន និងកម្មករគ្រួសារគ្មានប្រាក់ខែ ព្រោះថា ការងារទាំងនេះជាប្រភេទការងារដែលអស្ថេរភាព ពិសេសក្នុងបរិបទជនបទ។ សម្រាប់ FDG ដែលជាស្រ្តីគ្មានការងារធ្វើ អ្នកចូលរួមមានទាំងស្រ្តីគ្មានការងារធ្វើប៉ុន្តែកំពុងស្វែងរកការងារ ស្រ្តីអសកម្ម ស្រ្តីមិនកំពុងស្វែងរកការងារមានប្រាក់ខែ និងស្រ្តីធ្វើការនៅឯផ្ទះសុទ្ធសាត។ កម្រិតអប់រំ នៃក្រុមនីមួយៗក៏ត្រូវបានពិចារណាផង ដើម្បីចាប់យកក្រែងលោមានគម្លាតកម្រិតអប់រំដែលរារាំងដល់ឱកាសរបស់យុតីក្នុងការស្វែងរកការងារល្អ ឬចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងផលិតភាព។

ទស្សនៈវិស័យរបស់បុរសស្រ្តីវ័យចំណាស់មួយចំនួននៅក្នុងសហគមន៍ដែលមានប្រវត្តិផ្សេងៗគ្នាក៏ត្រូវបានរាប់បញ្ចូលផងដែរ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីបទដ្ឋានវប្បធម៌សង្គមពីសំណាស្រ្តីចាស់ៗដែលជាគំរូពាក់ព័ន្ធនឹងតួនាទីស្រ្តីនៅក្នុងគ្រួសារនិងសហគមន៍។ ទស្សនៈវិស័យទាំងនេះស្វែងយល់តាមរយៈ 2 FGDs ជាស្រ្តីវ័យចំណាស់ និង KIIs ជាមួយថ្នាក់ដឹកនាំសហគមន៍។

**តារាង 57 (4A-1-2) ចំនួននៃ FGDs តាមខេត្ត**

| កណ្តាលក្រុង | ជាយក្រុង | ប្រជុំជនខេត្ត/ស្រុក | ជនបទ | ប្រជុំជនខេត្ត/ស្រុក | ជនបទ | ប្រជុំជនខេត្ត/ស្រុក | ជនបទ |
|---|---|---|---|---|---|---|---|
| (ភូមិឫស្សី 2 គម) | (ភូមិបាក់ខែង 15 គម ) | (ភូមិអូរតូច 4គម) | (ភូមិត្រពាំងឫស្សី 60គម) | (ភូមិមណ្ឌលបី 2គម) | (ភូមិបាត់ដងកោ 33គម) | (ភូមិចម្ការទឹក 2គម) | (ភូមិព្រៃជ្រី 37គម) |
| 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| 1 | - | - | - | - | - | - | 1 |
| **5** | | **4** | | **4** | | **5** | |

សរុបមក ក្រុមពិភាក្សាគោលដៅចំនួន 16 ក្រុម (16 FGDs) គឺជាយុវតីមាននិងគ្មានងារធ្វើ និង 2 FGDs ទៀត គឺជាស្ត្រីវ័យចំណាស់ និង 8 KIIs ជាមួយថ្នាក់ដឹកនាំសហគមន៍ (មេភូមិដែលបានជួប) ។ ការជ្រើសរើសអ្នកចូលរួមក្នុង FGDs មានគោលបំណងសន្មត់យកតែភាពខុសគ្នារវាងយុវតីដែលមាននិងគ្មានការងារធ្វើ។ មេដឹកនាំសហគមន៍ដែលស្គាល់ទីតាំងស្ត្រីវ័យក្មេងក្នុងសហគមន៍បានជួយមួយផ្នែកធំក្នុងការរៀបចំជំនួប FGDs ឱ្យប្រព្រឹត្តទៅសមរម្យ។ ទោះយ៉ាងណា FGDs និង KIIs អាចធ្វើបានតែនៅចុងសប្តាហ៍ប៉ុណ្ណោះ ដោយសារតែក្នុងសប្តាហ៍ ពួកគេជាប់រវល់ និងត្រូវធ្វើការងារផ្ទះ។ FDGs ជាស្ត្រីយុវតីមិនមែនមានតែអាយុពី 15 ទៅ 30 ឆ្នាំ សុទ្ធនោះទេ។ ចំនួនលម្អិតនៃអ្នកផ្តល់ចម្លើយ និងលក្ខណៈរបស់ពួកគេនឹងបង្ហាញដូចខាងក្រោម៖

ការប្រមូលទិន្នន័យ និងការវិភាគ

ការប្រមូលទិន្នន័យចំណាយពេលប្រហែលមួយខែ គឺចន្លោះខែកក្កដានិងខែសីហា ឆ្នាំ 2016 និងត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ និងខេត្តគោលដៅទាំងបី (កំពត សៀមរាប និងរតនគីរី) ។ ទិន្នន័យរបស់ FGDs ជាយុតីមានការងារធ្វើ អាចប្រមូលបានតែនៅចុងសប្តាហ៍ប៉ុណ្ណោះ ម្យ៉ាងទៀតជំនួបជាមួយគំរូគោលដៅ (ដើម្បីរកអ្នកមាន និងគ្មានការងារធ្វើ ដូចនិយមន័យដែលកំណត់ដោយ ILOនោះ) គឺពិបាករៀបចំណាស់ ព្រោះថា នៅជនបទ ស្ត្រីភាគច្រើនជាប់រវល់នឹងការងារកសិកម្ម ឬសកម្មភាពសេដ្ឋកិច្ចផ្សេងទៀត ដែលធ្វើឱ្យមានការពិបាកក្នុងការកំណត់និយមន័យនៃប្រភេទស្ត្រីដែលមានការងារ និងគ្មានការងារ ។

ដោយមានការអនុញ្ញាតពីអ្នកផ្តល់ឆ្លើយ ទិន្នន័យត្រូវបានថតជាអាត់សម្លេង និងបានសង្ខេបភ្លាមបន្ទាប់ពីបទសម្ភាស ទៅតាមរចនាសម្ព័ន្ធប្រធានបទបានរៀបរាប់មុននេះ។ គំរូ ឬប្រធានបទទូទៅដែលពាក់ព័ន្ធសេចក្តីដកស្រង់ និងបរិបទ ត្រូវបានកំណត់តាមរយៈការអានទិន្នន័យ ការវិភាគ និងការបកស្រាយ ដើម្បីធ្វើសម្មតិកម្មលើតួនាទីយេនឌ័រ និងការអនុវត្តលើសពីប្រធានបទដែលបានកំណត់ទុក ដោយទាញចេញពីការវិភាគឯកសារនេះ។

សីលធម៌ស្រាវជ្រាវ

ការស្រាវជ្រាវនេះបានធ្វើឡើងជាមួយនឹងស្ត្រីដែលមាននិងគ្មានការងារធ្វើ ទាំងអ្នកនៅលីវនិងរៀបការរួច ដែលជាទូទៅពួកគេមានពេលវេលាតិចតួចសម្រាប់ចូលរួមការពិភាក្សា ឬការសម្ភាសដោយសារតែជាប់រវល់នឹងការងាររកប្រាក់ចំណូល ឬទំនួលខុសត្រូវក្នុងការថែទាំផ្ទះសម្បែង។ ដូច្នេះ ក្រុមពិភាក្សាគោលដៅ (FGDs) ត្រូវបានធ្វើឡើងតាមពេលវេលាសមរម្យរបស់ពួកគេ ភាគច្រើននៅចុងសប្តាហ៍។ ទម្រង់បែបបទយល់ព្រមមួយជាភាសាខ្មែរត្រូវបានបង្កើតឡើង និងបានអានជូនអ្នកចូលរួមដើម្បីឱ្យពួកគាត់បានយល់ច្បាស់នូវ រូបភាពនៃការពិភាក្សា ឬសម្ភាសន៍ យល់អំពីគោលបំណងនៃការស្រាវជ្រាវ ចរិតលក្ខណៈនៃការចូលរួមក្នុងការពិភាក្សាឬសម្ភាសន៍ ហានិភ័យ អត្ថប្រយោជន៍ និងសេរីភាពផ្សេងទៀតដែលពួកគេអាចមាននៅអំឡុងពេលសម្ភាសន៍។ មេភូមិនីមួយដើរតួនាទីក្នុងការទំនាក់ទំនងជាមួយពួកគេដើម្បីធានា ថាតើសម្ភាសន៍អាចធ្វើទៅបានឬអត់ និងធានាថា សំណួររបស់យើងមិនបានប៉ះពាល់ដល់សភាពចិត្ត ឬសិទ្ធិរបស់ពួកគេ។ ក្រុមស្រាវជ្រាវគោរពសិទ្ធិរបស់ពួកគេយ៉ាងពេញលេញក្នុងការចូលរួម ឬដកខ្លួនចេញពីសម្ភាសន៍ ហើយអាជ្ញាធរមូលដ្ឋាននឹងការពារពួកគេ។

បញ្ជីឈ្មោះអ្នកផ្តល់ចម្លើយសម្ភាស

**តារាង 58 (4A-1-3) បញ្ជីឈ្មោះអ្នកផ្តល់ចម្លើយសម្ភាស**

| ក្រុមពិភាក្សាគោលដៅ (FGDs) | អាយុ | ស្ថានភាពគ្រួសារ | បញ្ចប់ថ្នាក់ទី | ការងារ | ប្រាក់ចំណូលមធ្យម | ទំហំគ្រួសារ |
|---|---|---|---|---|---|---|
| FGD 1<br>ក្រុមស្ត្រីមានការងារធ្វើនៅជាយភ្នំពេញ | 25 | នៅលីវ | ថ្នាក់ទី ១០ | កម្មកររោងចក្រ | 160 | 6 |
| | 28 | នៅលីវ | ថ្នាក់ទី ១០ | កម្មកររោងចក្រ | 160 | 6 |
| | 21 | នៅលីវ | ថ្នាក់ទី ៧ | កម្មកររោងចក្រ | 160 | 7 |
| | 31 | រៀបការរួច | ថ្នាក់ទី ៩ | កម្មកររោងចក្រ | 160 | 6 |

| ក្រុមពិភាក្សាគោលដៅ (FGDs) | អាយុ | ស្ថានភាពគ្រួសារ | បញ្ចប់ថ្នាក់ទី | ការងារ | ប្រាក់ចំណូលមធ្យម | ទំហំគ្រួសារ |
|---|---|---|---|---|---|---|
| | 21 | នៅលីវ | ថ្នាក់ទី ១២ | កម្មកររោងចក្រ | 160 | 4 |
| | 24 | រៀបការរួច | ថ្នាក់ទី ៩ | កម្មកររោងចក្រ | 160 | 4 |
| FGD 2<br>ក្រុមស្ត្រីគ្មានការងារធ្វើនៅជាយភ្នំពេញ | 30 | រៀបការរួច | ថ្នាក់ទី ២ | មិនស្វែងរកការងារ | 0 | 6 |
| | 32 | រៀបការរួច | ថ្នាក់ទី ៦ | មិនស្វែងរកការងារ | 0 | 5 |
| | 37 | រៀបការរួច | ថ្នាក់ទី ៥ | មិនស្វែងរកការងារ | 0 | 5 |
| | 27 | រៀបការរួច | ថ្នាក់ទី ៦ | មិនស្វែងរកការងារ | 0 | 3 |
| | 29 | រៀបការរួច | ថ្នាក់ទី ៦ | មិនស្វែងរកការងារ | 0 | 3 |
| FGD 3<br>ក្រុមស្ត្រីមានការងារធ្វើនៅកណ្តាលភ្នំពេញ | 23 | នៅលីវ | បរិញ្ញបត្រ | គ្រូបង្រៀន | មិនអាចរកបាន | |
| | 25 | នៅលីវ | | ស្ត្រីរត់តុ | មិនអាចរកបាន | មិនអាចរកបាន |
| | 25 | នៅលីវ | បរិញ្ញបត្រ | 03 បុគ្គលិក<br>ហាងអនឡាញ Room 03 | មិនអាចរកបាន | មិនអាចរកបាន |
| | 23 | នៅលីវ | បរិញ្ញបត្រ | គ្រូបង្រៀន | មិនអាចរកបាន | មិនអាចរកបាន |
| | 26 | នៅលីវ | ថ្នាក់ទី ៥<br>(នៅវៀតណាម) | ស្ត្រីរត់តុ | មិនអាចរកបាន | មិនអាចរកបាន |
| | 24 | នៅលីវ | បរិញ្ញបត្រ | ប្រធានគ្រប់គ្រងធនធានមនុស្ស | មិនអាចរកបាន | មិនអាចរកបាន |
| | 27 | នៅលីវ | បរិញ្ញបត្រ | មន្ត្រីរាជការ | មិនអាចរកបាន | មិនអាចរកបាន |
| | 27 | រៀបការរួច | បរិញ្ញបត្រ | កម្មករសំណង់ | មិនអាចរកបាន | មិនអាចរកបាន |
| | 24 | នៅលីវ | បរិញ្ញបត្រ | ជំនួយការស្រាវជ្រាវ | មិនអាចរកបាន | មិនអាចរកបាន |
| FGD 4<br>ក្រុមស្ត្រីគ្មានការងារធ្វើនៅកណ្តាលភ្នំពេញ | 21 | នៅលីវ | បរិញ្ញបត្រ | ជិតចូលធ្វើការ | 0 | 4 |
| | 21 | រៀបការរួច | បរិញ្ញបត្រ | មិនស្វែងរកការងារ | 0 | 9 |
| | 20 | នៅលីវ | បរិញ្ញបត្រ | កំពុងស្វែងរកការងារ | 0 | 4 |
| | 21 | នៅលីវ | បរិញ្ញបត្រ | កំពុងស្វែងរកការងារ | 0 | 8 |
| | 22 | នៅលីវ | វិទ្យាល័យ | អសកម្ម | 0 | 6 |
| | 23 | នៅលីវ | វិទ្យាល័យ | អសកម្ម | 0 | 6 |
| | 19 | នៅលីវ | វិទ្យាល័យ | អសកម្ម | 0 | 5 |
| FGD 5<br>ក្រុមស្ត្រីវ័យចំណាស់នៅកណ្តាលភ្នំពេញ | 36 | រៀបការរួច | ថ្នាក់ទី ១២ | គណនីផ្ទាល់ខ្លួន + មេផ្ទះ | 150 | 4 |

| ក្រុមពិភាក្សាគោលដៅ (FGDs) | អាយុ | ស្ថានភាពគ្រួសារ | បញ្ចប់ថ្នាក់ទី | ការងារ | ប្រាក់ចំណូលមធ្យម | ទំហំគ្រួសារ |
|---|---|---|---|---|---|---|
| | 49 | លែងលះគ្នា | ថ្នាក់ទី ១០ | ថែទាំក្មេង | 150 (ប្រាក់ខែផ្ទាល់ខ្លួន) | 3 |
| | 40 | រៀបការរួច | ថ្នាក់ទី ១២ | មេផ្ទះ | 1000 (បានមកពីប្តី) | 4 |
| | 55 | បែកបាក់គ្នា | ថ្នាក់ទី ៦ | មេផ្ទះ | 500 (បានមកពីបងស្រី) | 4 |
| | 65 | បែកបាក់គ្នា | ថ្នាក់ទី ៦ | មេផ្ទះ | 250 (បានមកពីកូន) | 4 |
| | 71 | បែកបាក់គ្នា | ថ្នាក់ទី ៧ | មេផ្ទះ | មិនទៀងទាត់ (ប្រាក់ចំណូលបានមកពីកូន + អាជីវកម្មផ្ទាល់ខ្លួន) | 5 |
| | 27 | រៀបការរួច | ថ្នាក់ទី ៦ | គណនីផ្ទាល់ខ្លួន + កសិករ | មិនអាចរកបាន | 4 |
| | 30 | រៀបការរួច | ថ្នាក់ទី ៦ | កសិករ | មិនអាចរកបាន | 4 |
| | 29 | រៀបការរួច | ថ្នាក់ទី ៩ | កសិករ | មិនអាចរកបាន | 5 |
| FGD 6<br>ក្រុមស្ត្រីមានការងារធ្វើនៅជនបទខេត្តកំពត | 31 | រៀបការរួច | ថ្នាក់ទី ៧ | កសិករ | មិនអាចរកបាន | 4 |
| | 28 | រៀបការរួច | ថ្នាក់ទី ៥ | កសិករ | មិនអាចរកបាន | 2 |
| | 18 | នៅលីវ | ថ្នាក់ទី ៦ | កសិករ | មិនអាចរកបាន | 3 |
| | 30 | រៀបការរួច | ថ្នាក់ទី ១១ | កសិករ | មិនអាចរកបាន | 3 |
| | 23 | បែកបាក់គ្នា | ថ្នាក់ទី ៩ | មេផ្ទះ | មិនអាចរកបាន | 5 |
| | 24 | រៀបការរួច | ថ្នាក់ទី ៨ | មេផ្ទះ | មិនអាចរកបាន | 3 |
| | 20 | រៀបការរួច | ថ្នាក់ទី ៨ | មេផ្ទះ | មិនអាចរកបាន | 2 |
| | 26 | រៀបការរួច | ថ្នាក់ទី ៥ | មេផ្ទះ | មិនអាចរកបាន | 6 |
| | 17 | នៅលីវ | ថ្នាក់ទី ៨ | សិស្ស | មិនអាចរកបាន | 5 |
| FGD 7<br>ក្រុមស្ត្រីគ្មានការងារធ្វើនៅជនបទខេត្តកំពត | 14 | នៅលីវ | ថ្នាក់ទី ១០ | សិស្ស | មិនអាចរកបាន | 4 |
| | 24 | រៀបការរួច | ថ្នាក់ទី ៧ | មេផ្ទះ | មិនអាចរកបាន | 8 |
| | 25 | រៀបការរួច | ថ្នាក់ទី ៩ | មេផ្ទះ | មិនអាចរកបាន | 3 |
| | 14 | នៅលីវ | ថ្នាក់ទី ៨ | សិស្ស | មិនអាចរកបាន | 5 |
| | 21 | រៀបការរួច | ថ្នាក់ទី ៨ | មេផ្ទះ | មិនអាចរកបាន | 5 |
| | 26 | រៀបការរួច | ថ្នាក់ទី ៩ | មេផ្ទះ | មិនអាចរកបាន | 4 |
| FGD 8<br>ក្រុមស្ត្រីមានការងារធ្វើនៅកណ្តាល ខេត្តកំពត | 20 | នៅលីវ | ថ្នាក់ទី ១១ | កម្មកររោងចក្រ | ប្រហែល $200 | 6 |

| ក្រុមពិភាក្សាគោលដៅ (FGDs) | អាយុ | ស្ថានភាពគ្រួសារ | បញ្ចប់ថ្នាក់ទី | ការងារ | ប្រាក់ចំណូលមធ្យម | ទំហំគ្រួសារ |
|---|---|---|---|---|---|---|
| | 21 | នៅលីវ | ថ្នាក់ទី ៨ | កម្មកររោងចក្រ | ប្រហែល $200 | |
| | 27 | នៅលីវ | ថ្នាក់ទី ៦ | កម្មកររោងចក្រ | ប្រហែល $200 | 7 |
| | 32 | រៀបការរួច | ថ្នាក់ទី ៤ | កម្មកររោងចក្រ | ប្រហែល $200 | 5 |
| | 23 | រៀបការរួច | ថ្នាក់ទី ៨ | កម្មកររោងចក្រ | ប្រហែល $200 | 7 |
| | 23 | រៀបការរួច | ថ្នាក់ទី ៧ | កម្មកររោងចក្រ | ប្រហែល $200 | 6 |
| | 21 | នៅលីវ | ថ្នាក់ទី ៧ | កសិករ | $200 | 8 |
| | 30 | រៀបការរួច | ថ្នាក់ទី ៩ | កម្មកររោងចក្រ | ប្រហែល $200 | 7 |
| | 30 | រៀបការរួច | ថ្នាក់ទី ៦ | កម្មកររោងចក្រ | Appx. $200 | 6 |
| | 20 | រៀបការរួច | ថ្នាក់ទី ៩ | កសិករ | 2,000,000 រៀល | 5 |
| FGD 9<br>ក្រុមស្ត្រីគ្មានការងារធ្វើនៅកណ្តាលខេត្តកំពត | 16 | នៅលីវ | ថ្នាក់ទី ៩ | សិស្ស | មិនអាចរកបាន | 7 |
| | 17 | នៅលីវ | ថ្នាក់ទី ១០ | សិស្ស | មិនអាចរកបាន | 7 |
| | 17 | នៅលីវ | ថ្នាក់ទី ១០ | សិស្ស | មិនអាចរកបាន | 5 |
| | 14 | នៅលីវ | ថ្នាក់ទី ៧ | សិស្ស | មិនអាចរកបាន | 4 |
| | 15 | នៅលីវ | ថ្នាក់ទី ៧ | សិស្ស | មិនអាចរកបាន | 6 |
| | 14 | នៅលីវ | ថ្នាក់ទី ៦ | សិស្ស | មិនអាចរកបាន | 7 |
| FGD 10<br>ក្រុមស្ត្រីមានការងារធ្វើនៅជនបទខេត្តសៀមរាប | 50 | រៀបការរួច | 5 | កសិករ (ដាំស្រូវនិងបន្លែ) | 70 USD | 4 (ឯករាជ្យ ២នាក់) |
| | 45 | រៀបការរួច (មេម៉ាយ) | 5 | អ្នកដើរលក់ (បន្លែ) | 150 USD | 4 (ឯករាជ្យ ៣នាក់) |
| | 45 | រៀបការរួច | 0 | កសិករ / កម្មករសំណង់ | 60 USD | 6 (ឯករាជ្យ ៤នាក់) |
| | 48 | រៀបការរួច (មេម៉ាយ) | 0 | អ្នកលក់បបរ | 150 USD | 2 (ឯករាជ្យ ០នាក់) |
| | 33 | រៀបការរួច | 0 | អ្នកដើរលក់ | 300 USD | 8 (ឯករាជ្យ ៣នាក់) |
| | 20 | រៀបការរួច | 11 | កសិករ | មិនអាចរកបាន | 4 (ឯករាជ្យ ០នាក់) |
| | 40 | នៅលីវ | 8 | ម្ចាស់ហាងលក់គ្រឿងទេស | 150 USD (ប្រាក់ចំណេញសុទ្ធ) | 5 (ឯករាជ្យ ៣នាក់) |
| | 50 | រៀបការរួច | ថ្នាក់ទី ២ | កសិករ មេផ្ទះ | មិនអាចរកបាន | 6 (ឯករាជ្យ ៣នាក់) |
| FGD 11<br>ក្រុមស្ត្រីគ្មានការងារធ្វើនៅជនបទខេត្តសៀមរាប | 35 | រៀបការរួច | ថ្នាក់ទី ៥ | មេផ្ទះ | មិនអាចរកបាន | 4 |

| ក្រុមពិភាក្សាគោលដៅ (FGDs) | អាយុ | ស្ថានភាពគ្រួសារ | បញ្ចប់ថ្នាក់ទី | ការងារ | ប្រាក់ចំណូលមធ្យម | ទំហំគ្រួសារ |
|---|---|---|---|---|---|---|
| | 35 | រៀបការរួច | ថ្នាក់ទី ២ | មេផ្ទះ | មិនអាចរកបាន | 6 |
| | 28 | រៀបការរួច | ថ្នាក់ទី ៣ | មេផ្ទះ | មិនអាចរកបាន | 4 |
| | 35 | រៀបការរួច | គ្មាន | មេផ្ទះ | មិនអាចរកបាន | 3 |
| | 32 | រៀបការរួច | ថ្នាក់ទី ៦ | មេផ្ទះ | មិនអាចរកបាន | 4 |
| | 33 | រៀបការរួច | ថ្នាក់ទី ៣ | មេផ្ទះ | មិនអាចរកបាន | 7 |
| | 35 | រៀបការរួច | ថ្នាក់ទី ៨ | មេផ្ទះ | មិនអាចរកបាន | 5 |
| FGD 12<br>ក្រុមស្ត្រីមានការងារធ្វើនៅកណ្តាលខេត្តសៀមរាប | 28 | នៅលីវ | ថ្នាក់ទី ១២ | មន្ត្រីអង្គការក្រៅរដ្ឋាភិបាល | $200 | ម្នាក់ឯង |
| | 30 | ម្តាយនៅលីវ | មិនអាចរកបាន | ស្ត្រីអ្នករត់តុ | $70 | 07 |
| | 34 | រៀបការរួច | មិនអាចរកបាន | កម្មករសំណង់ | $5/ថ្ងៃ | 05 |
| | 37 | ម្តាយនៅលីវ | មិនអាចរកបាន | អ្នកសំអាត | $90 | 03 |
| | 31 | រៀបការរួច | មិនអាចរកបាន | អ្នកយាមផ្ទះ | $70 | 03 |
| | 39 | មេម៉ាយ | ថ្នាក់ទី ១២ | អ្នកលក់ដូរ | $40-$50/ថ្ងៃ | 05 |
| | 31 | ម្តាយនៅលីវ | មិនអាចរកបាន | ចុងភៅ | $25 | 04 |
| | 44 | មេម៉ាយ | មិនអាចរកបាន | ចុងភៅ | $100 | 03 |
| FGD 13<br>ក្រុមស្ត្រីគ្មានការងារធ្វើនៅកណ្តាលខេត្តសៀមរាប | 33 | រៀបការរួច | គ្មាន | មេផ្ទះ កសិករ | មិនអាចរកបាន | 4 |
| | 33 | រៀបការរួច | ថ្នាក់ទី ៣ | មេផ្ទះ កសិករ | មិនអាចរកបាន | 4 |
| | 27 | រៀបការរួច | ថ្នាក់ទី ៥ | Housewife | មិនអាចរកបាន | 8 |
| | 33 | រៀបការរួច | ថ្នាក់ទី ២ | មេផ្ទះ | មិនអាចរកបាន | 7 |
| | 14 | នៅលីវ | ថ្នាក់ទី ៦ | សិស្ស | មិនអាចរកបាន | 6 |
| | 14 | នៅលីវ | ថ្នាក់ទី ៥ | សិស្ស | មិនអាចរកបាន | 4 |
| | 14 | នៅលីវ | ថ្នាក់ទី ៦ | សិស្ស | មិនអាចរកបាន | 8 |
| FGD 14<br>ក្រុមស្ត្រីវ័យចំណាស់នៅជនបទខេត្តមណ្ឌលគិរី | 35 | បែកបាក់គ្នា | គ្មាន | អ្នកលក់ដូរ | មិនអាចរកបាន | 5 |
| | 35 | រៀបការរួច | គ្មាន | អ្នកលក់ដូរ កសិករ | មិនអាចរកបាន | 5 |
| | 55 | រៀបការរួច | គ្មាន | មេផ្ទះ | មិនអាចរកបាន | 5 |

| ក្រុមពិភាក្សាគោលដៅ (FGDs) | អាយុ | ស្ថានភាពគ្រួសារ | បញ្ចប់ថ្នាក់ទី | ការងារ | ប្រាក់ចំណូលមធ្យម | ទំហំគ្រួសារ |
|---|---|---|---|---|---|---|
| | 43 | រៀបការរួច | គ្មាន | កសិករ | មិនអាចរកបាន | 5 |
| | 46 | រៀបការរួច | គ្មាន | កសិករ | មិនអាចរកបាន | |
| | 38 | រៀបការរួច | គ្មាន | កសិករ | មិនអាចរកបាន | 4 |
| FGD 15<br>ក្រុមស្ត្រីមានការងារធ្វើនៅជនបទខេត្តមណ្ឌលគិរី | 28 | រៀបការរួច | ថ្នាក់ទី ៥ | អ្នកលក់<br>(ហាងលក់គ្រឿងទេស) | 700 USD<br>(ប្រាក់ចំណេញសរុប) | 4 (2 depend) |
| | 23 | រៀបការរួច | ថ្នាក់ទី ៤ | កសិករ | មិនអាចរកបាន | 4 (មិនឯករាជ្រ ២នាក់) |
| | 23 | រៀបការរួច | ថ្នាក់ទី ៦ | អ្នកលក់<br>(ហាងលក់គ្រឿងទេស) | មិនអាចរកបាន | 4 (មិនឯករាជ្រ ២នាក់) |
| | 25 | រៀបការរួច | ថ្នាក់ទី ៥ | អ្នកលក់<br>(ហាងលក់គ្រឿងទេស) | មិនអាចរកបាន | 5 (មិនឯករាជ្រ ៣នាក់) |
| ក្រុមស្ត្រីគ្មានការងារធ្វើនៅជនបទខេត្តមណ្ឌលគិរី | 20 | រៀបការរួច | ថ្នាក់ទី ៦ | មេផ្ទះ | មិនអាចរកបាន | 5 (មិនឯករាជ្រ ១នាក់) |
| | 28 | រៀបការរួច | ថ្នាក់ទី ៥ | មេផ្ទះ | មិនអាចរកបាន | 5 (មិនឯករាជ្រ ៣នាក់) |
| | 18 | រៀបការរួច | ថ្នាក់ទី ៥ | មេផ្ទះ | មិនអាចរកបាន | 2 (មិនឯករាជ្រ ០នាក់) |
| | 20 | រៀបការរួច | ថ្នាក់ទី ៦ | មេផ្ទះ | មិនអាចរកបាន | 2 (មិនឯករាជ្រ ០នាក់) |
| | 28 | រៀបការរួច | គ្មាន | មេផ្ទះ | មិនអាចរកបាន | 4 (មិនឯករាជ្រ) |
| | 15 | រៀបការរួច | ថ្នាក់ទី ៤ | មេផ្ទះ | មិនអាចរកបាន | 5 (មិនឯករាជ្រ ៣នាក់) |
| FGD 17<br>ក្រុមស្ត្រីមានការងារធ្វើនៅកណ្តាលខេត្តមណ្ឌលគិរី | 29 | រៀបការរួច | ថ្នាក់ទី ៨ | អ្នកលក់<br>(ហាងលក់គ្រឿងទេស) | មិនអាចរកបាន | 4 |
| | 37 | រៀបការរួច | ថ្នាក់ទី ១១ | អនុប្រធានភូមិ | មិនអាចរកបាន | 3 |
| | 28 | រៀបការរួច | ថ្នាក់ទី ៥ | កម្មករឯករាជ (កសិកម្ម) | មិនអាចរកបាន | 4 |
| | 24 | នៅលីវ | ថ្នាក់ទី ៤ | អ្នកធ្វើសក់ | មិនអាចរកបាន | 2 |
| | 38 | រៀបការរួច | គ្មាន | កសិករ | មិនអាចរកបាន | 9 |
| | 48 | រៀបការរួច | គ្មាន | កសិករ | មិនអាចរកបាន | 5 |
| FGD 18<br>ក្រុមស្ត្រីគ្មានការងារធ្វើនៅកណ្តាលខេត្តមណ្ឌលគិរី | 27 | រៀបការរួច | ថ្នាក់ទី ៤ | មេផ្ទះ | មិនអាចរកបាន | 6 |
| | 26 | រៀបការរួច | ថ្នាក់ទី ៧ | មេផ្ទះ | មិនអាចរកបាន | 4 |
| | 28 | រៀបការរួច | ថ្នាក់ទី ៨ | មេផ្ទះ | មិនអាចរកបាន | 3 |
| | 17 | នៅលីវ | ថ្នាក់ទី ៩ | និស្សិត (ជួយគ្រួសារលក់គ្រឿងទេស) | មិនអាចរកបាន | 6 |
| | 29 | រៀបការរួច | ថ្នាក់ទី ៧ | មេផ្ទះ | មិនអាចរកបាន | 3 |

| ក្រុមពិភាក្សាគោលដៅ (FGDs) | អាយុ | ស្ថានភាពគ្រួសារ | បញ្ចប់ថ្នាក់ទី | ការងារ | ប្រាក់ចំណូលមធ្យម | ទំហំគ្រួសារ |
|---|---|---|---|---|---|---|
| | 35 | រៀបការរួច | ថ្នាក់ទី ៩ | មេផ្ទះ មណ្ឌលគិរី | មិនអាចរកបាន | 7 |
| **ប្រវត្តិនៃ ថ្នាក់ដឹកនាំសហគមន៍ (CL) នៅក្នុង KIIs** | | | | | | |
| ភ្នំពេញ 1 | 60 | មេម៉ាយ | ថ្នាក់ទី ៩ | ជំនួយការភូមិ | 140000 រៀល | មិនអាចរកបាន |
| ភ្នំពេញ 2 | 65 | រៀបការរួច | វិទ្យាល័យ | មេភូមិរង មិនអាចរកបាន | 200000 រៀល | មិនអាចរកបាន |
| កំពត 1 | 50 | រៀបការរួច | ថ្នាក់ទី ៩ | មេភូមិ/ កសិករ | 200000 រៀល | មិនអាចរកបាន |
| កំពត 2 | 62 | រៀបការរួច | | មេភូមិ/ កសិករ | 200000 រៀល | មិនអាចរកបាន |
| សៀមរាប 1 | 30 | រៀបការរួច | ថ្នាក់ទី ១២ | ជំនួយការភូមិនិងបុគ្គលិកអង្គការ | 140000 រៀល + 200$ | មិនអាចរកបាន |
| សៀមរាប 2 | 68 | រៀបការរួច | ថ្នាក់ទី ៥ | មេភូមិ | 200000 រៀល | មិនអាចរកបាន |
| មណ្ឌលគិរី 1 | 47 | រៀបការរួច | ថ្នាក់ទី ៧ | មេភូមិ/ កសិករ ម្ចាស់ហាងគ្រឿងទេស | មិនអាចរកបាន | មិនអាចរកបាន |
| មណ្ឌលគិរី 2 | 45 | រៀបការរួច | ថ្នាក់ទី ៧ | មេភូមិ/ កសិករ | មិនអាចរកបាន | មិនអាចរកបាន |

# របាយការណ៍ពិនិត្យឡើងវិញ

## លើ

# គោលនយោបាយស្តីពីសុខុមាលភាពយុវជនកម្ពុជា

www.oecd.org/dev/inclusivesocietiesanddevelopment/youth-country-studies.htm

This project is co-funded by
the European Union